រាជរដ្ឋាភិបាលកម្ពុជា

របាយការណ៍
ស្តីពីវឌ្ឍនភាពនៃការអនុវត្ត
គោលនយោបាយអភិវឌ្ឍន៍វិស័យខ្សែសង្វាក់តម្លៃកម្ពុជា
ឆ្នាំ ២០១៥-២០២៥

គិតត្រឹមខែធ្នូ ឆ្នាំ២០១៦

ដាក់ទទួលការពិភាក្សាពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃ៥កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧

រាជរដ្ឋាភិបាលកម្ពុជា

របាយការណ៍

ស្តីពីវឌ្ឍនភាពនៃការអនុវត្ត

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

ឆ្នាំ ២០១៥-២០២៥

គិតត្រឹមខែធ្នូ ឆ្នាំ២០១៦

ដោយទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃ៥កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ត្រូវនឹងថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៧

មាតិកា

ខ្លឹមសារសង្ខេបប្រតិបត្តិ.....i

១. សេចក្តីផ្តើម ១

២. វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ ២

២.១. ការត្រៀមរៀបចំ និងវឌ្ឍនភាព..... ២

២.១.១. ការរៀបចំយន្តការស្ថាប័ន..... ៣

២.១.២. ការពិភាក្សាបឋមលើប្រធានបទជាអាទិភាព..... ៣

២.២. វឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង ដើម្បីជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍
វិស័យឧស្សាហកម្ម.....៥

២.២.១. វិធានការទី១.....៥

២.២.២. វិធានការទី២.....៦

២.២.៣ វិធានការទី៣.....៨

២.២.៤ វិធានការទី៤..... ១០

២.៣. វឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព..... ១១

២.៣.១. ការជំរុញការទាក់ទាញវិនិយោគ..... ១១

២.៣.២. ការពង្រីក និងទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម.....២៣

២.៣.៣. ការកែលម្អបរិស្ថានទិន្នន័យតកម្ម.....៣៣

២.៣.៤ ការសម្របសម្រួលគោលនយោបាយគាំទ្រ.....៤២

២.៣.៥ ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា.....៥៨

៣. បញ្ហាប្រឈម និងហានិភ័យនៃការអនុវត្តគោលនយោបាយ.....៦០

៤. សេចក្តីសន្និដ្ឋាន..... ៦២

ឧបសម្ព័ន្ធទី១ : ឧបសម្ព័ន្ធ "គ": ម៉ាទ្រីសអំពីវិធានការគន្លឹះបួនជាក់ស្តែង ដើម្បីជំរុញ "គោលនយោបាយអភិវឌ្ឍន៍វិស័យ
ឧស្សាហកម្ម"

ឧបសម្ព័ន្ធទី២ : ឧបសម្ព័ន្ធ "ឃ": ម៉ាទ្រីសនៃវិធានការគោលនយោបាយ និងផែនការសកម្មភាព

ខ្លឹមសារសង្ខេបប្រតិបត្តិ

១. បន្ទាប់ពីគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ត្រូវបានអនុម័ត ដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥ និងត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធបានដាក់ចេញនូវវិធានការគោលនយោបាយ និងផែនការសកម្មភាពរបស់ខ្លួន ព្រមទាំងបានធ្វើសកម្មភាពជាក់ស្តែង ក្នុងការអនុវត្តគោលនយោបាយនេះ ដោយសម្រេចបាននូវសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ និងកំពុងស្ថិតនៅលើផ្លូវត្រូវឈានទៅសម្រេចបាននូវគោលដៅចម្បងៗរបស់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម នេះ។

២. ជាក់ស្តែង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ក្នុងនាមជាស្ថាប័នដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ បានរៀបចំ និងដឹកនាំកិច្ចប្រជុំអន្តរក្រសួងជាច្រើនលើក ហើយអង្គប្រជុំបានសម្រេចដាក់ចេញនូវវិធានការជាច្រើនរួមទាំងការរៀបចំយន្តការផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម, ការរៀបចំផែនការសកម្មភាពការងារនិងថវិកា, ការកំណត់ការងារដែលត្រូវធ្វើចំពោះមុខដែលអាចទទួលបាននូវផ្លែផ្កាឆាប់រហ័សទាំងផ្នែកសេដ្ឋកិច្ចនិងសង្គម (Low Hanging Fruits) ដូចជាការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម, ការជំរុញការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម, ការជំរុញការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស និងការជំរុញការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម។

៣. បន្ថែមលើនេះ ក្រសួង ស្ថាប័នគន្លឹះ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បានដឹកនាំ សម្របសម្រួល និង/ឬអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព ក្នុងគោលបំណងឈានទៅសម្រេចឱ្យបានគោលដៅចម្បងទាំងបីនៃគោលនយោបាយនេះ។ វឌ្ឍនភាពសំខាន់ៗ មានដូចខាងក្រោម÷

គោលដៅទី១: *ការកែប្រែ និងពង្រីងរចនាសម្ព័ន្ធឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិដោយបង្កើនអនុ-បាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. ឱ្យបាន៣០%នៅឆ្នាំ២០២៥ ក្នុងនោះវិស័យកម្មន្តសាលត្រូវកើនដល់២០% នៅឆ្នាំ២០២៥។*

យោងតាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្ហាញថា អនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. បានកើនឡើងពី២៤,១%នៅឆ្នាំ២០១៣ ដល់ ២៩,0%នៅឆ្នាំ២០១៦ ពោលបានកើនឡើង៤,៩% ឬសម្រេចបាន៩០,៣% បើធ្វើ

ការប្រៀបធៀបនឹងគោលដៅដែលបានកំណត់ឲ្យបាន៣០% នៅឆ្នាំ២០២៥។ ទន្ទឹមគ្នានេះ អនុបាតវិស័យកម្មន្តសាលក្នុង ផ.ស.ស. បានកើនឡើងពី១៥,៥%នៅឆ្នាំ២០១៣ ដល់១៦,៣%នៅឆ្នាំ២០១៦ ពោលបានកើនឡើង0,៨% ឬសម្រេចបាន៨១,៥% បើធ្វើការប្រៀបធៀបនឹងគោលដៅដែលបានកំណត់ឲ្យបាន២0%នៅឆ្នាំ២0២5។

គោលដៅទី២: *ការបង្កើន និងពិពិធកម្មមុខទំនិញនាំចេញ ដោយបង្កើនការនាំចេញទំនិញកម្មន្តសាល (មិនមែនជាវាយនភណ្ឌ) ឱ្យបាន១5%នៃបរិមាណនាំចេញសរុបនៅឆ្នាំ២0២5 ទន្ទឹមនឹងការជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន១២%នៃបរិមាណនាំចេញសរុបនៅឆ្នាំ២0២5។*

យោងតាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្ហាញថា ការនាំចេញសម្លៀកបំពាក់និងស្បែកជើងមានការធ្លាក់ចុះពី **៧៧**,១% នៅឆ្នាំ២0១3 មកត្រឹម **៧**3,១% នៅឆ្នាំ២0១6 នៅខណៈពេលដែលការនាំចេញទំនិញកម្មន្តសាល (មិនមែនវាយនភណ្ឌ) ធៀបនឹងការនាំចេញសរុប មានការកើនឡើងពី ១6,6% នៅឆ្នាំ២0១3 ដល់២២,3% នៅឆ្នាំ២0១6 និងការនាំចេញកសិផលកែច្នៃមានចំនួនប្រមាណ ៤,6%នៃការនាំចេញសរុបនៅឆ្នាំ២0១6។ នេះឆ្លុះបញ្ចាំងឱ្យឃើញថាកម្ពុជាបាននិងកំពុងធ្វើពិពិធកម្មមុខទំនិញនាំចេញរបស់ខ្លួនជាបន្តបន្ទាប់ ដោយមិនពឹងផ្អែកតែទៅលើការនាំចេញសម្លៀកបំពាក់និងស្បែកជើង និងផលិតផលកសិកម្មនោះទេ។

គោលដៅទី3: *ការពង្រឹងយន្តការគ្រប់គ្រង និងជំរុញការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ដោយជំរុញការចុះបញ្ជីផ្លូវការនៃសហគ្រាសទាំងនោះ និងលើកកម្ពស់អភិបាលកិច្ចសាជីវកម្ម តាមរយៈការកាន់បញ្ជីការគណនេយ្យ និងតាវាងតុល្យការ។*

យោងតាមទិន្នន័យពីក្រសួងឧស្សាហកម្មនិងសិប្បកម្មបានបង្ហាញថា ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម តាមរយៈយន្តការច្រកចេញចូលតែមួយនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានកើនឡើងពីចំនួន ៥3**៧** នៅឆ្នាំ២0១5 ដល់ ៨0១នៅឆ្នាំ២0១6 ពោលគឺកើនឡើងចំនួន៤៩,១6%។ ទន្ទឹមគ្នានេះ យោងតាមទិន្នន័យពីក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានបង្ហាញថាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មមានចំនួន៤៤៩0 នៅឆ្នាំ២0១5 និងចំនួន ៤២**៧**១ នៅឆ្នាំ២0១6 ពោលគឺធ្លាក់ចុះប្រមាណជា ៤,៨% នៅខណៈពេលដែលក្រុមហ៊ុនបានចុះបញ្ជីបង់ពន្ធដារ (តាមរបបពិត) បានកើនឡើងពីចំនួន១**៧**0១ នៅឆ្នាំ២0១5 ដល់ចំនួន5២5**៧** នៅឆ្នាំ២0១6 គឺមានការកើនឡើងរហូតដល់២0៩%។

៤. លើសពីនេះទៅទៀត ក្រសួង ស្ថាប័នមួយចំនួន បានសម្រេចនូវវឌ្ឍនភាពមួយចំនួនទាក់ទងនឹងវិធានការគន្លឹះបួនជាក់ស្តែងដូចខាងក្រោម÷

វិធានការទី១- *"រៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនីសម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជ-កម្ម រួមទាំងការពង្រឹងភាពទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី"*

តាមទិន្នន័យពីក្រសួងរ៉ែនិងថាមពលបានបង្ហាញថា ការងារកសាងខ្សែបញ្ជូនតង់ស្យុងខ្ពស់ឥតភ្ជាប់រាជធានីខេត្ត ដែលសម្រេចបានការផ្គត់ផ្គង់អគ្គិសនីតំបន់ប៉ូលសេដ្ឋកិច្ចសំខាន់ៗប្រមាណជា៥0% ក្នុងឆ្នាំ២0១6 និងគ្របដណ្តប់ ១00% ក្នុងឆ្នាំ២0១៨ (ចំពោះតំបន់ឧស្សាហកម្មស្ថិតនៅវង្វង់ ២៥ គ.ម. ពីអនុស្ថានីយ)។ ជាមួយគ្នានេះ រាជរដ្ឋាភិបាល តាមរយៈអាជ្ញាធរអគ្គិសនីកម្ពុជា និងក្រសួងរ៉ែនិងថាមពល បានសហការបញ្ចប់ការសិក្សាផែនការសម្រាប់អនុវត្តការបន្ទុយអត្រា និងកំណត់ថ្លៃលក់អគ្គិសនីតាមបណ្តាខេត្ត និងរាជធានីភ្នំពេញ, ចុះស្រង់ស្ថិតិ និងកសាងមូលដ្ឋានទិន្នន័យអំពីអស្ថិ-ភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅតាមតំបន់សេដ្ឋកិច្ចពិសេស, អនុម័តផែនការសម្រាប់អនុវត្តការបន្ទុយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីតាមបណ្តាខេត្ត និងរាជធានី សម្រាប់ឆ្នាំ២0១៥-២0១6 ដោយបានអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាថ្ងៃ-យប់សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្ម ព្រមទាំងបាននិងកំពុងសិក្សាថ្លៃលក់តាមពេលវេលាថ្ងៃ-យប់សម្រាប់ឆ្នាំ២0១៧។

វិធានការទី២ - *"រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម"*

តាមទិន្នន័យពីក្រសួងសាធារណការនិងដឹកជញ្ជូនបានបង្ហាញថា ក្រសួងបានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២0១7-២0១៩ លើការរៀបចំផែនការមេប្រព័ន្ធភស្តុភារកម្ម ដោយក្នុងនោះក្រុមជំនាញការកូរ៉េ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនកំពុងសិក្សាអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម និងការរៀបចំផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម។ ក្រសួងក៏បានបង្កើតអគ្គនាយកដ្ឋានភស្តុភារកម្ម ដែលមានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារពាក់ព័ន្ធវិស័យភស្តុភារកម្ម ព្រមទាំងបានបញ្ចប់លក្ខខណ្ឌយោង ក៏ដូចជាកំពុងត្រៀមរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាភស្តុភារកម្ម។ ទន្ទឹមគ្នានេះ ក្រសួងបានបញ្ចុះតម្លៃសេវាពាក់ព័ន្ធនឹងភស្តុភារកម្មជាច្រើន ដូចជាការបញ្ចុះតម្លៃសេវាបើកឡានកាត់ផ្លូវ[illegible] នៅទីលានកុងតឺន័រក្នុងកំពង់ផែស្វយ័តក្រុងព្រះសីហនុ ១0%, [illegible]

៥%, បញ្ចុះតម្លៃ១0%នៃតម្លៃសេវាកត់ត្រាកុងតឺន័រលើសម៉ោង និងបញ្ចុះតម្លៃ ១0% ទៀតនៃតម្លៃត្រួតពិនិត្យកុងតឺន័រនៅពេលលើកដាក់នៅនាវា ដោយភ្នាក់ងារកាំសាបជាដើម។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាល តាមរយៈក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងចរចាលើកិច្ចសន្យាសម្បទានលើគម្រោងផ្លូវលឿនលឿន (ភ្នំពេញ-ព្រះសីហនុ) ដែលនឹងវិនិយោគដោយក្រុមហ៊ុនមកពីសាធារណរដ្ឋប្រជាមានិតចិន ហើយគ្រោងចាប់ផ្តើមដំណើរការគម្រោងនៅចុងឆ្នាំ ២០១៧នេះ, និងបានពិនិត្យលទ្ធភាពរៀបចំគម្រោងផ្លូវលឿនលឿន (ភ្នំពេញ-បាវិត) ដែលនឹងអាចផ្តល់ហិរញ្ញប្បទានដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន។

វិធានការទី៣- *"ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះបណ្តាលជំនាញ"*

រាជរដ្ឋាភិបាល តាមរយៈក្រសួង ស្ថាប័ន បានសម្រេចវឌ្ឍនភាពជាច្រើនលើវិធានការនេះ ដូចជា ការអនុវត្តច្បាប់ស្តីពីការងារ, ការរៀបចំ និងអនុវត្តច្បាប់ស្តីពីសហជីព, ការកំណត់លក្ខណៈវិនិច្ឆ័យបែបសេដ្ឋកិច្ច និងសង្គមក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា ព្រមទាំងបានបង្កើនប្រាក់ឈ្នួលអប្បបរមាដោយសុខដុមនីយមកម្ម, ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា, ការរៀបចំគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥, ការបង្កើនថវិកាជាតិសម្រាប់គាំទ្រការងារកសាងសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងការងារបណ្តុះបណ្តាលជំនាញបច្ចេកទេស, ការអនុវត្តកម្មវិធីកសាងសមត្ថភាពជាច្រើនដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ និងការសិក្សាស្រាវជ្រាវលើសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម និងភាពប្រកួតប្រជែង និងឥទ្ធិពលប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៥ ទៅលើសុខុមាលភាពកម្មករ ការវាស់វែង និងគណនាប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៦ នៅក្នុងវិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ជាដើម។

វិធានការទី៤ - *"អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស"*

ទាក់ទងនឹងវិធានការនេះ ក្រសួង ស្ថាប័នគន្លឹះ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានធ្វើសកម្មភាពសំខាន់ៗជាច្រើន ដូចជា (១) ការបន្តអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការបន្តផ្តល់កិច្ចសម្រួលដល់អ្នកវិនិយោគក្នុងតំបន់, ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់

សេដ្ឋកិច្ចពិសេស, (២) ការរៀបចំផែនការសកម្មភាព និងគោលនយោបាយអភិវឌ្ឍន៍តាមវិស័យ រួមមាន÷ ការរៀបចំផែនការអភិវឌ្ឍសេវាកម្មអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ, ការរៀបចំសេចក្ដីព្រាងផែនការសកម្មភាព ឆ្នាំ២០១៨-២០២៥ លើវិស័យអាកាសចរស៊ីវិល, ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តព្រះសីហនុ ឆ្នាំ២០១៦-២០២៥ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍នៅខេត្តព្រះសីហនុ, ការរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនា-គមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០, (៣) ការកសាងបណ្ដាញខ្សែកាប្ដីអុបទិកបានប្រវែង ១១ ០០០គ.ម ទូទាំងប្រទេស និងការកសាងខ្សែកាប្ដីអុបទិកឆ្លងកាត់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងការបញ្ចប់ការធ្វើទំនើបកម្មនៃប្រព័ន្ធប្រៃសណីយ៍ ដើម្បីជួយសម្រួលដល់ប្រព័ន្ធភស្តុភារកម្មដោយការបង្កើតប្រព័ន្ធត្រួតពិនិត្យតាមបញ្ជូរ (Counter Automation) និងប្រព័ន្ធតាមដានបញ្ជី International Postal System និងប្រព័ន្ធ International Financial System, និង (៤) ការកៀរគរហិរញ្ញវត្ថុសម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍នៅខេត្តព្រះ-សីហនុ ជាដើម ដើម្បីចូលរួមអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង។

៥. លើសពីនេះទៅទៀត ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បានអនុវត្តសកម្មភាពយ៉ាងច្រើន ដោយអនុលោមតាមវិធានការគោលនយោបាយ និងផែនការសកម្មភាពដែលបានកំណត់នៅក្នុងតារាងម៉ាទ្រីសនៃគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មនេះ ដូចបានជូនភ្ជាប់មកជាមួយនេះ។

៦. ទន្ទឹមនឹងសមិទ្ធផលសំខាន់ៗដែលសម្រេចបានដូចមានរៀបរាប់ខាងលើ ការអនុវត្តគោល-នយោបាយនេះក៏បានជួបប្រទះនឹងបញ្ហាប្រឈម និងហានិភ័យមួយចំនួន ដូចជា (១) កង្វះធនធានមនុស្ស និងថវិកាសម្រាប់គាំទ្រផ្នែកគោលនយោបាយ និងបច្ចេកទេស, (២) ការផ្ដល់កិច្ចសហការ និងការសម្របសម្រួលយន្តការស្ថាប័ននៅមានកម្រិត, (៣) កន្លងមកការកែសម្រួលរចនាសម្ព័ន្ធ និងការផ្លាស់ប្តូរមន្ត្រីទទួលបន្ទុកអនុវត្តគោលនយោបាយនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន បានធ្វើឱ្យការតាមដានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយមានភាពអាក់រអួល, (៤) ការជំរុញការអភិវឌ្ឍតាមវិស័យសម្រាប់គាំទ្រដល់សកម្មភាពឧស្សាហកម្មនៅមានល្បឿនយឺត មិនទាន់មានភាពឆ្លើយឆ្លងនិងប្រទាក់ក្រឡាគ្នានៅឡើយ, (៥) ការរៀបចំនយោបាយប្រជាភិថុត និងបំផុសចលនាអសកម្មរបស់ក្រុម ឬអង្គការមួយចំនួនកំពុងដើរតួនាទីធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់ពុរជន និងអ្នកវិនិយោគ, (៦) ការកើនឡើងនូវប្រាក់ឈ្នួលអប្បបរមា ខណៈពេលដែលផលិតភាពការងារនៅមានកំណើនយឺតបើធៀបនឹងប្រទេសជាដៃគូប្រកួតប្រជែង, (៧) ការកែតម្រូវការ

គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានសម្រេចវឌ្ឍនភាពល្អប្រសើរច្រើន ប៉ុន្តែនៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ទាំងផ្នែកបច្ចេកទេស ដែលចាំបាច់ត្រូវបន្តពង្រឹង និងរៀបចំផែនការកសាងសមត្ថភាព ដើម្បីជោគជ័យនៃកម្មវិធីកំណែទម្រង់សំដៅបង្កើនលំហសារពើពន្ធ និងលទ្ធភាពនៃការវិនិយោគសាធារណៈសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម, (៨) ការសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបរបស់កម្ពុជាអាចនឹងជះឥទ្ធិពលដល់ទំហំហិរញ្ញប្បទានពីក្រៅប្រទេស ជាពិសេស ហិរញ្ញប្បទានសហប្រតិបត្តិការសុទ្ធអាចនឹងមានការធ្លាក់ចុះ, (៩) ការដាក់ចេញនូវគោលនយោបាយអនុគ្រោះពាក់ព័ន្ធនឹងការជំរុញ និងលើកទឹកចិត្តការវិនិយោគរបស់បណ្តាប្រទេសក្នុងតំបន់ ជាពិសេស ប្រទេសថៃ វៀតណាម និងមីយ៉ាន់ម៉ា បានធ្វើឱ្យកម្ពុជាប្រឈមនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស, (១០) ភាពរង្គោះរង្គើនៃស្ថានភាពសេដ្ឋកិច្ចក្នុងសហគមន៍អ៊ីរ៉ុប អាចបង្កហានិភ័យដល់ការនាំចេញទំនិញរបស់កម្ពុជាទៅក្នុងទីផ្សារអន្តរជាតិដ៏ធំមួយនេះ, និង (១១) ការប្រែប្រួលរបបពាណិជ្ជកម្មដែលបណ្តាលមកពីនិន្នាការគាំពារនិយម និងការហូរត្រឡប់ទៅវិញនៃវិនិយោគផ្ទាល់ពីបរទេស ដែលតម្រូវឱ្យកម្ពុជាពង្រឹងសមត្ថភាពទីផ្សារក្នុងស្រុក និងខិតខំទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការចូលរួមក្នុងសមាហរណកម្មសេដ្ឋកិច្ចតំបន់។

៧. ជារួម តាមការពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ នាពេលកន្លងមក បានបង្ហាញឱ្យឃើញថា ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកំពុងស្ថិតនៅក្នុងទិសដៅត្រឹមត្រូវ និងអាចឈានទៅសម្រេចគោលដៅដែលបានកំណត់នៅឆ្នាំ២០២៥។ ក្នុងន័យនេះ ការបន្តកិច្ចខិតខំប្រឹងប្រែងប្រកបដោយការទទួលខុសត្រូវខ្ពស់ និងកិច្ចសហការដ៏ល្អរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងការប្រើប្រាស់នូវធនធានសរុប មធ្យោបាយសរុបក្រោមការដឹកនាំសម្របសម្រួលដ៏មានប្រសិទ្ធភាព គឺជាកត្តាគន្លឹះនៃការធានាជោគជ័យលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនេះ។

របាយការណ៍

ស្តីពី

វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ត្រីមខែធ្នូ ឆ្នាំ២០១៦

១. សេចក្តីផ្តើម

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ត្រូវបានអនុម័តដោយគណៈ-រដ្ឋមន្ត្រី កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥ និងត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋ-មន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ គោលនយោបាយនេះ គឺជាមគ្គុទ្ទេសក៍ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម នៅកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពនិងបរិយាបន្ន តាមរយៈ ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។ ចក្ខុវិស័យនៃគោល-នយោបាយនេះ គឺជំរុញ កែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ ដោយខិតខំសម្រេចគោលដៅបីសំខាន់គឺ ទី១ បង្កើនចំណែកនៃវិស័យឧស្សាហកម្ម ជាពិសេសវិស័យកម្មន្តសាល ក្នុងផលិតផលក្នុងស្រុកសរុប, ទី២ ជំរុញពិពិធកម្ម មុខទំនិញនាំចេញក្រៅពីសម្លៀកបំពាក់ និងការនាំចេញកសិផលកែច្នៃ, និងទី៣ គាំទ្រដល់សហគ្រាសធុនតូច និងមធ្យម។ ដើម្បីសម្រេចបានទ្រឹស្តីចក្ខុវិស័យ និងគោលដៅខាងលើនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធ-សាស្ត្រគន្លឹះបួន ទី១ ការកៀរគរ និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងវិនិយោគឯកជនក្នុងស្រុក, ទី២ ការអភិវឌ្ឍ និងធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម, ទី៣ ការកែលម្អបរិស្ថានទិយតកម្មដើម្បីពង្រឹងភាពប្រកួតប្រជែង និងទី៤ ការសម្របសម្រួលគោលនយោបាយគាំទ្រ។

តាមរយៈគោលនយោបាយនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងនាមជាស្ថាប័នដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ត្រូវបានទទួលនូវសិទ្ធិអំណាចពេញលេញ និងបំពាក់មុខងារចាំបាច់សម្រាប់ការសម្រេចចិត្តផ្អែកគោលនយោបាយ ការរៀបចំ និងការអនុវត្តផែនការ ក៏ដូចជាការដោះស្រាយបញ្ហាប្រឈមចំពោះមុខ។ ក្នុងស្មារតីនេះ ថ្នាក់ដឹកនាំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានធ្វើការងារយ៉ាងសកម្ម និងដឹកនាំកិច្ចប្រជុំជាមួយតំណាងក្រសួង ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធ, តំណាងអភិបាលនៃគណៈអភិបាលរាជធានីខេត្តពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ជាច្រើនលើកច្រើនសារ ក្នុង

គោលបំណងបញ្ជាបការយល់ដឹងអំពីខ្លឹមសារសំខាន់ៗនៃគោលនយោបាយ ព្រមទាំងជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនេះ ឱ្យទទួលបានលទ្ធផលជោគជ័យតាមការកំណត់។

ដើម្បីធានាវឌ្ឍនភាពជាប្រចាំនូវប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្តគោលនយោបាយនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏ត្រូវបានតម្រូវឱ្យធ្វើការរៀបចំ និងសម្របសម្រួលអនុវត្តប្រព័ន្ធតាមដាន និងត្រួតពិនិត្យមួយដ៏មានប្រសិទ្ធភាព ជាពិសេស របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ ក្នុងបរិការណ៍នេះ ដើម្បីឆ្លើយតបនឹងការតម្រូវខាងលើ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំ**របាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ត្រីមាសទី២ ឆ្នាំ២០១៦** នេះឡើង។ គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីធ្វើការបូកសរុបនូវសមិទ្ធផលដែលសម្រេចបាន ដកស្រង់ចំណុចខ្វះចន្លោះនិងបញ្ហាប្រឈម ព្រមទាំងលើកឡើងនូវវិធានការបន្ត និងវិធានការបន្ទាន់ចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខដែលកើតមានឡើងក្នុងពេលអនុវត្ត ព្រមទាំងពន្លឿន និងសម្រួចការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។

របាយការណ៍នេះត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រមួយចំនួន ដូចជា (១) ការសិក្សាលើរបាយការណ៍ និងឯកសារពាក់ព័ន្ធនានាដែលមានស្រាប់សម្រាប់ធ្វើជាគំរូ, (២) ការសិក្សា និងបូកសរុបរបាយការណ៍វឌ្ឍនភាពរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយ និង (៣) ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីបង្គោល និងមន្ត្រីបច្ចេកទេសរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល។ សមាសធាតុសំខាន់ៗនៃរបាយការណ៍មានចំនួន ៤ គឺ (១) សេចក្ដីផ្ដើម, (២) វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ, (៣) បញ្ហាប្រឈម និងហានិភ័យនៃការអនុវត្តគោលនយោបាយ, និង (៤) សន្និដ្ឋាន។

២. វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ

២.១. ការត្រៀមរៀបចំ និងវឌ្ឍនភាព

បន្ទាប់ពីគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងតួនាទីជាអ្នកដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយនេះ បានរៀបចំកិច្ចប្រជុំអន្តរក្រសួងចំនួន៦លើក នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីពិនិត្យ និងពិភាក្សាការងារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។ ប្រធានបទដែលបានពិភាក្សា រួមមាន ការរៀបចំបង្កើតអង្គភាពទទួលបន្ទុក និងចាត់តាំងមន្ត្រីបង្គោលសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជានៅតាមក្រសួង ស្ថាប័ន, ការលើកយកនូវ[illegible]ពីបញ្ហាប្រឈម, ការតម្រង់ទិសក្រសួង ស្ថាប័នក្នុងការរៀបចំផែនការសកម្មភាព និងចរិកតាំងចាំបាច់សម្រាប់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា, ការកំណត់ការងារអាទិភាព, ការកំណត់ការងារ[illegible]

ដែលត្រូវធ្វើចំពោះមុខដែលអាចទទួលបានន្ទវផ្លែផ្លាឆាប់រហ័សទាំងផ្នែកសេដ្ឋកិច្ច និងសង្គម (Low Hanging Fruits), ព្រមទាំងការកំណត់ការងារដែលត្រូវធ្វើក្នុងរយៈពេលមធ្យម និងវែង។ ជារួម កិច្ចប្រជុំខាងលើនេះ ទទួលបានលទ្ធផលដូចខាងក្រោម÷

២.១.១. ការរៀបចំយន្តការស្ថាប័ន

ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មមានចំនួនសរុប ៣១ ក្នុងនោះក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធចំនួន÷

- ៣១ បានចាត់តាំងមន្ត្រីបង្គោល និងមន្ត្រីបច្ចេកទេសទទួលបន្ទុកការងារអនុវត្តគោលនយោបាយ
- ១៤ បានបង្កើតអង្គភាពទទួលបន្ទុកអនុវត្តគោលនយោបាយ និង
- ២០ បានរៀបចំផែនការសកម្មភាពស្តីពីការអនុវត្តគោលនយោបាយនេះ។

២.១.២ ការពិភាក្សាបឋមលើប្រធានបទជាអាទិភាព

ក្នុងការចាប់ផ្តើមការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ប្រធានបទជាអាទិភាពចំនួន ៤ ត្រូវបានលើកយកមកធ្វើជាកម្មវត្ថុនៃកិច្ចប្រជុំពិភាក្សា រួមមាន÷

ប្រធានបទទីមួយ: ការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥។ អង្គប្រជុំបានសម្រេច ទី១ ស្នើឱ្យក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ សម្រួចតួនាទីនិងភារកិច្ច និងធ្វើសុខដុមនីយកម្មផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួន ជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម, ទី២ ស្នើឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយក្រសួងពាណិជ្ជកម្ម សិក្សាកំណត់ន្ទវមុខទំនិញអាទិភាពដែលមានសក្តានុពលសម្រាប់ធ្វើការកែច្នៃនាំចេញ និងទី៣ ផ្តល់រយៈពេល១ខែជូនក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីមានលទ្ធភាពរៀបចំផែនការសកម្មភាពនិងធាតុចូលផ្សេងៗ។

ប្រធានបទទីពីរ: ការជំរុញការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ដែលបានប្រព្រឹត្តទៅនាថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥។ អង្គប្រជុំបានសម្រេច ទី១ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការគ្នាដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការកំណត់អត្តសញ្ញាណរបស់សហគ្រាសធុនតូចនិងមធ្យមឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលដល់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ និងកម្មវិធីគាំទ្រនិងលើកទឹកចិត្ត, ទី២ ប្រគល់ភារកិច្ចជូនឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធ្វើការសម្របសម្រួលជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើម្បីបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្របសម្រួលការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យមនៅក្នុងក្របខ័ណ្ឌដំបូលតែមួយ និងទី៣ ប្រគល់ភារកិច្ចជូនឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការទីតាំងសម្ព្រាន និង

អភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំកិច្ចការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការពីដៃគូអភិវឌ្ឍន៍ ដើម្បីផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ជាពិសេស ជួយដល់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។

ប្រធានបទទីបី: ការជំរុញការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៥។ ដោយយល់ឃើញពីសារៈសំខាន់នៃជំនាញផ្នែកទន់ក្នុងការបង្កើនសមត្ថភាព និងផលិតភាពការងារ ក្រសួងអប់រំ យុវជន និងកីឬា បាននិងកំពុងរៀបចំបញ្ចូលជំនាញផ្នែកទន់ចូលក្នុងកម្មវិធីសិក្សានៅថ្នាក់បឋមសិក្សា ហើយជំហានបន្ទាប់នឹងសាកល្បងដាក់បញ្ចូលទៅក្នុងគ្រប់ភូមិសិក្សាបន្ថែមទៀត។ លើសពីនេះ អង្គប្រជុំបានស្នើឱ្យជំរុញភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ក្នុងការវិនិយោគលើការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ព្រមទាំងពិចារណាបង្កើតអត្រាពន្ធថ្មីគឺ ពន្ធបណ្តុះបណ្តាលវិជ្ជាជីវៈពីនិយោជក ដើម្បីបំពេញបន្ថែមលើកញ្ចប់ថវិកាជាតិសម្រាប់ការជំរុញការបណ្តុះបណ្តាលបច្ចេកទេសជំនាញវិជ្ជាជីវៈ។ ទន្ទឹមគ្នានោះ ក្នុងដំណាក់កាលដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កំពុងរៀបចំតាក់តែងច្បាប់ស្តីពីវិនិយោគថ្មី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងធ្វើការគិតគូរផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនដែលមានការរៀបចំនូវអន្តេវាសិកដ្ឋាន អាហារដ្ឋាន ការផ្តល់សេវាដឹកជញ្ជូន និងការបណ្តុះបណ្តាលដល់កម្មករ និយោជិតជាដើម។

ប្រធានបទទីបួន: ការជំរុញការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥។ អង្គប្រជុំបានស្នើ ទី១ ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ រៀបចំផែនការថវិកាឱ្យបានច្បាស់លាស់ផ្ញើជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីស្នើសុំកញ្ចប់ថវិកាសម្រាប់អនុវត្តតាមផែនការសកម្មភាពដែលបានកំណត់សម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម, ទី២ បង្កើតក្រុមការងារ និងអនុក្រុមការងារពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីសម្រួលការដឹកជញ្ជូន និងទាញយកផលប្រយោជន៍ជាអតិបរមាពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ទាំងផ្នែកវីងនិងផ្នែកទន់ និងទី៣ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយវិស័យឯកជន ដើម្បីស្វែងរកលទ្ធភាពបញ្ចុះថ្លៃចំណាយលើសេវាដឹកជញ្ជូន និងភស្តុភារកម្ម នៅក្នុងរយៈពេលណាមួយកំណត់។

ដោយមើលឃើញពីសារៈសំខាន់នៃប្រធានបទអាទិភាពទាំង៤នេះ បច្ចុប្បន្នក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំក្រុមការងារសិក្សាស្រាវជ្រាវស៊ីជម្រៅលើប្រធានបទទាំង៤នេះ ក្នុងគោលបំណងរៀបចំជំនួយស្មារតីសម្រាប់ផ្តល់ជាព័ត៌មានបន្ថែម និងអនុសាសន៍ផ្នែកគោលនយោបាយសមស្របជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធពិចារណាអនុវត្ត ក្នុងក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

២.២. វឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង ដើម្បីជំរុញការអនុវត្តគោលនយោ-បាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

បន្ថែមលើការដាក់ចេញនូវវិធានការគោលនយោបាយ និងផែនការសកម្មភាពក្នុងការអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលដែលមានក្រសួង ស្ថាប័នពាក់ព័ន្ធជាសេនាធិការ បាននិងកំពុងអនុវត្តនូវវិធានការជាក់ស្តែងគន្លឹះបួនយ៉ាង ឱ្យសម្រេចបាននៅមុនដំណាច់ឆ្នាំ២០១៨ ដែលជាបង្គោលចរដ៏សំខាន់សម្រាប់ជាស់វែងកិច្ចខិតខំប្រឹងប្រែង និងវឌ្ឍនភាពនៃការអនុវត្ត **"គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម"** ព្រមទាំងជាមួលដ្ឋាន និងបុរេលក្ខខណ្ឌមិនអាចខ្វះបាន ដែលនឹងកំណត់នូវជោគជ័យក្នុងការអនុវត្តនូវចក្ខុវិស័យ គោល-បំណង និងគោលដៅនៃគោលនយោបាយនេះ។

ចាប់តាំងពី **"គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម"** ត្រូវបានអនុម័តរហូតមកទល់បច្ចុប្បន្ន ក្រសួង ស្ថាប័នមួយចំនួន បានអនុវត្តសកម្មភាពការងាររបស់ខ្លួនជាច្រើន ដើម្បីសម្រេចឱ្យបាននូវវិធានការគន្លឹះបួនជាក់ស្តែងដូចការគ្រោងទុកមុនដំណាច់ឆ្នាំ២០១៨ ដូចតទៅ÷

២.២.១. វិធានការទី១ - *"រៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី សម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្ដប់នៃការផ្គត់ផ្គង់អគ្គិសនី"*

ក្រសួងរ៉ែនិងថាមពល បានធ្វើការកសាងខ្សែបញ្ជូនតង់ស្យុងខ្ពស់ឆ្លងកាត់រាជធានីខេត្ត ដែលសម្រេចបានការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ប៉ូលសេដ្ឋកិច្ចសំខាន់ៗប្រមាណជា៥0% ក្នុងឆ្នាំ២០១៦ និងគ្រោងគ្របដណ្ដប់ ១00% ក្នុងឆ្នាំ២០១៨ ចំពោះតំបន់ឧស្សាហកម្មស្ថិតនៅរង្វង់២៥គ.ម. ពីអនុស្ថានីយ, ព្រមទាំងបាននិងកំពុងសាងសង់ខ្សែបណ្ដាញមេចេញពីអនុស្ថានីយ និងខ្សែបណ្ដាញជាកងសម្រាប់តំបន់សំខាន់ៗ។ ជាមួយគ្នានេះផងដែរ ក្រសួងបានចេញប្រកាសស្ដីពីការកំណត់ផែនការយុទ្ធសាស្ត្រ ដើម្បីបន្ថយអត្រា និងកំណត់ថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥-២០២០។

អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រសួងរ៉ែនិងថាមពល បានសហការបញ្ចប់ការសិក្សាផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងកំណត់ថ្លៃលក់អគ្គិសនីតាមបណ្ដាខេត្តនិងរាជធានីភ្នំពេញ, ចុះស្រង់ស្ថិតិអំពីអស្ថិ-ភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅតាមតំបន់សេដ្ឋកិច្ចពិសេស និងកសាងមូលដ្ឋានទិន្នន័យ, ព្រមទាំងលើកគម្រោងវិនិយោគកែលម្អប្រព័ន្ធ និងបំពាក់ឧបករណ៍បច្ចេកទេសដើម្បីលើកកម្ពស់ស្ថិរភាពនៃការផ្គត់ផ្គង់។ ទន្ទឹមគ្នានេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានអនុម័តផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងតម្លាត់ថ្លៃលក់អគ្គិសនី តាមបណ្ដាខេត្តនិងរាជធានីសម្រាប់ឆ្នាំ២០១៥-២០១៦ ដោយបានអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាថ្ងៃយប់សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្ម ព្រមទាំងបាននិងកំពុងសិក្សាថ្លៃលក់ តាមពេលវេលាថ្ងៃយប់សម្រាប់ឆ្នាំ២០១៧។ បញ្ជីថ្លៃលក់ត្រូវបានធ្វើបច្ចុប្បន្នកម្មឆ្នាំ២០១៧-២០២០។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើគម្រោងពង្រីកខ្សែបញ្ជូនអគ្គិសនីជនបទ ជំហានទី៥ និងទី៦ មានទំហំទឹកប្រាក់សរុបចំនួន ៥០លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៦ និងកំពុងចរចាលើគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីក្រចេះ និងស្ទឹងត្រែងជំហានទី៣ និងគម្រោងសាងសង់ប្រព័ន្ធខ្សែបញ្ជូន និងចែកចាយអគ្គិសនីនៅរាជធានីភ្នំពេញ។ ជាមួយគ្នានេះ ក្រសួងបាននិងកំពុងជួយអគ្គិសនីកម្ពុជាក្នុងការរៀបចំផែនការវិនិយោគ ២០១៦-២០២០ ដើម្បីជាមូលដ្ឋានគ្រប់ជ្រុងជ្រោយសម្រាប់ស្វែងរកហិរញ្ញប្បទាន និងចាប់ផ្តើមអនុវត្តគម្រោងសាងសង់ខ្សែអគ្គិសនីបណ្តាញមេជំហានទី១ (ខេត្តបាត់ដំបង-ខេត្តសៀមរាប-ខេត្តកំពង់ចាម) មានទំហំទឹកប្រាក់សរុប ១៦៧លានដុល្លារអាមេរិក។ ក្រសួងក៏បានបញ្ចប់ការរៀបចំឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូ រវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ ដែលនឹងរួមចំណែកយ៉ាងសំខាន់ដល់ការកៀរគរទុនវិនិយោគរបស់វិស័យឯកជនក្នុងការចូលរួមវិនិយោគលើវិស័យថាមពលអគ្គិសនី។ ទន្ទឹមគ្នានេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្សព្វផ្សាយផែនការសម្រាប់អនុវត្តការបន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីនៅតាមតំបន់សំខាន់ៗជូនវិនិយោគិន និងទាក់ទាញការវិនិយោគបន្ថែមក្នុងវិស័យផលិតថាមពលអគ្គិសនី។

២.២.២ វិធានការទី២- *"រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម"*

ក្រសួងសាធារណការនិងដឹកជញ្ជូន បានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១៧-២០១៩ លើការរៀបចំផែនការមេប្រព័ន្ធភស្តុភារកម្ម ដោយក្នុងនោះក្រុមជំនាញការកូរ៉េ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន កំពុងសិក្សាអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម និងការរៀបចំផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម។ ក្រសួងក៏បាននិងកំពុងអភិវឌ្ឍចំណតពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុប្រវែង ៣៣០ម៉ែត្រ ជម្រៅទឹក -១៣,៥ម៉ែត្រ សម្រេចបាន ៦៨,១៥% ព្រមទាំងបាននិងកំពុងបញ្ចុះតម្លៃសេវាពាក់ព័ន្ធនឹងភស្តុភារកម្មជាច្រើនដូចជា ការបញ្ចុះតម្លៃសេវាលើកដាក់កុងតឺន័រនៅទីលានកុងតឺន័រក្នុងកំពង់ផែស្វយ័តក្រុងព្រះសីហនុ ១០%, កំពង់ផែស្វយ័តភ្នំពេញ ៥%, បញ្ចុះតម្លៃ ១០% នៃតម្លៃសេវាកត់ត្រាកុងតឺន័រលើសម៉ោង និងបញ្ចុះតម្លៃ ១០% ទៀតនៃតម្លៃត្រួតពិនិត្យកុងតឺន័រនៅពេលលើកដាក់នៅលើនាវាដោយភ្នាក់ងារកាំសាបជាដើម។ ក្រសួងសាធារណការនិងដឹកជញ្ជូន ក៏បានបង្កើតអគ្គនាយកដ្ឋានភស្តុភារកម្ម ដែលមានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារពាក់ព័ន្ធវិស័យភស្តុភារកម្ម ព្រមទាំងបានបញ្ចប់លក្ខខណ្ឌយោង ត្រៀមបកប្រែ និងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាភស្តុភារកម្ម ដើម្បីដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។ ក្រសួងក៏បានស្នើសុំទៅរដ្ឋាភិបាលជប៉ុន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ក្នុងការសិក្សាលើគម្រោងរៀបចំស្វយ្យប្រវត្តិកម្មរដ្ឋមន្ត្រីក្រសួង

ទិន្នន័យអេឡិចត្រូនិក (Electronic Data Interchange) ដើម្បីសម្រួលលំហូរបែបបទនាវានិងនាវិកចេញចូលនៅតាមកំពង់ផែជាតិនិងអន្តរជាតិ។

លើសពីនេះ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងចរចាលើកិច្ចសន្យាសម្បទានលើគម្រោងផ្លូវល្បឿនលឿន (ភ្នំពេញ-ព្រះសីហនុ) ដែលនឹងវិនិយោគដោយក្រុមហ៊ុនមកពីសាធារណរដ្ឋប្រជាមានិតចិន ហើយគ្រោងចាប់ផ្តើមដំណើរការគម្រោងនៅចុងឆ្នាំ២០១៧នេះ ព្រមទាំងគម្រោងផ្លូវល្បឿនលឿន (ភ្នំពេញ-បាវិត) ដែលនឹងគ្រោងបញ្ចប់ការសិក្សារបាយការណ៍បឋមនៅខែមករា ឆ្នាំ ២០១៧។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់សំណើសុំជំនួយបច្ចេកទេសសម្រាប់រៀបចំផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្មទៅភាគីចិន។ ក្រៅពីនេះ ក្រសួងក៏បានរៀបចំសេចក្តីព្រាងទស្សនាទាននិងប្រមូលទិន្នន័យសម្រាប់គម្រោងស្តីពីហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ ដោយមានកិច្ចសហការ និងគាំទ្រពីសាធារណរដ្ឋកូរ៉េ។ លើសពីនេះ ក្រសួងបានវិភាជន៍ថវិកាជាតិចំនួនប្រមាណ ៦០លានដុល្លារអាមេរិក សម្រាប់អនុវត្តគម្រោងជួសជុល និងស្តារផ្លូវដែកកម្ពុជាខ្សែទិសខាងត្បូង និងទិសខាងជើង ព្រមទាំងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ១ ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ដែលរួមមានការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្រុងព្រះសីហនុ និងក្រុងកំពត (ការសាងសង់ស្ថានីយច្រោះទឹកកខ្វក់ ប្រព័ន្ធរំដោះទឹកភ្លៀង និងទីលានចាក់សំរាម)។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាការងារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដោយផ្តោតសំខាន់លើប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម។ ក្រៅពីការងារសម្របសម្រួលខាងលើ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏បានចូលរួមពិនិត្យ ពិភាក្សា និងផ្តល់យោបល់ក្នុងកិច្ចប្រជុំមួយចំនួនពាក់ព័ន្ធការអភិវឌ្ឍវិស័យដឹកជញ្ជូន និងភស្តុភារកម្ម ដូចជា (១) កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងរបាយការណ៍បញ្ចប់ស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធភស្តុភារកម្ម, (២) កិច្ចប្រជុំជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ដើម្បីពិភាក្សាអំពីការសិក្សាលើប្រព័ន្ធភស្តុភារកម្មនៅកម្ពុជា, (៣) កិច្ចប្រជុំអនុក្រុមការងារបច្ចេកទេសដឹកជញ្ជូនផ្លូវគោក, (៤) កិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍សិក្សាស្តីពីការសម្របសម្រួលសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ដែលត្រូវបានសហការរៀបចំដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ និងក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងជំរុញការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក, (៥) កិច្ចប្រជុំអន្តរក្រសួងពាក់ព័ន្ធនឹងការពិភាក្សាលើកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន ក្នុងក្របខ័ណ្ឌមហាអនុតំបន់មេគង្គ និងក្នុងក្របខ័ណ្ឌទ្វេភាគី, (៦) កិច្ចប្រជុំគណៈកម្មការចម្រុះអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ លើគម្រោងបើកច្រកអន្តរជាតិថ្មីនៅខេត្តបន្ទាយមានជ័យ និង

ខេត្តស្រះកែវ (ច្រកណងអៀន-ស្ទឹងបត់) ដើម្បីដោះស្រាយបញ្ហាកកស្ទះនូវរថយន្តដឹកទំនិញ, (៧) កិច្ចប្រជុំអន្តរក្រសួងលើគម្រោងសាងសង់ផ្លូវលឿនលឿនភ្នំពេញ-បាវិត និងគម្រោងសាងសង់ផ្លូវលឿនលឿនភ្នំពេញ-ព្រះសីហនុ, និង (៨) កិច្ចសន្ទនាគោលនយោបាយស្តីពីភស្តុភារកម្ម និងសិក្ខាសាលាស្តីពីភស្តុភារកម្មដែលសហការរៀបចំដោយក្រសួងសាធារណការនិងដឹកជញ្ជូន ជាមួយក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍នៃប្រទេសជប៉ុន ក្រោមក្របខ័ណ្ឌនៃ "ភាពជាដៃគូដឹកជញ្ជូនអាស៊ាន-ជប៉ុន" ក្នុងគោលបំណងពិនិត្យលើស្ថានភាពភស្តុភារកម្មនៅកម្ពុជា និងក្របខ័ណ្ឌនៃការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន ព្រមទាំងលើកឡើងពីសំណូមពររបស់ភាគីជប៉ុន ក្នុងការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មនៅកម្ពុជា។

២.២.៣. វិធានការទី៣- *"ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះ-បណ្តាលជំនាញ"*

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធបានដឹកនាំសម្របសម្រួលការងារកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៧ ក្នុងក្របខ័ណ្ឌគណៈកម្មការប្រឹក្សាការងារ, ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា, ការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥, ការរៀបចំ និងអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ, ការរៀបចំ និងអនុវត្តច្បាប់ស្តីពីសហជីព, និងការអនុវត្តច្បាប់ស្តីពីការងារ។

ក្រសួងអប់រំ យុវជន និងកីឬា បានបញ្ជាបខ្លឹមសារពាក់ព័ន្ធនឹងវិធានការនេះទៅក្នុងឯកសារពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ និងបានសមាហរណកម្មទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាពពាក់ព័ន្ធ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានចូលរួមក្នុងការអនុវត្តវិធានការនេះ តាមរយៈការបង្កើតក្រុមការងារ ដើម្បីធ្វើការសិក្សាកំណត់នូវកត្តាដែលជះឥទ្ធិពលដល់ផលិតភាពក្នុងវិស័យវាយនភណ្ឌរបស់កម្ពុជា, បង្កើនថវិកាសម្រាប់បន្តការគាំទ្រដល់ការងារកសាងសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងកញ្ចប់ចំណាយសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសជំនាញ រយៈពេលពី១ទៅ៣ឆ្នាំ (ពី៥០ម៉ឺនរៀល/ម្នាក់ទៅ១លានរៀល/ម្នាក់), និងបានដាក់បញ្ចូលកម្មវិធីកសាងសមត្ថភាពដើម្បីបង្កើនភាពប្រកួតប្រជែង (Skills for Competitiveness Development Program) ដែលមានទឹកប្រាក់ប្រមាណ ៦០លានដុល្លារអាមេរិក ទៅក្នុងបញ្ជីគម្រោង/កម្មវិធីដែលគ្រោងចុះហត្ថលេខាក្នុងឆ្នាំ២០១៧-២០១៩។ លើសពីនេះទៀត ដើម្បីចូលរួមលើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពបងប្អូនកម្មករនិយោជិត ក្រសួងបានដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ (មាត្រា៤៧ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ), ព្រមទាំងបានដាក់ចេញនូវយន្តការអនុគ្រោះពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែមសម្រាប់ចំណាយលើការដឹកជញ្ជូន, ស្នាក់នៅ និងហូបចុកសម្រាប់កម្មករនិយោជិត។ ក្រៅពីការងារខាងលើ ក្រសួងក៏បាននិងកំពុងពិនិត្យសំណើគម្រោងមជ្ឈមណ្ឌលបណ្តុះបណ្តាល

ជំនាញនិងវិជ្ជាជីវៈទេសចរណ៍នៅខេត្តបាត់ដំបងរបស់ក្រសួងទេសចរណ៍, គម្រោងអគារស្ថិតក្នុងវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា និងគម្រោងអគារស្ថិតក្នុងវិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្រុមប្រឹក្សាជាតិគណនេយ្យ បានសហការជាមួយវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ដើម្បីបង្កើតកម្មវិធីសិក្សាគណនេយ្យជំនាញថ្នាក់ជាតិ។ ជាលទ្ធផល សេចក្តីព្រាងកម្មវិធីសិក្សានេះ ត្រូវបានរៀបចំរួចរាល់និងបានសម្រេច ព្រមទាំងបាននិងកំពុងរៀបចំទម្រង់នៃវិញ្ញាសាសម្រាប់ការប្រឡងលើមុខវិជ្ជានីមួយៗ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានដឹកនាំកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យនិងពិភាក្សាការងារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដោយផ្តោតសំខាន់លើការជំរុញការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងការងារកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៧ ក្នុងក្របខ័ណ្ឌគណៈកម្មការប្រឹក្សាការងារ, រៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា, ការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥, ការរៀបចំ និងអនុវត្តគោលនយោបាយគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងច្បាប់ស្តីពីសហជីព។

ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំ និងផ្តល់ធាតុចូលពាក់ព័ន្ធនឹងវិធានការនេះផងដែរ ដើម្បីជំរុញការអភិវឌ្ឍ និងបណ្តុះបណ្តាលធនធានមនុស្ស។

គណៈកម្មាធិការផលិតភាពកម្ពុជា បានសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយគម្រោងស្រាវជ្រាវចំនួន៣ ដូចជា (១) សុខុមាលភាព និងផលិតកម្មពលកម្ម របស់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងនៅកម្ពុជា, (២) ការវិភាគលើវិស័យឧស្សាហកម្មកម្ពុជា÷ យល់ដឹងពីឥទ្ធិពលទៅលើផលិតភាពពលកម្ម ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងភាពប្រកួតប្រជែង, និង (៣) តម្រូវការជំនាញក្នុងវិស័យឧស្សាហកម្មកំពុងលូតលាស់នៅកម្ពុជា។ ទន្ទឹមគ្នានេះ គណៈកម្មាធិការផលិតភាពកម្ពុជា បានរៀបចំកិច្ច-ប្រជុំចំនួន ២លើកគឺ (១) ការពិនិត្យនិងពិភាក្សាអំពីសេចក្តីព្រាងផែនការសកម្មភាព និងទិសដៅសិក្សាស្រាវជ្រាវលើសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម និងភាពប្រកួតប្រជែង របស់គណៈកម្មាធិការផលិតភាពកម្ពុជា និង (២) ការត្រួតពិនិត្យទៅលើលទ្ធផលសិក្សាស្រាវជ្រាវនៃឥទ្ធិពលប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៥ ទៅលើសុខុមាលភាពកម្មករ ការវាស់វែង និងគណនាប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៦ នៅក្នុងវិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង។ លើសពីនេះ គណៈកម្មាធិការផលិតភាពកម្ពុជា បានសិក្សាស្រាវជ្រាវលើ "សន្ទស្សន៍ថ្លៃអ្នកផលិត" សម្រាប់ពង្រឹងការគណនាពីផលិតភាពពលកម្ម ដើម្បីអ្នកជ្ញាពីស្ថានភាពនៃផលិតភាពការងាររបស់កម្មករ និងបានសហការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍ក្ងីង សិក្សាស្រាវជ្រាវស្តីពី

"ការអភិវឌ្ឍជំនាញ និងវិស័យឧស្សាហកម្ម ដើម្បីលើកកម្ពស់ផលិតភាពពលកម្មក្នុងប្រទេសកម្ពុជា" ដែលផ្តោតលើវិស័យកសិ-ឧស្សាហកម្ម។

២.២.៤. វិធានការទី៤ - *"អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុ-បំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស"*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចូលរួមសម្រួលឱ្យមានកិច្ចដំណើរការរោងចក្រ និងក្រុមហ៊ុនជាង ១០០រួចហើយនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងបានជំរុញណែនាំឱ្យអ្នកអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្នុងភូមិសាស្ត្រនេះកសាងហេដ្ឋារចនាសម្ព័ន្ធឱ្យបានឆាប់ដើម្បីឈានទៅទាក់ទាញវិនិយោគិនបន្ថែមទៀត។

ក្រសួងពាណិជ្ជកម្ម បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ក្នុងវិស័យពាណិជ្ជកម្ម ដើម្បីជួយសម្រួលដល់បរិយាកាសធុរកិច្ចនិងវិនិយោគក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម ហើយច្បាប់និងអនុក្រឹត្យពាក់ព័ន្ធមួយចំនួនបានបញ្ចប់ និងមួយចំនួនទៀតកំពុងបន្តតាក់តែងបញ្ចប់។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានពិភាក្សាជាមួយមន្ត្រីជំនាញតំណាងក្រុមហ៊ុនខេមបូឌែរ អ៊ែរផត មន្ត្រីជំនាញតំណាងក្រុមហ៊ុនខាមបូឌែរ អ៊ែរត្រាហ្វិកស៊ីវិល និងនាយកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ដើម្បីសិក្សាពីផែនការអភិវឌ្ឍន៍សេវាកម្មអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ, ព្រមទាំងបាននិងកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាព ២០១៨-២០២៥ លើវិស័យអាកាសចរស៊ីវិល ដើម្បីចូលរួមអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង។

ក្រសួងទេសចរណ៍ បានរៀបចំ និងប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ ២០១៦-២០២៥ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍទេសចរណ៍នៅខេត្តព្រះសីហនុ។ លើសពីនេះ ក្នុងនាមជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា និងជាប្រធានក្រុមការងារអចិន្ត្រៃយ៍ដើម្បីដោះស្រាយជំរុញ និងតាមដានការអភិវឌ្ឍលើកោះរ៉ុង, ក្រសួងទេសចរណ៍បានចូលរួមជំរុញការរៀបចំគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ដូចជាការរៀបចំសម្អាតឆ្នេរ ការគ្រប់គ្រងឆ្នេរ ការគ្រប់គ្រងសំណល់ និងបរិស្ថានតាមឆ្នេរខេត្តព្រះសីហនុ ការរៀបចំបុណ្យសមុទ្រលើកទី២ នៅក្នុងខេត្តព្រះ-សីហនុ ព្រមទាំងបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការជំរុញដោះស្រាយផលប៉ះពាល់ទាក់ទងនៅ-កោះរ៉ុង។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០ ដោយបានបញ្ចូលការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ នៅតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច។ ក្នុងកិច្ចការនេះផងដែរ សហគ្រាសមួយចំនួនក៏បានចូលរួមជាមួយ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងការអភិវឌ្ឍវិស័យនេះ ដូចជា (១) ក្រុមហ៊ុន (ខេមបូឌា) ហ្វីប៊ើរ អុបទិច ខមញ្ជូនីខេសិន ណេតវើក (Cambodia Fiber Optic Communication Network Co.,Ltd - CFOCN) បានកសាងបណ្តាញខ្សែកាប្លិ៍អុបទិកបានប្រវែង ១១ ០០០គ.ម. ទូទាំងប្រទេស និងបានកសាងខ្សែកាប្លិ៍ អុបទិកឆ្លងកាត់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុរួចរាល់, (២) ក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា បានកសាង បណ្តាញអុបទិកតភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ក្រុងព្រះសីហនុ ដែលមានចំណុះ ៤៨សរសៃ និងមានកម្រិត បញ្ជូន និងទទួលបាន Bandwith ១០ជីហ្គាប៊ីតក្នុង១វិនាទី, បានស្ថាបនាអគារជាស្ថានីយចែកចាយសេវា និង បានស្ថាបនាបណ្តាញចែកចាយសេវាអ៊ីនធើណេតនិងទូរស័ព្ទ តាមរយៈបច្ចេកវិទ្យា Gigabit Ethernet Passive Optical Network (GEPON) ដែលនឹងអាចផ្តល់សេវា Triple Play បានទៅថ្ងៃអនាគត និងសេវា Internet Protocol Port (IP Port), Domestic Private Leased Circuit (DPLC), International Private Leased Circuit (IPLC), Virtual Private Network (VPN) និង (៣) ប្រៃសណីយ៍កម្ពុជា បាន បញ្ចប់ការធ្វើទំនើបកម្មនៃប្រព័ន្ធប្រៃសណីយ៍ដើម្បីជួយសម្រួលដល់ប្រព័ន្ធភស្តុភារកម្ម នៅតាមតំបន់ទាំង នោះដោយការបង្កើតប្រព័ន្ធត្រួតពិនិត្យតាមបញ្ជរ (Counter Automation) និងប្រព័ន្ធតាមដានបញ្ជើ ប្រៃសណីយ៍អន្តរជាតិ (International Postal System) និងប្រព័ន្ធតាមដានសេវាផ្ទេរប្រាក់អន្តរជាតិ (International Financial System)។

២.៣. វឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព

២.៣.១. ការជំរុញការទាក់ទាញវិនិយោគ

ក. បរិយាកាសវិនិយោគ

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន១០ ដែលពាក់ព័ន្ធទៅនឹង "បរិយាកាសវិនិយោគ" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើនដូចខាងក្រោម÷

ក.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបន្តសកម្មភាពយ៉ាងផុសផុលក្នុងការចែករំលែកនូវខ្លឹមសារគោល នយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដល់មន្ត្រីបង្គោលនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីឱ្យមានការយល់ឃើញរួមគ្នាពីទិសដៅនៃការអនុវត្តគោលនយោបាយ, ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីវិនិយោគ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស, ការរៀបចំសេវា ថែទាំការវិនិយោគ, ការរៀបចំកែសម្រួលរចនាសម្ព័ន្ធអភិបាលកិច្ចក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ការពង្រឹងសមត្ថភាព

មន្ត្រីលើការរៀបចំអនុវត្ត និងពិនិត្យតាមដានការអនុវត្តគោលនយោបាយបន្ថែមលើតួនាទីជាប្រតិបត្តិករ ព្រមទាំងបានបន្តបង្កើនប្រសិទ្ធភាពយន្តការច្រកចេញ-ចូលតែមួយ និងបានចុះបញ្ជីគម្រោងវិនិយោគចំនួន១៨១ នៅឆ្នាំ២០១៥ និងចំនួន១៧១ នៅឆ្នាំ២០១៦។

ក្នុងក្របខ័ណ្ឌនៃការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីវិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលធាតុចូលដែលពាក់ព័ន្ធក្នុងការរៀបចំសេចក្ដីព្រាងច្បាប់, បានប្រជុំពិភាក្សាក្នុងកម្រិតក្រុមការងារបច្ចេកទេសចំនួន ២១លើក, បានរៀបចំសិក្ខាសាលាស្ដីពីរបបលើកទឹកចិត្តវិនិយោគនៅកម្ពុជាក្រោមកិច្ចសហការជាមួយធនាគារពិភពលោក និងសហគមន៍អ៊ីរ៉ុប ព្រមទាំងបានពិចារណាផ្ដល់ការលើកទឹកចិត្តបន្ថែមចំពោះគម្រោងវិនិយោគដែលបានចូលរួមក្នុងការបណ្ដុះបណ្ដាលជំនាញ, ការស្រាវជ្រាវ និងអភិវឌ្ឍន៍, ការផ្ដល់សេវាដឹកជញ្ជូន និងការកសាងកន្លែងស្នាក់នៅសម្រាប់កម្មករនិយោជិតជាដើម។ ទន្ទឹមគ្នានេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំកិច្ចប្រជុំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ដីពីសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបំពេញបន្ថែមមាត្រា១៥ នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ផ្ដល់ការលើកទឹកចិត្តចំពោះគម្រោងពង្រីកផលិតកម្ម។

ជាមួយគ្នានេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងសិក្សារៀបចំផែនការសកម្មភាពរយៈពេលខ្លីនិងរយៈពេលមធ្យម ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការទាក់ទាញវិនិយោគ ព្រមទាំងការជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម, បានបន្តតាមដានក្រុមហ៊ុនដែលគ្មានសកម្មភាព និងបិទទ្វារដែលមិនបានបំពេញបែបបទតាមនីតិវិធីនៃច្បាប់ ព្រមទាំងបានធ្វើបច្ចុប្បន្នកម្មតួលេខវិនិយោគ, បានរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីចុះពិនិត្យការអនុវត្តគម្រោងរបស់បណ្ដាក្រុមហ៊ុន ដែលបានចុះកិច្ចសន្យាវិនិយោគលើកោះនានា នៅខេត្តកែប កំពត ព្រះសីហនុ និងកោះកុង, បន្តតាមដាននិងជំរុញការអនុវត្តជាក់ស្ដែងរបស់បណ្ដាតំបន់សេដ្ឋកិច្ចពិសេស ដែលបានទទួលអនុក្រឹត្យបង្កើតតំបន់សេដ្ឋកិច្ចពិសេសពីរាជរដ្ឋាភិបាលឱ្យស្របតាមគោលការណ៍កំណត់, បានរៀបចំកម្រងសំណួរ និងក្រុមការងារចុះប្រមូលព័ត៌មាន ក្នុងគោលបំណងស្វែងយល់ពីបញ្ហាប្រឈមរបស់គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីជាធាតុចូលសម្រាប់រៀបចំយុទ្ធសាស្ត្រសេវាថែទាំការវិនិយោគ, ព្រមទាំងបានរៀបចំវីដេអូផ្សព្វផ្សាយដើម្បីទាក់ទាញការវិនិយោគ ដោយផ្ដោតលើប្រទេសគោលដៅមួយចំនួនដូចជា ជប៉ុន និងចិន។

លើសពីនេះទៀត ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំសិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពីការជំរុញនិងកិច្ចសម្រួលការវិនិយោគជូនមន្ត្រីកំពុងបម្រើការនៅអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត និងតំណាងផ្នែកឯកជនទាំង២៥រាជធានីខេត្ត សំដៅធានាគុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាដល់វិនិយោគិនឱ្យកាន់តែមានភាពទាក់ទាញ និងមានទំនុកចិត្តពីវិនិយោគិនបន្ថែមទៀត ព្រមទាំងបានរៀបចំវេទិការជុំកិច្ចភ្ជាប់-

ចិន, វេទិកាវិនិយោគកម្ពុជា-កូរ៉េ, និងបានរៀបចំ និងចូលរួមព្រឹត្តិការណ៍ សិក្ខាសាលា និងវេទិកាជាច្រើនទៀត ទាំងក្នុង និងក្រៅប្រទេសទាក់ទងនឹងការទាក់ទាញវិនិយោគ និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។ ស្របគ្នានេះដែរ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរបស់ខ្លួន តាមរយៈការតាមដាន និងវិភាគនូវប្រសិទ្ធភាពនៃការផ្តល់សេវាបច្ចុប្បន្ន និងដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដូចជាការកំណត់សេវាអាទិភាពជាដើម ព្រមទាំងបាននិងកំពុងរៀបចំគេហទំព័រថ្មី, ការដាក់ពាក្យស្នើសុំចុះបញ្ជីគម្រោងវិនិយោគតាមប្រព័ន្ធអេឡិចត្រូនិក, ការដាក់ពាក្យស្នើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ ចំពោះវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងតាមប្រព័ន្ធអេឡិចត្រូនិក, និងការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក។

ក.២. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ពាក់ព័ន្ធនឹងការជំរុញ និងលើកទឹកចិត្តគម្រោងវិនិយោគ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងសិក្សាពិនិត្យអំពីចំណុចដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង សម្រាប់ចូលរួមរៀបចំច្បាប់ស្តីពីវិនិយោគថ្មី ព្រមទាំងរៀបចំបញ្ចូលប្រការពាក់ព័ន្ធនឹងការលើកទឹកចិត្តវិនិយោគ ទៅក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ។ ស្របគ្នានេះ ក្រសួងបានធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិមួយចំនួន ដើម្បីលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិកម្ម ថាមពល និងការសម្អាតកាកសំណល់រឹងរាវ។ល។ ហើយក៏បានចូលរួមកែសម្រួល និងផ្តល់ធាតុចូលលើឯកសារសំខាន់ៗពាក់ព័ន្ធដូចជា កញ្ចប់ឯកសារកិច្ចព្រមព្រៀងប្រេងកាត, កិច្ច-ព្រមព្រៀងស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ, សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការប្រមូលចំណូលសួយសារធនធានរ៉ែពីការប្រើប្រាស់ធនធានរ៉ែសំណង់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ, និងឯកសារផ្សេងៗទៀត។ កន្លងមក ក្រសួងបានរៀបចំប្រកាសរួមជាមួយក្រសួងស្ថាប័នប្រមូលចំណូលមិនមែនសារពើពន្ធសំខាន់ៗដូចជារដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, ក្រសួងរ៉ែនិងថាមពល, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្រសួងពាណិជ្ជកម្ម ។ល។ ដើម្បីកំណត់តម្លៃសេវាសំខាន់ៗមួយចំនួន, ឈ្នួលដី, សួយសារ ជាដើម។ ក្នុងកិច្ចការនេះផងដែរ ក្រសួងបានបញ្ចប់ការសិក្សាដោយសង្ខេបស្តីពីការកែទម្រង់គោលនយោបាយពន្ធអាករ, បញ្ចប់ការពិនិត្យឡើងវិញលើចំណាយសាធារណៈស្តីពីចំណាយពន្ធ, ចូលរួមផ្តល់យោបល់ និងសម្របសម្រួលការកែតម្រូវបន្ទាត់ពន្ធសម្រាប់ឆ្នាំ២០១៧, ចូលរួមកសាង និងដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយ និង/ឬលុបបំបាត់ពន្ធគយ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងទៀតជាធរមាន (អនុក្រឹត្យលេខ១១៧១ អនក្រ.បក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥), និងចូលរួមផ្តល់ធាតុចូលសម្រាប់រៀបចំលិខិតបទដ្ឋានក្នុងការផ្តល់ការលើកទឹកចិត្តចំពោះគម្រោងពង្រីកផលិតកម្ម។ លិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលត្រូវបានរៀបចំ និងដាក់ចេញ ដើម្បីលើកទឹកចិត្តផ្នែកពន្ធដារ និងពន្ធគយអាចរួមជា (១) ប្រកាសលេខ១០៥ សហវ.ប្រក ស្តីពីការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ, (២) ប្រកាសលេខ១១៣ សហវ.ប្រក ស្តីពីការគ្រប់គ្រងឯកសារបញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀត

ទាក់ទងនឹងការនាំចេញ នាំចូល, (៣) ប្រកាសលេខ ៩២៨ សហវ.ប្រក ស្តីពីការនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិក, និង (៤) ប្រកាសលេខ ៣៨៨ សហវ.ប្រក ស្តីពីយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។

ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃយន្តការភាពជាដៃគូគយ-ផ្នែកឯកជន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំលើកទី៦ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ដោយបានពិនិត្យនិងដោះស្រាយបញ្ហា និងសំណូមពរចំនួន១៦ របស់វិស័យឯកជនបន្ថែមលើបញ្ហា និងសំណូមពរចំនួន ៣០ ដែលត្រូវបានដោះស្រាយរួចក្នុងកម្រិតក្រុមការងារបច្ចេកទេសនៃកិច្ចប្រជុំភាពជាដៃគូគយ-ផ្នែកឯកជន (៤៣ បានដោះស្រាយរួច និង ៣ទៀតត្រូវដោះស្រាយតាមវេទិកាផ្សេងទៀត)។ ផ្អែកតាមស្មារតីនៃកិច្ចប្រជុំ សេចក្តីណែនាំចំនួន២ ត្រូវបានដាក់ចេញពាក់ព័ន្ធនឹង (១) ការបិទផ្សាយលំហូរនីតិវិធី និងស្តង់ដាការងារ, (២) ការអនុញ្ញាតឱ្យរើទំនិញច្រើនម្ចាស់ផ្ទុកក្នុងកុងតឺន័រ (Less Than Container Load), (៣) ការកែលម្អគេហទំព័រគយ, (៤) ការពង្រឹងប្រសិទ្ធភាពនៃការបង្ក្រាបបទល្មើស, (៥) ការអនុញ្ញាតឱ្យនាំចេញទំនិញកាត់ដេរមានម្ចាស់តែមួយក្នុងរថយន្តមានលក្ខណសម្បត្តិជាកុងតឺន័រ, (៦) ការទទួលយកតម្លៃប្រកាសសម្រាប់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ និង (៧) ការបង្កើត Hotline សម្រាប់តវ៉ាតាមមាត់ច្រក។

ពាក់ព័ន្ធនឹងការពង្រឹងយន្តការត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងវិនិយោគ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុវត្តសកម្មភាពជាច្រើនដូចជា វាយតម្លៃទំហំទំនិញនាំចូលនិងទឹកប្រាក់ពន្ធ និងអាករជាបន្ទុករដ្ឋរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមខែនីមួយៗជាប្រចាំ, ពង្រីកយន្តការសវនកម្មគយតាមអាជីវកម្មដ្ឋានពីវិស័យកាត់ដេរ ទៅវិស័យនិងរបបគយផ្សេងទៀតចំនួន ១៣៦ក្រុមហ៊ុន តាមទិន្នន័យឆ្នាំ២០១៥, ចូលរួមក្នុងការពង្រឹង និងតាមដានការអនុវត្តគម្រោងវិនិយោគ តាមរយៈការវាយតម្លៃ និងផ្តល់ជូននូវវិញ្ញាបនបត្របញ្ជាក់អំពីកម្រិតអនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ, និងចូលរួមពិនិត្យ ផ្តល់មតិ និងកែសម្រួលកិច្ចព្រមព្រៀងមួយចំនួនពាក់ព័ន្ធនឹងអាជីវកម្ម។ លើសពីនេះ ក្រសួងក៏បានរៀបចំប្រកាសអន្ត-ស្ថាប័នរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បង្កើតគណៈកម្មការដើម្បីចុះពិនិត្យការអនុវត្តកិច្ចសន្យាវិនិយោគកោះ និងរមណីយដ្ឋានផងដែរ។

ក.៣. ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម បានធ្វើវិមជ្ឈការ និងវិសហមជ្ឈការនូវកិច្ចការមួយចំនួនធំដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម និងលិខិតស្នាមផ្សេងៗ។ ក្រៅពីនេះ ក្រសួងក៏បានរៀបចំបង្កើតឱ្យមានសភាពាណិជ្ជកម្មតាមរាជធានីខេត្ត ដោយបច្ចុប្បន្នមានសភាពាណិជ្ជកម្ម ១៥មណ្ឌល, ចងក្រងផលិតករ និងកសិករជាបណ្តាញអាជីវកម្មដូចជា សមាគមដំឡូងមីចំនួន១៤, សម្ព័ន្ធសមាគមជលផល សមុទ្រកម្ពុជាដែលប្រមូលសមាគមជលផលសមុទ្រចំនួន៥ នៅខេត្តកំពត ព្រះសីហនុ និងកោះកុង, សមាគម

ស្ងួតចំនួន១, សមាគមក្រូចពោធិ៍សាត់ចំនួន១, សមាគមស្វាយកែវរមៀតចំនួន១, សមាគមពងទាកូនចំនួន១, ព្រមទាំងបានបង្កើតកម្មវិធីបង្កើនសមត្ថភាពសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីមានលទ្ធភាពអាចដំណើរការ និងទទួលខុសត្រូវលើការងារអនុវត្តផែនការរបស់ខ្លួន ជាពិសេស ពង្រឹងយន្តការនៃការត្រួតពិនិត្យគុណភាពអង្ករកម្ពុជា និងជំរុញការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិឱ្យបានច្រើន។

ក.៤ ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន បានធ្វើបច្ចុប្បន្នកម្មប្រភពបំពុល និងការព្យាករការបំពុលពីប្រភពបំពុល (Industrial Pollution Projection System - IPPS) និងធ្វើបច្ចុប្បន្នកម្មរោងចក្រ សហគ្រាស ទីតាំងអាជីវកម្ម និងសេវាកម្ម ដែលត្រូវធ្វើការកែលម្អ និងបំពេញបន្ថែមទៅតាមបទប្បញ្ញត្តិច្បាប់ ក្នុងគោលដៅនៃការអភិវឌ្ឍវិស័យឧស្សាហកម្ម ដោយរក្សាបាននិរន្តរភាពបរិស្ថាន។ ជាងនេះទៅទៀត ក្រសួងបានប្រជុំក្រុមការងារនាយកដ្ឋានពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមដំបូងចំនួន ៤៥គម្រោង និងពេញលេញចំនួន ៤ពាគម្រោង, ព្រមទាំងបានរៀបចំលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូងចំនួន ១៩គម្រោង, របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញចំនួន ១៩គម្រោង និងកិច្ចសន្យាការពារបរិស្ថានចំនួន ១៨ពាគម្រោង។ ក្នុងកិច្ចការនេះផងដែរ ក្រសួងក៏បានបន្តបង្កើន និងពង្រឹងសកម្មភាពចុះត្រួតពិនិត្យតាមដាន និងធ្វើអធិការកិច្ចនៅតាមទីតាំងប្រភពបំពុលនៅទូទាំងប្រទេស, សកម្មភាពដោះស្រាយបណ្តឹងរបស់ប្រជាជនលើករណីបង្ករការបំពុលបរិស្ថាន និងផលប៉ះពាល់មកលើសុខភាពសាធារណៈពីបណ្តារោងចក្រមួយចំនួន, សកម្មភាពជំរុញការអនុវត្តយន្តការស្វ័យត្រួតពិនិត្យការគ្រប់គ្រង និងប្រព័ន្ធប្រព្រឹត្តកម្មសំណល់ និងប្រព័ន្ធស្វ័យរាយការណ៍ព័ត៌មាន និងទិន្នន័យសំណល់ពីទីតាំងប្រភពបំពុលបរិស្ថានខ្លាំង។ លើសពីនេះ ក្រសួងបានបញ្ចប់ការរៀបចំសេចក្តីព្រាងច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធមួយចំនួនដូចជា (១) ច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន, (២) អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និង (៣) អនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក ដើម្បីការពារបរិស្ថាន និងលើកកម្ពស់ការវិនិយោគប្រកបដោយនិរន្តរភាព។

ក.៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកែលម្អនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតបង្កើតរោងសន្ធិធិលក់ចែកចាយផល និងអនុផលព្រៃឈើ ឬរោងសិប្បកម្មកែច្នៃផល និងអនុផលព្រៃឈើប្រភេទតួច, បានចងក្រង និងរៀបចំផែនទីចង្អុលបង្ហាញតំបន់ផលិតកម្មដំណាំចំនួន ៧មុខ (សណ្តែកបាយ សណ្តែកដី ពោត ដំឡូងមី ស្វាយ ម្រេច និងល្ង), បានរៀបចំកិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរព័ត៌មាន និងបទពិសោធស្តីពីដំណើរការ និងការធ្វើពាណិជ្ជកម្មផលិតផលឈើស្របច្បាប់ជាមួយគណៈប្រតិភូរដ្ឋបាលព្រៃឈើនៃសាធារណរដ្ឋប្រជាមានិតចិន និងគណៈប្រតិភូនៃក្រសួងកសិកម្មនិងអភិវឌ្ឍន៍ជនបទនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ព្រមទាំង

បាននិងកំពុងរៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីផលិតកម្ម និងសុខភាពសត្ត។ ជាមួយគ្នានេះដែរ ក្រសួងបាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួន ពិសេសសេចក្តីព្រាងច្បាប់ស្តីពីការការពារក្ខជាតិនិងភ្ជួតតាមអនាម័យ និងសេចក្តីព្រាងអនុក្រឹត្យ ប្រកាសអន្តរក្រសួង ប្រកាសក្រសួងមួយចំនួនទៀត ព្រមទាំងផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍន៍ពូជស្រូវនៅកម្ពុជា។

ក.៦ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានរៀបចំច្បាប់ស្តីពីទូរគមនាគមន៍ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ ការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់ស៊ីវិទ្យុ។ ក្រៅពីនេះ ក្រសួងបានចូលរួមនិងរៀបចំកិច្ចពិភាក្សាការងារមួយចំនួន ពាក់ព័ន្ធនឹងការអនុវត្តគម្រោងមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (Data Management Center - DMC) ព្រមទាំងផែនការលម្អិត និងនីតិ-វិធីទម្លាក់ចូលក្នុងដីរាល់ខ្សែកាប្ដ៏ទូរគមនាគមន៍ដែលកំពុងព្យួរនៅតាមបង្គោលភ្លើងក្នុងរាជធានីភ្នំពេញ។

ក.៧ ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃ បានបន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន ការរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, បន្តជំរុញកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ, និងបន្តពង្រឹងយន្តការគណនេយ្យភាពរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ សំដៅធ្វើយ៉ាងណាឱ្យយន្តការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ជាមួយគ្នានោះដែរ ក្រសួងក៏បានបន្តធ្វើវិមជ្ឈការហិរញ្ញវត្ថុ, បង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យច្រកចេញចូលតែមួយចំនួន៤៦ (ក្រុង៣២ ស្រុក២ និងខណ្ឌ១២ ក្នុងខេត្ត២៤ និងរាជធានីភ្នំពេញ), និងផ្តល់សេវារដ្ឋបាលចំនួន ១៨៦ប្រភេទ ដែលបានទទួលប្រតិភូកម្មមុខងារពីក្រសួង ស្ថាប័នចំនួន១២ រួមមាន វិស័យសាធារណការ និងដឹកជញ្ជូន ពាណិជ្ជកម្ម រ៉ែ និងថាមពល សំណង់ សុខាភិបាល កសិកម្ម អប់រំ នីត្យ-នុកូលកម្ម អត្រានុកូលដ្ឋាន និងសុរិយោដី។

ក.៨ រដ្ឋបាលរាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញ បានចេញសេចក្តីសម្រេចលេខ១៩២ សសរ.ធវិ ចុះថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៥ រៀបចំបង្កើតឱ្យមានអង្គភាពទទួលបន្ទុកសម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តគោល-នយោបាយនៅថ្នាក់រាជធានី សំដៅយ៉ាងណាឱ្យស្ទារតីស្ទួលនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ត្រូវបានយកមកអនុវត្តជាដំណាក់កាលៗ នៅក្នុងរយៈពេលខ្លី មធ្យម និងវែង គឺតម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផល ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម។ ជាក់ស្តែងអង្គភាពនេះ មិនត្រឹមតែបានដើរតួនាទីជាសេនាធិការជូនរដ្ឋបាលរាជធានីភ្នំពេញ នៅក្នុងការអនុវត្តគោល-

នយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានសហការយ៉ាងស្និតរមួត ជាមួយអនុគណៈកម្មាធិការវិនិយោគរាជធានី និងមន្ទីរអង្គភាពជំនាញផ្សេងៗក្នុងការទាក់ទាញអ្នកវិនិយោគ និងចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មីៗដោយផ្តល់ជូននូវយន្តការសម្របសម្រួលកាត់បន្ថយពេលវេលា ថវិកា និងការលើកទឹកចិត្ត តាមរយៈយន្តការច្រកចេញ-ចូលតែមួយ អនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋានដូចបានអនុវត្តនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា។ ជាលទ្ធផល គិតត្រឹមខែធ្នូ ឆ្នាំ២០១៦ សហគ្រាសធុនតូចនិងមធ្យមដែលបានមកចុះបញ្ជីតាមរយៈយន្តការច្រកចេញ-ចូលតែមួយ នៅរដ្ឋបាលរាជ-ធានីភ្នំពេញសរុបមានចំនួន ២ ៣០៩ សហគ្រាស។ លើសពីនេះ រដ្ឋបាលរាជធានីភ្នំពេញ បានជំរុញជាបន្ត បន្ទាប់ឱ្យរោងចក្រ (មានទុនវិនិយោគក្រោម ២លានដុល្លារអាមេរិក) សហគ្រាសធុនតូចនិងមធ្យម ចូលរួមក្នុងការថែរក្សាគុណភាពបរិស្ថានតាមរយៈការគ្រប់គ្រងបានច្បាស់លាស់នូវសំណល់រឹង សំណល់ឧស្សាហកម្ម និងសំណល់រាវដែលបញ្ចេញដោយរោងចក្រ និងជំរុញឱ្យមូលដ្ឋានខាងលើរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន ឬកិច្ចសន្យាការពារបរិស្ថាន។

២- ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការរៀបចំតំបន់ឧស្សាហកម្ម

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន ១៣ ដែលពាក់ព័ន្ធទៅនឹង "ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការរៀបចំតំបន់ឧស្សាហកម្ម" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើនដូចខាងក្រោម÷

២.១- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានធ្វើការសិក្សាស្រាវជ្រាវ ប្រមូលធាតុចូលដែលពាក់ព័ន្ធ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសពីបណ្តាប្រទេសនានានៅក្នុងតំបន់។ បច្ចុប្បន្ន សេចក្តីព្រាងច្បាប់នេះត្រូវបានបញ្ចប់ក្នុងកម្រិតបច្ចេកទេស ដោយបានគិតគូរគ្រប់ជ្រុងជ្រោយពីប្រព័ន្ធគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ការតភ្ជាប់ខ្សែចង្វាក់តម្លៃរវាងសហគ្រាសក្នុងស្រុក និងសហគ្រាសធំបរទេស ព្រមទាំងការលើកទឹកចិត្ត ជាពិសេសការលើកទឹកចិត្តពិសេសជូនក្រុមហ៊ុនទាំងឡាយរាប់ទាំងសហគ្រាសធុនតូចនិងមធ្យម ដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

ស្របគ្នានេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានពិភាក្សា និងដាក់បញ្ចូលការលើកទឹកចិត្តមួយចំនួនដោយផ្អែកតាមតំបន់ (ឧទាហរណ៍: តំបន់ឧស្សាហកម្មតាមខេត្ត) ទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីវិនិយោគ ដើម្បីជំរុញការអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញការលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ។

បន្ថែមលើនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងបន្តកិច្ចសហការជាមួយអ្នកអភិវឌ្ឍន៍តំបន់លើកិច្ចការផ្សព្វផ្សាយ និងទាក់ទាញវិនិយោគិនថ្មីៗឱ្យមកបណ្តាក់ទុនវិនិយោគនៅតំបន់នានា, ជំរុញអ្នកអភិវឌ្ឍន៍តំបន់ឱ្យបន្តកាន់តែសកម្មថែមទៀតក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសរៀងៗខ្លួន និងកំពុងពង្រឹងសមត្ថភាពមន្ត្រីនៅតាមរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដើម្បីផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជូនវិនិយោគិន។

ទាក់ទងនឹងការអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេស ផ្តោតលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំកិច្ចប្រជុំលើកទី៣របស់គណៈកម្មាធិការសម្របសម្រួលតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន, បានរៀបចំវេទិការបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គលើកទី៨ និងចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គលើកទី២១ ព្រមទាំងបានចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីមហាអនុតំបន់មេគង្គជាច្រើនលើក។

ដើម្បីលើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនានា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងធ្វើការសិក្សាស្រាវជ្រាវពីយន្តការក្នុងការវាយតម្លៃប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចពិសេសពីបណ្តាប្រទេសក្នុងតំបន់ ក្នុងគោលបំណងបង្កើតសូចនាករស្នូលសម្រាប់វាស់ស្ទង់សមិទ្ធកម្មនៃកិច្ច-ដំណើរការរបស់តំបន់សេដ្ឋកិច្ចពិសេសទាំងនោះ។

១.២. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបញ្ចប់សេចក្តីព្រាងឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្ត-ការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០។ ទន្ទឹមគ្នានេះ ក្រសួងបានដាក់ចេញនូវយន្តការអនុគ្រោះពន្ធលើប្រាក់ចំណូលតម្លៃបន្ថែមសម្រាប់ចំណាយលើការដឹកជញ្ជូន ស្នាក់នៅ និងហូបចុករបស់កម្មករនិយោជិត។

ក្នុងការចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងនគរូបនីយកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបន្តផ្តល់ការគាំទ្រ សិក្សា និងពិនិត្យលើគម្រោងអភិវឌ្ឍន៍សំខាន់ៗជាច្រើន ដូចជា (១) គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ និងផ្លូវល្បឿនលឿន ភ្នំពេញ-បាវិត, (២) គម្រោងចែកចាយទឹកស្អាតតភ្ជាប់ពីទីរួមខេត្តស្វាយរៀងទៅតំបន់សេដ្ឋកិច្ចពិសេសបាវិត របស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, (៣) គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសរបស់កំពង់ផែស្វយ័តភ្នំពេញ, (៤) គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូ ស្ថានីយសម្អាតទឹកលូ និងការកែច្នៃសំណល់រឹងនៅក្រុងខេមរភូមិន្ទ ក្រុងកែប ក្រុងកំពត និងក្រុងព្រះសីហនុ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន របស់ក្រសួងបរិស្ថាន, និង (៥) គម្រោងមជ្ឈមណ្ឌលភស្តុភារ នៅខេត្តចំនួន ១០ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន របស់ក្រសួងសាធារណការនិងដឹកជញ្ជូន, (៦) គម្រោងអភិវឌ្ឍន៍ទីក្រុងអាស៊ីអ

មហាអនុតំបន់មេគង្គទី២ ដោយផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបវន្តក្រុង២ គឺក្រុងកំពត និងក្រុងព្រះ-សីហនុ, និង (៣)គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងទី៣។

ក្រៅពីគម្រោងខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុវត្តការងារពាក់ព័ន្ធនឹងហិរញ្ញប្បទានគម្រោងមួយចំនួនទៀតដូចជា (១) បានរៀបចំបញ្ជីគម្រោង/កម្មវិធីដែលគ្រោងចុះហត្ថលេខាក្នុងឆ្នាំ២០១៧ ក្នុងក្របខ័ណ្ឌនៃហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីដែលនឹងចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ-រូបវន្ត រួមមានផ្លូវថ្នល់ ទឹកស្អាត អគ្គិសនី និងទូរគមនាគមន៍, (២) បានចុះហត្ថលេខាលើគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជំហានទី២ ដែលអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងទឹកប្រាក់សរុប ១៦,៥ លានដុល្លារអាមេរិក, (៣) បានដាក់បញ្ចូលគម្រោងផ្គត់ផ្គង់ទឹកស្អាតនៅថ្នាក់ខេត្តចំនួន១ ទៅក្នុងផែនការផ្តល់ហិរញ្ញប្បទាន ២០១៧-២០១៩ របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានទឹកប្រាក់សរុប ៦០លានដុល្លារអាមេរិក, និង (៤) បានត្រៀមចុះហត្ថលេខាលើគម្រោងទឹកស្អាតនៅភ្នំពេញជាមួយទីភ្នាក់ងារអភិវឌ្ឍន៍នៃប្រទេសបារាំង ដែលមានទឹកប្រាក់សរុប ៣០លានដុល្លារអាមេរិក។

ទន្ទឹមនឹងការអភិវឌ្ឍទាំងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានចូលរួមដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍ជាច្រើន ក្នុងនោះ ក្រសួងបានពិនិត្យ និងអនុម័តផែនការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍បណ្តាក្រុងរបៀងទី១ និងគម្រោងអភិវឌ្ឍន៍បណ្តាក្រុងរបៀងទី២ និងសេចក្តីព្រាងផែនការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងសមធម៌ និងកែលម្អគុណភាពសេវាសុខាភិបាល។ ស្របគ្នានេះដែរ ក្រសួងបានបញ្ចប់ និងកំពុងបន្តការងារដោះស្រាយផលប៉ះពាល់លើទីតាំង និងគម្រោងមួយចំនួនដូចជា (១) គម្រោងអភិវឌ្ឍន៍ទីប្រជុំជននៃទីរួមខេត្តត្បូងឃ្មុំ ដោះស្រាយបានប្រមាណ ៨០%, (២) គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងទី២ ដោះស្រាយបាន៨០%, (៣) ទីតាំងដីសម្រាប់សាងសង់ស្ថានីយបូមទឹកកខ្វក់ និងចម្រោះទឹកកខ្វក់ នៅក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង និងក្រុងបាវិត, (៤) ទីតាំងសម្រាប់សាងសង់សាលាជាតិបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ នៅរាជធានីភ្នំពេញ, (៥) គម្រោងផ្លូវជាតិលេខ១, លេខ១៣, លេខ ១៥៧ក, លេខ២, លេខ២១, លេខ២២, លេខ៣១, លេខ៣៣, លេខ៥ (កំណាត់ផ្លូវពីស្ពានព្រែកព្នៅទៅស្ពានព្រែកក្តាម ព្រមទាំងកំណាត់ផ្លូវពីបាត់ដំបង-បន្ទាយមានជ័យ និងព្រែកក្តាម-ធ្លាមួម), លេខ៥៣, លេខ ៥៦, លេខ៥៨,លេខ៦, និងផ្លូវខេត្តលេខ១៥0B, ១៥១B និង៣១4D, (៦) គម្រោងស្តារឡើងវិញផ្លូវដែកនៅកម្ពុជា (ខ្សែភ្នំពេញ-ព្រះសីហនុ), (៧) គម្រោងជួសជុលកែលម្អស្ពានមិត្តភាពកម្ពុជា-ជប៉ុនជ្រោយចង្វារ, និង (៨) គម្រោងសាងសង់ប៉ុស្តិ៍ត្រួតពិនិត្យច្រកទ្វារអន្តរជាតិចំនួន៣គឺ ព្រែកច្ចូរ ស្ទឹងបត់ និងព្រៃវល្លិ៍។

ខ.៣ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំផែនការសកម្មភាពការងារឆ្នាំ ២០១៥-២០២៥ ក្នុងការចុះគាំទ្របច្ចេកទេសរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីទីក្រុង ស្រុក និងទីប្រជុំជន ជាម

លំដាប់អាទិភាពអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ព្រមទាំងបាននិងកំពុងរៀបចំច្បាប់ និងក្របខ័ណ្ឌគតិយុត្ត ដើម្បីគាំទ្រដល់ការគ្រប់គ្រងការអភិវឌ្ឍ និងការសាងសង់ដូចជា ច្បាប់សំណង់, ច្បាប់រៀបចំដែនដីនិងនគរូបនីយកម្ម, ច្បាប់គ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា, អនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានីក្រុង និងទីប្រជុំជន និងបទដ្ឋានគតិយុត្តមួយចំនួនទៀត ដើម្បីគាំទ្រ និងចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។ ជាពិសេសជាងនេះទៅទៀត ក្រសួងបានបញ្ចប់ការរៀបចំ និងបានស្នើសុំការអនុម័តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញដែលទទួលបានការឯកភាពនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។

ផ្អែកតាមផែនការសកម្មភាពខាងលើ ឯកសារយុទ្ធសាស្ត្រសំខាន់ៗកំពុងត្រូវបានរៀបចំ រួមមាន÷ (១) សេចក្ដីព្រាងយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ និងផែនការរៀបចំដែនដីខេត្តព្រះសីហនុសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដែលកំពុងស្នើសុំការអនុម័ត, (២) ផែនការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រទាំងនៅលើដីគោក និងតាមកោះ ដែលកំពុងត្រូវបានរៀបចំ, (៣) ផែនការប្រើប្រាស់ដីតំបន់ពយកំពេញ ដែលត្រូវបានបញ្ចប់ការសិក្សា, (៤) ផែនការប្រើប្រាស់ដីតំបន់បឹងព្រែកទប់ ដែលត្រូវបានសិក្សានិងរៀបចំជាតំបន់អភិរក្សទឹកសាប, និង (៥) ប្លង់គោលនិងផែនការប្រើប្រាស់ដីកោះរ៉ុង ដែលកំពុងត្រូវបានសិក្សា និងធ្វៀលដីតាមរូបមន្តស្បែកខ្ចីជូនប្រជាពលរដ្ឋនៅលើកោះ។ បន្ថែមពីនេះ ក្រសួងក៏បាននិងកំពុងពិនិត្យ វាយតម្លៃ និងកែសម្រួលឯកសារពាក់ព័ន្ធផ្សេងទៀតដូចជា ឯកសារក្របខ័ណ្ឌអភិវឌ្ឍន៍តំបន់ទីក្រុងជុំវិញបឹងទន្លេសាប និងផែនការរៀបចំដែនដីខេត្តបាត់ដំបង, ព្រមទាំងបាននិងកំពុងចុះប្រមូល និងចងក្រងទិន្នន័យសម្រាប់ធ្វើការវិភាគគម្រោងកសាងផែនការរៀបចំដែនដីខេត្តសៀមរាប។

ក្នុងកិច្ចការនេះផងដែរ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានគាំទ្របច្ចេកទេសរៀបចំកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុងចំនួន ៨ រួមមានក្រុងព្រះសីហនុ ក្រុងកែប ក្រុងសៀមរាប ក្រុងច្បារមន ក្រុងកំពត ក្រុងព្រៃវែង ក្រុងកំពង់ឆ្នាំង និងក្រុងតាខ្មៅ, ថ្នាក់ស្រុកចំនួន ៦ រួមមានស្រុករលាប្អៀរ ស្រុកលំផាត់ ស្រុកជ្រើនសៃ ស្រុកថាឡាបរិវ៉ាត់ ស្រុកបរវេល និងស្រុកស្អាង, ថ្នាក់ទីប្រជុំជនចំនួន ២ រួមមានទីប្រជុំជនស្វាយអន្ទរ និងទីប្រជុំជនអ្នកលឿង, និងថ្នាក់ឃុំចំនួន ៦ រួមមាន ឃុំទួលគគីរ ឃុំតាតៃក្រោម ឃុំស្នាមព្រះ ឃុំរកាត ឃុំរាម និងឃុំអ្ករឧកញ៉ាហេង។ លើសពីនេះ ក្រសួងក៏បានជ្រើសរើសយកស្រុកស្ទឹងហាវ ដើម្បីសិក្សាកសាងប្លង់គោលប្រើប្រាស់ដី ដោយបានពិគ្រោះយោបល់លើការងារនេះជាមួយរដ្ឋបាលខេត្តព្រះសីហនុ និងរដ្ឋបាលស្រុកស្ទឹងហាវ, រៀបចំសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈនូវគម្រោងសិក្សាប្លង់គោលស្រុកស្ទឹងហាវ, និងចុះប្រមូលទិន្នន័យរូបវន្តនៃព្រំប្រទល់រដ្ឋបាលដែលបានកែសម្រួលថ្មី ទិន្នន័យបណ្តាញផ្លូវ និងទិន្នន័យប្រើប្រាស់ដីស្រុកស្ទឹងហាវ។

១.៤ ក្រសួងសាធារណការនិងដឹកជញ្ជូន

ក្រសួងសាធារណការនិងដឹកជញ្ជូនបានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១៥-២០១៨ លើការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងភាគខាងត្បូង ដោយផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនក្នុងក្រុងចំនួនបួន រួមមាន ក្រុងប៉ោយប៉ែត (សាងសង់ប្រព័ន្ធលូចម្រោះទឹកសំណល់ និងទីលានកែច្នៃសំរាម), ក្រុងបាត់ដំបង (សាងសង់ប្រព័ន្ធលូចម្រោះទឹកសំណល់ ប្រព័ន្ធការពារទឹកជំនន់ ទប់ច្រាំងបាក់ និងទីលានកែច្នៃសំរាម), ក្រុងបាវិត (សាងសង់ផ្លូវក្រុង ប្រព័ន្ធលូចម្រោះទឹកសំណល់ និងទីលានកែច្នៃសំរាម), និងទីប្រជុំជនអ្នកលឿង (សាងសង់ទំនប់ការពារទឹកជំនន់ និងផ្លូវវាង) ដែលគ្រោងចំណាយទឹកប្រាក់ប្រមាណ ៦០លានដុល្លារអាមេរិក និងមានរយៈពេលគម្រោង ៥ឆ្នាំ។ បច្ចុប្បន្ន ក្រសួងកំពុងបន្តរៀបចំវាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស ហើយគ្រោងនឹងចាប់ផ្តើមអនុវត្តការងារសាងសង់ខាងលើនៅដើមឆ្នាំ២០១៧។ ជាងនេះទៅទៀត ក្រសួងបានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១៦-២០១៩ លើគម្រោងអភិវឌ្ឍន៍ទីក្រុងរបៀងនៃមហាអនុតំបន់មេគង្គទី២ ដោយផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនក្នុងក្រុងចំនួន២ រួមមាន÷ ក្រុងព្រះសីហនុ (សាងសង់ប្រព័ន្ធលូរំដោះទឹកភ្លៀង និងស្តារទីលានចាក់សំរាមដែលមានស្រាប់ឡើងវិញ) និងក្រុងកំពត (សាងសង់ស្ថានីយច្រោះទឹកកខ្វក់ ប្រព័ន្ធលូចម្រោះទឹកសំណល់ ប្រព័ន្ធលូរំដោះទឹកភ្លៀង និងទីលានចាក់សំរាមថ្មី) ដែលគ្រោងចំណាយទឹកប្រាក់សរុបចំនួនប្រមាណ ៣៨,១លានដុល្លារអាមេរិក ដែលក្នុងនោះកម្ចីឥណទានសម្បទានពីធនាគារអភិវឌ្ឍន៍អាស៊ីមានចំនួន ៣៣លានដុល្លារអាមេរិក និងបដិភាគពីរាជរដ្ឋាភិបាលកម្ពុជាមានចំនួន ៥,១លានដុល្លារអាមេរិក។ គម្រោងនេះ មានរយៈពេល៤ឆ្នាំ ហើយគ្រោងនឹងអនុវត្តការងារនៅឆ្នាំ២០១៧។ លើសពីនេះទៀត ក្រសួងក៏បាននិងកំពុងអភិវឌ្ឍចំណតពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុប្រវែង ៣៣០ម៉ែត្រ ជម្រៅទឹក -១៣,៥ម៉ែត្រ សម្រេចបាន ៦៨,១៥% ដើម្បីជួយជំរុញដល់ការអភិវឌ្ឍផ្នែកឧស្សាហកម្ម និងការរីកលូតលាស់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដោយបានធ្វើពិធីបើកការដ្ឋានសាងសង់កាលពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៥។

១.៥ ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន បានកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង តាមរយៈអនុក្រឹត្យលេខ១១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន, ពន្លឿនដំណើរការរៀបចំក្រមបរិស្ថាន, រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថាន (២០១៦-២០២៣) ព្រមទាំងបានផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុវត្តថវិកាកម្មវិធី ដើម្បីចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ដោយបាននិងកំពុងគិតគូរ និងពិនិត្យលើការអនុវត្តសេវាកម្មចុះបញ្ជី ការផ្តល់អាជ្ញាបណ្ណ និងការកសាងឯកសារបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំមួយចំនួនពាក់ព័ន្ធការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស សហគ្រិនភាពផលិតកម្ម និងតំបន់ឧស្សាហកម្មផ្សេងៗទៀត។ ពាក់ព័ន្ធនឹងការងារអនាម័យបរិស្ថាន ការគ្រប់គ្រងសំរាមសំណល់រឹងនៅទីប្រជុំជនតាមរាជធានីខេត្ត ត្រូវបានកែលម្អជាបណ្តើរៗ ស្របគ្នានឹងការទទួលបានការគ្រប់គ្រ

សេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង-រាវនៃទីក្រុងទាំង២៦ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកញ្ចប់ថវិកានេះបានកើនទឹកប្រាក់ពី ៥ ០០០ លានរៀលនៅឆ្នាំ២០១៥ ដល់ ៨ ០០០លានរៀលនៅឆ្នាំ២០១៦។ ការគ្រប់គ្រងគុណភាពបរិស្ថានក៏ត្រូវបានពង្រឹង តាមរយៈការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន, អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក, អនុក្រឹត្យស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម, និងបញ្ចប់ការរៀបចំសេចក្តីព្រាងច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធផ្សេងៗទៀត។

១.៦ រដ្ឋបាលខេត្តស្វាយរៀង

រដ្ឋបាលខេត្តស្វាយរៀង បានសហការជាមួយបណ្តាភាគីពាក់ព័ន្ធ និងផ្នែកឯកជន ក្នុងការគាំទ្រការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មដែលមានស្រាប់ និង/ឬបង្កើតថ្មីក្នុងដែនសមត្ថកិច្ចខេត្តស្វាយរៀង ដោយកន្លងមក រដ្ឋបាលខេត្តស្វាយរៀង បានចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការសិក្សាវាយតម្លៃ និងកំណត់ទីតាំងសម្រាប់រៀបចំបង្កើតតំបន់ឧស្សាហកម្មសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ចំនួន ៩លើក។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្តស្វាយរៀង បានធ្វើការងារគ្រប់គ្រងសំណល់រឹង ដោយធ្វើការផ្សព្វផ្សាយ ណែនាំ និងអប់រំដល់បណ្តារោងចក្រទាំងអស់ដែលមាននៅក្នុងខេត្ត ឱ្យធ្វើការគ្រប់គ្រង និងទុកដាក់សំណល់ឧស្សាហកម្មឱ្យបានត្រឹមត្រូវ, បានធ្វើការតាមដានត្រួតពិនិត្យគុណភាពទឹកនៅតាមបណ្តាតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការយកសំណាកទឹកទៅពិសោធនៅក្រសួងបរិស្ថាន, ព្រមទាំងបានជំរុញឱ្យតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន សាងសង់អាងចម្រោះទឹកសម្ភមមួយកន្លែងលើផ្ទៃដី ១៥ ០០០ម៉ែត្រក្រឡា។ បច្ចុប្បន្ននៅក្រុងបាវិត មានក្រុមហ៊ុនដឹកជញ្ជូនសំណល់ឧស្សាហកម្ម ១ និងក្រុមហ៊ុនដឹកជញ្ជូនសំណល់ទីប្រជុំជន ១។

លើសពីនេះ រដ្ឋបាលខេត្តស្វាយរៀង បានជំរុញរោងចក្រ សហគ្រាស សិប្បកម្ម អាជីវកម្ម និងសេវាកម្ម ឱ្យធ្វើការកែលម្អខ្សែចង្វាក់ផលិតកម្ម ដើម្បីធានាបាននូវបរិស្ថានឧស្សាហកម្ម និងគុណភាពស្របតាមស្តង់ដាជាតិ និងអន្តរជាតិ និងជំរុញការអនុវត្តច្បាប់ក្នុងវិស័យឧស្សាហកម្មនិងសិប្បកម្ម តាមរយៈការចុះផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅតាមបណ្តារោងចក្រ សិប្បកម្ម នៅក្នុងក្រុង ស្រុករបស់ខេត្ត។

១.៧ រដ្ឋបាលខេត្តកោះកុង

រដ្ឋបាលខេត្តកោះកុង បានចូលរួមប្រជុំអន្តរក្រសួងរៀបចំបង្កើតតំបន់សេដ្ឋកិច្ចពិសេស ១កន្លែងនៅក្នុងខេត្តកោះកុង មានផ្ទៃដីសរុបចំនួន ១៨៥ហិកតា, បានកំពុងរៀបចំ និងសាងសង់រោងចក្រផលិតទឹកស្អាត ១កន្លែងនៅស្ទឹងអូរស្រីស្រណោះ ឬហៅថាទឹកជ្រោះតាប៉ន សម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់ក្រុងខេមរភូមិន្ទ, បានចូលរួមរៀបចំប្លង់គោលស្តីពីការប្រើប្រាស់ដីធ្លីក្នុងក្រុងខេមរភូមិន្ទ ដល់ដំណាក់កាលទី៧, និងបានកំណត់ទីតាំងសម្រាប់ដាក់សំរាមមួយកន្លែងមានផ្ទៃដីទំហំ ៣ហិកតា។

១.៤ រដ្ឋបាលរាជធានីភ្នំពេញ

ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការរៀបចំតំបន់ឧស្សាហកម្មជាការងារ ដែលរដ្ឋបាលរាជធានីភ្នំពេញបាននឹងកំពុងយកចិត្តទុកដាក់ ស្របពេលដែលមានការសិក្សាអំពីការរៀបចំសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុក ជាពិសេសការចូលរួមក្នុងខ្សែចង្វាក់តម្លៃនិងខ្សែចង្វាក់ផលិតកម្ម ក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានីភ្នំពេញ នៅក្នុងបរិការណ៍នៃសមាហរណកម្មតំបន់។ ឆ្លើយតបនឹងការងារខាងលើ ប្លង់គោលប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥របស់រាជធានីភ្នំពេញ ត្រូវបានបង្កើតឡើងដោយយកចិត្តទុកដាក់ និងត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ បន្ទាប់ពីទទួលបានការអនុម័តក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។ ប្លង់គោលប្រើប្រាស់ដីធ្លីនេះ ត្រូវបានប្រើប្រាស់ជាឧបករណ៍គោលក្នុងការតម្រង់ទិស និងគ្រប់គ្រងការអភិវឌ្ឍក្នុងន័យធានាដល់សក្តានុពលដែលមានស្រាប់របស់ទីក្រុង គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ធានាសន្តិសុខស្បៀង ជាពិសេស តម្រង់ទិសនៃការអភិវឌ្ឍប្រកបដោយតុល្យភាព និងភាពស៊ីចង្វាក់គ្នារវាងរាជធានី និងទីក្រុងតូចបន្ទាប់ខេត្ត និងទីក្រុងរបស់ប្រទេសជាដៃគូកិច្ចសហប្រតិបត្តិការ តាមរយៈការបែងចែកជាតំបន់សំខាន់ៗដូចជា ប ូ ល អភិវឌ្ឍន៍ស្នូលតំបន់ទីក្រុងប្រកបដោយគុណភាពអន្តរជាតិ តំបន់បម្រុងទុកនូវហេដ្ឋារចនាសម្ព័ន្ធរួបវន្តមេចាំបាច់ តំបន់អភិវឌ្ឍនគរូបនីយកម្មក្នុងកម្រិតទីក្រុងធំ និងតំបន់ពិសេសៗ ដែលមានបេតិកភណ្ឌ និងផ្តល់សោភ័ណភាពទីក្រុង។ បច្ចុប្បន្ននេះ នៅរាជធានីភ្នំពេញមានតំបន់ឧស្សាហកម្មសំខាន់ៗដូចជា តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ សួនឧស្សាហកម្មកាណាឌីយ៉ា សួនឧស្សាហកម្មវឌ្ឍនៈI និងសួនឧស្សាហកម្មវឌ្ឍនៈII ។ល។

២.៣.២ ការពង្រីក និងធំឡើងកម្មសហគ្រាសធុនតូចនិងមធ្យម

ក. ការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន ១០ ដែលពាក់ព័ន្ធទៅនឹង "ការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពដូចខាងក្រោម÷

ក.១. ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្របសម្រួលការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម និងសេវាកម្ម នៅក្រោមក្របខ័ណ្ឌដំបូលតែមួយ ដែលបច្ចុប្បន្នបានដាក់ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច ដើម្បីដាក់ប្រជុំឆ្លងចុងក្រោយ មុននឹងជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។ តាមរយៈយន្តការក្រោមដំបូលតែមួយ ក្រសួងកំពុងពង្រឹងក្របខ័ណ្ឌ និងយន្តការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម សំដៅដល់ការរៀបចំចុះបញ្ជី និងការគ្រប់គ្រង។ ក្នុងការរៀបចំឯកសារគតិយុត្តពាក់ព័ន្ធ ក្រសួងឧស្សាហកម្មនិងសិប្បកម្មបានចេញប្រកាសស្តីពីនីតិវិធី និងបែបបទស្នើសុំប្រកាសរោងចក្រ និងសិប្បកម្ម, និងប្រកាសស្តីពីនីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម ព្រមទាំ

ទាំងបាននិងកំពុងរៀបចំនិយមន័យទៅតាមវិស័យនីមួយៗ, និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដើម្បីពង្រឹងការគ្រប់គ្រងរោងចក្រ និងសិប្បកម្មនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងជំរុញការចុះបញ្ជីឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសង្គតិភាពខ្ពស់។ មិនតែប៉ុណ្ណោះ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានរៀបចំកម្មវិធីផ្តល់ពានរង្វាន់"ស៥" ចំនួន ៥រង្វាន់ ជូនដល់ក្រុមហ៊ុន សហគ្រាស រោងចក្រ និងសិប្បកម្ម។

ក.២ ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម បានអនុវត្តកម្មវិធីភ្ជាស់សហគ្រាសធុនតូចនិងមធ្យម ដើម្បីជួយសហគ្រាសទាំងនោះ ពង្រឹងសមត្ថភាពដែលអាចធ្វើអាជីវកម្មរបស់ខ្លួន និងបានរៀបចំសិក្ខាសាលាជាស៊ីរីដើម្បីបង្កើតគំនិតច្នៃប្រឌិតក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (MoC101), បានរៀបចំយុទ្ធនាការទិញផលិតផលខ្មែរបានចំនួន ៤លើក នៅក្នុងរាជធានី-ខេត្ត ដោយបានប្រមូលកៀរគរសហគ្រាសតូចធំដែលបាននិងកំពុងផលិតផលិតផល និងសេវាកម្មមកដាក់តាំងបង្ហាញ ដើម្បីស្វែងរកដៃគូពាណិជ្ជកម្ម និងទទួលការបណ្តុះបណ្តាលបន្ថែមពីកិច្ចការអភិវឌ្ឍផលិតផល និងសេវាកម្ម និងការពង្រឹងឡើងវិញនូវប្រព័ន្ធផលិតកម្ម ដើម្បីផលិតទំនិញ និងសេវាមានគុណភាព និងសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់, ព្រមទាំងបាននិងកំពុងធ្វើការកំណត់ និងពង្រីកទីផ្សារគោលដៅសំខាន់ៗថ្មីបន្ថែមទៀតសម្រាប់ការនាំចេញផលិតផលកម្ពុជា ដោយក្នុងនោះ ក្រសួងបានបើកមជ្ឈមណ្ឌលតាំងបង្ហាញផលិតផលកម្ពុជានៅប្រទេសចិនចំនួន ៥ទីតាំង និងបន្តចរចាបើកមជ្ឈមណ្ឌលដាក់លក់ផលិតផលខ្មែរនៅក្នុងប្រទេសវៀតណាម និងប្រទេសថៃ និងតំបន់មួយចំនួននៅក្នុងប្រទេសចិនបន្តទៀត។

ទន្ទឹមនឹងនេះ ក្រសួងបានសម្របសម្រួល និងលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម ឱ្យចូលរួមតាំងពិព័រណ៍ តាមរយៈការផ្តល់ជូនស្តង់ដោយឥតគិតថ្លៃ, ចូលរួមព្រឹត្តិការណ៍ពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស, និងរៀបចំបេសកកម្មពាណិជ្ជកម្មទៅកាន់ទីផ្សារគោលដៅ ដើម្បីឱ្យសហគ្រាសធុនតូចនិងមធ្យមបានសិក្សារៀនសូត្រពីភាពជឿនលឿននៃឧស្សាហកម្មខ្នាតតូច និងមធ្យមនៃបណ្តាប្រទេសទាំងនោះ។ ជាងនេះទៅទៀត ក្រសួងបានទទួលចុះបញ្ជីសមាគមចំនួន៩៨ ដូចជាសមាគមម៉ាស៊ីនកិនស្រូវ សមាគមស្វាយចន្ទី សមាគមដំឡូងមី សមាគមស្វាយ សមាគមគ្រឿងអលង្ការ សមាគមស្ករត្នោត ។ល។ លើសពីនេះ ក្រសួងបានធ្វើកំណែ-ទម្រង់ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធអេឡិចត្រូនិក ដែលប្រព័ន្ធនេះបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីចុងឆ្នាំ២០១៥ កន្លងទៅ។ ពាក់ព័ន្ធនឹងការផ្តល់កិច្ចសម្រួលដល់សហគ្រាសធុនតូចនិងមធ្យម ក្រសួងពាណិជ្ជកម្មបានចាត់បញ្ជូនមន្ត្រីជំនាញចូលរួមក្នុងក្រុមការងារទទួលចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម នៅច្រកចេញចូលតែមួយដែលមានការិយាល័យនៅក្រសួងឧស្សាហកម្មនិងសិប្បកម្ម។

ក.៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើវិមជ្ឈការតម្លៃគិតពន្ធគយដល់មាត់ច្រកបំពេញបែបបទគយ និងបានរៀបចំ (១) សេចក្តីណែនាំបន្ថែមមួយចំនួនលើនីតិវិធីគយដើម្បីបង្កលក្ខណៈងាយស្រួលដល់ការនាំចេញ-នាំ

ធុរជនពាក់ព័ន្ធ, (២) សេចក្តីណែនាំស្តីពីការពង្រឹងប្រសិទ្ធភាពនៃការផ្តល់ប្រព្រឹត្តកម្មសមធម៌ក្នុងការត្រួតពិនិត្យ បែបបទគយ, និង (៣) ការកែសម្រួល និងការកំណត់បន្ថែមមួយចំនួនលើនីតិវិធីគយដើម្បីបង្កលក្ខណៈងាយស្រួលដល់វិនិយោគគិន និងធុរជនពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ ក្រសួងបានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនដូចជា ប្រកាសស្តីពីភតិសន្យាហិរញ្ញវត្ថុ ដែលកម្រិតការអនុវត្តអាករលើតម្លៃបន្ថែម ត្រឹមតែថ្លៃទំនិញ ឬទ្រព្យសកម្ម, អនុក្រឹត្យ និងប្រកាស ចាត់ទុកការផ្គត់ផ្គង់មិនជាប់អាករនូវផលិតផលមិនទាន់កែច្នៃ, ព្រមទាំងបានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសខ្នាតតូចនិងមធ្យម ដែលចុះបញ្ជីដោយស្ម័គ្រចិត្ត។

ក.៤ ក្រុមប្រឹក្សាជាតិគណនេយ្យ

ក្រុមប្រឹក្សាជាតិគណនេយ្យបានបង្កើតក្រុមការងារគណនេយ្យពន្ធដារ និងមូលបត្រ ដើម្បីពិភាក្សាលើការអភិវឌ្ឍក្របខ័ណ្ឌគណនេយ្យងាយស្រួលសម្រាប់សហគ្រាសធុនតូច សម្រាប់សម្រួលដល់ការបង់ពន្ធរបបពិត និងបង្កលក្ខណៈងាយស្រួលដល់សហគ្រាសទាំងនោះអាចចូលរួមក្នុងទីផ្សារមូលបត្រ។ ជាលទ្ធផលក្រុមប្រឹក្សាជាតិគណនេយ្យបានបង្កើតឡើងនូវឯកសារគំរូកត់ត្រាចំណូល ចំណាយងាយៗ និងរបាយការណ៍ហិរញ្ញវត្ថុគំរូងាយៗសម្រាប់មីក្រូសហគ្រាស។ បន្ថែមលើនេះ ក្រុមការងារក្រុមប្រឹក្សាជាតិគណនេយ្យ នឹងបន្តការសិក្សាអំពីលទ្ធភាពរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងការចូលរួមក្នុងទីផ្សារមូលបត្រ។

ក.៥ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងទី១ រហូតដល់ទី១១ និងសេចក្តីព្រាងបឋមនៃច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ, បានចេញប្រកាសលេខ៥២៣ ក.ប/ប្រ.ក ស្តីពីការដាក់ឱ្យប្រើប្រាស់លក្ខណៈវិនិច្ឆ័យទាំង៦ នៃការធានាគុណភាពវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ, និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត។ ទន្ទឹមនឹងនេះ ក្រសួងបានបណ្តុះបណ្តាលកម្លាំងពលកម្មផ្អែកលើសមត្ថភាព ដើម្បីបម្រើដល់តម្រូវការពលករជំនាញផ្នែកឧស្សាហកម្ម ពិសេសក្នុងតំបន់សេដ្ឋកិច្ចពិសេស, អនុវត្តវិធីសាស្ត្របណ្តុះបណ្តាលផ្អែកលើសមត្ថភាព (CBT Methodology) សម្រាប់ជ្រើសរើសគ្រូបង្គោលចំនួន១០រូប ដំណាក់កាលទី១ ចំនួន ៤វគ្គ មានគ្រូបច្ចេកទេសចូលរួមចំនួន ១១៨នាក់ ក្នុងនោះស្រី ១១នាក់។ ជាងនេះទៅទៀត ក្រសួងកំពុងអភិវឌ្ឍស្តង់ដាសមត្ថភាព, កម្មវិធីសិក្សាផ្អែកលើសមត្ថភាព, និងកញ្ចប់វាយតម្លៃលើមុខរបរ÷ ផ្សារអគ្គិសនី បន្ទ្យីលោហៈ ផលិតនំ និងកែច្នៃបន្លែផ្លែឈើ ចាប់ពីកម្រិត១ ដល់កម្រិត៤ ព្រមទាំងអភិវឌ្ឍកម្មវិធីសិក្សាក្របខ័ណ្ឌគុណវុធ្ឍិជាតិកម្ពុជា កម្រិត៥ ដែលនឹងដាក់ឱ្យសាកល្បងនៅវិទ្យាស្ថានពហុបច្ចេកទេសជាតិកម្ពុជា វិទ្យាស្ថានពហុបច្ចេកទេសព្រះកីសុមៈ និងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស នៅឆ្នាំ២០១៧។ ម្យ៉ាងវិញទៀត ក្រសួងក៏បានរៀបចំសិក្ខាសាលា

កសាងសមត្ថភាពមន្ត្រីជាច្រើនពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធ TVETMIS, ប្រព័ន្ធធានាគុណភាព, ដំណើរការត្រួតពិនិត្យ និងការធានាគុណភាពនៃវិស័យអប់រំបណ្តុះបណ្តាលនិងវិជ្ជាជីវៈ។

ក.៦ ក្រសួងអប់រំ យុវជន និងកីឬា

ក្រសួងអប់រំ យុវជន និងកីឬា បានអភិវឌ្ឍផែនការគោលស្តីពីការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ, បានកែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងកំពុងរៀបចំស្តង់ដាអ្នកផ្តល់សេវាបណ្តុះបណ្តាលគ្រូ, បានលើកគម្រោងសាងសង់សាលាមធ្យមសិក្សាបន្ថែមសំដៅបង្កើនលទ្ធភាពទទួលបានការអប់រំនៅមធ្យមសិក្សាកាន់តែច្រើន, និងបានអភិវឌ្ឍគោលនយោបាយស្តីពីចក្ខុវិស័យអប់រំឧត្តមសិក្សាឆ្នាំ២០៣០ ផ្តោតលើដំណើរការបង្កើតគោលការណ៍គម្រោងផ្តល់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភ និងឥណទានសម្រាប់អ្នកសិក្សានៅកម្រិតឧត្តមសិក្សា។ លើសពីនេះ ទាក់ទិននឹងការលើកស្ទួយសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សាដើម្បីជាមូលដ្ឋានរឹងមាំមួយសម្រាប់ក្រេបជញ្ជក់យកវិទ្យាសាស្ត្រ បង្កើនការហ្វឹកហ្វឺន និងនវានុវត្តន៍ បច្ចេកវិទ្យាថ្មីៗ សម្រាប់តម្រូវការទីផ្សារ ក្រសួងបានលើកទឹកចិត្តឱ្យគ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ ទាំងឯកជន បង្កើតផែនការយុទ្ធសាស្ត្រ និងបង្កើនសកម្មភាពស្រាវជ្រាវទាំងសាស្ត្រាចារ្យ និងនិស្សិត, បានទទួលថវិការវិភាជពីរាជរដ្ឋាភិបាលសម្រាប់ការបង្រៀនមុខជំនាញពាក់ព័ន្ធ នៅតាមវិទ្យាស្ថាន និងគ្រឹះស្ថានឧត្តមសិក្សានានា, បានកែលម្អនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំនៅគ្រឹះស្ថានឧត្តមសិក្សា និងកំពុងធ្វើការវាយតម្លៃលើគ្រឹះស្ថានឧត្តមសិក្សាចំនួន ១៦,ព្រមទាំងបានពង្រឹង និងពង្រីកការសិក្សាមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា និងសិល្ប:ច្នៃប្រឌិត (STEAM) នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដែលជាលទ្ធផល និស្សិតបរិញ្ញាបត្រលើមុខវិជ្ជា STEAM មានចំនួនកើនឡើងប្រមាណ ២៥ភាគរយធៀបនឹងនិស្សិតបរិញ្ញាបត្រសរុប។ បច្ចុប្បន្ន ក្រសួងកំពុងអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងភូមិភាគបាត់ដំបងឱ្យក្លាយជាវិទ្យាស្ថានគរុកោសល្យ។

ក.៧ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងសិក្សាលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីស្នើសុំបង្កើតសាខាត្រួតពិនិត្យភ្ជួតគាមអនាម័យចំនួន ៥កន្លែង និងស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីចាត់បញ្ជូនមន្ត្រីភ្ជួតគាមអនាម័យទៅបំពេញការងារនៅតាមច្រកទ្វារព្រំដែនឡើងវិញ ព្រមទាំងបានរៀបចំសំណើថវិការដ្ឋ ដើម្បីរៀបចំស្ថានីយចត្តាឡីស័កសត្វចំនួន ៤កន្លែង ដែលក្នុងនោះនៅខេត្តបន្ទាយមានជ័យចំនួន ២កន្លែង និងខេត្តតាកែវចំនួន ២កន្លែង។ លើសពីនេះទៀត ក្រសួងបាននិងកំពុងរៀបចំចងក្រងឯកសារមគ្គុទ្ទេសក៍សម្រាប់អ្នកវិនិយោគក្នុងវិស័យកសិកម្ម (Guidebook for Investor in Agricultural Sector) ដែលបានបង្ហាញអំពីស្ថានភាពនៃការអភិវឌ្ឍវិស័យកសិកម្ម លក្ខណៈអំណោយផល សក្តានុពលនៃការអភិវឌ្ឍ និងនីតិវិធីសំខាន់ៗសម្រាប់ការធ្វើវិនិយោគក្នុងវិស័យនេះ។

ក.៨. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្រាប់គ្រប់គ្រងមូលនិធិកសាងសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន, បានបង្កើតយន្តការពិគ្រោះយោបល់ និងទំនាក់ទំនងជាប្រចាំជាមួយក្រុមហ៊ុនដែលប្រតិបត្តិការក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងស្រុក។ ព្រមជាមួយគ្នានោះផងដែរ ក្រសួងក៏បានរៀបចំពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឆ្នាំ២០១៥ និង២០១៦ ក្នុងគោលបំណងលើកទឹកចិត្តក្រុមហ៊ុនប្រតិបត្តិករឱ្យខិតខំបន្តអភិវឌ្ឍវិស័យនេះតទៅមុខទៀត។

ក.៩ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ចេញប្រកាសលេខ១១៦៤ ស.អ.យ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មរាជធានីខេត្ត។ រហូតមកដល់ឆ្នាំ២០១៦ មានមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន ១១កន្លែង និងសហគ្រាសផលិតរទេះជនពិការ ពីកន្លែង ដែលស្ថិតនៅក្នុងរាជធានីខេត្តចំនួន៧គឺ រាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តបាត់ដំបង និងខេត្តសៀមរាប។ មជ្ឈមណ្ឌលទាំងនោះ ជាកន្លែងសម្រាប់ផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា និងជាសហគ្រាសធុនតូចមានបច្ចេកវិទ្យា-វិទ្យាសាស្ត្រក្នុងការផលិតឧបករណ៍សិប្បនិម្មិត និងរណបជូនជនពិការ។ ក្នុងឆ្នាំ២០១៦ មជ្ឈមណ្ឌលទាំងនោះបានផលិតឧបករណ៍សិប្បនិម្មិតនិងរណបចំនួន ១៩ ១៣៧គ្រឿង និងរទេះប្រមាណ ១ ៨០០គ្រឿង ជូនជនពិការចំនួនប្រមាណ ២០ ០០០នាក់/ឆ្នាំដោយឥតគិតថ្លៃ។ ឧបករណ៍សិប្បនិម្មិត និងរណបរួមមានឈើច្រត់ ឈើជ្រែងគ្រោងលើនិងក្រោមក្បាលជង្គង់ គ្រោងដៃ ប្រអប់ដៃកៅស៊ូ ប្រអប់ដៃមានរាងទំពក់គ្រោងរណបនិងប្រអប់ជើង។

ក.១០. រដ្ឋបាលរាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញ បានជំរុញការចុះបញ្ជីផ្លូវការរបស់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងស្មារតីនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។ ក្នុងកំលុងឆ្នាំ២០១៦ កន្លងទៅនេះ រដ្ឋបាលរាជធានីភ្នំពេញ ដែលមានមន្ទីរឧស្សាហកម្មនិងសិប្បកម្មជាសេនាធិការ បានចុះជំរុញឱ្យម្ចាស់សិប្បកម្មចុះបញ្ជីសិប្បកម្មស្របតាមច្បាប់បានចំនួន ៤១៥មូលដ្ឋាន ក្នុងនោះមូលដ្ឋានថ្មីមានចំនួន ២៣១មូលដ្ឋាន និងចុះបញ្ជីបន្តមានចំនួន ១៨៤ទីតាំង, បានចុះពិនិត្យ និងវាយតម្លៃពាក្យស្នើសុំបង្កើត បន្ត និងសុំវិញ្ញាបនបត្រដំណើរការច្បាប់ថ្នាក់ក្រសួងបានចំនួន ១០២មូលដ្ឋាន ក្នុងនោះសំណើសុំថ្មីមានចំនួន ២៨មូលដ្ឋាន បន្តមានចំនួន ៤៧មូលដ្ឋាន និងសំណើសុំវិញ្ញាបនបត្រដំណើរការមានចំនួន ២៧មូលដ្ឋាន, បានចុះជំរុញមូលដ្ឋានផលិតម្ហូបអាហារឱ្យយកផលិតផលទៅពិនិត្យគុណភាពបាន ២៩១មុខផលិតផល, បានចុះពិនិត្យ និងអនុវត្តផលិតកម្មល្អ (GMP) និងអនាម័យល្អ

(GHP) ចំនួន ៥៦មូលដ្ឋាន, បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដែបាញ់ប្រេងនៅស្ថានីយប្រេងឥន្ធនៈ បានចំនួន ២០២ស្ថានីយ និង៥៣៣ទូ ស្មើនឹង ២ ៧០៤ដែបាញ់ប្រេង, បានចុះត្រួតពិនិត្យលើបរិមាណ ចំណុះ និងទម្ងន់លើផលិតផលវេចខ្ចប់ចំនួន ៥៩ច្បាប់ មាន ១០៥មុខផលិតផល, និងបានចុះយកសំណាកទឹក នៅស្ថានីយផលិតទឹកស្អាតចំនួន ៣មូលដ្ឋាន ទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា។

រដ្ឋបាលរាជធានីភ្នំពេញ ក៏បានបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពីគីមីចំណីអាហារ (គ្រឿងផ្សំក្នុងចំណីអាហារ) Food Additive, និងវគ្គផ្សព្វផ្សាយច្បាប់រោងចក្រ សិប្បកម្ម ដើម្បីពង្រឹងខ្សែចង្វាក់ផលិតកម្មទឹកកកដើម ទឹកកកអនាម័យ និងការពង្រឹងគុណភាព។ លើសពីនេះ រដ្ឋបាលរាជធានីភ្នំពេញ បានជួបជាមួយអង្គការ PUM Netherland senior experts (Non-profit organization) និងផ្នែកសហគ្រាសធុនតូចនិងមធ្យម ដើម្បីពិភាក្សាលើផ្នែកអនាម័យចំណីអាហារ ការលើកកម្ពស់ផលិតភាពផលិតផលក្នុងវិស័យ SMEs និងការពិភាក្សាពីបញ្ហាកម្ចីមូលនិធិក្នុងអត្រាការប្រាក់ទាបដើម្បីអភិវឌ្ឍខ្សែចង្វាក់ផលិតកម្មក្រោមការសម្របសម្រួលពីមន្ទីរ, និងបានបង្កើតយន្តការច្រកចេញ-ចូលតែមួយ ដើម្បីកែសម្រួលក្នុងការបំពេញបែបបទ កាត់បន្ថយពេលវេលា និងចំណាយផ្សេងៗ ។

ក.១១- រដ្ឋបាលខេត្តស្វាយរៀង

រដ្ឋបាលខេត្តស្វាយរៀង បានជំរុញសហគ្រាសធុនតូចនិងមធ្យមដែលមាននៅក្នុងខេត្ត ធ្វើការផលិតនូវផលិតផលពាក់កណ្តាលសម្រេច ឬគ្រឿងបង្គុំសម្រាប់គាំទ្រ ឬផ្គត់ផ្គង់ឱ្យសហគ្រាសធុនធំ។

ខ- ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន៦ ដែលពាក់ព័ន្ធទៅនឹង "ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពដូចតទៅ÷

ខ.១- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយបច្ចុប្បន្នច្បាប់នេះត្រូវបានអនុម័តកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ព្រមទាំងបាននិងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យចំនួន៣ រួមមាន អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ, អនុក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម, និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ទន្ទឹមនឹងការរៀបចំសេចក្តីព្រាងប្រកាសមួយចំនួន តាមខ្លឹមសារនៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម។ ក្នុងការត្រៀមលក្ខណៈទុកជាមុន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិគណនេយ្យ បានរៀបចំការបណ្តុះបណ្តាលមន្ត្រីពន្ធដារអំពីឯកសារគំរូបញ្ជីគណនេយ្យសាមញ្ញ សម្រាប់មីក្រូសហគ្រាស ដើម្បីបណ្តុះបណ្តាលបន្ថែមសហគ្រាសជាប់កាតព្វកិច្ច, ព្រមទាំងបានរៀបចំចងក្រងទិន្នន័យសហគ្រាសធុនតូចនិងមធ្យមដែលបានចុះបញ្ជី ក៏ដូចជា

ផ្សព្វផ្សាយអំពីសារៈសំខាន់នៃការកាន់បញ្ជីគណនេយ្យជូនសហគ្រាសធុនតូចនិងមធ្យម។ គំរូបញ្ជីគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច (មីក្រូសហគ្រាស) ត្រូវបានបង្កើត និងដាក់ឱ្យអនុវត្តដោយប្រកាសលេខ ១៨២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកំណត់វិធាន និងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច។ ក្នុងកិច្ចការនេះ លិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត ក៏ត្រូវបានដាក់ចេញផងដែរ រាប់បញ្ចូលទាំងប្រកាសលេខ៤៩៦ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីពន្ធដារ, និងសេចក្តីជូនដំណឹងលេខ១៧៦៩ អពដ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ អំពីការដាក់ឱ្យប្រើប្រាស់ទម្រង់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែសម្រាប់អ្នកជាប់ពន្ធតូច។

ក្រៅពីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានផ្តល់កិច្ចសម្រួលបន្ថែមទៀតដល់ការចុះបញ្ជី និងការកាន់កាប់បញ្ជីគណនេយ្យរបស់សហគ្រាសធុនតូចនិងមធ្យម ដូចជា (១) ផ្តល់កិច្ចសហការក្នុងការពង្រឹងយន្តការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យមជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម, (២) សម្រេចជាគោលការណ៍អនុញ្ញាតឱ្យរោងចក្រកាត់ដេរប្រតិបត្តិតាមមូលដ្ឋានផលិតកម្ម (Free on Board: FOB) ផង និងមូលដ្ឋានកាត់ដេរ/ផលិត និងតម្រឹម/សម្អាត (Cut, Make and Trim: CMT) ផង ក្នុងករណីរោងចក្រកាត់ដេរកាន់បញ្ជីគណនេយ្យត្រឹមត្រូវ, (៣) សម្រេចជាគោលការណ៍ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធចំពោះសហគ្រាសធុនតូចនិងមធ្យមដែលកាន់បញ្ជីគណនេយ្យត្រឹមត្រូវ, និង (៤) បានលើកទឹកចិត្តដល់អ្នកជាប់ពន្ធគ្រប់ប្រភេទ ដែលបានកាន់កាប់បញ្ជីគណនេយ្យបានត្រឹមត្រូវឱ្យរួចផុតពីការបង់ពន្ធអប្បបរមា។

ខ.២ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

ដើម្បីសម្របសម្រួលការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម និងសេវាកម្ម ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្របសម្រួលការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម និងសេវាកម្ម នៅក្រោមក្របខ័ណ្ឌដំបូលតែមួយ។ បច្ចុប្បន្ន សេចក្តីព្រាងអនុក្រឹត្យនេះ ត្រូវបានដាក់ជូនទៅដល់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច ដើម្បីប្រជុំឆ្លងចុងក្រោយ មុននឹងដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

គិតត្រឹមដំណាច់ឆ្នាំ២០១៦ ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម បាន៤១% (ក្នុងនោះ៨៩% នៅមន្ទីរឧស្សាហកម្មរាជធានីខេត្ត និង១១% នៅក្រសួង) គឺមានការកើនឡើងមួយកម្រិត បើប្រៀបធៀបនឹងឆ្នាំ២០១៥ មានតែ៣៧%។

ខ.៣ ក្រសួងពាណិជ្ជកម្ម

ក្នុងការពង្រឹងអភិបាលកិច្ចសាជីវកម្ម ក្រសួងពាណិជ្ជកម្មបានបើកវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវពាណិជ្ជកម្ម ដើម្បីពង្រឹងសមត្ថភាពវិស័យឯកជនឱ្យបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិញ្ញាសារៈមិនាញ ក្នុងការធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព។

១.៤ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានបញ្ចប់សេចក្តីព្រាងប្រកាសស្តីពីការចុះបញ្ជី និងផ្តល់អាជ្ញា-បណ្ណដល់ក្រុមហ៊ុនដែលប្រតិបត្តិការលើវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានក្នុងស្រុក។

១.៥ រដ្ឋបាលខេត្តស្វាយរៀង

រដ្ឋបាលខេត្តស្វាយរៀង បានជំរុញការចុះបញ្ជីរោងចក្រចំនួន៦២ និងចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យមចំនួន៦៥។

គ. ការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន៥ ដែលពាក់ព័ន្ធទៅនឹង "ការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម÷

គ.១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ដើម្បីជំរុញដល់ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម បច្ចេកទេសកសិកម្ម និងធនធានមនុស្ស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តនូវសកម្មភាពជាច្រើនដូចជា បានកំពុងអនុវត្តផែនការស្រាវជ្រាវរបស់ខ្លួនក្នុងការអភិវឌ្ឍបច្ចេកវិទ្យា មានដូចជាពូជដំណាំ បង្កុំបច្ចេកវិទ្យាដាំដុះដំណាំប្រកបដោយគុណភាព និងទិន្នផលខ្ពស់ ដើម្បីជាធាតុចូលក្នុងដំណើរការរៀបចំយន្តការសម្របសម្រួល និងគាំទ្រដល់ការបង្កើត និងដំណើរការតំបន់កសិ-ឧស្សាហកម្ម, បានសហការជាមួយក្រុមហ៊ុន Tian Rui (Cambodia) Agriculture Cooperation SEZ Co., Ltd នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងផ្នែកសហប្រតិបត្តិការបច្ចេកទេសកសិកម្ម ដើម្បីដំណើរការតំបន់សេដ្ឋកិច្ចពិសេសអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម តាមរយៈការអនុវត្តអនុស្សរណៈយោគយល់គ្នាដែលបានចុះហត្ថលេខាកាលពីខែតុលា ឆ្នាំ២០១៦, ព្រមទាំងបានរៀបចំសកម្មភាពស្តីពីការសិក្សា វិភាគ និងវាយតម្លៃតំបន់សក្តានុពលនៃផលិតកម្មកៅស៊ូធម្មជាតិនៅកម្ពុជា។ ទន្ទឹមនឹងនេះ ក្រសួងក៏បានកំពុងដាំពិសោធពោតពូជ Hybrid សណ្តែកបាយ សណ្តែកសៀង ម្រេច ស្វាយចន្ទី ជាដើម និងកំពុងអភិវឌ្ឍបច្ចេកទេសដាំដុះដំណាំស្រូវ ស្របតាមបរិបទនៃការប្រែប្រួលអាកាសធាតុ, បានចងក្រងផលិត និងបោះពុម្ពផ្សព្វផ្សាយផែនទីកំណត់តំបន់ដាំដុះដំណាំចំនួន ៨ស្រុក និងផែនទីនៃការប្រើប្រាស់ដីកសិកម្មចំនួន ៩ខេត្ត ព្រមទាំងបានសិក្សា និងចងក្រងទិន្នន័យផ្ទៃដីដាំដុះដំណាំឈើហូបផ្លែនៅតាមបណ្តាឃុំ/សង្កាត់ចំនួន ១០២ និងរៀបចំជាផែនទីចង្អុលបង្ហាញតំបន់ផលិតកម្មដំណាំចំនួន ៧មុខ (សណ្តែកបាយ សណ្តែកដី ពោត ដំឡូងមី ស្វាយ ម្រេច និងល្ង)។

ក្រៅពីនេះ ក្រសួងបានកែលម្អនីតិវិធីសម្រាប់ផ្តល់លិខិតអនុញ្ញាតបង្កើតរោងសន្ធិចិលជ័ណ្ដែកចាយផ្ទាល់ អនុផលព្រៃឈើ ឬរោងសិប្បកម្មកែច្នៃកសិផល អនុផលព្រៃឈើប្រភេទតូចជូនដល់អតិថិជនតាមការស្នើសុំ

ជាក់ស្តែង ដោយបានអនុញ្ញាតផ្តល់ជាគោលការណ៍ប្រចាំឆ្នាំជូនដល់ខណ្ឌរដ្ឋបាលព្រៃឈើ ដើម្បីផ្តល់សេវារហ័សជូនអ្នកស្នើសុំ។ បន្ថែមពីនេះទៀត ក្រសួងបានខិតខំជំរុញឱ្យក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ចធ្វើការដាំដុះដំណាំកសិ-ឧស្សាហកម្មតាមកិច្ចសន្យា ដោយសម្រេចការដាំដុះបានប្រមាណជាង៤៣ម៉ឺនហិកតាត្រឹមឆ្នាំ២០១៦នេះ។

ក.២ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានបង្កើតក្រុមការងារចុះពិនិត្យសិក្សា និងកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់នូវតំបន់ការពារដីស្រែអំបិល និងរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ស្រែអំបិល។ ពាក់ព័ន្ធនឹងការងារនេះ ក្រសួងបានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិលដាក់ជូនថ្នាក់ដឹកនាំចុះហត្ថលេខា និងប្រើប្រាស់ជាផ្លូវការ។ ដើម្បីជំរុញការនាំចេញកសិផល ក្រសួងក៏បាននិងកំពុងរៀបចំកម្រងបណ្តុំសហគ្រាសធុនតូចនិងមធ្យមនៅខេត្តកណ្តាលដើម្បីកែច្នៃផលិតផលផ្លែឈើសម្រាប់នាំចេញ និងនៅកំពង់ឆ្នាំងដើម្បីកែច្នៃជលផលកម្ពុជាសម្រាប់នាំចេញ។

ក.៣ ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម បានសម្របសម្រួលក្រុមហ៊ុនមកពីចិន មកបង្កើតតំបន់កែច្នៃផលិតផលកសិ-ឧស្សាហកម្មកម្ពុជា នៅខេត្តព្រះសីហនុ ព្រមទាំងកំពុងធ្វើសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលអាស៊ាន-ចិន អាស៊ាន-ជប៉ុន អាស៊ាន-កូរ៉េ និងដៃគូជំរុញពាណិជ្ជកម្មដទៃទៀត ទាំងក្នុងតំបន់ ទាំងក្នុងពិភពលោក ដើម្បីបើកច្រកទីផ្សារលើផលិតផលដែលបានកែច្នៃរួចហើយ, និងសហការជាមួយអង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហ-ប្រជាជាតិ ក្នុងការរៀបចំកែលម្អទីតាំងមួយកន្លែងនៅខេត្តកំពតធ្វើជាផ្សាររួមសម្រាប់ការដាក់តាំងបង្ហាញ និងលក់ផលិតផលជលផលសមុទ្ររបស់សមាជិកសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជា។

ក្រៅពីនេះ ក្រសួងក៏បានរៀបចំអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា ដើម្បីបម្រើទីផ្សារក្នុងស្រុក និងជំរុញការនាំចេញផលិតផលហាឡាលកម្ពុជាទៅទីផ្សារអន្តរជាតិ ជាពិសេស ទីផ្សារនៅមជ្ឈិមបូព៌ា, និងប្រកាសស្តីពីនីតិវិធីនៃការនាំចូលអង្ករពីបរទេសដើម្បីពង្រឹងឧស្សាហកម្មស្រូវអង្ករ ជាពិសេសថែរក្សាការពារទីផ្សារអង្ករកម្ពុជា។

ទន្ទឹមនឹងការផ្តល់កិច្ចសម្រួល និងការរៀបចំឯកសារគតិយុត្តខាងលើ ក្រសួងបាននិងកំពុងអនុវត្តកំណែទម្រង់លើវិស័យជាច្រើនទៀត ដើម្បីជួយសម្រួលដល់វិស័យឯកជនដូចជា ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស ូ យប្រវត្តិកម្ម, ការចុះបញ្ជីក្រុមហ៊ុនតាមប្រព័ន្ធស ូ យប្រវត្តិកម្ម និងការចុះបញ្ជីពាណិជ្ជនាមតាមប្រព័ន្ធស ូ យប្រវត្តិកម្ម។ ព្រមគ្នានេះ ក្រសួងក៏បាននិងកំពុងធ្វើបច្ចុប្បន្នកម្មពីវឌ្ឍនភាពផលិតផលម្រេចនៅកម្ពុជា, សិក្សាស្រាវជ្រាវពីចង្វាក់តម្លៃទៅលើផលិតផលមួយចំនួនគឺស្ករត្នោត និងផ្លែស្វាយ ព្រមទាំងសិក្សាអំពីផលិតផលថ្មីៗដែលមានសក្តានុពលបម្រើឱ្យទីផ្សារក្នុងស្រុក និងសម្រាប់នាំចេញដែរទើប

តែលេចចេញនៅខេត្តមួយចំនួនដូចជា ស្ករអំពៅខេត្តស្វាយរៀង កោះកុង ព្រះវិហារ, ផ្លែចេកខេត្តកំពង់ចាម ព្រះវិហារ, ផ្លែល្មៅខេត្តព្រះវិហារ, និងផលិតផលសូត្រខេត្តសៀមរាប កំពង់ធំ តាកែវ បន្ទាយមានជ័យ កំពត និងខេត្តកណ្តាល។

ค.๔ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាការងារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដោយផ្តោតសំខាន់លើការជំរុញវិស័យកសិ-ឧស្សាហកម្ម។ ក្រៅពីការងារសម្របសម្រួលខាងលើ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏បានធ្វើការផ្សព្វផ្សាយជូនវិនិយោគិនទាំងក្នុង និងក្រៅប្រទេសអំពីបរិយាកាស និងកាលានុវត្តភាពវិនិយោគនៅកម្ពុជា ជាពិសេសសក្តានុពលនៃការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម ព្រមទាំងបានពិភាក្សាការងារជាមួយតំណាងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ក្នុងការផ្តល់ការគាំទ្រ និងលើកកម្ពស់ការវិនិយោគក្នុងវិស័យនេះ។

លើសពីនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចូលរួមពិភាក្សា និងផ្តល់យោបល់លើការលើកកម្ពស់ខ្សែចង្វាក់តម្លៃនៃផលិតផលកសិកម្ម និងការកំណត់មុខដំណាំអាទិភាពមួយចំនួនសម្រាប់កែច្នៃនាំចេញ ក្នុងកិច្ចប្រជុំ និងសិក្ខាសាលាពាក់ព័ន្ធមួយចំនួនដូចជា (១) កិច្ចប្រជុំតុមូលដែលសហការរៀបចំដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងអង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ ដើម្បីសិក្សា និងកំណត់ដំណាំអាទិភាពមួយចំនួនរួមមាន អង្ករ កៅស៊ូ (ផលិតផលពាក់កណ្តាលសម្រេច) ស្វាយ ម្រេច អំបិល គ្រាប់ស្វាយចន្ទី ដំឡូងមី សណ្តែកសៀង និងពោត ដែលអាចធ្វើការកែច្នៃសម្រាប់នាំចេញ, (២) សិក្ខាសាលាស្តីពីការផ្សព្វផ្សាយលទ្ធផលសិក្សាស្រាវជ្រាវលើខ្សែចង្វាក់ផលិតផលស្ករត្នោត និងស្វាយ ដែលមានសក្តានុពលសម្រាប់កែច្នៃ និងនាំចេញ, (៣) សិក្ខាសាលាស្តីពីភាពជាដៃគូ Grow Asia នៅកម្ពុជា ដើម្បីវិស័យកសិកម្មប្រកបដោយនិរន្តរភាព ដោយបានកំណត់បញ្ហាប្រឈម និងជំរុញខ្សែចង្វាក់តម្លៃនៃផលិតផលកសិកម្ម ៦មុខ រួមមាន ដំឡូងមី ដូង ម្រេច អង្ករ បន្លែ និងស្ករត្នោត, និង (៤) សិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍ពាក់កណ្តាលការសិក្សារៀបចំគម្រោងខ្សែចង្វាក់តម្លៃនៃកសិធុរកិច្ចប្រកបដោយភាតរបរិស្ថាន ដោយផ្តោតលើមុខដំណាំ ៤មុខរួមមាន ស្រូវ ពោត ដំឡូងមី និងស្វាយ ដែលគ្រោងអនុវត្តនៅខេត្តតាកែវ កំពត កំពង់ចាម និងត្បូងឃ្មុំ ក្នុងគោលបំណងបង្កើនផលិតភាព តាមរយៈការអនុវត្តផលិតកម្ម និងការកែច្នៃផលិតផលកសិកម្មឱ្យមាននិរន្តរភាព និងសម្របតាមការប្រែប្រួលអាកាសធាតុ កែលម្អគុណភាព និងបង្កើនតម្លៃបន្ថែម។

ค.๕ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិមួយចំនួន ដើម្បីលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិកម្ម ដូចជាច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, អនុក្រឹត្យលេខ១៤៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៥៦ នៃអនុក្រឹត្យលេខ១១១៤ អនក្រ.បក

ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម, ប្រកាសលេខ៤៩៥ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃជាដើម។ បន្ថែមពីនេះ ក្រសួងបានរៀបចំប្រកាសរួម និងប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងនានា ហើយក៏បាននិងកំពុងបន្តចូលរួមជាមួយក្រុមការងាររបស់ក្រសួងមុខងារសាធារណៈ ក្នុងការចុះពិនិត្យ និងកែលម្អការផ្តល់សេវាសាធារណៈអាទិភាពសំខាន់ៗ។ ពាក់ព័ន្ធនឹងសេវាសាធារណៈនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានបន្តកែសម្រួលនីតិវិធីតយដើម្បីបង្កលក្ខណៈងាយស្រួលដល់វិនិយោគិន និងធុរជនពាក់ព័ន្ធ ដោយយោងតាមស្មារតីនៃកិច្ចប្រជុំភាពជាដៃគូតយ-ផ្នែកឯកជន លើកទី៥ និងលើកទី៦ រួមមាន (១) ការបិទផ្សាយលំហូរនីតិវិធី និងស្តង់ដាការងារ, (២) ការអនុញ្ញាតឱ្យលើទំនិញច្រើនម្ចាស់ផ្ទុកក្នុងកុងតឺន័រ (Less Than Container Load), (៣) ការកែលម្អគេហទំព័រតយ, (៤) ការពង្រឹងប្រសិទ្ធភាពនៃការបង្ក្រាបបទល្មើស, (៥) ការអនុញ្ញាតឱ្យនាំចេញទំនិញកាត់ដេរមានម្ចាស់តែមួយក្នុងរថយន្ត មានលក្ខណសម្បត្តិជាកុងតឺន័រ, (៦) ការទទួលយកតម្លៃប្រកាសសម្រាប់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ និង (៧) ការបង្កើត Hotline សម្រាប់តវ៉ាតាមមាត់ច្រក។

ក្នុងការជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ចប់ការចរចាលើគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (Accelerating Inclusive Markets for Smallholders - AIMS) ជាមួយមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម (International Fund for Agricultural Development: IFAD) ដែលមានទឹកប្រាក់សរុបប្រមាណ ៦១ លានដុល្លារអាមេរិក។

ក.៦ ទីស្តីការគណៈរដ្ឋមន្ត្រី

ទីស្តីការគណៈរដ្ឋមន្ត្រី បាននិងកំពុងចូលរួមប្រជុំ និងផ្តល់ធាតុចូលផងដែរពាក់ព័ន្ធនឹងការជំរុញ និងអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម។

២.៣.៣ ការកែលម្អបរិស្ថានគោលនយោបាយ

ក. វិធានការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញ

ក្នុងរយៈពេលកន្លងមកនេះ ក្នុងចំណោមវិធានការគោលនយោបាយចំនួន១១ ដែលពាក់ព័ន្ធនឹង "ការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញ" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម÷

ក.១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងរៀបចំប្រព័ន្ធតាមដានការវិនិយោគ (Investment Tracking System) ដើម្បីសម្រួលដល់ដំណើរការឯកសារស្នើសុំវិនិយោគរបស់វិនិយោគិន។ លើសពីនេះ ក្រុមប្រឹក្សា

អភិវឌ្ឍន៍កម្ពុជា បានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគុណភាព និងរយៈពេលនៃការផ្តល់សេវាសាធារណៈជាប្រចាំ ដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងបានបន្តពង្រឹងការពិនិត្យ និងការអនុម័តលើសំណើសុំនាំចូលដោយពន្ធជាបន្ទុករបស់រដ្ឋ របស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។

ក.២. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដំឡើងប្រព័ន្ធអាស៊ីគូដាតាមការិយាល័យគយ និងរដ្ឋាករចំនួន ៥៤ ព្រមទាំងបានសិក្សាអំពីគម្លាតផ្នែកច្បាប់ និងផែនការលម្អិតសម្រាប់អនុវត្តគម្រោងបញ្ជីតែមួយជាតិ, និងបានបង្កើតក្រុមការងារចំនួន ៣ គឺទី១ ក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់ និងគោលនយោបាយ, ទី២ ក្រុមអនុវត្តគម្រោង និងទី៣ លេខាធិការដ្ឋានបញ្ជីតែមួយជាតិ ដើម្បីពន្លឿនបញ្ចប់ការអនុវត្តផែនការកែទម្រង់ការសម្រួលពាណិជ្ជកម្ម និងដាក់ឱ្យប្រើប្រាស់សេវា "បញ្ជីតែមួយជាតិ"។ បច្ចុប្បន្នប្រព័ន្ធនេះកំពុងត្រូវបានពង្រីកភាពគ្របដណ្ដប់ ដែលជាមូលដ្ឋាននៃប្រព័ន្ធបញ្ជីតែមួយជាតិទៅគ្រប់ការិយាល័យគយសំខាន់ៗ ហើយក្រសួងក៏បានជ្រើសរើសនិងបណ្ដុះបណ្ដាលជើងសាគយវិជ្ជាជីវៈជាមធ្យមជាង ១០០រូបក្នុងមួយឆ្នាំ ដើម្បីត្រៀមបម្រុងអនុវត្តប្រព័ន្ធនេះ។

ទន្ទឹមគ្នានេះ អគ្គនាយកដ្ឋានក៏បានដាក់ឱ្យដំណើរការ និងធ្វើបច្ចុប្បន្នកម្មគេហទំព័រគយថ្មី www.customs.gov.kh, កម្រងអត្ថបទនីតិវិធីបំពេញបែបបទបញ្ជេញទំនិញពីគយ និងបញ្ជីកម្រៃគយផ្លូវការ, បានរៀបចំកែលម្អស្តង់ដាសេវាសាធារណៈ និងបានជំរុញឱ្យអនុវត្តប្រកាសរួមរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ដែលជាវឌ្ឍនភាពនៃការអនុវត្តវិធានការប្រមូលផ្តុំ និងផ្សព្វផ្សាយនូវព័ត៌មានអំពីវិធានពាណិជ្ជកម្ម តារាងពន្ធ និងកម្រៃផ្លូវការដែលត្រូវបង់ដោយពាណិជ្ជករ។ ជាងនេះទៅទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំរវាងគយ និងផ្នែកឯកជន ព្រមទាំងជំរុញឱ្យអនុវត្តនូវប្រកាសស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ សំដៅកែលម្អការធ្វើបែបបទបញ្ជេញទំនិញ សម្រាប់ទំនិញដែលលើកលែងពន្ធ និងប្រកាសអន្តរក្រសួងស្តីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យជាធរមាន។ លើសពីនេះ ក្រសួងក៏បានដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងភាពជឿជាក់ធុរជន (Trader Credibility Management System)។

តាមរយៈសូចនាករនៃការសិក្សារយៈពេលបញ្ជេញទំនិញពីគយ (Time Release Study - TRS) ដែលត្រូវបានធ្វើចុងក្រោយនាខែវិច្ឆិកា ឆ្នាំ២០១៤ រយៈពេលបំពេញបែបបទគយត្រូវបានកាត់បន្ថយមកត្រឹម ១ម៉ោងពានាទីសម្រាប់ផ្លូវអាកាស, ២ម៉ោង៥៨នាទី សម្រាប់ផ្លូវទឹក, និង ១ម៉ោង៣៥នាទី សម្រាប់ផ្លូវគោក (គិតពីពេលចុះបញ្ជីកាងកសាររដ្ឋបាលតែមួយដល់ពេលអនុញ្ញាតឱ្យកទំនិញចេញ - Release order)។ ការសិក្សានេះនឹងបន្តធ្វើនៅពេលដ៏ខ្លីខាងមុខទៀត។ ដើម្បីបន្តកាត់បន្ថយចំណាយក្រៅផ្លូវការឱ្យកាន់តែស្រួលឡើង ក្រសួងក៏បាននិងកំពុងកសាងសេចក្ដីព្រាងចុងក្រោយនៃប្រកាសមួយចំនួនពាក់ព័ន្ធនឹងកម្រៃគយផ្សេងៗទៀត។

ផ្អែកតាមកិច្ចខិតខំប្រឹងប្រែងកន្លងមកក្នុងកិច្ចការខាងលើនេះ ការវាយតម្លៃលើសន្ទស្សន៍ភស្តុភារកម្ម របស់ធនាគារពិភពលោករបស់កម្ពុជា ត្រូវបានកែលម្អ ៤៦ចំណាត់ថ្នាក់ ពោលគឺពីចំណាត់ថ្នាក់ ១២៩/១៦០ នាឆ្នាំ២០១០ មកចំណាត់ថ្នាក់ ៨៣ នាឆ្នាំ២០១៤ និងមកចំណាត់ថ្នាក់ ៧៣ នាឆ្នាំ២០១៦ ដែលនេះជាការវាយតម្លៃដ៏វិជ្ជមានមួយសម្រាប់កម្ពុជា។

គួរកត់សម្គាល់ផងដែរថា ចំណូលពន្ធគយ និងអាករឆ្នាំ២០១៦ មានកំណើនប្រមាណ ១៥% ប្រៀបធៀបឆ្នាំ២០១៥។ ចំនួនឯកសាររដ្ឋបាលតែមួយ (SAD) ច្រកក្រហមមានកម្រិត ១២,៣៨% នៃចំនួនឯកសាររដ្ឋបាលតែមួយសរុប (៩ខែ) ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក.៣ ក្រសួងសាធារណការនិងដឹកជញ្ជូន

ក្រសួងសាធារណការនិងដឹកជញ្ជូន បានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្ត ឆ្នាំ២០១៧-២០១៩ លើការរៀបចំផែនការមេប្រព័ន្ធភស្តុភារកម្ម ដោយក្នុងនោះក្រុមជំនាញការកូរ៉េ និងទីភ្នាក់ងារសហ-ប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន កំពុងសិក្សាអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម និងការរៀបចំផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម។

ទន្ទឹមគ្នានេះ ក្រសួងបាននិងកំពុងបន្តពិភាក្សា ដើម្បីធ្វើការកែលម្អគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលមានអនុគណៈកម្មាធិការភស្តុភារកម្ម អនុគណៈកម្មាធិការសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (ប៉ុស្តិ៍ព្រំដែន) និងអនុគណៈកម្មាធិការប្រតិបត្តិការឆ្លងកាត់ព្រំដែន (សម្រួលការអនុវត្តច្បាប់)។ ក្នុងការធ្វើឱ្យប្រសើរឡើងនូវការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ក្រសួងសាធារណការនិងដឹកជញ្ជូនបាននិងកំពុងបន្តអនុវត្តផែនការសកម្មភាពជាបន្តបន្ទាប់ជាមួយប្រទេសជិតខាង ដើម្បីផ្តល់ការសម្រួលដល់ការធ្វើចរាចរណ៍ជាលក្ខណៈពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។

ក្នុងកិច្ចសហប្រតិបត្តិការជាមួយឡាវ គណៈកម្មាធិការសម្រួលការដឹកជញ្ជូនរបស់ភាគីទាំងពីរ កម្ពុជា-ឡាវ បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំកាលពីថ្ងៃទី២២-២៣ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយបានឯកភាពគ្នាដំឡើងកូតាយានយន្តឱ្យដល់ ១៥០គ្រឿង។

រីឯនៅក្នុងកិច្ចសហប្រតិបត្តិការជាមួយវៀតណាមវិញ ភាគីទាំងពីរបានបន្តអនុវត្តកូតាយានយន្ត ៥០០ គ្រឿង ក្នុងក្របខ័ណ្ឌអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-វៀតណាម។ កន្លងមក ភាគីកម្ពុជាបានស្នើដល់ភាគីវៀតណាមនូវចំណុចមួយចំនួនដូចជា ពិចារណាឱ្យក្រុមហ៊ុនកម្ពុជាអាចបើកការិយាល័យសាខានៅប្រទេសវៀតណាមបាន, ពិនិត្យបញ្ជាបង់ប្រាក់ការដឹកទំនិញកុងតឺន័រឆ្លងកាត់, និងស្នើបន្ថែមមន្ត្រីអន្តោប្រវេសន៍បំពេញការងារនៅបញ្ជរ៥ដែលមានស្រាប់។ រីឯភាគីវៀតណាមវិញក៏បានស្នើឡើងនូវចំណុចមួយចំនួន ដូចជា (១) សុំបង្កើតគណៈកម្មការរួមអ្នកតំណាងនាយក-រដ្ឋមន្ត្រី ដើម្បីអនុវត្តអនុស្សរណៈស្តីពីការផ្តួចផ្តើមអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនដែលមាន

អនុតំបន់មេគង្គ (MOU-IICBTA) ដែលបានចុះហត្ថលេខាឆ្នាំ២០០៦, (២) ការត្រួតពិនិត្យរួមគ្នាឈប់តែមួយលើក (SSI) និងការត្រួតពិនិត្យរួមគ្នាបញ្ជូនតែមួយ (SWI), (៣) ការងារសាងសង់ទីលានត្រួតពិនិត្យរួមគ្នា (CCA) ចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីនីតិវិធីគយរវាងប្រទេសទាំងពីរ, (៤) ការស្នើឱ្យមានការដឹកជញ្ជូនឆ្លងកាត់ Transit ពីហូជីមិញ-ភ្នំពេញ-បាងកក, និង (៥) ការរៀបចំខ្សែផ្លូវដឹកជញ្ជូន ឬរបៀងថ្មី និងច្រកទ្វារថ្មីនៅតំបន់បាវិត-ម៉ុកបាយ។ល។ ក្រសួងសាធារណការនិងដឹកជញ្ជូន គ្រោងប្រើប្រាស់ថវិកាជាតិ ដើម្បីពង្រីកកំណាត់ផ្លូវជាតិលេខ១ ពីទីតាំងម៉ាស៊ីនស្ពែន (ស្នាក់ការគយ) ដល់ប៉ុស្តិ៍ព្រំដែនបាវិត និងពង្រីកផ្លូវជា ៤ ឬ ៦គន្លង ដើម្បីតភ្ជាប់ផ្លូវពីប៉ុស្តិ៍ច្រកទ្វារព្រំដែនបាវិតទៅដល់ចំណុចសួន្យ ហើយស្នើភាគីវៀតណាមធ្វើបន្តដល់ប៉ុស្តិ៍ម៉ុកបាយ។ លើសពីនេះ ភាគីទាំងពីរកំពុងបន្តពិនិត្យពិភាក្សាបញ្ចប់ និងគ្រោងចុះហត្ថលេខាលើសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នាស្តីពីការជំរុញការសាងសង់ផ្លូវល្បឿនលឿន និងចំណុចតភ្ជាប់ផ្លូវល្បឿនលឿន និងអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់វិស័យដឹកជញ្ជូន ឆ្នាំ២០១៦-២០២០ និងទស្សនវិស័យឆ្នាំ២០៣០។ ជាបន្តបន្ទាប់ ក្រសួងបានប្រជុំពិគ្រោះយោបល់ផ្ទៃក្នុង និងជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធស្តីពីការកំណត់ចំណុចតភ្ជាប់ផ្លូវល្បឿនលឿនភ្នំពេញ-ហូជីមិញ ដែលសិក្សាដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ដែលគ្រោងធ្វើនៅក្បែរបង្គោលព្រំដែនលេខ១១៦៤ (ភូមិធ្លក) មានចម្ងាយប្រមាណ ៤គីឡូម៉ែត្រពីផ្លូវជាតិលេខ១ ត្រង់ភូមិព្រៃផ្តៅ សង្កាត់ច្រកម្នេស ក្រុងបាវិត។

ដោយឡែក ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ឡាវ-វៀតណាម អនុស្សរណៈនៃការយោគ-យល់គ្នាស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-ឡាវ-វៀតណាម បានចូលជាធរមាន និងត្រូវបានរៀបចំពិធីសម្ពោធបើកប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ប្រទេសទាំង៣ កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៥។ ភាគីនីមួយៗមានកូតាយានយន្តចំនួន ១៥០គ្រឿង សម្រាប់ធ្វើប្រតិបត្តិការឆ្លងកាត់៣ប្រទេស។ ភាគីវៀតណាមបានផ្តួចផ្តើមឱ្យមានអនុស្សរណៈនៃការយោគយល់គ្នា និងផែនការមេសម្រាប់ការតភ្ជាប់និងអភិវឌ្ឍវិស័យដឹកជញ្ជូនរវាងប្រទេសទាំងបី។

ចំពោះកិច្ចសហប្រតិបត្តិការជាមួយថៃ ភាគីកម្ពុជា និងថៃបានចុះហត្ថលេខាលើអនុស្សរណៈស្តីពីការដំឡើងកូតាយានយន្តពី ៤០គ្រឿងដល់ ១៥០គ្រឿង តាមច្រកទ្វារប៉ោយប៉ែត-អារញ្ញប្រាថេតក្នុងឱកាសនៃកិច្ចប្រជុំលើកទី៥ គណៈកម្មការរួមនៃគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូន អនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែននៃមហាអនុតំបន់មេគង្គ កាលពីថ្ងៃទី១៤-១៥ ខែធ្នូ ឆ្នាំ២០១៦។ អនុស្សរណៈនេះនឹងចូលជាធរមាននៅចុងខែមីនា ឆ្នាំ២០១៧។ ទន្ទឹមគ្នានេះ ចំពោះគម្រោងសាងសង់ច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់-ណងអៀន និងសាងសង់ផ្លូវភ្ជាប់ពីអគារប៉ុស្តិ៍ព្រំដែនមកភ្ជាប់នឹងផ្លូវជាតិលេខ៥ ក្នុងខេត្តបន្ទាយមានជ័យ ក្រសួងសាធារណការនិងដឹកជញ្ជូនរបស់កម្ពុជា និងក្រសួងដឹកជញ្ជូនរបស់ថៃ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការសាងសង់ស្ពានឆ្លងកាត់ចំណុចព្រំដែន (ស្ទឹងមាន)។ បច្ចុប្បន្ន

គណៈកម្មការវិចលនាលទ្ធកម្ម និងគណៈកម្មការវាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស កំពុងពិនិត្យ និងវាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស។

ក.៤ ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម បាននិងកំពុងកែលម្អនីតិវិធីពាណិជ្ជកម្មយ៉ាងសស្រាក់សស្រាំ រួមមានការរៀបចំ និងដាក់ឱ្យអនុវត្តតាមប្រព័ន្ធអេឡិចត្រូនិកនូវការចុះបញ្ជីសហគ្រាស, ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ, ការចុះបញ្ជីម៉ាក និងការបង់កម្រៃសេវាសាធារណៈ (E-payment) ព្រមទាំងបានធ្វើវិមជ្ឈការនៃការកំណត់តម្លៃគិតពន្ធគយដល់ការិយាល័យបំពេញបែបបទគយ ដែលទាំងអស់នេះ គឺជាយន្តការពង្រឹងការសម្រួលពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះ ក្រសួងពាណិជ្ជកម្ម ក៏បានចាត់មន្ត្រីជំនាញចូលរួមចរចាលើកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ, កម្ពុជា-វៀតណាម និងកម្ពុជា-ឡាវ ព្រមទាំងបានចូលរួមសិក្ខាសាលា និងកិច្ចប្រជុំពាក់ព័ន្ធ។ ដើម្បីជួយសម្រួល និងលើកកម្ពស់សហគ្រាសក្នុងស្រុក ក្រសួងពាណិជ្ជកម្ម បានចូលរួម និងរៀបចំជាប្រចាំនូវការតាំងពិព័រណ៍ផលិតផលកម្ពុជានៅក្នុង និងក្រៅប្រទេស ព្រមទាំងរៀបចំជំនួបពាណិជ្ជកម្ម និងបណ្តាញធុរកិច្ច, វេទិកាអភិវឌ្ឍកសិ-ពាណិជ្ជកម្មនៅតាមរាជធានីខេត្ត, កម្មវិធីជួនបណ្ណសរសើរដល់កសិករឆ្នើម និងពាណិជ្ជករគំរូ, និងសហការនាំយកផលិតផលខ្មែរទៅដាក់លក់ក្នុងផ្សារទំនើប។ ដោយឡែក ចំពោះការជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ក្រសួងបានទទួលចុះបញ្ជីសមាគមចំនួន១១៨ ពាក់ព័ន្ធនឹងអាជីវកម្មរោងម៉ាស៊ីនកិនស្រូវ ស្វាយចន្ទី ដំឡូងមី ស្វាយ ស្ករត្នោត គ្រឿងអលង្ការ។ល។ ថែមទាំងបានបង្កើតកម្មវិធីពង្រឹងសមត្ថភាពសមាគមទាំងនោះ ជាក់ស្តែងដូចជាគម្រោងកម្មវិធីពង្រឹងសមត្ថភាពសមាគមដំឡូងមីកម្ពុជា ក្រោមកិច្ចសហការជាមួយអង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ, ព្រមទាំងបានរៀបចំវេទិកាជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍កសិ-ពាណិជ្ជកម្ម។

ក.៥ រដ្ឋបាលខេត្តស្វាយរៀង

រដ្ឋបាលខេត្តស្វាយរៀង បានខិតខំដោះស្រាយការកកស្ទះមធ្យោបាយដឹកជញ្ជូន នៅច្រកអន្តរជាតិបាវិត តាមរយៈការណែនាំឱ្យធុរជនធ្វើការផ្លាស់ប្តូរព័ត៌មានពាណិជ្ជកម្មឱ្យបានលឿន, ពន្លឿនការដាក់ពាក្យបំពេញបែបបទមធ្យោបាយដឹកជញ្ជូននៅច្រកទ្វារព្រំដែន, បង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូន, បន្ថែមពេលវេលាធ្វើការរបស់មន្ត្រីជំនាញ, ពិនិត្យលទ្ធភាពពង្រីកទីតាំង និងបន្ថែមម៉ាស៊ីនស្កេនកុងតឺន័រ នៅការិយាល័យគយបាវិត។

ខ- ការពង្រឹងបទដ្ឋានឧស្សាហកម្ម និងកម្មសិទ្ធិឧស្សាហកម្ម

ក្នុងការអនុវត្តវិធានការគោលនយោបាយទាំង៩ ដែលពាក់ព័ន្ធទៅនឹងការពង្រឹងបទដ្ឋានឧស្សាហកម្ម និងកម្មសិទ្ធិឧស្សាហកម្ម ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បាននិងកំពុងអនុវត្តសកម្មភាពការងារយ៉ាង

សស្រាក់សស្រាំ។ ក្រោយពីមានការកែទម្រង់ការងារកម្មសិទ្ធិឧស្សាហកម្មរួចមក ក្នុងឆ្នាំ២០១៦ ក្រសួងបានទទួលការស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្តកម្មចំនួន ៧៧ ដែលក្នុងនោះមាន ១ ជាតក្តករខ្មែរ, វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ចំនួន ១៧ និងគំនូរឧស្សាហកម្មចំនួន ១០២។

ក្នុងគោលបំណងជំរុញការស្នើសុំចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្មពីក្នុង និងក្រៅប្រទេស ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានខិតខំអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការផ្តល់សិទ្ធិចុះបញ្ជីដល់ភ្នាក់ងារនៃប្រទេសដៃគូនានា និងបានស្នើសុំប្រមុខរាជរដ្ឋាភិបាលចេញលិខិតូបករណ៍មួយចំនួន ដូចជា (១) ប្រកាសលេខ១៨១ MIH/2016 ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្តកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្តកម្មកម្ពុជា ទាក់ទងនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្តកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្តកម្មជប៉ុន, (២) ប្រកាសលេខ១៨២ MIH/2016 ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្តកម្មសិង្ហបុរីនៅកម្ពុជា, (៣) លិខិតូបករណ៍លេខ៥១ លស.សប្រ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីលិខិតូបករណ៍នៃការចូលជាសមាជិកសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្តកម្ម (PCT), និង (៤) លិខិតូបករណ៍លេខ១០៦៥ លស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីលិខិតូបករណ៍នៃការចូលជាសមាជិកសន្ធិសញ្ញាទីក្រុងហ្ស៊ីណែវ (ឆ្នាំ១៩៩៩) និងកិច្ចព្រមព្រៀងទីក្រុងឡាអេ ទាក់ទងនឹងការងារចុះបញ្ជីឧស្សាហកម្មអន្តរជាតិដែលកម្ពុជាជាសមាជិកពេញសិទ្ធិទី១៥១។

ក្នុងគោលបំណងពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាពផលិតផល និងសេវា ក្រសួងបានអនុវត្តកិច្ចការមួយចំនួន ដូចជា បានបង្កើតក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ (CANC), បានដាក់ឱ្យដំណើរការជាផ្លូវការនូវគេហទំព័ររបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ដែលមានឈ្មោះ www.da-canc.gov.kh និងបានរៀបចំបង្កើតឯកសារផ្សេងៗ ពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងគុណភាព។ ជាងនេះទៅទៀត ក្រសួងបានចេញប្រកាសស្តីពីការបង្កើតស្តង់ដាជាតិរួមមាន អង្ករផ្កាវ៉ាដ្ឋ និងអង្ករផ្កាច័ន្ទសែនស, ផ្នែកផលិតផលពីឈើចំនួន ៣៤ស្តង់ដា, ផ្នែកផលិតផលពីកៅស៊ូចំនួន ៤៦ស្តង់ដា, ផ្នែកផលិតផលយានយន្តចំនួន ១៩ស្តង់ដា, ផ្នែកផលិតផលអគ្គិសនី និងអេឡិចត្រូនិកចំនួន ១១៩ស្តង់ដា, និងផ្នែកវិធីសាស្ត្រធ្វើតេស្តចំនួន ៩៩ស្តង់ដា។

ក្រៅពីនេះ ពាក់ព័ន្ធនឹងការបង្កើនការយល់ដឹងលើស្តង់ដា មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានធ្វើការផ្សព្វផ្សាយអំពីស្តង់ដាកម្ពុជា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការវាយតម្លៃភាពអនុលោម តាមគេហទំព័រវិទ្យាស្ថានស្តង់ដា និងតាមប្រព័ន្ធផ្សព្វផ្សាយនានា, បានរៀបចំបណ្ណាល័យតម្កល់ឯកសារស្តង់ដា និងបន្ទប់ស្រាវជ្រាវសម្រាប់អតិថិជនសិក្សាស្វែងយល់ ដូចជាច្បាប់ស្តីពីស្តង់ដាកម្ពុជា ស្តង់ដាទឹកពិសា ស្តង់ដាអគ្គិសនីនិងអេឡិចត្រូនិក គោលការណ៍រួម និងតម្រូវការរបស់អាស៊ានសម្រាប់អនាម័យម្ហូបអាហារជាដើម, ព្រមទាំងបានរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលផ្សេងៗពាក់ព័ន្ធនឹងកិច្ចការនេះ ដោយមានការចូលរួមពីបណ្តាសហគ្រិន ម្ចាស់រោងចក្រ សិប្បកម្ម ដៃគូអភិវឌ្ឍន៍ និងក្រសួងស្ថាប័នពាក់ព័ន្ធនានា។

ក្នុងការពង្រឹងសមត្ថភាពមាត្រាសាស្ត្រ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានបង្កើនសមត្ថភាពមន្ទីរពិសោធន៍មាត្រាសាស្ត្រឱ្យទទួលបាន ISO/IEC 17025, ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិឱ្យជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស ឧបករណ៍មាត្រាសាស្ត្រ និងឧបករណ៍ស្តង់ដាមាត្រាសាស្ត្របន្ថែមទៀត, ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងតាមផ្សារ ជញ្ជីងថ្លឹងស្រូវ ម៉ាស៊ីនចែកចាយប្រេងរថយន្តផ្ទុកទម្ងន់ដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីជាប្រយោជន៍ដល់សាធារណជនទាំងអស់, ព្រមទាំងបានធ្វើការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាសាធារណៈដែលពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្របានយ៉ាងទូលំទូលាយដល់សហគ្រិន។

គ. ការសម្រួលការបំពេញកាតព្វកិច្ចពន្ធ និងអាករ

ក្នុងការអនុវត្តវិធានការគោលនយោបាយទាំង៥ ដែលពាក់ព័ន្ធទៅនឹងការសម្រួលការបំពេញកាតព្វកិច្ចពន្ធនិងអាករ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកែប្រែរបបកំណត់ពន្ធដោយលុបចោលរបបម៉ៅការទៅជារបបស្វ័យប្រកាសសម្រាប់អ្នកជាប់ពន្ធតូច មធ្យម និងធំ, និងអនុគ្រោះពីការប្រមូលពន្ធ ចំពោះអ្នកជាប់ពន្ធមានផលរបរក្រោមអប្បបរមានៃការចុះបញ្ជី (២៥០លានរៀល), បានរៀបចំការទទួលប្រាក់ពន្ធតាមបញ្ជរប្រព័ន្ធធនាគារដៃគូ, បានបង្កើតការិយាល័យទំនាក់ទំនងអតិថិជន (Call Center), និងបានបង្កើតបញ្ជរពិគ្រោះយោបល់ និងបញ្ជូលព័ត៌មានចាំបាច់នានាសម្រាប់អ្នកជាប់ពន្ធទៅក្នុងគេហទំព័រអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងកំពុងរៀបចំប្រតិបត្តិការពាក់ព័ន្ធនឹងពន្ធដារផ្សេងៗទៀតតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ក្នុងកិច្ចការនេះផងដែរ ក្រសួងក៏បានបញ្ចប់ការសិក្សាដោយសង្ខេបស្តីពីការកែទម្រង់គោលនយោបាយពន្ធអាករ និងបញ្ចប់ការសិក្សា និងវាយតម្លៃគោលនយោបាយពន្ធបច្ចុប្បន្ន។

ចំពោះការរៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ ក្រសួងបានបន្តរៀបចំសេចក្ដីព្រាងប្រកាសស្ដីពីចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធ, និងបទប្បញ្ញត្តិផ្សេងៗទៀតទាក់ទិននឹងការសម្រួល ឬដកចេញនូវយន្តការទាំងឡាយណាដែលបណ្ដាលឱ្យខ្វាស់គ្នារវាងនីតិវិធីនៃការយកពន្ធ និងការលើកលែងពន្ធ។ ក្រៅពីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើរបាយការណ៍ស្ដីពីការអនុវត្តការងារពាក់ព័ន្ធនឹងក្របខ័ណ្ឌនៃការលើកទឹកចិត្តវិនិយោគនៅកម្ពុជា ដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រៀមជំហរពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មច្បាប់ស្ដីពីវិនិយោគ ព្រមទាំងបានបង្កើតក្រុមការងារមួយសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ។

ឃ. ការរៀបចំទីផ្សារពលកម្ម និងទំនាក់ទំនងវិជ្ជាជីវៈ:

ក្នុងចំណោមវិធានការគោលនយោបាយទាំង៩ ដែលពាក់ព័ន្ធនឹង "ការរៀបចំទីផ្សារពលកម្ម និងទំនាក់ទំនងវិជ្ជាជីវៈ" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម:

ឃ.១- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្នុងក្របខ័ណ្ឌនៃការកំណត់ប្រាក់ឈ្នួលអប្បបរមា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រេចបានន្យូវសកម្មភាពជាច្រើន ដូចជា (១) បានបង្កើតក្រុមការងារបច្ចេកទេសត្រីភាគីដែលមានតំណាងពីត្រីភាគីចំនួន ១៦-១៦-១៦ ដើម្បីពិភាក្សាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៧ និងបានប្រជុំពិភាក្សាអស់រយៈពេល៦ថ្ងៃ ស្មើនឹង៩លើក, (២) បានសិក្សា រៀបចំ កំណត់និងផ្សព្វផ្សាយអំពីប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា និងក្នុងតំបន់ និងលក្ខណៈវិនិច្ឆ័យបែបសង្គម-សេដ្ឋកិច្ច, (៣) បានប្រើប្រាស់ទិន្នន័យផ្លូវការបែបវិទ្យាសាស្ត្រ ដែលមានប្រភពពីវិទ្យាស្ថានជាតិស្ថិតិ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងទិន្នន័យពីអង្គការអន្តរជាតិខាងការងារ ដើម្បីសិក្សាពីបម្រែបម្រួលនៃលក្ខណៈវិនិច្ឆ័យបែបសេដ្ឋកិច្ច និងសង្គម, (៤) បានបន្តសហការជាមួយអង្គការអន្តរជាតិខាងការងារ សិក្សាពីបម្រែបម្រួលលក្ខណៈវិនិច្ឆ័យទាំង**៧** ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាសម្រាប់ឆ្នាំ**២០១៧** ដោយអង្គការអន្តរជាតិខាងការងារ បានបណ្តុះបណ្តាលមន្ត្រីលេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារក្នុងនិងក្រៅប្រទេសចំនួន ២លើក, និង (៥) បានកំណត់ប្រាក់ឈ្នួលអប្បបរមាដោយជោគជ័យ នាថ្ងៃទី**២៩** ខែកញ្ញា ឆ្នាំ**២០១៦** ស្របតាមកាលវិភាគដែលត្រីភាគីបានឯកភាពដោយកំណត់យកប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ**២០១៧** ចំនួន ១៥៣ដុល្លារ/ខែ។

ដោយឡែក ពាក់ព័ន្ធនឹងការចុះអធិការកិច្ចការងារវិញ ក្រសួងបានផ្លាស់ប្តូរន្យូវបទពិសោធអំពីការធ្វើអធិការកិច្ចការងារ ការដោះស្រាយវិវាទការងារ និងការបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសនៃលេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារអំពីវិធីសាស្ត្រក្នុងការគណនាប្រាក់ឈ្នួលអប្បបរមា, បានធ្វើការចុះអង្កេតស្ថានភាពជីវភាពរបស់កម្មករ និយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង, និងចុះធ្វើអធិការកិច្ចការងារដើម្បីត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌទូទៅនៃការងារនៅតាមរោងចក្រ សហគ្រាស ជាពិសេស នៅតាមសិប្បកម្មឡវ៉ដ្ត និងការងារពលកម្មកុមារ ព្រមទាំងការងារត្រួតពិនិត្យលើការអនុវត្តប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ។

ក្នុងគោលបំណងលើកកម្ពស់ផលិតភាពការងារ និងសុខុមាលភាពកម្មករនិយោជិត គណៈកម្មការប្រឹក្សាការងារ បានសម្រេចឱ្យមានការបន្តផ្តល់ជូនន្យូវអត្ថប្រយោជន៍ផ្សេងៗដល់កម្មករនិយោជិត ដែលក្នុងនោះរួមមាន ប្រាក់រង្វាន់ការងារទៀងទាត់ចំនួន ១០ដុល្លារ/ខែ សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន **៧** ដុល្លារ/ខែ និងប្រាក់រង្វាន់អតីតភាពការងារពី ២ដុល្លារ ទៅ ១១ដុល្លារ/ខែ។ ទន្ទឹមនឹងនេះ ដោយមានសំណូមពររួមពីភាគីសហជីព និងនិយោជកក្នុងក្របខ័ណ្ឌគណៈកម្មាធិការប្រឹក្សាការងារ រាជរដ្ឋាភិបាលបានដាក់ចេញន្យូវគោលនយោបាយមួយចំនួន ដូចជា ការអនុគ្រោះពន្ធលើប្រាក់អត្ថប្រយោជន៍ដោយមិនរាប់បញ្ចូលទៅក្នុងមូលដ្ឋានគិតពន្ធលើប្រាក់ខែ, ការតបណ្តាញទឹកស្អាត និងអគ្គិសនីដល់បន្ទប់ជួលរបស់កម្មករ និយោជិត បានជា

ច្រើនបន្ទប់នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ, កម្រិតប្រាក់បៀវត្សជាប់ពន្ធត្រូវបានដំឡើងដល់ ១ 000 000 រៀលនៅឆ្នាំ២០១៧ ដែលអាចកាត់បន្ថយចំណាយបង់ពន្ធរបស់កម្មករនិយោជិតដែលមានប្រាក់ចំណូលទាបជាង ១ 000 000រៀលប្រមាណ ២,៥ដុល្លារក្នុង១ខែ ធៀបនឹងឆ្នាំមុន។

លើសពីនេះ ក្រសួងក៏បានបន្តរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងនោះ ច្បាប់ស្តីពីសហជីព ត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចំណែកឯសេចក្តីព្រាងដំបូងនៃច្បាប់ស្តីពីតុលាការការងារ ក៏ត្រូវបានដាក់ជូនក្រសួងយុត្តិធម៌ និងអង្គការអន្តរជាតិខាងការងារ ដើម្បីពិនិត្យ និងផ្តល់យោបល់។ បន្ថែមពីនេះ ក្រសួងក៏បាននិងកំពុងរៀបចំគណៈកម្មការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ ដើម្បីពិនិត្យឡើងវិញនូវច្បាប់ការងារ និងការអនុវត្តកន្លងមក រួមទាំងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការអនុវត្តក្របខ័ណ្ឌគុណវុធិជាតិកម្ពុជា សម្រាប់វិស័យអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជាពិសេសទៅទៀតនោះ ក្រសួងបានរៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ដែលត្រូវបានអនុម័តកាលពីខែកញ្ញា ឆ្នាំ២០១៥ ព្រមទាំងត្រូវបានប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តកាលពីខែតុលា ឆ្នាំ២០១៥ កន្លងទៅ។ បច្ចុប្បន្ន យន្តការអនុវត្តផែនការសកម្មភាព និងគោលនយោបាយនេះ កំពុងត្រូវបានរៀបចំ។

ក្រៅពីនេះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានអនុវត្តសកម្មភាពគួរឱ្យកត់សម្គាល់មួយចំនួនទៀត ដូចជា បានរៀបចំសិក្ខាសាលាកសាងសមត្ថភាពជាច្រើនដល់មន្ត្រីពាក់ព័ន្ធ ដើម្បីជំរុញការដោះស្រាយបញ្ហារបស់កម្មករស្របទៅតាមច្បាប់ការងារ និងបទប្បញ្ញត្តិជាធរមាន, បានកសាងទិន្នន័យស្តីពីរោងចក្រ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត តាមបែបព័ត៌មានវិទ្យា, បានបង្កើតមជ្ឈមណ្ឌលការងារថ្មីចំនួន ២ (ខេត្តបន្ទាយ-មានជ័យ និងព្រះសីហនុ), រៀបចំពិព័រណ៍ថ្នាក់ជាតិ/ខេត្ត ពិព័រណ៍ចល័ត និងវេទិកាការងារ, និងប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្ម ចំនួន ៦២ ៤២០កន្លែង, បានផ្តល់ព័ត៌មានអំពីទីផ្សារពលកម្មកាន់តែទូលំទូលាយ និងបានចាត់វិធានការពាក់ព័ន្ធសម្រាប់ធានាដល់ការបញ្ជូនពលករទៅធ្វើការនៅបរទេសដោយស្របច្បាប់ ចៀសវាងការឆបោក និងកេងប្រវ័ញ្ច។ ជាមួយគ្នានេះដែរ ក្រសួងបានចេញប្រកាសលេខ៤៦៣ ក.ប/ប្រក ស្តីពីទីភ្នាក់ងារឯកជនផ្តល់សេវាកការងារឱ្យធ្វើក្នុងស្រុក ព្រមទាំងបានរៀបចំផែនការសកម្មភាព ៣ឆ្នាំ របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដែលស្របតាមគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ។

២.២ រដ្ឋបាលខេត្តស្វាយរៀង

រដ្ឋបាលខេត្តស្វាយរៀង បានចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់កម្មករ និយោជិត ពាក់ព័ន្ធនឹងច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ កិច្ចសង្គ្រោះបឋម ការគ្រប់គ្រងសារធាតុគីមីក្នុងរោងចក្រ សហគ្រាស អំពីអាហារូបត្ថម្ភ និងបំណិនជីវិត សរុបចំនួន ២០វគ្គ មានអ្នកចូលរួមសរុប ៤ផ្លូវនាក់ ក្នុងនោះ ស្រី ២៧ពាន់នាក់, ព្រមទាំងបានសហការពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មាន

ទីផ្សារពលកម្មនិងបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាព និងសិទ្ធិស្របច្បាប់របស់ខ្លួន។ ម្យ៉ាងវិញទៀត កន្លងមក រដ្ឋបាលខេត្តស្វាយរៀង បានចុះធ្វើអធិការកិច្ចចំនួន ៤៥លើក នៅតាមសហគ្រាសចំនួន ៤៥ ក្នុងនោះអធិការកិច្ចការងារសាមញ្ញ ២៨លើក និងអធិការកិច្ចការងារពិសេស ១៧លើក។ លើសពីនេះ រដ្ឋបាលខេត្តក៏បានចុះដោះស្រាយវិវាទ ដូចជា វិវាទបុគ្គលមាន ១៨ករណី ក្នុងនោះសះជា ១១ករណី និងមិនសះជា ៧ករណី លើសហគ្រាសគ្រឹះស្ថានចំនួន ១៤, ព្រមទាំងវិវាទការងារចំនួន ៩ករណី ក្នុងនោះសះជា ៦ករណី និងមិនសះជា ៣ករណី លើសហគ្រាសគ្រឹះស្ថានចំនួន ៩ ដែលមានកម្មករនិយោជិតចូលរួមចំនួន ៥ ៨៤៣នាក់។

គិតត្រឹមបំណាច់ឆ្នាំ២០១៦ ខេត្តស្វាយរៀងមាន (១) រោងចក្រ សហគ្រាស គ្រឹះស្ថានសរុបចំនួន ១៥៥ ដែលបាននិងកំពុងដំណើរការសកម្មភាព មានកម្មករនិយោជិតសរុប ៥៧ ១៣៧នាក់ ស្រី ៣៨ ១០៤នាក់ ក្នុងនោះកម្មករនិយោជិតខ្មែរមានចំនួន ៥៥ ១៦៦នាក់ ស្រី ៦១៣នាក់, (២) គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកជនសរុបចំនួន ៧គ្រឹះស្ថាន និងវិទ្យាស្ថានពហុបច្ចេកទេសតេជោសែនភូមិភាគស្វាយរៀង ១កន្លែង ដែលគ្រឹះស្ថានទាំងនេះ ក្នុងឆ្នាំ២០១៦កន្លងទៅ បានបណ្តុះបណ្តាលធនធានមនុស្សចំនួន ១ ៦៧៦នាក់ ស្រី ៦១៣ នាក់, និង (៣) គ្រឹះស្ថានហ្វឹកហ្វឺនកូនជាងចំនួន ៤២កន្លែង ដែលមានកូនជាងសរុបចំនួន ២ ៣៨២នាក់ ស្រី ១ ៥៤៦នាក់។

២.៣.៤ ការសម្រួបសម្រួលគោលនយោបាយគាំទ្រ

ក. ការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស

ក្នុងចំណោមវិធានការគោលនយោបាយទាំង១៣ ពាក់ព័ន្ធទៅនឹង "ការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើនដូចខាងក្រោម÷

ក.១. ក្រសួងអប់រំ យុវជន និងកីឬា

នៅក្នុងឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឬា បានរៀបចំគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី និងបានដាក់ឱ្យដំណើរការសាលារៀនជំនាន់ថ្មីនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ ដោយរៀបចំឱ្យមានបន្ទប់ពិសោធន៍តាមមុខវិជ្ជា បន្ទប់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់សាស្ត្រាចារ្យ និងបណ្ណាល័យ។ ទន្ទឹមនឹងនេះ ក្រសួងបានអនុម័ត និងផ្សព្វផ្សាយក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស, បានអនុម័តនិងដាក់ឱ្យអនុវត្តបញ្ញត្តិធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា, បានអនុម័តស្តង់ដាគ្រឹះស្ថានបណ្តុះ-បណ្តាលគ្រូ, កំពុងរៀបចំស្តង់ដាគ្រូបង្រៀន និងបានពិភាក្សាលើឯកសារទស្សនទានស្តីពីគន្លងអាជីព។

លើសពីនេះទៅទៀត ក្រសួងក៏បានអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសនៅសាលាគរុកោសល្យផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ និងកម្មសិក្សាគរុកោសល្យ និងកែលម្អកម្មវិធីសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារលើជំនាញ មេកានិក អគ្គិសនី អេឡិចត្រូនិក ក្សេត្រសាស្ត្រ និងបសុវប្បកម្ម សំដៅពង្រឹងសមត្ថភាពមូលដ្ឋានចំណេះដឹងរបស់កុមារ និងយុវជន លើផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងបច្ចេកវិទ្យា និងអភ្នើនការបណ្តុះ-

បណ្តាលបច្ចេកទេសបន្ថែមទៀតដល់យុវជន។ ជាមួយគ្នានេះ ក្រសួងក៏បានសហការជាមួយបណ្តាប្រទេស និងដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា សាធារណរដ្ឋប្រជាមានិតចិន, ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋកូរ៉េ, ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ក្នុងទិសដៅពង្រឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដោយផ្តោតលើការពង្រឹងមូលដ្ឋានចំណេះដឹងរបស់កុមារ និងយុវជន លើផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងបច្ចេកវិទ្យា។

ក.២ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធសម្រាប់ជំរុញការបណ្តុះបណ្តាលធនធានមនុស្ស មានដូចជា (១) សេចក្តីព្រាងទី១ នៃគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ, (២) ច្បាប់ស្តីពីប្រាក់ពន្ធសម្រាប់ការអភិវឌ្ឍជំនាញ ដែលជាផ្នែកមួយពាក់ព័ន្ធទៅនឹងការជំរុញស្ថាប័ននីយកម្មនូវកម្មវិធីប្រព័ន្ធកម្មសិក្សា (Apprenticeship Schemes), (៣) ប្រកាសស្តីពីការវាយតម្លៃសមត្ថភាព និងការផ្តល់គុណវុធិ ដើម្បីចូលរួមបង្កើតឱកាសទីពីរ សម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា, និង (៤) ផែនការសកម្មភាពសម្រាប់សិក្សាលទ្ធភាពពីមូល-និធិបណ្តុះបណ្តាល។ ពាក់ព័ន្ធនឹងការងារទាំងនេះ ក្រសួងបានអភិវឌ្ឍមុខរបរចំនួន ២១ សម្រាប់សិស្សដែលបោះបង់ចោលការសិក្សាមុនបញ្ចប់ថ្នាក់ទី៩ ពាក់ព័ន្ធនឹងវិស័យធុរកិច្ចនិងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន, សំណង់, និងមេកានិក ជាដើម, ថែមទាំងបានអភិវឌ្ឍកម្មវិធីសិក្សាជំនាញទន់ និងសហគ្រិនភាព ដោយបានចងក្រងមេរៀនស្តីពីជំនាញទន់ ដល់សិស្ស និស្សិត យុវជន និងអ្នកស្វែងរកការងារ។

ទន្ទឹមនឹងកិច្ចការខាងលើ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្តសកម្មភាពជាច្រើនទៀតដូចជា (១) ប៉ាន់ប្រមាណការយល់ដឹងនូវសមត្ថភាពជំនាញ និងចំណេះដឹងអំពីជំនាញទន់នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ, (២) បានចុះផ្សព្វផ្សាយតម្រង់ទិសវិជ្ជាជីវៈដល់សិស្សមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា ២០១៥-២០១៦ នៅទូទាំងរាជធានីភ្នំពេញ, (៣) កំពុងរៀបចំចងក្រងសៀវភៅណែនាំពីគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំង៣៩, (៤) បានរៀបចំសិក្ខាសាលាស្តីពីមគ្គុទ្ទេសក៍អាជីព និងការងារ នៅតាមវិទ្យាល័យ សាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលវិជ្ជា-ជីវៈ, និង (៥) បានជំរុញ និងលើកទឹកចិត្តការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងវិក្រឹតការជំនាញជាប្រចាំ ដើម្បីឆ្លើយតបទៅតាមការរីកចម្រើនរបស់បច្ចេកវិទ្យា សំដៅពង្រីកការបណ្តុះបណ្តាលជំនាញនៅនឹងកន្លែង។ លើសពីនេះ រដ្ឋាភិបាលចិនបាននិងកំពុងជួយសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមួយកន្លែងនៅតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ (បន្ថែមលើគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលមានស្រាប់ចំនួន ៨២គ្រឹះស្ថាន)។ ជាងនេះទៅទៀត ក្រសួងក៏បានពង្រឹង និងពង្រីកគ្រឹះស្ថានអប់រំ

បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលនូវកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ២ ៣ និងសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេសលើកម្មវិធីបណ្តុះបណ្តាលផ្នែកលើសមត្ថភាព។

ក.៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការរួមគ្នាជាមួយសមាគមបច្ចេកវិទ្យា និងវិទ្យាសាស្ត្រអាហារកម្ពុជា ដែលមាន ២០ក្រុមហ៊ុន ដើម្បីធ្វើសិក្ខាសាលាបណ្តុះបណ្តាល និងរៀបចំដំណើរទស្សនកិច្ចសិក្សាជូនសមាជិកសមាគម មន្ត្រីសាស្ត្រាចារ្យ និងនិស្សិត ព្រមទាំងបានរៀបចំវេទិកាសាកលវិទ្យាល័យ-វិស័យឯកជន ដើម្បីស្វែងយល់អំពីស្ថានភាពចំណុចខ្វះខាតនៃនិស្សិតដែលបញ្ចប់ការសិក្សា តម្រូវការបុគ្គលិកនាពេលអនាគត និងឱកាសសហការរវាងក្រសួង និងវិស័យឯកជន ដើម្បីផ្តល់ឱកាសហាត់ការ និងការស្រាវជ្រាវដើម្បីអភិវឌ្ឍ។ លើសពីនេះ ក្រសួងក៏បានបញ្ជូននិស្សិតជំនាញកសិ-ឧស្សាហកម្មចំនួន ៤រូប និងសាស្ត្រាចារ្យ ១រូប ចូលរួមវេទិកាប្រកួតប្រជែងចំណេះដឹងផ្នែកកសិ-ឧស្សាហកម្មនៅប្រទេសហ្ស៊ីលីពីន។

ក.៤ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិសង្គមកិច្ច ក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ វិទ្យាស្ថាននេះមានមហាវិទ្យាល័យចំនួន២គឺ មហាវិទ្យាល័យសង្គមកិច្ច និងមហាវិទ្យាល័យវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប និងនៅក្នុងឆ្នាំ២០១៦ មាននិស្សិតបាននិងកំពុងសិក្សាចំនួន ៤៣៣ នាក់ និងបានបញ្ចប់ការសិក្សាចំនួន ៣៣នាក់ ក្នុងនោះមាននិស្សិតបរទេសចំនួន ៧នាក់។ នេះជាវិទ្យាស្ថានតែមួយគត់ដែលបម្រើលើវិស័យសង្គមកិច្ច ស្តារលទ្ធភាពពលកម្មកាយសម្បទាសម្រាប់ជនពិការ អាចដោះស្រាយឧបសគ្គក្នុងសង្គម បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា បង្កើនគុណវុធ្ឍិវិជ្ជាជីវៈ ព្រមទាំងអាចឱ្យជនងាយរងគ្រោះ បានចូលរួមយ៉ាងពេញលេញរាល់សកម្មភាពសង្គមដោយស្មើភាព ស្មើសិទ្ធិ និងថ្លៃថ្នូ។

ជាមួយគ្នានេះដែរក្រសួង បានសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានរៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ចំនួន ១៩ ជូនជនពិការ នៅក្នុងឆ្នាំ២០១៦, បានផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសរុបចំនួន ១៦ ៩៣១ នាក់។ ជំនាញទាំងនេះរួមមានជួសជុលគ្រឿងអេឡិចត្រូនិក, ជួសជុលកុំព្យូទ័រ, កសិកម្ម, ជាងដែក, ជួសជុលទូរស័ព្ទ, កាត់ដេរ, សំអាងការ, ជួសជុលគ្រឿងម៉ាស៊ីន, គំនូរ, ក្បាច់, ចម្លាក់។ល។

ក.៥ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ អ៊ីនធើណែត និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ចំនួន ១០ក្រុមហ៊ុន ដើម្បីកាត់ប្រាក់ប្រើ

អភិវឌ្ឍកម្មវិធីសិក្សាឱ្យត្រូវតាមទីផ្សារបច្ចុប្បន្ន និងបានបំពាក់ឧបករណ៍បច្ចេកវិទ្យាថ្មីៗដូចជាយន្តហោះគ្មានអ្នកបើកបរ (Drone) និងទូរស័ព្ទឆ្លាតវៃសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍។

ខ- ការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ក្នុងចំណោមវិធានការគោលនយោបាយទាំង១០ ដែលពាក់ព័ន្ធទៅនឹង "ការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម÷

ខ.១- ក្រសួងផែនការ

ក្រសួងផែនការ បានកសាងផែនការមេជាតិស្តីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ឆ្នាំ២០១៤-២០២០ ក្រោមជំនួយរបស់សាធារណរដ្ឋកូរ៉េ ដែលមានគោលបំណងសំខាន់៤គឺ បង្កើតមូលដ្ឋានសម្រាប់ជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ពង្រឹងសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ បង្កើតបរិយាកាសវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងពង្រឹងសមត្ថភាពឧស្សាហកម្មស្នូល។ ជាមួយគ្នានេះ ក្រសួងបានបង្កើតក្របខ័ណ្ឌគតិយុត្ត និងកសាងយន្តការស្ថាប័នជាមូលដ្ឋាន។ ក្រសួងក៏បានរាយការណ៍ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា អំពីលទ្ធផលនៃកិច្ចប្រជុំក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាលើកទី១ និងទទួលបានការអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់លើចំណុចជាយុទ្ធសាស្ត្របី (១) កំណត់យកបច្ចេកវិទ្យាអាទិភាពជាតិ៦ សម្រាប់ឆ្នាំ២០១៧-២០២០, (២) បង្កើនការវិនិយោគរបស់រដ្ឋលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ និង (៣) ផ្តល់អាទិភាពក្នុងការទទួលជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ បច្ចុប្បន្ន ក្រសួងបាននិងកំពុងរៀបចំគោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០១៧-២០២៥។

លើសពីនេះទៅទៀត ក្រសួងផែនការ បានចូលរួមចំណែកធ្វើឱ្យបរិយាកាសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅកម្ពុជាកាន់តែប្រសើរ ដែលសកម្មភាពទាំងនោះរួមមាន បង្កើតគេហទំព័រដើម្បីផ្តល់ព័ត៌មានអំពីការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, សហការជាមួយភាគីកូរ៉េក្នុងការកសាងផែនការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មាននៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ជាតិ, ចូលរួម និងផ្សព្វផ្សាយពីសារៈសំខាន់នៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច និងគុណភាពជីវិតឱ្យកាន់តែប្រសើរឡើងនៅក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលានិងព្រឹត្តិការណ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដទៃទៀត, និងបង្កើតព្រឹត្តិបត្រព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

ខ.២- ក្រសួងអប់រំ យុវជន និងកីឬា

ក្រសួងអប់រំ យុវជន និងកីឬា បានអនុម័តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា និងបានផ្សព្វផ្សាយដល់អង្គភាពពាក់ព័ន្ធនានា ដើម្បីអនុវត្ត, បំប៉នគ្រូ និងរៀបចំមុខវិជ្ជា និងសៀវភៅគោលដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាពិសេសបានផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ និងនវានុវត្តន៍ នៅតាមគ្រឹះស្ថានឧត្តមសិក្សា, និងបានបង្កើតមណ្ឌលអ្នក

ស្រាវជ្រាវ និងស្គង់ជាស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ទន្ទឹមគ្នានេះ ក្រសួងបានលើកកម្ពស់ការបណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ព្រមទាំងបានពង្រឹង និងពង្រីកការអប់រំបច្ចេកទេសនៅថ្នាក់មធ្យមសិក្សា។

ខ.៣ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកបច្ចេកវិទ្យា (NCOST) ស្តីពីការធ្វើផែនការ និងលើកទិសដៅតាមវិស័យ ដើម្បីអនុវត្តផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (APASTI 2016-2025)។ ក្នុងការជំរុញការសិក្សាស្រាវជ្រាវ និងលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានចូលរួមកិច្ចសហប្រតិបត្តិការជាមួយអន្តរក្រសួង និងបណ្តាដៃគូអន្តរជាតិលើការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថានឧស្សាហកម្ម ដូចជា ជីវៈបច្ចេកវិទ្យា (Biotechnology) ណាណូបច្ចេក-វិទ្យា (Nanotechnology) ការអភិវឌ្ឍកាបូនកម្រិតទាបសម្រាប់ផលិតភាព និងការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ តាមរយៈការផ្ទេរវិធីសាស្ត្របច្ចេកវិទ្យាត្រឹមត្រូវដែលស្របតាមបទដ្ឋានបរិស្ថាន បរិស្ថានឧស្សាហកម្ម និងការជំរុញការគ្រប់គ្រងសុវត្ថិភាពនៅកម្ពុជា។ ក្នុងកិច្ចការនេះផងដែរ ក្រសួងបានរៀបចំជំនួយបច្ចេកទេសផ្នែកសុវត្ថិភាព និងបរិស្ថានឧស្សាហកម្មដល់វិស័យឯកជន ព្រមទាំងបានចុះអនុស្សរណៈយោគយល់គ្នាអំពីវិទ្យាសាស្ត្របរិស្ថាន និងវិទ្យាសាស្ត្រទឹក ជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រនៃសាធារណរដ្ឋប្រជាមានិតចិន។

ក្នុងការពិនិត្យឡើងវិញ និងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានរៀបចំលើកគម្រោងថវិកាតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់អនុវត្តផែនការសកម្មភាពឆ្នាំ២០១៧ និងឆ្នាំបន្តបន្ទាប់ ដើម្បីសិក្សាលើកិច្ចការខាងលើនេះ។

ខ.៤ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ជាតិលើកទី៥ ឆ្នាំ២០១៥, ការប្រកួតប្រជែងរ៉ូបូត ដែលសហការរៀបចំរួមគ្នាដោយទូរទស្សន៍ជាតិកម្ពុជា និងក្រុមហ៊ុនតូយ៉ូតា ដោយមានបេក្ខជនមកពីគ្រឹះស្ថានបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ចូលរួម និងការប្រកួតប្រជែងជំនាញ Industrial Automation ដោយមានបេក្ខជន ៧ក្រុម តំណាងឱ្យ ៦ប្រទេស ក្នុងនោះបេក្ខជនតំណាងឱ្យប្រទេសកម្ពុជាទទួលបានមេដាយមាស។ ម្យ៉ាងវិញទៀត ក្រសួងបានបញ្ជូនបេក្ខជន ១៣នាក់ ទៅចូលរួមប្រកួតប្រជែងជំនាញថ្នាក់អាស៊ានលើកទី៩ នៅប្រទេសអាស៊ានលើមុខជំនាញចំនួន ៣ ដែលរួមមាន ស្វយកម្ម ឧស្សាហកម្ម (Industrial Automation), សេវាកម្មភោជនីយដ្ឋាន, និងជំនាញតបណ្តាញអ៊ីស្រាអ៊ីត ដោយសុទ្ធតែទទួលបានលទ្ធផលល្អ។ ដែលជាយន្តការមួយនៃការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា អ្នកមាន

គំនិតផ្តួចផ្តើមធុរកិច្ច និងវិស្វករដែលមានទេពកោសល្យ។ លើសពីនេះ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ដែលស្ថិតនៅក្រោមក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងប្រែក្លាយទៅជាសាកលវិទ្យាល័យជាតិពហុបច្ចេកទេសកម្ពុជា ដើម្បីពង្រីកវិសាលភាពការសិក្សាស្រាវជ្រាវ ក៏ដូចជាការអភិវឌ្ឍធនធានមនុស្ស ដើម្បីបម្រើឱ្យវិស័យឧស្សាហកម្ម។

ខ.៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រសរុប ៨០អត្ថបទ និងធ្វើបទបង្ហាញផ្ទាល់នៅក្នុងសន្និសីទវិទ្យាសាស្ត្រថ្នាក់ជាតិលើកទី២ ស្តីពីកសិកម្មនិងអភិវឌ្ឍន៍ជនបទ ដែលអត្ថបទស្រាវជ្រាវនេះជាធាតុចូលសម្រាប់ការសិក្សាបន្ត ដើម្បីសិក្សាគោលនយោបាយជំរុញការអភិវឌ្ឍកសិកម្ម និងកសិ-ឧស្សាហកម្ម។

ខ.៦ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានចូលរួមជាសមាជិកនៃការរៀបចំគោលការណ៍អភិវឌ្ឍន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

ខ.៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល, បានចូលរួមរៀបចំនិងផ្តល់យោបល់លើអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់គ្រឹះស្ថានចំនួន ១០/៣០, ជំរុញគ្រឹះស្ថានសាធារណៈរដ្ឋបាលឱ្យរៀបចំអនុក្រឹត្យថ្មីស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល, ព្រមទាំងបានពិនិត្យ និងស្រាវជ្រាវច្បាប់ចាស់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសហគ្រាសសាធារណៈ។

គ. ការកសាងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ឧស្សាហកម្ម

ក្នុងចំណោមវិធានការទាំង១២ ពាក់ព័ន្ធនឹង "ការកសាងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ឧស្សាហកម្ម" ក្រសួង ស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើនដូចខាងក្រោម÷

គ.១ ក្រសួងសាធារណការនិងដឹកជញ្ជូន

ក្នុងវិស័យដឹកជញ្ជូនខាងផ្លូវគោក ក្រសួងសាធារណការនិងដឹកជញ្ជូន បានធ្វើការពង្រីក ថែទាំ ស្តារ និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវនិងស្ពានសំខាន់ៗដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញ ដោយបានប្រើប្រាស់កញ្ចប់ថវិកាជាតិ និងជំនួយរបស់ប្រទេសជាមិត្តដូចជា ចិន ជប៉ុន កូរ៉េ វៀតណាម និងធនាគារអភិវឌ្ឍន៍អាស៊ី។

កំណាត់ផ្លូវជាតិមួយចំនួនត្រូវបានសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការក្នុងឆ្នាំ២០១៦ រួមមាន ផ្លូវជាតិលេខ ៤៤ ប្រវែង១៣៩,១៤គ.ម. (ច្បារមន-ឌ៉ាល់-ឧត្តុង្គ), កំណាត់ផ្លូវជាតិលេខ៧៦បន្តប្រវែង១០១,៧ធ.ម.

(សែនមនោរម្យ-កោះញ្ញែក ខេត្តមណ្ឌលគីរី ដល់លំជាត់-តាអង ខេត្តរតនគីរី), និងផ្លូវជាតិលេខ៥៦ កំណាត់ទី១ ក្រាលកៅស៊ូ DBST ប្រវែង២៩គ.ម. (សីរីសោភ័ណ-ស្វាយចេក) និងកំណាត់ទី២ ប្រវែង៨៤,៤៥គ.ម. (ស្វាយចេក-សំរោង) និងផ្លូវចូលប្រាសាទបន្ទាយឆ្មារ ប្រវែង១០,៧៥គ.ម។

ក្រៅពីនេះ ការកសាង និងកែលម្អកំណាត់ផ្លូវជាតិមួយចំនួនទៀត ក៏សម្រេចបានវឌ្ឍនភាពជាហូរហែ មានដូចជា (១) គម្រោងកែលម្អផ្លូវជាតិលេខ១ ដំណាក់កាលទី៤ ប្រវែង៤គ.ម. (គល់ស្ពានព្រះមុនីវង្ស-វត្តក្ដីតាកុយ) សម្រេចបាន ៧០,១០%, (២) ផ្លូវជាតិលេខ១៣ ប្រវែង៦២,៤០គ.ម. (កំចាយមារ ខេត្តព្រៃវែង-ប្រសូត ខេត្តស្វាយរៀង) សម្រេចបាន ៣៨,៣០% និងផ្លូវខេត្តលេខ៣១៤D ប្រវែង២៥,៥០គ.ម. (ប្រសូត-ព្រៃវល្លិ ព្រំដែនកម្ពុជា-វៀតណាម) សម្រេចបាន ៤៥%, (៣) គម្រោងស្តារឡើងវិញផ្លូវជាតិលេខ២១ ប្រវែង ៥៥គ.ម. (រង្វង់មូលតាខ្មៅ-ជ្រៃធំ) សម្រេចបាន ៣៨%, (៤) កំណាត់ផ្លូវជាតិលេខ៥ ប្រវែង៣០,៣៣គ.ម. (ភ្នំពេញ-ព្រែកក្តាម) សម្រេចបាន ៩៧,២០%, (៥) ផ្លូវជាតិលេខ៥៣ ផ្លូវខេត្តលេខ១៥០B និងផ្លូវខេត្តលេខ ១៥១B ប្រវែងសរុប៨៧,៩០គ.ម. (តាជេស ខេត្តកំពង់ឆ្នាំង-អមលាំង ខេត្តកំពង់ស្ពឺ) សម្រេចបាន ៣៨,៥០%, (៦) ផ្លូវជាតិលេខ៥៥ ប្រវែង១៨២,១៦គ.ម. (ពោធិ៍សាត់-ភ្លាលវែង-ថ្មដា ព្រំប្រទល់កម្ពុជា-ថៃ) សម្រេចបាន ៦៨,៦១%, (៧) ផ្លូវជាតិលេខ៥៨ ប្រវែង ១៧៤គ.ម. (ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ-ត្រង់ផ្ទុង ខេត្តឧត្តរមានជ័យ) សម្រេចបាន ៤៨,៩៧%, (៨) ផ្លូវខេត្តលេខ១៥៧៧ ប្រវែង៥១,៧៩គ.ម. (ឃុំត្រែង ស្រុករតនមណ្ឌល-ឃុំសំឡូត ខេត្តបាត់ដំបង) សម្រេចបាន ៥២,៣៥%, (៩) កំណាត់ផ្លូវជាតិលេខ៦ ប្រវែង ២៤៧,៧០គ.ម. (ថ្នល់កែង-អង្ក្រង ខេត្តសៀមរាប) សម្រេចបាន ៩៨,១២%, (១០) គម្រោងសាងសង់ស្ពានជ្រៃធំ ប្រវែង៤២៧,៨ម៉ែត្រ និងផ្លូវតភ្ជាប់ស្ពាន ប្រវែង២,៦៦គ.ម. (ស្រុកកោះធំ ខេត្តកណ្ដាល-ឡុងបិញ ខេត្តអាងយ៉ាង) សម្រេចបាន ៨៧,២៦%, និង (១១) ស្ពានកោះធំ ប្រវែង៤១៥ម៉ែត្រ សម្រេចបាន ១០០%។

ដោយឡែក កំណាត់ផ្លូវផ្សេងៗទៀត ដែលស្ថិតក្នុងដំណាក់កាលរៀបចំ និងគ្រោងនឹងសាងសង់ រួមមាន (១) ផ្លូវជាតិលេខ១១ (អ្នកលឿង-ថ្នល់ទទឹង) បានរៀបចំស្នើសុំគម្រោងទៅម្ចាស់ជំនួយសម្រាប់ឆ្នាំ២០១៦, (២) ផ្លូវជាតិលេខ២ (ក្រុងតាខ្មៅ-ក្រុងដូនកែវ) និងផ្លូវជាតិលេខ២២ (អូរចំបក់-អង្គតាសោម) ត្រូវបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្ព្ធទាន និងកំពុងដំណើរការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស, (៣) គម្រោងលើកកម្រិតផ្លូវជាតិលេខ៣ (ចោមចៅ-ភ្លាលរេញ) ប្រវែង២០១,៧គ.ម. ក្រាលកៅស៊ូ AC បច្ចុប្បន្ន ធនាគារ EXIM ក្ងរ៉ែបានបញ្ចប់លើការសិក្សារបាយការណ៍បឋម, (៤) ផ្លូវជាតិលេខ៥១ (ឧត្តុង្គ-ថ្នល់ទទឹង) ត្រូវបានធ្វើការសិក្សា ចរចា និងចុះកិច្ចសន្យាគម្រោងរួចហើយ ដែលបានចាប់ផ្ដើមសាងសង់ក្នុងឆ្នាំ២០១៦, (៥) កំណាត់ផ្លូវជាតិលេខ៥ ប្រវែង១៣៥,៤គ.ម. (ព្រែកក្តាម-ឆ្លាមួម ខេត្តពោធិ៍សាត់) បានបញ្ចប់សិក្សារបាយ-ការណ៍លម្អិត និងកំពុងរៀបចំនីតិវិធីលើងកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនសាងសង់ ហើយបានចាប់ផ្ដើមអនុវត្តការដេញថ្លៃសាងសង់នៅចុងឆ្នាំ២០១៦, (៦) គម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ៥ ក្រាលកៅស៊ូ AC

ប្រវែង១៣៣គ.ម. (ផ្លាមួម ខេត្តពោធិ៍សាត់-បាត់ដំបង និងសិរីសោភ័ណ-ប៉ោយប៉ែត) បច្ចុប្បន្ន បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ហើយគ្រោងនឹងចាប់ផ្តើមអនុវត្តការងារសាងសង់នៅឆ្នាំ២០១៧, និង (៣) កំណាត់ផ្លូវជាតិលេខ៥ ប្រវែង៨៤,៧៤គ.ម. (បាត់ដំបង-សិរីសោភ័ណ) កំពុងបន្តរៀបចំឯកសារតាមនីតិវិធី ដើម្បីជ្រើសរើសក្រុមហ៊ុនសាងសង់ ហើយគ្រោងការសាងសង់នៅខែមករា ឆ្នាំ២០១៧ វិញ។

ទន្ទឹមគ្នានេះ ការសាងសង់ផ្លូវល្បឿនលឿនចំនួន ២ខ្សែ ក៏បាននិងកំពុងបោះជំហានទៅមុខ ក្នុងនោះ (១) ផ្លូវល្បឿនលឿន ភ្នំពេញ-បាវិត ត្រូវបានធ្វើពិធីចុះហត្ថលេខារវាងក្រសួងសាធារណការនិងដឹកជញ្ជូនជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ហើយបច្ចុប្បន្ន ក្រុមការងារផ្លូវល្បឿនលឿនរបស់ក្រសួងបានបញ្ចប់ការសិក្សាបច្ចេកទេស និងបន្តចុះប្រជុំពិគ្រោះយោបល់សាធារណៈ និងការងារដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋនៅតាមភូមិ-ឃុំនីមួយៗ ក្នុងខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តស្វាយរៀង កាលពីថ្ងៃទី១៧-២២ ខែតុលា ឆ្នាំ២០១៦ ហើយគ្រោងបញ្ចប់ការសិក្សារបាយការណ៍បឋម នៅខែមករា ឆ្នាំ២០១៧, និង (២) ផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ កំពុងចរចាលើកិច្ចសន្យាសម្បទានដែលនឹងវិនិយោគដោយក្រុមហ៊ុនមកពីសាធារណរដ្ឋប្រជាមានិតចិន ហើយគ្រោងចាប់ផ្តើមដំណើរការគម្រោងនៅចុងឆ្នាំ២០១៧នេះ។ ចំពោះវឌ្ឍនភាពនៃការកសាងផ្លូវក្រវាត់ក្រុងវិញ ក្នុងនោះ (១) ផ្លូវក្រវាត់រាជធានីភ្នំពេញទី២ (ទឹកថ្លា-វេងស្រេង-ព្រែកហ្វូ) ត្រូវបានធ្វើការសិក្សា ចរចា និងចុះកិច្ចសន្យាគម្រោងរួចហើយ ដែលគ្រោងនឹងចាប់ផ្តើមសាងសង់ក្នុងឆ្នាំ២០១៦, និង (២) ផ្លូវក្រវាត់រាជធានីភ្នំពេញទី៣ (ព្រែកញ្ជ-ទំនប់កប់ស្រូវ-អូរដីម-ទួលក្រសាំង-សិតត្ស-បន្ទាយដែក) កំពុងធ្វើការចរចា និងបានប្រជុំដើម្បីបង្ហាញ និងពិនិត្យអំពីគម្រោងនៃការសិក្សាបឋម។

ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក ក្រសួងសាធារណការនិងដឹកជញ្ជូន បាននិងកំពុងបន្តរៀបចំច្បាប់ពាក់ព័ន្ធនឹងការងារកំពង់ផែ ដើម្បីជំរុញអនុវត្តជាបន្តបន្ទាប់នូវគោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ, សេចក្តីព្រាងប្រកាសស្តីពីសន្តិសុខសហនីយកណ្ឌ ផ្តោតលើសន្តិសុខជុំវិញផែ, ព្រមទាំងកំពុងកែលម្អកំពង់ផែសំខាន់ៗមួយចំនួន។ ជាមួយគ្នានេះ គម្រោងអភិវឌ្ឍន៍ចំណតពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុ សម្រេចបាន ៦៨,១៥% និងគម្រោងសាងសង់ចំណតផែកុងតឺន័រថ្មី គឺបានកំពុងដំណើរការស្នើសុំប្រាក់កម្ចីសម្បទានពីជប៉ុន។ ចំពោះការពង្រឹងសមត្ថភាពទីលានកុងតឺន័រ ៤០០ម៉ែត្រ ដោយបំពាក់បន្ថែមនូវគ្រឿងចក្រលើកដាក់កុងតឺន័រ QC ២គ្រឿង និង RTG ៩គ្រឿង នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ បច្ចុប្បន្ននេះកំពុងដំណើរការសាងសង់ និងធ្វើលទ្ធកម្ម។ លើសពីនេះ កំពង់ផែស្វយ័តភ្នំពេញបានពង្រីកសមត្ថភាពទីលានរបស់ចំណតផែកុងតឺន័រថ្មី (ជំហានទី២) ដោយធ្វើផ្លូវតភ្ជាប់ពីទីលានបច្ចុប្បន្នរបស់ចំណតលើកម្ពស់ ភ្ជាប់ទៅទីលានដែលគ្រោងផ្តើមសម្រាប់ជំហានទី២ រួចហើយ។

ចំពោះការអភិវឌ្ឍផ្លូវដែកវិញ ក្រសួងសាធារណការនិងដឹកជញ្ជូន បានបន្តអភិវឌ្ឍខ្សែផ្លូវដែកទិសខាងត្បូង និងទិសខាងជើង។ ការជួសជុលខ្សែផ្លូវដែកទិសខាងត្បូង សម្រេចបាន ៦២,០៧%។ ដោយឡែក ការជួសជុល និងសាងសង់ជាអាទិភាពសម្រាប់ខ្សែផ្លូវដែកទិសខាងជើង សម្រេចបានវឌ្ឍនភាពតាមកំណាត់ផ្លូវដែកនីមួយៗ ក្នុងនោះ (១) គ.ម. ២៧៣+២៥០ ដល់ គ.ម. ៣០០+០០០ សម្រេចបាន ១២,០៨%, (២) គ.ម. ៣០០+០០០ ទៅ គ.ម. ៣១០+០០០ សម្រេចបាន ៥៣%, (៣) គ.ម. ៣១០+០០០ ទៅ គ.ម. ៣២៨+៥០០ សម្រេចបាន ១១,២៦%, (៤) គ.ម. ៣២៨+០០០ ទៅ គ.ម. ៣៣៨+០០០ ពីមង្គលបុរី-សិរីសោភ័ណ សម្រេចបាន ២២,៤៨%, (៥) គ.ម. ៣៣៨+៥០០ ទៅ គ.ម. ៣៧៨+៥០០ សម្រេចបាន ២១,៧៥%, និង (៦) គ.ម. ៣៧៨+៥០០ ទៅ គ.ម. ៣៨៥+០៥០ នៅក្រុងប៉ោយប៉ែត និងផ្លូវរថភ្លើងជៀសក្នុងស្ថានីយប៉ោយប៉ែត សម្រេចបាន ៤៥,៨៦%។ ស្របគ្នានេះ ការងារជួសជុលពង្រឹងស្ពាន (គ.ម. ៣២៨+៥០០ ទៅ គ.ម. ៣៧៨+៥០០) សម្រេចបាន ១៤% ខណៈដែលការងារបំពាក់ប្រព័ន្ធសុវត្ថិភាពផ្លូវឆ្លងកាត់ផ្លូវដែកពាយ័ព្យ (គ.ម. ៣៨៤+៥៦៥ ទៅ គ.ម. ៣៨៤+៩២១) សម្រេចបាន ៥%។ ក្នុងកិច្ចការខាងលើនេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួង ត្រូវបានបង្កើតឡើង ដើម្បីពិភាក្សាលើសេចក្តីព្រាងកិច្ចព្រមព្រៀងបច្ចេកទេស និងនីតិវិធីដឹកជញ្ជូនឆ្លងកាត់ព្រំដែនតាមផ្លូវដែកកម្ពុជា-ថៃ ដោយបច្ចុប្បន្នកំពុងរៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងសាធារណការនិងដឹកជញ្ជូនរបស់កម្ពុជា និងក្រសួងដឹកជញ្ជូនរបស់ថៃ។

ค.២ ក្រសួងរ៉ែនិងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា

ក្រសួងរ៉ែនិងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា បានរៀបចំផែនការផលិតកម្មថាមពលសម្រាប់ឆ្នាំ២០១៦, ២០១៧ និង២០១៨ ក្នុងនោះរោងចក្រធ្យូងថ្មម៉ាស៊ីនទី៣ របស់រោងចក្រធ្យូងថ្ម CIIDG កំពុងដំណើរការសាកល្បង និងវារីអគ្គិសនីសេសានក្រោម២ អានុភាព ៤០០MW កំពុងសាងសង់បាន ៨០% ដែលនឹងដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ២០១៨ ដោយឡែក ម៉ាស៊ីនទី១ អានុភាព ៥០MW គ្រោងដំណើរការនៅចុងឆ្នាំ២០១៧។ ទន្ទឹមគ្នានេះ ស្ថាប័នទាំង៣ បានរៀបចំផែនការផ្ទេរខ្សែបញ្ជូនជាតិចាប់ពីចុងឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០២០ រួមមាន ខ្សែបញ្ជូន ១១៥KV គភ្ជាប់ពីភ្នំពេញ-កំពង់សិង្ហ-បាវិត, ខ្សែបញ្ជូន ២៣០KV ខេត្តកំពង់ចាម-ក្រចេះ-ស្ទឹងត្រែង, ខ្សែបញ្ជូន ១១៥KV ព្រះវិហារ-ឡាវ, ខ្សែបញ្ជូន ១១៥KV បាត់ដំបង-ប៉ៃលិន, ខ្សែបញ្ជូន ២៣០KV អនុស្ថានីយកោះកុង-ក្រុងកោះកុង, ខ្សែបញ្ជូន ២៣០KV បទុមសាគរ-ចំការលួង, ខ្សែបញ្ជូន ១១៥KV កំពង់ចាម-ព្រៃកប្រសព្ធ, ខ្សែបញ្ជូន ១១៥KV ព្រះវិហារ-កំពង់ធំ, ខ្សែបញ្ជូន ១១៥KV ក្រុងព្រះសីហនុ-ភម, ខ្សែបញ្ជូន ១១៥KV កំពង់សិង្ហ-ស្វាយអន្ទរ, ខ្សែបញ្ជូន ២៣០KV បាត់ដំបង-សៀមរាម-កំពង់ធំ-កំពង់ចាម និងបណ្តាញជាកងបន្ថែមជុំវិញរាជធានីភ្នំពេញ, ខ្សែបញ្ជូន ១១៥KV ក្រឡាញ់-ឧត្តរមានជ័យ, ខ្សែបញ្ជូន ២៣០KV រាជធានីភ្នំពេញ-ខេត្តព្រះសីហនុ តាមផ្លូវជាតិលេខ៤, ខ្សែបញ្ជូន ២៣០KV ស្ទឹងត្រែង-រតនគិរី, និងខ្សែបញ្ជូន ២៣០KV ក្រចេះ-មណ្ឌលគិរី។ បច្ចុប្បន្ន គម្រោងខ្សែបញ្ជូនមួយចំនួនខាងលើកំពុងត្រូវបានសិក្សាលើលក្ខណៈបច្ចេកទេស វាយតម្លៃ ដេញថ្លៃ ជ្រើសរើសទីប្រឹក្សា និងមួយចំនួនទៀតស្ថិតក្នុងដំណាក់ឱ្យ

ដំណើរការនាពេលឆាប់ៗខាងមុខ។ ជាមួយគ្នានេះ របាយការណ៍ស្តីពីផែនការឆ្នាំ២០១៥ ក៏ត្រូវបានបញ្ចប់ការសិក្សា និងរៀបចំ រីឯផែនការមេវិស័យថាមពលដែលមានការព្យាករតម្រូវការពីឆ្នាំ២០១៥-២០៣០ ក៏ត្រូវបានកែសម្រួលដើម្បីធ្វើបច្ចុប្បន្នកម្មផងដែរ។

ក.៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ដើម្បីដោះស្រាយបញ្ហាហិរញ្ញប្បទានសំដៅបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកែលម្អសេវា និងមធ្យោបាយដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់រយៈពេលវែង និងបានចូលរួមក្នុងដំណើរការរៀបចំ និងបង្កើតមូលនិធិវិនិយោគអាស៊ាន (ASEAN Investment Fund-AIF) និងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (Asian Infrastructure Investment Bank-AIIB)។ ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ដែលក្រសួងបានរៀបចំ ត្រូវបានអនុម័តរួចរាល់សម្រាប់ជាមូលដ្ឋានក្នុងការកៀរគរទុនវិនិយោគពីវិស័យឯកជនសម្រាប់រួមចំណែកវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

ពាក់ព័ន្ធនឹងការកែលម្អការដឹកជញ្ជូនផ្លូវគោក ក្រសួងបានអនុវត្តឥណទានថវិការដ្ឋ សម្រាប់ការងារថែទាំកំណាត់ផ្លូវជាតិសំខាន់ៗ ជាពិសេស កំពុងអនុវត្តគម្រោងពង្រីកផ្លូវជាតិលេខ១, លេខ៥, លេខ៦, និងលេខ៧ ឱ្យទៅជា៤គន្លង (តាមតំបន់) ដែលផ្តល់ហិរញ្ញប្បទានដោយភាគីចិន ជប៉ុន ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក។ លើសពីនេះ ក្រសួងបានចូលរួមសិក្សារៀបចំគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-បាវិត ដែលនឹងផ្តល់ហិរញ្ញប្បទានដោយភាគីជប៉ុន និងគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ ដែលនឹងហិរញ្ញ-ប្បទានដោយភាគីចិន ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងទាំងពីរនេះ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានចូលរួមយ៉ាងសកម្មក្នុងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ផ្សេងៗទៀត ព្រមទាំងការដោះស្រាយផលប៉ះពាល់នៃគម្រោងទាំងនោះ។

ក.៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានជំរុញឱ្យអ្នកអភិវឌ្ឍតំបន់ ធ្វើការអភិវឌ្ឍ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសរបស់ខ្លួននីមួយៗឱ្យកាន់តែល្អប្រសើរឡើងស្របទៅតាមផែនការមេ និងតម្រូវការជាក់ស្តែងនៃសកម្មភាពវិនិយោគនៅក្នុងតំបន់ទាំងនោះ និងកំពុងសិក្សាបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស នូវបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធ និងពិចារណាកំណត់តំបន់ឧស្សាហកម្ម/តំបន់សេដ្ឋកិច្ចពិសេស ឱ្យស្របទៅនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ក្នុងគោលបំណងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធដែលមាននៅពេលបច្ចុប្បន្ន និងពេលអនាគត។

គ.៥ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន។ ក្នុងឆ្នាំ២០១៦ ការផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន បានចំនួន ២៨១ ៩២៥ ៦៥៦ ម៉ែត្រគូប មានកំណើនស្មើនឹង ២៨% បើប្រៀបធៀបនឹងឆ្នាំ២០១៥។

គ.៦ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានជំរុញប្រតិបត្តិការទូរគមនាគមន៍ឱ្យពង្រីង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មជាពិសេសនៅខេត្តស្វាយរៀង និងខេត្តព្រះសីហនុ។

គ.៧ រដ្ឋបាលខេត្តស្វាយរៀង

រដ្ឋបាលខេត្តស្វាយរៀង បាននិងកំពុងសហការជំរុញការអនុវត្តគម្រោងថ្នាក់ជាតិ ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥KV ឱ្យសម្រេចបានទាន់ពេលវេលាតាមផែនការដែលបានកំណត់ ព្រមទាំងកំពុងរៀបចំផែនការវិនិយោគ ផែនការសាងសង់ និងពង្រីកបណ្តាញអគ្គិសនី ដែលអាចមានលទ្ធភាពផលិត និងផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យបានកាន់តែទូលំទូលាយ។ ក្នុងវិស័យថាមពលនេះផងដែរ រដ្ឋបាលខេត្តក៏បានចូលរួមសហការក្នុងគម្រោងពង្រីកបណ្តាញចែកចាយសម្រាប់ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន អគ្គិសនីកម្ពុជា និងអាជ្ញាធរដែនដីស្រុកស្វាយទាប និងក្រុងបាវិត ដោយប្រើគម្រោងបណ្តាញចែកចាយ ២២KV តាមផ្លូវជាតិលេខ១ ប្រវែង៣៧,៥០គ.ម. ដែលចេញពីអនុស្ថានីយច្រកម្ទេស ឆ្ពោះទៅទីតាំងចំនួន២ គឺទីតាំងទី១ ចេញទៅអង្គភាពអគ្គិសនីខេត្តស្វាយរៀងប្រវែង ២៦,៥គ.ម. និងទី២ ចេញទៅតំបន់សេដ្ឋកិច្ចពិសេសមេនហាធេន មានប្រវែង១១គ.ម. ប្រើបង្គោលសរុប ៥៩០បង្គោល, ព្រមទាំងបានចូលរួមពិគ្រោះយោបល់លើការកែសម្រួលតម្លៃអគ្គិសនីនៅស្រុកស្វាយជ្រំចំនួន ៣តំបន់ ដែលទទួលប្រភពអគ្គិសនីពីប្រទេសវៀតណាមក្នុងតម្លៃ ៩៥០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។

ទន្ទឹមគ្នានោះ រដ្ឋបាលខេត្តក៏បានសហការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀត ដូចជា (១) គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ក្រុងបាវិត ដូចជាសាងសង់ផ្លូវក្រុង ប្រព័ន្ធលូ អាងចម្រោះកាកសំណល់ និងទីលាន កែច្នៃសំរាម សម្រាប់គម្រោងរបៀងសេដ្ឋកិច្ចភាគខាងត្បូង, (២) គម្រោងស្ថាបនាលូមេរ៉ដោះទឹកនៅក្រុងស្វាយរៀង ដែលបានបញ្ចប់នៅឆ្នាំ២០១៦, (៣) គម្រោងអាងចម្រោះទឹកកាកសំណល់សម្រាប់អនុវត្តឆ្នាំ២០១៧, និង (៤) គម្រោងពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត នៅក្នុងតំបន់ទីប្រជុំជនតំបន់ជាយក្រុង តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មក្នុងខេត្តស្វាយរៀង ជាដើម។ ជាមួយគ្នានេះផងដែរ រដ្ឋបាលខេត្ត បាននិងកំពុងសហការសិក្សាផ្លូវរៀងសម្រាប់រថយន្តដឹកជញ្ជូនធុនធ្ងន់នៅក្រុងបាវិត និងសិក្សាផែនការអភិវឌ្ឍន៍ផ្លូវលៀនលឿន ភ្នំពេញ-បាវិត ព្រមទាំងកំពុងអនុវត្តគម្រោងជួសជុលផ្លូវជាតិលេខ

១៣ ពីកំចាយមារ ខេត្តព្រៃវែង ទៅក្រុងស្វាយរៀង តភ្ជាប់ផ្លូវជាតិលេខ១ និងផ្លូវជាតិលេខ៨ ប្រវែង៦២គ.ម. និងផ្លូវជាតិលេខ១៨ ពីផ្លូវជាតិលេខ១ ត្រង់ចំណុចផ្សារប្រស្ងូត ស្រុកស្វាយទាប ទៅច្រកទ្វារអន្តរជាតិព្រៃវល្លិ៍ ព្រំដែនកម្ពុជា-វៀតណាម ប្រវែង២៦គ.ម.។

ค.៨ រដ្ឋបាលរាជធានីភ្នំពេញ

រដ្ឋបាលរាជធានីភ្នំពេញ ដែលមានមន្ទីរសាធារណការ និងដឹកជញ្ជូនជាសេនាធិការ បានដាក់ចេញនូវសកម្មភាព និងទិសដៅអនុវត្តការងារនាឆ្នាំ២០១៦ រួមមាន (១) ស្ថាបនាកំណាត់ផ្លូវលេខ១០១៩ (ផ្លូវក្រវ៉ាត់ក្រុងទី២) ចាប់ពីទំនប់កប់ស្រូវដល់មហាវិថីសហព័ន្ធរុស្ស៊ីប្រវែង១០,១២០ម, (២) ស្ថាបនាពង្រីកផ្លូវទំនប់កប់ស្រូវ (ផ្លូវក្រវ៉ាត់ក្រុងទី៣) ដល់ផ្លូវជាតិ៥ ដល់ផ្លូវជាតិលេខ៤ ប្រវែង១៧,២៥០ម, (៣) ស្ថាបនាពង្រីកផ្លូវកំណាត់ផ្លូវជាតិលេខ៤ ចាប់ពីរង្វង់មូលចោមចៅ ដល់ផ្លូវទំនប់កប់ស្រូវ ប្រវែង១,៧៥០ម, (៤) ស្ថាបនាផ្លូវលេខ២១៧ (ផ្លូវជើងឯក)ចាប់ពីស្ពានអាកាសស្ទឹងមានជ័យ ដល់ផ្លូវជាតិលេខ២ ប្រវែង១២,៣២០ម និងផ្លូវបេតុងទំហំ ៩,៧៥ម, (៥) ជួសជុលគ្រឹះ និងចាក់អ៊ីតកៅស៊ូកំណាត់ផ្លូវជាតិលេខ២ ចាប់ពីស្ពានអាកាសក្បាលថ្នល់ដល់រូបសំណាកព្រះនរាយណ៍ប្រវែង៤,៣៥០ម, (៦) ស្ថាបនាពង្រីកកំណាត់ផ្លូវជាតិលេខ៥ ចាប់ពីមុខឃ្លាំងស្តុកប្រេងឥន្ធនៈសូគីមុិចដល់ព្រែកព្នៅប្រវែង៥,៣៨០ម, និង (៧) ដំឡើងបង្គោលភ្លើង, ស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ (២០១៥-២០១៨)។

ឃ. វិធានការផ្នែកហិរញ្ញាប្បទាន

ក្នុងចំណោមវិធានការគោលនយោបាយទាំង៦ ពាក់ព័ន្ធនឹង "វិធានការផ្នែកហិរញ្ញាប្បទាន" ក្រសួងស្ថាប័នទទួលខុសត្រូវពាក់ព័ន្ធសម្រេចបានវឌ្ឍនភាពជាច្រើន ដូចខាងក្រោម÷

ឃ.១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្នុងក្របខ័ណ្ឌនៃការបន្តអនុវត្ត "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០" ដែលជាក្របខ័ណ្ឌរួមនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្របសម្រួល និងសហការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីរៀបចំសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេស និងសេចក្តីសម្រេចតែងតាំងសមាសភាពនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ, ព្រមទាំងបានសម្របសម្រួលរាល់ការចុះបំពេញបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិភាក្សាការងារអំពីការរៀបចំធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រឱ្យសមស្របតាមការវិវឌ្ឍនៃស្ថានភាពវិស័យហិរញ្ញវត្ថុ, និងជាពិសេស បានរៀបចំឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ ដែលត្រូវបានអនុម័តនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦។ ចំពោះការរៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ ក្រសួងបានសម្របសម្រួលដឹកនាំរៀបចំកិច្ចប្រជុំ និងសិក្ខាសាលាជាច្រើនលើកពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងកម្មនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ។

ជាមួយគ្នានេះ ដើម្បីសម្រួលការទទួលបានឥណទានសម្រាប់វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ក៏ដូចជាសហគ្រាសធុនតូចនិងមធ្យម ក្រសួងបានចូលរួមតាមដានវឌ្ឍនភាពនៃការកែទម្រង់ និងការកសាងសមត្ថភាពរបស់ធនាគារអភិវឌ្ឍន៍ជនបទ, ចូលរួមប្រជុំគណៈកម្មការឥណទាននៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្មចំនួន ៣លើក ដើម្បីពិនិត្យ និងវាយតម្លៃឥណទានកម្ចីដល់អតិថិជនគាំទ្រវិស័យស្រូវ-អង្ករ, រៀបចំសិក្ខាសាលា និងរបាយការណ៍ថ្នាក់ជាតិស្តីពីការទទួលហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងត្រៀមសហការជាមួយជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការអនុវត្តគម្រោងធានាឥណទាន សម្រាប់គាំទ្រការអភិវឌ្ឍវិស័យស្រូវ-អង្ករនៅកម្ពុជា ដោយបានបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ និងរៀបចំយុទ្ធសាស្ត្រនេះ។

ក្នុងការរៀបចំក្របខ័ណ្ឌវិនិយោគសាធារណៈ ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានអនុម័ត ដែលជាមូលដ្ឋាននៃការធ្វើវិចារណកម្មក្នុងការវិភាជ និងអនុវត្តថវិកាសម្រាប់ការវិនិយោគសាធារណៈរាប់ទាំងការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលផ្តល់ហិរញ្ញប្បទានពីប្រភពថវិការដ្ឋ ថវិកាពីដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ទាក់ទិននឹងការពង្រឹងទីផ្សារមូលបត្រ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងការបោះផ្សាយមូលបត្ររដ្ឋកម្រិតអន្តរស្ថាប័ន, សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងការបោះផ្សាយមូលបត្ររដ្ឋ, សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងការបោះផ្សាយមូលបត្ររដ្ឋកម្រិតបច្ចេកទេស, សេចក្តីព្រាងប្រកាសស្តីពីប្រតិបត្តិការមូលបត្ររដ្ឋកម្រិតបច្ចេកទេស, និងសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជាកម្រិតបច្ចេកទេស។ លើសពីនេះ ក្រសួងក៏បានចេញប្រកាសលេខ៨៥៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញសម្រាប់ក្រុមហ៊ុន/សហគ្រាសទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, និងបានលើកលែងពន្ធប្រថាប់ត្រាក្នុងការទទួលសិទ្ធិកាន់កាប់ភាគហ៊ុន តាមរយៈការជួញដូរមូលបត្រក្នុងទីផ្សារដំបូងឬក្នុងទីផ្សារបន្ទាប់ ផ្អែកតាមប្រកាសលេខ២៧៣ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា។

ក្នុងការពង្រឹងយន្តការសន្សំក្នុងស្រុក រួមមាន ការអភិវឌ្ឍ និងការកែទម្រង់មូលនិធិសោធន និងវិស័យធានារ៉ាប់រង ក្រសួងបានរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាច្រើន ក្នុងនោះរួមមាន សេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងជាកាតព្វកិច្ច, សេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច, សេចក្តីព្រាងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណជូនភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង, សេចក្តីព្រាងប្រកាសមួយចំនួនពាក់ព័ន្ធនឹងកិច្ចការពារអតិថិជន, និងសេចក្តីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធមួយចំនួនទៀត។ ទន្ទឹមគ្នានេះ ក្រសួងក៏បានរៀបចំធ្វើបច្ចុប្បន្នកម្មគេហទំព័រ (website) និង server ដើម្បីឆ្លើយតបនឹងតម្រូវការនៃការគ្រប់គ្រងទីផ្សារធានារ៉ាប់រង,

ព្រមទាំងបានបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម ដែលកំពុងស្ថិតនៅជាសេចក្តីព្រាងបឋម។ ចំពោះវិស័យសោធន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបញ្ចប់ការរៀបចំក្របខ័ណ្ឌគោលនយោបាយជាតិតាំពារសង្គមត្រឹមកម្រិតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ព្រមទាំងបាននិងកំពុងប្រមូលធាតុចូលដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម។

២.២ ធនាគារជាតិនៃកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ដែលមានធនាគារជាតិនៃកម្ពុជា ជាសេនាធិការ បានរក្សាស្ថិរភាពថ្លៃ និងអត្រាប្តូរប្រាក់ ដើម្បីរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានបង្កបរិយាកាសអំណោយផលដល់ការវិនិយោគ។ ជាក់ស្តែងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ អត្រាប្តូរប្រាក់ធៀបនឹងប្រាក់ដុល្លារអាមេរិកមានកម្រិតជាមធ្យមត្រឹម ៤ ០៨២ រៀល ហើយនៅឆ្នាំ២០១៦កន្លងទៅ មានកម្រិតជាមធ្យម ៤ ០៥០ រៀល/ដុល្លារអាមេរិក ជាមួយនឹងកំណើន ១០,៤% នៃប្រាក់រៀលត្រូវបានប្រើប្រាស់ក្នុងចរាចរណ៍ ដែលបានឆ្លុះបញ្ចាំងឱ្យឃើញពីតម្រូវការប្រាក់រៀលមានការកើនឡើងជាលំដាប់។ ព្រមជាមួយគ្នានេះផងដែរ អត្រាអតិផរណាត្រូវបានរក្សាឱ្យស្ថិតក្នុងកម្រិតទាប ស្របតាមក្របខ័ណ្ឌគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ដែលមានកម្រិតទាបជាមធ្យមប្រមាណ ២,៩% ចាប់តាំងពីឆ្នាំ២០០៩មក។ ក្នុងឆ្នាំ២០១៦ដដែល ជញ្ជីងទូទាត់កម្ពុជាមានអតិរេកប្រមាណ ៥,៧% នៃផ.ស.ស. គឺកើនឡើង ៤៣% ស្មើនឹង ១ ១៤៨ លានដុល្លារអាមេរិក ដែលបានរួមចំណែកគរពួនទុនបម្រុងអន្តរជាតិដុលដល់ ៦,៤ ប៊ីលានដុល្លារអាមេរិក និងអាចធានាការនាំចូលទំនិញ និងសេវាបានប្រមាណ ៥ខែ។ លើសពីនេះ ប្រព័ន្ធធនាគារ និងការកេណ្ឌប្រមូលមូលនិធិ ត្រូវបានពង្រឹង និងលើកកម្ពស់ សម្រាប់បម្រើដល់គម្រោងវិនិយោគរបស់ក្រុមហ៊ុន និងសហគ្រាសឯកជន។ ជាក់ស្តែង គិតត្រឹមចុងឆ្នាំ ២០១៦ កម្ពុជាមានធនាគារពាណិជ្ជចំនួន ៣៧ និងធនាគារឯកទេសចំនួន ១៥ ហើយសាខារបស់គ្រឹះស្ថានធនាគារបានកើនដល់ ៨១០ សាខា និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិបានកើនដល់ ១ ២៥៥ ម៉ាស៊ីន។ ក្នុងឆ្នាំ២០១៦ ចំនួនអ្នកដាក់ប្រាក់បញ្ញើបានកើនដល់ ១៤% ស្មើនឹងប្រមាណ ៣ លាននាក់ បើធៀបនឹងឆ្នាំ ២០១៥ ស្របពេលដែលចំនួនប្រជាជន ដែលទទួលបានឥណទានកើនឡើងដល់ ៤៩% ស្មើនឹងប្រមាណ ០,៨ លាននាក់។

ទន្ទឹមគ្នានោះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម តាមរយៈការលើកកម្ពស់ការទទួលបានឥណទាន។ ជាក់ស្តែង ឥណទានបានកើនដល់ ៥៦,៣ ទ្រីលានរៀល (ប្រមាណ ១៣,៩ ប៊ីលានដុល្លារអាមេរិក) មានកំណើន ១៨% ដែលបានដើរតួនាទីយ៉ាងសកម្មក្នុងការជំរុញការពង្រីកអាជីវកម្ម និងការប្រើប្រាស់ក្នុងស្រុក។ កំណើនឥណទានត្រូវបានបែងចែកទៅតាមវិស័យសំខាន់ៗក្នុងនោះ វិស័យពាណិជ្ជកម្ម ៣២% សំណង់និងអចលនទ្រព្យ ២១% កសិកម្ម ១១% ជាពិសេស វិស័យកម្មន្តសាលដែលជាវិស័យអាទិភាពសម្រាប់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា បានស្រូបយក

ប្រមាណ ៨% នៃសំពៀតឥណទានសរុប។ ជាមួយគ្នានោះដែរ ធនាគារជាតិនៃកម្ពុជា បានបន្តអភិវឌ្ឍប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដើម្បីពង្រឹងតម្លាភាព និងកាត់បន្ថយហានិភ័យក្នុងប្រព័ន្ធធនាគារ ដែលទាំងនេះនឹងរួមចំណែកបង្កើនគុណភាពសំពៀតឥណទាន បន្ថយចំណាយប្រតិបត្តិការឥណទាន និងអត្រាការប្រាក់, ព្រមទាំងខិតខំជំរុញប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដោយគិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ១២។

ក្រៅពីការងារខាងលើ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអភិវឌ្ឍការការពារអតិថិជន ដោយកំពុងសហការជាមួយស្ថាប័នសាធារណៈកម្មហិរញ្ញវត្ថុអន្តរជាតិ ដើម្បីសិក្សារៀបចំ និងអភិវឌ្ឍក្របខ័ណ្ឌការងារនេះ, លើកកម្ពស់ការអប់រំអំពីសេវាហិរញ្ញវត្ថុ ដោយចុះធ្វើការផ្សព្វផ្សាយដល់សាធារណជននៅស្ទើរគ្រប់រាជធានីខេត្តអំពីអន្តរការីកម្មធនាគារ ជាពិសេសទាក់ទងនឹងសេវាឥណទាន, និងបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដើម្បីពង្រីកការផ្តល់សេវាហិរញ្ញវត្ថុឱ្យបានកាន់តែទូលំទូលាយដល់ក្រុមហ៊ុន សហគ្រាសឯកជន សម្រាប់ទទួលបានមូលនិធិក្នុងការពង្រីកសកម្មភាពធុរកិច្ច។ ជាក់ស្តែង បច្ចុប្បន្ន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានពង្រីកបណ្តាញប្រតិបត្តិការដល់ ៤ ០៧៩ សាខា និងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិកើនដល់ ៣១០ ម៉ាស៊ីន។ ការពង្រីកវិសាលភាពនេះ បានជំរុញឱ្យទំហំឥណទាន កើនដល់ ១២,២ ទ្រីលានរៀល (ប្រមាណ ៣ប៊ីលានដុល្លារអាមេរិក) ដោយបានបែងចែកទៅតាមវិស័យផ្សេងៗរួមមាន វិស័យកសិកម្ម ៣៤% ក្រុមគ្រួសារ ២៨% ពាណិជ្ជកម្ម ១៨% សេវាកម្ម ១០% ដឹកជញ្ជូន ៤% សំណង់ ៣% និងវិស័យផ្សេងៗ ២%។ ចំនួនអ្នកខ្ចីប្រាក់ក្នុងវិស័យនេះ បានកើនឡើងដល់ ១,៩ លាននាក់ ស្របពេលដែលចំនួនអ្នកដាក់ប្រាក់បញ្ញើមានចំនួន ១,៥ លាននាក់ ដែលបានគណនីប្រាក់បញ្ញើដល់ ៥,៩ ទ្រីលានរៀល (ប្រមាណ ១,៥ ប៊ីលានដុល្លារអាមេរិក)។ អត្រាការប្រាក់ឥណទានប្រចាំឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានទិន្នាការថយចុះជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងមក ដោយបានថយចុះពី ៣៦% ក្នុងឆ្នាំ២០០៦ មក ២២,៥% ក្នុងឆ្នាំ២០១៦ ហើយត្រូវបានរំពឹងថានឹងថយចុះបន្ថែមទៀត។

ដោយឡែក ក្នុងការអភិវឌ្ឍផ្នែកភស្តុភារកម្ម ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ ធ្វើទំនើបកម្ម និងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា ឱ្យកាន់តែប្រសើរឡើងថែមទៀត ដែលក្នុងនោះរួមមានប្រព័ន្ធអេឡិចត្រូនិកសម្រាប់សេវាទូទាត់រហ័ស (Fast Payment) និងប្រព័ន្ធ Cambodia Shared Switch និងទូទាត់ថ្លៃទំនិញតាមម៉ាស៊ីន POS ពីគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានផ្តល់សេវាផ្ទេរប្រាក់តាមសេវា Western Union, Money Gram និង IME ដែលមានភ្នាក់ងារសរុបចំនួន ២០៣ កន្លែង និងប្រតិបត្តិការផ្តល់សេវាទូទាត់ចល័តមានចំនួន ៦។

លើសពីនេះ ពាក់ព័ន្ធនឹងការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីរៀបចំសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈធនាគារ។

សញ្ញាបត្រជំនាញធនាគារនេះ នឹងត្រូវបានទទួលស្គាល់ពីប្រទេសក្នុងតំបន់ផងដែរ មានន័យថា បុគ្គលដែលត្រូវបានបណ្តុះបណ្តាលក្នុងសាលានេះ អាចទទួលបានឱកាសក្នុងការស្វែងរកការងារនៅបរទេស។

២.៣ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

ក្រសួងឧស្សាហកម្មនិងសិប្បកម្ម កំពុងជ្រើសរើសធនាគារដែលមានភាពអនុគ្រោះបំផុត និងផ្តល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម ដើម្បីធ្វើជាដៃគូក្នុងការជំរុញកិច្ចអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងរៀបចំសិក្ខាសាលា ដើម្បីផ្តល់ឱកាសឱ្យធនាគារដែលបានជ្រើសរើសទាំងអស់ធ្វើការបង្ហាញផលិតផលរបស់ខ្លួន និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និងមធ្យមទាំងឡាយណាដែលមានបំណងទទួលយកកម្ចីពីធនាគារសាមី។ ក្នុងនោះផងដែរ ក្រសួងបានអញ្ជើញធនាគារពាណិជ្ជចំនួន ២៨ ដើម្បីពិភាក្សាអំពីការផ្តល់កម្ចីអនុគ្រោះបំផុត និងលើកទឹកចិត្តដល់ការបង្កើតសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។ រហូតមកដល់ពេលនេះ ក្រុមការងាររបស់អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម បាននិងកំពុងសរុបលទ្ធផលដែលបានពិភាក្សាសម្រាប់ដាក់ជូនថ្នាក់ដឹកនាំសម្រេចជ្រើសរើសយកធនាគារអនុគ្រោះបំផុត និងមានការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម។

២.៤ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយប្រទេសជប៉ុន ដើម្បីសិក្សាអំពីការគ្រប់គ្រង និងចាត់ចែងរបបប្រាក់សោធន, ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា និងការរៀបចំដំណើរការបើកផ្តល់តាវកាលិក។ ស្របគ្នានេះ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍន៍ដូចជា អង្គការអន្តរជាតិខាងការងារ ដើម្បីសិក្សាអំពីលទ្ធភាពដាក់ឱ្យដំណើរការរបបប្រាក់សោធន, ពិភាក្សាអំពីទិដ្ឋភាពផ្នែកលិខិតបទដ្ឋានគតិយុត្ត, លើកគម្រោងស្នើសុំអ្នកវិភាគសន្តិសុខសង្គម, និងធ្វើសិក្ខាសាលាពិគ្រោះយោបល់អំពីការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម។

កន្លងមក ក្រសួងបានអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាជាច្រើន ដើម្បីសម្រួលការងារ ដូចជា ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់តាវកាលិកវិភាជន៍សោធនជរភាព វិភាជន៍សោធនទុព្វលភាព និងវិភាជន៍សោធនអ្នកនៅក្នុងបន្ទុក, កម្មវិធីចុះបញ្ជីកា និងបង់ភាគទានផ្នែកប្រាក់សោធន (E-Form), រៀបចំបណ្តាញព័ត៌មានវិទ្យាជាមួយធនាគារដៃគូ ដើម្បីធានាបានន្ធវ្ប្រសិទ្ធភាព និងភាពទាន់ពេលវេលាសម្រាប់ការគ្រប់គ្រងទិន្នន័យអ្នកសិទ្ធិវន្ត, និងតភ្ជាប់បណ្តាញជាមួយនាយកដ្ឋានអត្តសញ្ញាណកម្មសម្រាប់គ្រប់គ្រងព័ត៌មានកម្មករនិយោជិត។ ទន្ទឹមនឹងនេះ ក្រសួងបានរៀបចំសេចក្តីព្រាងលិខិតបទដ្ឋាន និងបែបបទផ្សេងៗ ជាច្រើនដូចជា ប្រកាសស្តីពីការបង់ភាគទាន, ប្រកាសស្តីពីតាវកាលិក, ប្រកាសស្តីពីការដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន, ការសិក្សាអំពីនីតិវិធីនៃការបើកផ្តល់ និងការត្រួតពិនិត្យលើសិទ្ធិវន្តផ្នែកប្រាក់សោធន, ការរៀបចំទម្រង់របាយការណ៍ ដើម្បីវាយតម្លៃលើ

ដំណើរការរបបប្រាក់សោធន, និងរៀបចំសេចក្ដីព្រាងកិច្ចព្រមព្រៀងជាមួយធនាគារដៃគូ។ ដើម្បីបង្កើនការយល់ដឹងបន្ថែមទៀត ក្រសួងក៏បានសហការជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកាតព្វកិច្ច អត្ថប្រយោជន៍ និងនីតិវិធីនៃរបបប្រាក់សោធន និងរបបធានារ៉ាប់រងផ្សេងៗ រួមមានកិច្ចសហការជាមួយ (១) នាយកដ្ឋានអត្តសញ្ញាណកម្មសម្រាប់គ្រប់គ្រងព័ត៌មានអត្តសញ្ញាណរបស់កម្មករនិយោជិត, (២) ជំនាញការរបស់ HITACHI, ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន, អង្គការអន្តរជាតិខាងការងារ, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, អគ្គិសនីកម្ពុជា និងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា និង (៣) ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា ដើម្បីបញ្ជូនមន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រាក់សោធន នៅប្រទេសវៀតណាម សាធារណរដ្ឋកូរ៉េ ជប៉ុន និងអ៊ីតាលី។

២.៣.៥- ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា

រាជរដ្ឋាភិបាលទទួលស្គាល់អំពីតួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រដល់ការអនុវត្តអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ទន្ទឹមនឹងការប្រែប្រួលបរិការណ៍សេដ្ឋកិច្ចរបស់ប្រទេស តំបន់ និងសកលលោក។ លើមូលដ្ឋាននេះ ហិរញ្ញប្បទានសហប្រតិបត្តិការនៅរក្សាតួនាទីសំខាន់សម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា និងបំពេញតួនាទីជាកាតាលីករសម្រាប់កៀរគរធនធានដទៃ ទាំងវិស័យសាធារណៈ និងឯកជន ពិសេសគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

ក- ការបង្កើតបរិស្ថានអំណោយផល និងកាតាលីករសម្រាប់ជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

ហិរញ្ញប្បទានសហប្រតិបត្តិការមានតួនាទីបង្កើតបរិស្ថានអំណោយផលសម្រាប់ការវិនិយោគឯកជន និងផ្តល់មូលដ្ឋានគ្រឹះខាងសម្ភារៈ និងសេវាសម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម។ ទន្ទឹមនឹងនេះ ក៏ជាកាតាលីករសម្រាប់កៀរគរហិរញ្ញប្បទានពីប្រភពផ្សេងៗ និងអាចផ្តល់ហិរញ្ញប្បទានផ្ទាល់ដើម្បីជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

ក្នុងការកៀរគរហិរញ្ញប្បទានសម្រាប់បន្តជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ដៃគូអភិវឌ្ឍន៍បានរៀបចំកម្មវិធីសហប្រតិបត្តិការរបស់ខ្លួន ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នរបស់រាជរដ្ឋាភិបាលទទួលខុសត្រូវដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

ខ- សក្តានុពលសម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

ហិរញ្ញប្បទានសហប្រតិបត្តិការអាចផ្តល់ការគាំទ្រសម្រាប់អភិវឌ្ឍវិស័យឧស្សាហកម្ម ជាអាទិ៍: ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ពិសេស ការអភិវឌ្ឍ

ពលកម្មជំនាញ ដើម្បីបង្កើនភាពប្រកួតប្រជែងសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវបរិស្ថានអំណោយផល សម្រាប់ជំរុញពាណិជ្ជកម្ម និងការវិនិយោគ ។ ក្នុងស្មារតីនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំឯកសារទស្សនាទានដើម្បីកំណត់តួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ក៏ដូចជាកំណត់វិស័យសំខាន់ៗដែលមានសក្តានុពលសម្រាប់ដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្ររួមមាន ១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងប្រព័ន្ធភស្តុភារកម្ម ២) ភាពជាដៃគូដោយផ្ទាល់ជាមួយវិស័យឯកជន ៣) ការវិនិយោគគន្លឹះជាយុទ្ធសាស្ត្រសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម និងលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច និង ៤) ការគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលសម្រាប់ធ្វើឱ្យមានភាពប្រសើរឡើងនូវបរិស្ថានអំណោយផល និងការទាក់ទាញវិនិយោគ ។

គ. ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

កិច្ចការសំខាន់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺការកៀរគរ និងសម្របសម្រួលហិរញ្ញប្បទានសហ-ប្រតិបត្តិការសម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។ ការងារដំបូងគឺការកំណត់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការដែលគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មតាមរយៈការកែសម្រួល និងបង្កើតវិស័យនិងអនុវិស័យបន្ថែមក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធានាសង្គតិភាពជាមួយនឹងកម្មវិធី និងអនុកម្មវិធីអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហ-កម្មកម្ពុជា (ទំព័រ២២-៣៦នៃឯកសារគោលនយោបាយ)។ លើមូលដ្ឋាននៃព័ត៌មានទាំងនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំរបាយការណ៍វិភាគស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៦ ក្នុងនោះបានវិភាគអំពីនិន្នាការនៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

ជារួម ហិរញ្ញប្បទានសហប្រតិបត្តិការប្រមាណ ១៥០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ ២០១៥-២០១៨ ត្រូវបានប្រើប្រាស់សម្រាប់គាំទ្រការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង ព្រមទាំងវិធានការគោលនយោបាយ និងផែនការសកម្មភាពនៃគោលនយោបាយនេះ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗដែលបានផ្តល់ការគាំទ្ររួមមាន សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, ធនាគារអភិវឌ្ឍន៍អាស៊ី, បារាំង, និងសហភាពអឺរ៉ុប។

ធនធានរយៈពេលមធ្យមសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (ពាន់ដុល្លារអាមេរិក)

វិធានការគោលនយោបាយ និងវិធានការ គន្លឹះជាក់ស្តែង	**ឆ្នាំ ២០១៥**	**ឆ្នាំ ២០១៦**	**ឆ្នាំ ២០១៧ (ប៉ាន់ស្មាន)**	**ឆ្នាំ ២០១៨ (ព្យាករណ៍)**	**សរុប**
ការជំរុញការវិនិយោគ	២៣៥	៣ ៣០៥	១ ៥៤៥	៨ ៥២៣	១៣ ៦០៨
ការពង្រីកសហគ្រាសធុនតូចនិងមធ្យម	១ ០៧០	១ ៧០២	៣ ១៥៥	៦ ២៦០	១២ ១៨៧
ការកែលម្អបរិស្ថានវិយតកម្ម	៤ ៣០៤	៩ ០៤១	២៥ ៤៣៦	៧ ០២៤	៤៥ ៨០៥
គោលនយោបាយគាំទ្រ	២៧ ៣៧០	២២ ១៨២	១៧ ៣៨១	១៥ ៨៦២	៨២ ៧៩[illegible]
វិធានការគន្លឹះ៤ជាក់ស្តែង	៥៥ ៨៥៩	១៥៣ ៥៧៥	៩៤ ០៤៦	១៣៧ ៧៩២	៤[illegible]
សរុប	**៨៨ ៨៣៨**	**១៨៩ ៨០៥**	**១៤១ ៥៦៣**	**១៧៥ ៤៦១**	**[illegible]**

២. អាទិភាពការងារក្នុងការកៀរគរ និងគ្រប់គ្រងធនធានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

គ.ជ.ន/ក.អ.ក នឹងបញ្ចូលសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មទៅក្នុងផែនការសកម្មភាព ដែលត្រូវមានសង្គតិភាពជាមួយក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សម្រាប់ពង្រឹងភាពជាដៃគូ ការតម្រឹម និងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល។ គ.ជ.ន/ក.អ.ក នឹងរៀបចំផែនការវិនិយោគ ដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងបានវាយតម្លៃអំពីតម្រូវការធនធាន និងរៀបចំបញ្ជីសំណើគម្រោងសម្រាប់គាំទ្រការអនុវត្តផែនការសកម្មភាពរបស់ក្រសួង និងស្ថាប័ននីមួយៗ។ ទន្ទឹមនឹងនេះ គ.ជ.ន/ក.អ.ក នឹងដឹកនាំការកៀរគរធនធានស្របតាមផែនការវិនិយោគដែលផ្តល់ជូនក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងប្រកាន់យកអភិក្រមបុរេសកម្ម ដើម្បីកំណត់ ឬស្វែងរកដៃគូ និងកៀរគរធនធានផ្ទៃទៀតសម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។

៣. បញ្ហាប្រឈម និងហានិភ័យនៃការអនុវត្តគោលនយោបាយ

ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនេះ ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការដាក់ចេញ និងអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ សំដៅជំរុញឱ្យសម្រេចបានតាមគោលដៅដែលបានគ្រោងទុក ឈានទៅរកការធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ព្រមទាំងរក្សាឱ្យបាននូវបរិយាបន្ន និងចីរភាពនៃការអភិវឌ្ឍ។ ឆ្លងកាត់ការអនុវត្តនាពេលកន្លងមក ទោះបីជាមានវឌ្ឍនភាពការងារល្អប្រសើររបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធក្នុងការជំរុញការអនុវត្តគោលនយោបាយនេះក្តី ក៏នៅតែមានការលេចចេញនូវបញ្ហាប្រឈម និងហានិភ័យមួយចំនួន ដែលបង្កឱ្យរាំងស្ទះដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ពាក់ព័ន្ធនឹងប្រព័ន្ធអភិបាលកិច្ចស្ថាប័ន និងការសម្របសម្រួលការអនុវត្តគោលនយោបាយ, ការគ្រប់គ្រងស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច, ព្រមទាំងការប្រែប្រួលបរិការណ៍តំបន់ និងពិភពលោក ដែលបញ្ហាទាំងនោះមានដូចខាងក្រោម÷

១. ប្រព័ន្ធអភិបាលកិច្ចស្ថាប័ន និងការសម្របសម្រួលការអនុវត្តគោលនយោបាយ÷

- កង្វះធនធានមនុស្ស និងថវិកាសម្រាប់គាំទ្រផ្នែកគោលនយោបាយ និងបច្ចេកទេស
- ការផ្តល់កិច្ចសហការ និងការសម្របសម្រួលយន្តការស្ថាប័នសម្រាប់អនុវត្តគោលនយោបាយនៅមានបញ្ហាប្រឈមមួយចំនួន ដែលទាមទារឱ្យមានការប្តេជ្ញាចូលរួមអនុវត្ត និងផ្តល់ការគាំទ្រកាន់តែខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធ

- កន្លងមក ការកែសម្រួលរចនាសម្ព័ន្ធ និងការផ្លាស់ប្តូរមន្ត្រីទទួលបន្ទុកអនុវត្តគោលនយោបាយនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន បានធ្វើឱ្យការតាមដានវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយមានភាពរអាក់រអួល
- ការជំរុញការអភិវឌ្ឍតាមវិស័យមួយចំនួនសម្រាប់គាំទ្រដល់សកម្មភាពឧស្សាហកម្ម នៅមានល្បឿនយឺត និងមិនទាន់មានភាពឆ្លើយឆ្លងនិងប្រទាក់ក្រឡាគ្នានៅឡើយ។

២. ការគ្រប់គ្រងស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច÷

- ការរៀបចំនយោបាយប្រជាភិថុត និងបំផុសចលនាអសកម្មរបស់ក្រុមឬអង្គការមួយចំនួនតូចបានធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់ធុរជន និងអ្នកវិនិយោគ, ជីវភាពរស់នៅរបស់ប្រជាជន និងកម្មករ កម្មការិនី, ព្រមទាំងបង្អាក់ដល់សកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម ដែលជាផ្នែកមួយនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម
- ការកើនឡើងនូវប្រាក់ឈ្នួលពលកម្ម ខណៈដែលផលិតភាពការងារនៅមានកំណើនយឺត បើធៀបនឹងប្រទេសជាដៃគូប្រកួតប្រជែង នៅតែចោទជាបញ្ហាចំពោះតម្រូវការកម្លាំងពលកម្ម ជាពិសេស ពលកម្មដែលមានជំនាញសម្រាប់សហគ្រាសឧស្សាហកម្មនៅកម្ពុជា ដែលទាមទារឱ្យមានការបង្កើនការវិនិយោគបន្ថែមទៀតក្នុងវិស័យអប់រំ បណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈ
- ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសម្រេចវឌ្ឍនភាពល្អប្រសើរច្រើន ប៉ុន្តែនៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ទាំងផ្នែកសម្របសម្រួល និងផ្នែកបច្ចេកទេស ដែលចាំបាច់ត្រូវបន្តពន្លឿន និងរៀបចំផែនការកសាងសមត្ថភាព ដើម្បីជោគជ័យនៃកម្មវិធីកំណែទម្រង់ សំដៅបង្កើនលំហសារពើពន្ធ និងលទ្ធភាពនៃការវិនិយោគសាធារណៈសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម
- ការសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបរបស់កម្ពុជា អាចនឹងជះឥទ្ធិពលដល់ទំហំហិរញ្ញប្បទានពីក្រៅប្រទេស។ តាមបទពិសោធរបស់បណ្តាប្រទេសមួយចំនួនបន្ទាប់ពីសម្រេចបានឋានៈប្រទេសមានចំណូលមធ្យមកម្រិតទាប ហិរញ្ញប្បទានឥតសំណងអាចនឹងមានការធ្លាក់ចុះ និងត្រូវជំនួសវិញដោយកម្ចីសម្បទាន ហើយហិរញ្ញប្បទានសហ-ប្រតិបត្តិការសុទ្ធអាចធ្លាក់ចុះ ដោយសារការធ្លាក់ចុះនៃការបើកផ្តល់ហិរញ្ញប្បទានថ្មី ឬកំណើននៃការសងហិរញ្ញប្បទានកម្ចី។

៣. ការប្រែប្រួលបរិការណ៍តំបន់ និងពិភពលោក÷

- ការដាក់ចេញនូវគោលនយោបាយអនុគ្រោះពាក់ព័ន្ធនឹងការជំរុញ និងលើកទឹកចិត្តការវិនិយោគ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ចដែលមានសក្តានុពលខ្ពស់របស់បណ្តាប្រទេសក្នុងតំបន់ ជាពិសេស

ប្រទេសថៃ វៀតណាម និងមីយ៉ាន់ម៉ា បានធ្វើឱ្យកម្ពុជាប្រឈមនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស

- ភាពរង្គោះរង្គើនៃស្ថានភាពសេដ្ឋកិច្ចក្នុងសហគមន៍អឺរ៉ុប អាចបង្កហានិភ័យដល់ការនាំចេញទំនិញរបស់កម្ពុជានៅក្នុងទីផ្សារអន្តរជាតិដ៏ធំមួយនេះ ដែលតម្រូវឱ្យកម្ពុជាគិតគូរលើការស្វែងរកទីផ្សារថ្មីៗបន្ថែមទៀតសម្រាប់ផលិតផលកសិកម្ម និងឧស្សាហកម្មរបស់កម្ពុជា
- ការប្រែប្រួលរបបពាណិជ្ជកម្មដែលបណ្តាលពីនិន្នាការគាំពារនិយម និងការហូរត្រឡប់ទៅវិញនៃវិនិយោគផ្ទាល់ពីបរទេស អាចជាហានិភ័យមួយនៅពេលអនាគត ដែលតម្រូវឱ្យកម្ពុជាពង្រឹងសមត្ថភាពទីផ្សារក្នុងស្រុក និងខិតខំទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការចូលរួមក្នុងសមាហរណកម្មសេដ្ឋកិច្ចតំបន់។

៤. សេចក្តីសន្និដ្ឋាន

ការត្រួតពិនិត្យ និងតាមដានលើវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ នាពេលកន្លងមក បានបង្ហាញឱ្យឃើញថា ការអនុវត្តរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ កំពុងស្ថិតនៅក្នុងទិសដៅ និងមាគ៌ាដ៏ត្រឹមត្រូវ និងមានការចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឱ្យកម្ពុជាឈានឆ្ពោះទៅសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យម។ វឌ្ឍនភាពវិជ្ជមានដែលគួរឱ្យកត់សម្គាល់មួយចំនួន ត្រូវបានសម្រេចតាមរយៈការគិតគូរយ៉ាងច្បាស់លាស់អំពីវិស័យអាទិភាពដែលនឹងផ្តល់នូវអត្ថប្រយោជន៍ឆាប់រហ័ស, វិធានការគាំទ្រនានា, ការរៀបចំនូវផែនការសកម្មភាពចម្បងៗជាទៀតបន្ថែមលើផែនការសកម្មភាពដែលមានស្រាប់។ វឌ្ឍនភាពវិជ្ជមានទាំងនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈគោលដៅចម្បងទាំងបី និងវិធានការគន្លឹះបួនជាក់ស្តែងនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហ-កម្មកម្ពុជា។

ជាក់ស្តែងលើគោលដៅចម្បងទាំងបី អនុបាតវិស័យឧស្សាហកម្មក្នុង ផ.ស.ស. បានកើនឡើងប្រមាណជា ៥ពិន្ទុភាគរយពី២៤,១% នៅឆ្នាំ២០១៣ ដល់២៩,0% នៅឆ្នាំ២០១៦ ខណៈពេលដែលវិស័យកម្មន្តសាលក្នុង ផ.ស.ស. បានកើនឡើងពី១៥,៥%នៅឆ្នាំ២០១៣ ដល់១៦,៣% នៅឆ្នាំ២០១៦ ពោលគឺកើនឡើងចំនួន 0,៨ពិន្ទុភាគរយ។ ការនាំចេញសំលៀកបំពាក់ និងស្បែកជើងធៀបនឹងការនាំចេញសរុប មានការធ្លាក់ចុះប្រមាណជា ៤ពិន្ទុភាគរយពី**៧៧**,១% នៅឆ្នាំ២០១៣ មកត្រឹម**៧**៣,១%នៅឆ្នាំ២០១៦ នៅខណៈពេលដែលការនាំចេញទំនិញកម្មន្តសាល (មិនមែនវាយនភណ្ឌ) ធៀបនឹងការនាំចេញសរុប មានការកើនឡើងពី១៦,៦% នៅឆ្នាំ២០១៣ ដល់២២,៣%នៅឆ្នាំ២០១៦ និងការនាំចេញកសិផលកែច្នៃមានចំនួនប្រមាណ ៤,៦%នៃការនាំចេញសរុបនៅឆ្នាំ២០១៦។ នេះឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជាបាននិងកំពុងធ្វើពិពិធកម្មមុខទំនិញនាំចេញរបស់ខ្លួនជាបន្តបន្ទាប់ ដោយមិនពឹងផ្អែកតែទៅលើការនាំចេញសម្លៀកបំពាក់និងស្បែកជើង និងផលិតផលកសិ

កសិកម្មនោះទេ។ ទន្ទឹមគ្នានេះ ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម តាមរយៈយន្តការច្រកចេញចូលតែមួយនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានកើនឡើងពីចំនួន៥៣៧ នៅឆ្នាំ២០១៥ ដល់ ៨០១នៅឆ្នាំ២០១៦ ពោលគឺកើនឡើងចំនួន៤៩,១៦%។ ជាមួយគ្នានោះដែរ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម មានការធ្លាក់ចុះប្រមាណជា៨,៨% ក្នុងឆ្នាំ២០១៦ បើធៀបនឹងតួលេខចុះបញ្ជីក្នុងឆ្នាំ២០១៥ ខណៈដែលក្រុមហ៊ុនបានចុះបញ្ជីបង់ពន្ធដារ (តាមរបបពិត) មានកំណើនយ៉ាងខ្ពស់ប្រមាណ ២០៩% ក្នុងឆ្នាំ២០១៦ បើធៀបនឹងតួលេខចុះបញ្ជីក្នុងឆ្នាំ២០១៥។

ដោយឡែក ចំពោះវិធានការគន្លឹះជាក់ស្តែងបួនដែលត្រូវសម្រេចឱ្យបានមុនឆ្នាំ២០១៨ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀត បានចូលរួមអនុវត្តសកម្មភាពការងារដែលនាំឱ្យសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់មួយចំនួន។ ជាក់ស្តែង ក្នុងវិស័យថាមពល ការផ្គត់ផ្គង់អគ្គិសនីនៅតាមតំបន់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ បានសម្រេចប្រមាណ ៥០% ក្នុងឆ្នាំ២០១៦ ហើយគ្រោងនឹងគ្របដណ្ដប់ពេញលេញ ១០០% នៅឆ្នាំ២០១៨ ខណៈពេលដែលថ្លៃអគ្គិសនីត្រូវបានបញ្ចុះជាបន្តបន្ទាប់។ រីឯក្នុងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម ការរៀបចំផែនការមេប្រព័ន្ធភស្តុភារកម្មកំពុងត្រូវបានសិក្សានិងគ្រោងរៀបចំនាពេលខាងមុខ ហើយគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ រួមមានផ្លូវថ្នល់ ផ្លូវដែកស្ពាន កំពង់ផែជាដើម ត្រូវបានស្ថាបនា សាងសង់ ជួសជុល និងរៀបចំកសាងជាបន្តបន្ទាប់ ក្នុងនោះគម្រោងសាងសង់ផ្លូវល្បឿនលឿនចំនួន២ គឺភ្នំពេញ-បាវិត និងភ្នំពេញ-ព្រះសីហនុ ត្រូវបានគ្រោងនឹងចាប់ផ្ដើមបើកការដ្ឋាននាប៉ុន្ទានឆ្នាំខាងមុខនេះ ដើម្បីសម្រួលដល់ការដឹកជញ្ជូនទាំងថ្លៃចំណាយ និងពេលវេលា។ ចំពោះវិធានការពាក់ព័ន្ធនឹងយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្ដុះបណ្ដាលជំនាញវិញ វឌ្ឍនភាពជាច្រើនក្នុងការងារនេះត្រូវបានសម្រេចជាបន្តបន្ទាប់ ដូចជាការបង្កើនប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង, ការដាក់ចេញនូវគោលនយោបាយជាតិស្ដីពីមុខរបរ និងការងារ, ការបង្កើនគុណភាពអប់រំ បណ្ដុះបណ្ដាលជំនាញ និងវិជ្ជាជីវៈ និងការជំរុញផលិតភាពការងារឱ្យស្របតាមតម្រូវការឧស្សាហកម្ម និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា។ រីឯវិធានការគន្លឹះចុងក្រោយ ពាក់ព័ន្ធនឹងការអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង កិច្ចការនេះនៅពុំទាន់សម្រេចបានវឌ្ឍនភាពគួរកត់សម្គាល់នៅឡើយទេ ដោយសារទាមទារឱ្យមានការចូលរួមពិភាក្សា និងផ្ដល់ធាតុចូលជាយុទ្ធសាស្ត្រ ឱ្យបានគ្រប់ជ្រុងជ្រោយពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងការរៀបចំផែនការមេ និងយន្តការរៀបចំអនុវត្ត និងគ្រប់គ្រងឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។ ទោះបីជាយ៉ាងក៏ដោយ ក្នុងវិធានការទី៤នេះ កន្លងមក ក៏មានសកម្មភាពការងារមួយចំនួនត្រូវបានអនុវត្តក្នុងការចូលរួមគាំទ្រដល់វិធានការនេះ ដូចជាការរៀបចំគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងប្រព័ន្ធទូរគមនាគមន៍ ព្រមទាំងការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេស ដើម្បីគាំទ្រដល់ការអភិវឌ្ឍខេត្តព្រះសីហនុក្លាយជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងនាពេលខាងមុខ។

ទន្ទឹមនឹងលទ្ធផលដែលកម្ពុជាសម្រេចបាន តាមរយៈគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម កម្ពុជា ក៏ឃើញមានលេចចេញនូវបញ្ហាប្រឈម និងហានិភ័យមួយចំនួនដែលបង្កឱ្យរាំងស្ទះដល់ការអភិវឌ្ឍ វិស័យឧស្សាហកម្មនៅកម្ពុជា ពាក់ព័ន្ធនឹងប្រព័ន្ធអភិបាលកិច្ចស្ថាប័ន និងការសម្របសម្រួលការអនុវត្តគោល នយោបាយ, ការគ្រប់គ្រងស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបម្រែបម្រួលបរិការណ៍តំបន់ និង ពិភពលោក ដែលតម្រូវឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានកិច្ចសហការរួមគ្នា ដើម្បី គ្រប់គ្រង និងដោះស្រាយបញ្ហាប្រឈមទាំងនេះឱ្យបានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃគោលនយោបាយនេះ។

ឧបសម្ព័ន្ធទី១ : ឧបសម្ព័ន្ធ "គ": យ៉ាន្ទ្រីសអំពីវិធានការគន្លឹះបួនជាក់ស្តែង ដើម្បីជំរុញ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម"

	វិធានការជាក់ស្តែងបួន	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប័នទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ទី១	រៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី សម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី។	- *បញ្ចុះថ្លៃទិញពីអនុស្ថានីយ្យដ្ឋាល់ មកត្រឹម **១២,៦០ សេនអាមេរិក** ក្នុង១គីឡូវ៉ាត់ម៉ោង* - *បញ្ចុះថ្លៃទិញពីប្រព័ន្ធភ្នំពេញ កណ្តាល និងកំពង់ស្ពឺរបស់អគ្គិសនីកម្ពុជា មកត្រឹម **១៦,៥០សេនអាមេរិក** ក្នុង១គីឡូវ៉ាត់ម៉ោង* - *បញ្ចុះថ្លៃទិញពីខ្សែបញ្ជូនរងនានា ដែលចេញពីអនុស្ថានីយ(ទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់សេវាកររងកជន) មកត្រឹមឯកតាថ្លៃរួមមួយ **១៦,៤០ សេនអាមេរិក** ក្នុង១គីឡូវ៉ាត់ម៉ោង* - *អនុម័តបញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាថ្ងៃ-យប់ សម្រាប់ឧស្សាហកម្ម* - *ពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីឱ្យដល់គ្រប់តំបន់ឧស្សាហកម្មគោលដៅ* - *ធានាស្ថិរភាពនិងភាពទុកចិត្តនៃការផ្គត់ផ្គង់អគ្គិសនីដោយកាត់បន្ថយអត្រាជាច់ចរន្ត មិនឱ្យលើសពី១២ដងឬ២៤ម៉ោង/ឆ្នាំ។*	២០១៨	- ក្រសួងរ៉ែ និងថាមពល ÷ ▪ បានធ្វើបច្ចុប្បន្នកម្ម និងអនុម័តផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងតម្លៃលក់អគ្គិសនីតាមបណ្តាខេត្ត និងរាជធានី ចាប់ពីខែមីនា ឆ្នាំ២០១៧ ដល់ ឆ្នាំ២០២០។ ▪ បានសាងសង់ខ្សែបណ្តាញមេចេញពីអនុស្ថានីយ ដើម្បីរំលែកបន្ទុកលើខ្សែចាស់ និងបង្កើនស្ថិរភាពក្នុងការផ្គត់ផ្គង់នូវរោងចក្រឧស្សាហកម្មក្នុងឆ្នាំ២០១៦ និងកំពុងបន្តទៀតនៅឆ្នាំ២០១៧។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បានផ្តល់ឱ្យអគ្គិសនីកម្ពុជាខ្ចីឥណទានចំនួន ៣២ ៤០០លានរៀល សម្រាប់អនុវត្តគម្រោងពង្រីកប្រព័ន្ធបញ្ជូនរងជនបទ។ ▪ បាននិងកំពុងជួយអគ្គិសនីកម្ពុជា (EDC) ក្នុងការរៀបចំផែនការវិនិយោគ ២០១៦-២០២០ ដើម្បីជាមូលដ្ឋានគ្រប់ជ្រុងជ្រោយសម្រាប់ស្វែងរកហិរញ្ញប្បទាន។ ▪ បានបញ្ចប់ការរៀបចំឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូ រវាងរដ្ឋ និង	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។ ▪ ស្នើសុំឱ្យក្រសួង និងស្ថាប័នដែលពាក់ព័ន្ធផ្តល់ការសហការលួងដល់ក្រុមការងារស្រាវជ្រាវក្នុងការចែករំលែកទិន្នន័យដែលពាក់ព័ន្ធនានា។

	វិធានការជាក់ស្តែងបន្ត	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពទទួលខុសត្រូវសម្រេចបានសម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				ឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ ដែលនឹងរួមចំណែកយ៉ាងសំខាន់ដល់ការកៀរគរទុនវិនិយោគរបស់វិស័យឯកជនក្នុងការចូលរួមវិនិយោគលើវិស័យថាមពលអគ្គិសនី។ ▪ បានរៀបចំសេចក្តីព្រាងទស្សនាទានអំពីការអភិវឌ្ឍវិស័យថាមពលនៅកម្ពុជា។ ▪ បានចុះហត្ថលេខាគម្រោងពង្រីកខ្សែបញ្ជូនអគ្គិសនីជនបទ ជំហានទី៥ និងទី៦ មានទឹកប្រាក់សរុបចំនួន ៥០លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦ និងកំពុងចរចាគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីក្រចេះ-ស្ទឹងត្រែង ជំហានទី៣ មានទឹកប្រាក់សរុបចំនួន ២០លានដុល្លារអាមេរិក និងគម្រោងសាងសង់ប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញ (ជំហានទី២ ដំណាក់កាលទី២) មានទឹកប្រាក់សរុបចំនួន ១៦៦ លានដុល្លារអាមេរិក ដោយគ្រោងនឹងចុះហត្ថលេខាក្នុងឆ្នាំ២០១៧។ ▪ បានចាប់ផ្តើមអនុវត្តគម្រោងសាងសង់ខ្សែអគ្គិសនីបណ្តាញមេ ជំហានទី១ (ពីខេត្តបាត់ដំបងទៅខេត្តសៀមរាបទៅខេត្តកំពង់ចាម) មានទឹកប្រាក់សរុប ១៦៧ លានដុល្លារអាមេរិក។ ▪ បានចាប់ផ្តើមការសិក្សាគម្រោង Scaling Solar	

	វិធានការជាក់ស្តែងបន្ត	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)។ ▪ បានចូលរួមចរចា ជាមួយក្រសួងរ៉ែ និងថាមពល អគ្គិសនីកម្ពុជា និងភាគីក្រុមហ៊ុន Cambodia Energy II លើគម្រោងវិនិយោគបន្ថែមម៉ាស៊ីន អគ្គិសនីដុតដោយធ្យូងថ្ម កម្លាំង ១៣៥ MW នៅ ខេត្តព្រះសីហនុ។ ▪ បានពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសហ គ្រាស សាធារណៈក្នុងវិស័យថាមពលក្នុងគោល ដៅ កាត់បន្ថយចំណាយប្រតិបត្តិការ និងបង្កើន ការយកចិត្តទុកដាក់ តាមរយៈការអភិវឌ្ឍប្រព័ន្ធ បណ្តាញអគ្គិសនីនៅជនបទ ដោយធ្វើការលើក ទឹកចិត្តទៅលើសេវាកម្ម ដើម្បីបន្ថយគម្លាតថ្លៃលក់ ថាមពលរវាងអគ្គិសនីភ្នំពេញដែលភ្ជាប់ពី បណ្តាញជាតិ និងការចូលរួមផ្តល់យោបល់លើ ផែនការអាជីវកម្ម និងវិនិយោគរបស់ EDC ប្រចាំឆ្នាំ ជាពិសេសផ្តល់យោបល់លើបញ្ជីថ្លៃលក់អគ្គិសនី និងឧបត្ថម្ភធនរបស់ EDC សម្រាប់បន្ថយតម្លៃ អគ្គិសនីឯកជននៅជនបទ និងអ្នកប្រើប្រាស់ អគ្គិសនីដែលមានជីវភាពក្រីក្រ។ ▪ បានចូលរួមកសាង និងដាក់ឱ្យអនុវត្តកម្មវិធីកាត់ បន្ថយ និង/ឬលុបបំបាត់ពន្ធគយក្រោមកិច្ចព្រម ព្រៀងពាណិជ្ជកម្មទំនិញសេរីផ្សេងទៀតជា	

	ទិដ្ឋានការជាក់ស្តែងបច្ចុ	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពនៃទិន្នន័យ និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				ធរមាន (អនុក្រឹត្យ លេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥)។ ▪ បានកំណត់ប្រធានបទស្រាវជ្រាវស្តីពីការកាត់បន្ថយថ្លៃអគ្គិសនីសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម (Reducing Energy Cost for Industrial Development) ដែលជាឧបសគ្គមួយក្នុងការទាក់ទាញវិនិយោគ និងដើម្បីជំរុញវិស័យឧស្សាហកម្មស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥។ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា "ក.អ.ក" ÷ បានផ្សព្វផ្សាយផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងតម្លាត់ថ្លៃលក់អគ្គិសនី នៅតាមតំបន់សំខាន់ៗ ជូនវិនិយោគិន និងទាក់ទាញការវិនិយោគបន្ថែមក្នុងវិស័យផលិតថាមពលអគ្គិសនី។ - អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា ÷ ▪ បាននិងកំពុងអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីតាមពេលវេលាថ្ងៃ-យប់ សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មដែលបច្ចុប្បន្នមានចំនួន ១៧អតិថិជន និងកំពុងសិក្សាថ្លៃលក់ តាមពេលវេលាថ្ងៃ-យប់ សម្រាប់ឆ្នាំ២០១៧។ ▪ បានសហការជាមួយក្រសួងរ៉ែ និងថាមពល ចុះ	

	វិធានការជាក់ស្តែងបន្ថែម	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពនៃទិន្នន័យ និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				ស្រង់ស្ថិតិអំពីអស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅតាមតំបន់សេដ្ឋកិច្ចពិសេស (SEZ) និងកសាងមូលដ្ឋានទិន្នន័យ។ ▪ បានលើកគម្រោងវិនិយោគកែលម្អប្រព័ន្ធ និងបំពាក់ឧបករណ៍បច្ចេកទេសដើម្បីលើកកម្ពស់ស្ថិរភាពនៃការផ្គត់ផ្គង់ ឆ្នាំ២០១៦។ ▪ កំពុងអនុវត្តគម្រោងវិនិយោគលើកកម្ពស់ស្ថិរ-ភាពនៃការផ្គត់ផ្គង់ ក្នុងឆ្នាំ២០១៧។ ▪ បានសាងសង់ខ្សែបណ្តាញមេចេញពីអនុស្ថានីយបន្ថែម និងខ្សែបណ្តាញជាកងសម្រាប់តំបន់សំខាន់ៗក្នុងឆ្នាំ២០១៦ និងគ្រោងបន្ថែមទៀតក្នុងឆ្នាំ២០១៧។	
ទ២	រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម ក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងប្រព័ន្ធភស្តុភារកម្មដែលមានសមាហរណកម្ម និងប្រសិទ្ធភាពខ្ពស់ ពិសេសផ្តោតលើការតភ្ជាប់ប៉ូល	- *ផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនស្តង់ដារអន្តរជាតិ* - *ផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ប្រកបដោយសមាហរណកម្ម និងប្រសិទ្ធ-ភាពសេដ្ឋកិច្ចខ្ពស់* - *ផែនការអភិវឌ្ឍន៍រៀងសេដ្ឋកិច្ច* - *ផែនការ កម្មវិធី និងគម្រោងវិនិយោគ* - *យន្តការគ្រប់គ្រង និងអនុវត្ត។*	២០១៨	- សម្របសម្រួលដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងស្ថាប័នចូលរួម ÷ - ក្រសួងសាធារណការ និងដឹកជញ្ជូន បាន÷ ▪ ធ្វើការជាមួយក្រុមជំនាញការរបស់កូរ៉ា ក្នុងការសិក្សាអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្មនៅកម្ពុជា។ ▪ សហការជាមួយក្រុមជំនាញទីភ្នាក់ងារសហ-ប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ក្នុងដំណើរការអង្កេត និងស្រាវជ្រាវដើម្បីរៀបចំ	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។ ▪ ព័ត៌មានអំពីកិច្ចសន្យារវាងរដ្ឋ និងឯកជន (PPP Contract) មិនត្រូវបានចែកអំណែតដោយស្វាយ-ន និងក្រសួងដែលពាក់ព័ន្ធ ដែលជាហេតុធ្វើឱ្យក្រុម

	ទិដ្ឋានការជាក់ស្តែងបច្ចុ	សូចនាករ	ឆ្នាំគោល	ស្ថានភាពទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
	សេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ច ***ភ្នំពេញ-ខេត្តព្រះសីហនុ ភ្នំពេញ-បាវិត*** និង ***ភ្នំពេញ-ប៉ោយប៉ែត*** ឱ្យក្លាយទៅជារបៀងសេដ្ឋកិច្ចគន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវហាយវេស្តង់ជាអន្តរជាតិ និងការបង្កើតប្រព័ន្ធភស្តុភារកម្ម ប្រកបដោយប្រសិទ្ធភាព។			ផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធភស្តុភារកម្មនៅកម្ពុជា។ ▪ វាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស ដើម្បីអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងខាងត្បូងដោយផ្តោតសំខាន់ទៅលើការអភិវឌ្ឍក្រុងប៉ោយប៉ែត បាត់ដំបង បាវិត និងទីប្រជុំជនអ្នកលឿង ហើយគ្រោងនឹងចាប់ផ្តើមអនុវត្តការងារសាងសង់នៅដើមឆ្នាំ២០១៧។ ▪ បានចុះហត្ថលេខាកិច្ចសន្យាជាមួយក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស កាលពីខែតុលា ឆ្នាំ២០១៦ ដើម្បីអនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងពីរដោយផ្តោតលើការអភិវឌ្ឍក្រុងព្រះ-សីហនុ និងក្រុងកំពត។ ▪ ចុះហត្ថលេខាជាមួយ JICA ដើម្បីជួយសិក្សាផ្លូវលឿនលឿនភ្នំពេញ-បាវិត ដោយបច្ចុប្បន្ន ការសិក្សាបច្ចេកទេសនេះត្រូវបានបញ្ចប់ ហើយក្រសួងបានបន្តចុះប្រជុំពិគ្រោះយោបល់សាធារ-ណៈ និងការងារផ្ទាល់ប៉ះពាល់ជាមួយប្រជាពលរដ្ឋនៅតាមភូមិ-ឃុំនីមួយៗ ក្នុងខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តស្វាយរៀង កាលពីថ្ងៃទី១៧-២២ ខែតុលា ឆ្នាំ២០១៦ ហើយគ្រោងបញ្ចប់ការសិក្សារបាយ-ការណ៍បឋម នៅខែមករា ឆ្នាំ២០១៧។	ការងារ និងជំនាញការកូរ៉ូ មានការលំបាកក្នុងការកំណត់ពីគោលការណ៍ បែងចែកហានិភ័យរវាងរដ្ឋ និងវិស័យឯកជន។ លើសពីនេះទៀត ផែនការមេសម្រាប់ការអភិវឌ្ឍហេដ្ឋា-រចនាសម្ព័ន្ធរបស់ក្រសួងនីមួយៗ មិនត្រូវបានធ្វើសមាហរណកម្ម។ ▪ ស្នើសុំដល់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនីមួយៗផ្តល់ការសហការឱ្យបានកាន់តែទូលំទូលាយបន្ថែមទៀត ក្នុងការចែករំលែកនូវទិន្នន័យ ឬព័ត៌មានដែលស្នើសុំដោយក្រុមការងារស្រាវជ្រាវនៃអគ្គនាយកដ្ឋានគោលនយោបាយ និងជំនាញការកូរ៉ូ។ ▪ ផែនការមេសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

	ទីតាំងការជាក់ស្តែងបូន	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពនៃទិន្នន័យសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				▪ កំពុងចរចាលើកិច្ចសន្យាសម្បទានលើគម្រោងផ្លូវ ល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ ដែលនឹងវិនិយោគដោយក្រុមហ៊ុនមកពីសាធារណរដ្ឋ-ប្រជាមានិតចិន ហើយគ្រោងចាប់ផ្តើមដំណើរការគម្រោងនៅចុងឆ្នាំ២០១៧នេះ។ ▪ បាននិងកំពុងអនុវត្តគម្រោងអភិវឌ្ឍន៍ចំណតពហុបំណងកំពង់ផែស្វយ័តក្រុងព្រះសីហនុ ប្រវែង ៣៣០ម៉ែត្រ ជម្រៅទឹក -១៣,៥ម៉ែត្រ សម្រេចបាន ៦៨,១៥% ដើម្បីជួយជំរុញដល់ការអភិវឌ្ឍផ្នែកឧស្សាហកម្ម និងការរីកលូតលាស់សេដ្ឋកិច្ចប្រទេសកម្ពុជា ដែលបានធ្វើពិធីបើកការដ្ឋានសាងសង់ កាលពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៥ ក្រោមអធិបតីភាព **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**។ ▪ គម្រោងកែលំអផ្លូវជាតិលេខ១ ជំណាក់កាលទី៤ ប្រវែង ៤ គ.ម. (គល់ស្ពានព្រះមុនីវង្ស-វត្តក្តីតាកុយ) សម្រេចបាន ៧0,១0%។ ▪ កំពង់ផែស្វយ័តក្រុងព្រះសីហនុ បញ្ចុះតម្លៃ១0% នៃតម្លៃសេវាលើកដាក់កុងតឺន័រនៅទីលានកុងតឺន័រ។ ▪ កំពង់ផែស្វយ័តភ្នំពេញ បញ្ចុះតម្លៃ ៥% នៃតម្លៃ	នីមួយៗ ដូចជា ផ្លូវថ្នល់ កំពង់ផែ ធារាសាស្ត្រជាដើម គួរតែត្រូវបានធ្វើសមាហរ-ណកម្ម និងឱ្យមានភាពស៊ីគ្នា។

	វិធានការជាក់ស្តែងបន្ត	សុចនាករ	ឆ្នាំគោលដៅ	ស្ថានភាពទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				សេវាលើកដាក់កុងតឺន័រនៅទីលានកុងតឺន័រ។ ▪ ភ្នាក់ងារកម្ពុជានាវាចរ កាំសាប បញ្ចុះតម្លៃ ១0% នៃតម្លៃសេវាកត់ត្រាកុងតឺន័រលើសម៉ោង និងបញ្ចុះតម្លៃ ១0% ទៀត នៃតម្លៃត្រួតពិនិត្យកុងតឺន័រនៅពេលលើកដាក់ទៅលើនាវា។ ▪ បានបង្កើតអគ្គនាយកដ្ឋានភស្តុភារកម្ម មានភារៈកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារពាក់ព័ន្ធវិស័យភស្តុភារកម្ម។ ▪ បានបង្កើតក្រុមប្រឹក្សាយោបល់ផ្នែកដឹកជញ្ជូន ដើម្បីពិភាក្សាការងារ និងផ្តល់ដំណោះស្រាយលើបញ្ហាប្រឈមពាក់ព័ន្ធតម្លៃដឹកជញ្ជូននៅកម្ពុជា។ ▪ បានបញ្ចប់លក្ខខណ្ឌយោង ត្រៀមបកប្រែ និងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាភស្តុភារកម្ម ដើម្បីដាក់ជូនប្រមុខរាជ-រដ្ឋាភិបាល ពិនិត្យ និងសម្រេច។ ▪ កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ បានដឹកនាំប្រជុំជាមួយអន្តរក្រសួង ដើម្បីពិនិត្យមើលលទ្ធភាពក្នុងការកាត់បន្ថយសេវាក្រៅផ្លូវការ។ ▪ បានស្នើសុំទៅរដ្ឋាភិបាលជប៉ុន និង JICA ក្នុងការសិក្សាលើគម្រោងរៀបចំស្វ័យប្រវត្តិកម្ម ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិក ដើម្បីសម្រួលលំហូរ បែបបទនាវា និងនាវិកចេញចូល	

	វិធានការជាក់ស្តែងបន្ត	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				នៅតាមកំពង់ផែជាតិ និងអន្តរជាតិ។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បាននិងកំពុងចូលរួមពិភាក្សាលើលទ្ធភាពនៃការរៀបចំគម្រោងផ្លូវរ៉ែ្យនលឿន ភ្នំពេញ-បាវិត ដែលនឹងអាចហិរញ្ញប្បទានដោយ JICA ។ ▪ បានរៀបចំសេចក្តីព្រាងទស្សនាទាន និងប្រមូលទិន្នន័យសំរាប់គម្រោង (KSP) ស្តីពីហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ ដោយមានការសហការ និងគាំទ្រពីសាធារណរដ្ឋកូរ៉េ។ គម្រោងនេះ មានគោលបំណងសិក្សាពីតម្រូវការហិរញ្ញប្បទាន និងប្រភពហិរញ្ញប្បទាន ទាំងបរទេស រដ្ឋាភិបាល និងឯកជន ដើម្បីគាំទ្រដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរួមមាន ផ្លូវថ្នល់ អគ្គិសនី ធារាសាស្ត្រ និងទឹកស្អាត។ ▪ បាននិងកំពុងចូលរួមរៀបចំ និងចរចាសេចក្តីព្រាងកិច្ចសន្យាសម្ព្ទានគម្រោងផ្លូវ ភ្នំពេញ-ព្រះសីហនុ។ ▪ កំពុងសិក្សាពីស្ថានភាព និងទីផ្សាររបស់វិស័យដឹកជញ្ជូន និងភស្តុភារកម្មដោយផ្សារភ្ជាប់ទៅនឹងថវិកា។ ▪ បានដាក់សំណើសុំជំនួយបច្ចេកទេសសម្រាប់រៀបចំផែនការមេសម្រាប់អភិវឌ្ឍប្រព័ន្ធដឹក	

	ទីតាំងការដាក់ស្នែងបូន	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពនៃទិន្នន័យខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				ជញ្ជូន និងភស្តុភារកម្មទៅភាគីចិន។ ▪ កំពុងចរចាកិច្ចសន្យាជាមួយក្រុមហ៊ុនសាងសង់សម្រាប់ស្ពានឡើងវិញផ្លូវជាតិលេខ៥ (North Section) ហិរញ្ញប្បទានដោយ JICA។ ▪ បានវិភាជថវិកាជាតិចំនួនប្រមាណ ៦០ លានដុល្លារអាមេរិកសម្រាប់គម្រោងជួសជុល និងស្ពានផ្លូវដែកកម្ពុជាខ្សែទិសខាងត្បូង និងទិសខាងជើង។ ▪ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាន ចំនួន ១ ជាមួយ ADB ដែលរួមមានការកែលម្អហេដ្ឋារចនាសម្ព័ន្ធរបវន្តនៅក្រុងព្រះសីហនុ និងក្រុងកំពត (ការសាងសង់ស្ថានីយច្រោះទឹកកខ្វក់ ប្រព័ន្ធរំដោះទឹកភ្លៀង និងទីលានចាក់សំរាម)។ ▪ បានដាក់ឱ្យដំណើរការផែស្ងួត ឆាយដា ឡូជិស្ទីក នៅភ្នំពេញ និង ៥ ទៀតនៅតាមមាត់ច្រកព្រំដែន (ប៉ៃលិន ម៉ាឡៃ ប៊ីងត្រកួន និងចាំយាម)។ ▪ បានចេញសេចក្តីណែនាំ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កែនកុងតឺន័រ ដែលរួមមាន (១) បង្កើតទម្រង់ផ្ទេរការវាយតម្លៃរូបភាពស្កែន, (២) ផ្ទាកកាតព្វកិច្ចឆ្លងកាត់ស្កែនចំពោះតំបន់សេដ្ឋកិច្ចពិសេស និង (៣) អនុញ្ញាតឱ្យស្កែន	

	វិធានការជាក់ស្តែងបន្ត	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប័នទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				ទំនិញវិស័យកាត់ដេរ បើមានការស្នើសុំ។ - ក្រសួងពាណិជ្ជកម្ម - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បានត្រៀមផ្តល់ធាតុចូល និងចូលរួមកិច្ចប្រជុំអន្ត-ក្រសួងពាក់ព័ន្ធនឹងការកសាងផ្លូវលឿនលឿនភ្នំពេញ-បាវិត និងភ្នំពេញ-ព្រះសីហនុ។ ▪ បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាការងារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដោយផ្តោត សំខាន់លើប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម។ ▪ បានចូលរួមពិនិត្យ ពិភាក្សា និងផ្តល់យោបល់ក្នុងកិច្ចប្រជុំមួយចំនួនពាក់ព័ន្ធការអភិវឌ្ឍវិស័យដឹកជញ្ជូន និងភស្តុភារកម្ម ដូចជា÷ (១) កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងរបាយការណ៍បញ្ចប់ស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធភស្តុភារកម្ម, (២) កិច្ចប្រជុំជាមួយ JICA ដើម្បីពិភាក្សាអំពីការសិក្សាលើប្រព័ន្ធភស្តុភារកម្មនៅកម្ពុជា, (៣) កិច្ចប្រជុំអនុក្រុមការងារបច្ចេកទេសដឹកជញ្ជូនផ្លូវគោក, (៤) កិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍សិក្សាស្តីពីការសម្របសម្រួលសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ដែលត្រូវបាន	

	ទិដ្ឋានការជាក់ស្តែងបច្ចុ	សូចនាករ	ឆ្នាំគោល	ស្ថាប៉ន់ធនធានខ្វះសក្តានុពលសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				សហការរៀបចំដោយអង្គការ USAID និងក្រសួងពាណិជ្ជកម្មក្នុងគោលបំណងជំរុញការអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជ-កម្ម របស់អង្គការពាណិជ្ជកម្មពិភពលោក, (៥) កិច្ចប្រជុំអន្តរក្រសួងពាក់ព័ន្ធនឹងការពិភាក្សាលើកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនក្នុងក្របខ័ណ្ឌមហាអនុតំបន់មេគង្គ និងក្នុងក្របខ័ណ្ឌទ្វេភាគី, (៦) កិច្ចប្រជុំគណៈកម្មការចម្រុះអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ លើគម្រោងបើកច្រកអន្តរជាតិថ្មីនៅខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ (ច្រកស្ទឹងបត់-ណងអៀន) ដើម្បីដោះស្រាយបញ្ហាកកស្ទះនូវរថយន្តដឹកទំនិញ, (៧) កិច្ចប្រជុំអន្តរក្រសួងលើគម្រោងសាងសង់ផ្លូវរ៉ែ្យនលឿន ភ្នំពេញ-បាវិត និងគម្រោងសាងសង់ផ្លូវរ៉ែ្យនលឿនភ្នំពេញ-ក្រុងព្រះសីហនុ, និង (៨) កិច្ចសន្ទនាគោលនយោបាយស្តីពីភស្តុភារកម្ម និងសិក្ខាសាលាស្តីពីភស្តុភារកម្ម ដែលសហការរៀបចំដោយក្រសួងសាធារណការ និងដឹកជញ្ជូន ជាមួយក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍នៃប្រទេសជប៉ុន ក្រោមក្របខ័ណ្ឌនៃ "ភាពជាដៃគូដឹកជញ្ជូនអាស៊ាន-ជប៉ុន" ក្នុងគោល	

	វិធានការជាក់ស្តែងបួន	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប័នទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				បំណងពិនិត្យលើស្ថានភាពភស្តុភារកម្មនៅកម្ពុជា និងក្របខ័ណ្ឌនៃការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន ព្រមទាំងលើកឡើងពីសំណូមពររបស់ភាគីជប៉ុន ក្នុងការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មនៅកម្ពុជា។ - ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំការងារពាក់ព័ន្ធវិស័យដឹកជញ្ជូន និងប្រព័ន្ធភស្តុភារកម្ម។	
ទី៣	ពង្រឹង និងបន្តអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះ-បណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាពនៃការផ្គត់-ផ្គង់កម្លាំងពលកម្ម លើកកម្ពស់ផលិតភាព និងកែលម្អកម្រិតជីវភាពរបស់ពលករ តាមរយៈការជំរុញការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលជំនាញ ការពង្រឹងយន្តការកំណត់ប្រាក់បៀវត្សអប្បរមា និងការពង្រឹងសុខដុមភាពនៃទំនាក់ទំនងវិជ្ជាជីវៈ ឈរ	- *ថ្លៃឈ្នួលអប្បបរមា ដែលធានាបានន្ទូវកម្រិតជីវភាពរស់នៅសមស្រប ភាពប្រកួតប្រជែង និងពិពិធកម្មនៃសេដ្ឋកិច្ច-ឧស្សាហកម្មកម្ពុជា* - *កែលម្អស្ថិរភាពទីផ្សារពលកម្ម និងកាត់បន្ថយចំនួនវិវាទការងារ* - *លក្ខខណ្ឌការងារ និងជីវភាពកម្មករប្រសើរឡើង* - *ផែនការមេសម្រាប់ការពង្រីក និងទំនើបកម្មប្រព័ន្ធបណ្តុះបណ្តាលបច្ចេកទេស និងជំនាញ* - *កម្មវិធី និងគម្រោងវិនិយោគសម្រាប់ការ បណ្តុះបណ្តាលបច្ចេកទេស និងជំនាញ ដែលមានការសម្របសម្រួលលក្ខណៈជាប្រព័ន្ធឆ្លើយតបនឹងតម្រូវការឧស្សាហកម្ម។*	២០១៨	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ - ក្រសួងអប់រំ យុវជន និងកីឬា បានបញ្ជូនបន្ទីមសារទៅក្នុងឯកសារពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ និងបានសមាហរណកម្មទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាពពាក់ព័ន្ធ។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានជ្រើសរើសបេក្ខជនមកពីវិស័យឯកជន និងមន្ត្រីស្ថាប័នរដ្ឋ ចំនួន ៧៥៧នាក់ ឱ្យចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រលើកកម្ពស់ផលិតភាពរបស់អង្គការផលិតភាពអាស៊ី និងអង្គការផលិតភាពជប៉ុន។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ បានបង្កើតក្រុមការងារដើម្បីធ្វើការសិក្សាកំណត់ន្ទូវកត្តាដែលជះឥទ្ធិពលដល់ផលិតភាពក្នុងវិស័យវាយនភណ្ឌរបស់កម្ពុជា។ ការសិក្សានេះនឹងផ្តល់	

	ទិដ្ឋានការជាក់ស្តែងបច្ចុ	សូចនាករ	ឆ្នាំគោល	ស្ថានភាពទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
	លើគោលការណ៍ គរិយាបថវិជ្ជមានរបស់ សហជីព និងព្រហ្មវិហារ-ធម៌របស់និយោជក ចំពោះនិយោជិត ដោយ ប្រើប្រាស់យន្តការមាន ស្រាប់ ជាអាទិ៍ យន្តការ *"គណៈកម្មការប្រឹក្សា ការងារ"* និង *"គណៈ-កម្មាធិការផលិតភាព កម្ពុជា"* ។			ជាធាតុចូលសម្រាប់ការកំណត់ប្រាក់ឈ្នួលអប្ប បរមា។ ▪ បានបង្កើនថវិកាសម្រាប់បន្តការគាំទ្រដល់ ការងារកសាងសុខដុមនីយកម្មក្នុងទំនាក់ទំនង វិជ្ជាជីវៈ បើធៀបនឹងថវិកាឆ្នាំ២០១៥ មាន កំណើន១៦,៣%។ ▪ បានបង្កើនទ្វេដងនូវកញ្ចប់ចំណាយសម្រាប់ការ បណ្តុះបណ្តាលបច្ចេកទេសជំនាញរយៈពេលពី ១ ឆ្នាំ-៣ឆ្នាំ (ពី៥០ម៉ឺនរៀល/ ម្នាក់ទៅ១លានរៀល/ ម្នាក់)។ ▪ បានបំពាក់ឧបករណ៍បច្ចេកទេសជំនាញសំណង់ ជួសជុលរថយន្ត បរិក្ខារត្រជាក់ អគ្គិសនី និង អេឡិចត្រូនិក។ ▪ បានចាប់ផ្តើមផ្តល់អាហារូបករណ៍ជីវភាពប្រចាំខែ (១៦ម៉ឺនរៀល) ដែលសិក្សាមុខជំនាញមួយចំនួន ដូចជា សំណង់ (ជាងកំបោរ), ជាងក្រឡឹង, ជាង ជួសជុលគ្រឿងយន្តកសិកម្ម។ ▪ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្ប ទានចំនួន ២ គឺគម្រោងពង្រឹងវិស័យអប់រំ បណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ជំហានទី២) មានទឹកប្រាក់សរុបចំនួន ១៥លានដុល្លារអាមេរិក និង (២) គម្រោងសាងសង់សាលាជាតិបណ្តុះ-	

	វិធានការជាក់ស្តែងបូន	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប័នទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				បណ្ណាលវិជ្ជាជីវៈទេសចរណ៍មានទឹកប្រាក់សរុបប្រមាណ ១៣,៥លានដុល្លារអាមេរិកជាមួយ AFD ។ ▪ បានបញ្ចប់ការសិក្សា និងរៀបចំសិក្ខាសាលាស្តីពីស្ថានភាព និងទីផ្សារពលកម្មដោយផ្សារភ្ជាប់នឹងថវិកាជាតិ។ ▪ បានចូលរួមពិភាក្សាក្នុងកម្រិតបច្ចេកទេសត្រីភាគីស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ ២០១៧ ក្នុងក្របខ័ណ្ឌគណៈកម្មការប្រឹក្សាការងារ។ ▪ បានចូលរួមចាប់ផ្តើមពិភាក្សាក្នុងកម្រិតបច្ចេកទេសលើសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា។ ▪ បានបញ្ចប់ការសិក្សាពីផលិតភាពក្នុងវិស័យកាត់ដេរ។ ▪ បានដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ (មាត្រា៤៧ថ្មី នៃច.ស.ព.)។ ▪ បានដំឡើងកម្រិតឲ្យជួនានសម្រាប់សហព័ន្ធ និងកូនក្នុងបន្ទុក ដើម្បីកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស (មាត្រា៤៦ថ្មី នៃច.ស.ព.)។ ▪ បានដាក់ចេញនូវយន្តការអនុគ្រោះពន្ធលើប្រាក់បៀវត្ស ចំពោះអត្ថប្រយោជន៍បន្ថែម សម្រាប់ចំណាយលើការដឹកជញ្ជូន, ស្នាក់នៅ និងហូប	

	វិធានការជាក់ស្តែងបួន	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប័នទទួលខុសត្រូវសម្រាបសម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				ចុករបស់កម្មករនិយោជិត។ ▪ បានបង្កើនការយល់ដឹងជាសាធារណៈលើការបំពេញកាតព្វកិច្ចពន្ធ និងសម្រួលនីតិវិធីពាក់-ព័ន្ធដល់សហគ្រាសរោងចក្រ។ ▪ បានតាមដានការអនុវត្តថវិកាសម្រាប់បន្តការគាំទ្រដល់ការងារកសាងសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ។ ▪ បានជំរុញការអនុវត្តកញ្ចប់ចំណាយសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសជំនាញ។ ▪ បានចូលរួមយ៉ាងសកម្មក្នុងការគាំទ្រ និងជំរុញឱ្យស្ថាប័នពាក់ព័ន្ធរៀបចំផែនការមេសម្រាប់ការពង្រីកនិងទំនើបកម្មប្រព័ន្ធបណ្តុះបណ្តាលបច្ចេកទេស និងជំនាញដោយផ្សារភ្ជាប់ទៅនឹងថវិកាប្រចាំឆ្នាំ។ ▪ កំពុងពិនិត្យសំណើគម្រោងមជ្ឈមណ្ឌលបណ្តុះ-បណ្តាលជំនាញ និងវិជ្ជាជីវៈទេសចរណ៍ នៅខេត្ត បាត់ដំបង របស់ក្រសួងទេសចរណ៍ និង គម្រោងអគារស្ថិតក្នុងវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា និងគម្រោងអគារស្ថិតក្នុងវិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជាតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។	

	ទិដ្ឋានការជាក់ស្តែងបច្ចុ	ស្ថានភាព	ឆ្នាំគោលដៅ	ស្ថានភាពទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				▪ បានចូលរួមសហការជាមួយភ្នាក់ងារប្រតិបត្តិគម្រោងក្នុងការអនុវត្តគម្រោងចំនួន២ដែលហិរញ្ញប្បទានដោយ ADB/AFD/China ។ ▪ បានដាក់បញ្ចូលកម្មវិធីកសាងសមត្ថភាពដើម្បីបង្កើនភាពប្រកួតប្រជែង ដែលមានទឹកប្រាក់ប្រមាណ ៦០ លានដុល្លារអាមេរិក នៅក្នុងបញ្ជីគម្រោង/កម្មវិធី ដែលគ្រោងចុះហត្ថលេខា ក្នុងឆ្នាំ២០១៧-២០១៩ ។ - ក្រុមប្រឹក្សាជាតិគណនេយ្យ÷ ▪ បានសហការជាមួយវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ដើម្បីបង្កើតកម្មវិធីសិក្សាគណនេយ្យជំនាញថ្នាក់ជាតិ។ ▪ បានរៀបចំ និងបានសម្រេចសេចក្តីព្រាងកម្មវិធីសិក្សារួចរាល់ ព្រមទាំងបាននិងកំពុងរៀបចំទម្រង់វិញ្ញាសាសម្រាប់ការប្រឡងលើមុខវិជ្ជានីមួយៗ។ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បានដឹកនាំកិច្ចប្រជុំពាក់ព័ន្ធនឹងការជំរុញការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស និងបានចូលរួមកិច្ចប្រជុំពិភាក្សាទាក់ទងនឹងការកំណត់ប្រាក់ឈ្នួលអប្បបរមា និងការពង្រឹងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ។	

	វិធានការជាក់ស្តែងបន្ត	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប៉ន់ធនធនមនុស្សត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				▪ បានចូលរួមយ៉ាងសកម្មក្នុងការងារកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៧ ក្នុងក្របខ័ណ្ឌគណៈកម្មការប្រឹក្សាការងារ, ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា, ការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥, ការរៀបចំ និងអនុវត្តគោលនយោបាយគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ, និងច្បាប់ស្តីពីសហជីព។ - ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំការងារពាក់-ព័ន្ធនឹង IDP លើការជំរុញការបណ្តុះបណ្តាលធនធានមនុស្ស។ - គណៈកម្មការប្រឹក្សាការងារ - គណៈកម្មាធិការផលិតភាពកម្ពុជា (គ.ផ.ក.)÷ ▪ រៀបចំកិច្ចប្រជុំចំនួន ២លើក ដោយក្នុងនោះលើកទី១ ស្តីពីការពិនិត្យ និងពិភាក្សាអំពីសេចក្តីព្រាងផែនការសកម្មភាព និងទិសដៅសិក្សាស្រាវជ្រាវទៅលើសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម និងភាពប្រកួតប្រជែង របស់ គ.ផ.ក. ដោយជាលទ្ធផល កិច្ចប្រជុំបានរកដំណោះស្រាយលើកិច្ចប្រឈមនៃប្រាក់ឈ្នួលអប្បបរមា និងជំរុញកំណើនផលិតភាព និងភាពប្រកួតប្រជែង	

	វិធានការជាក់ស្តែងបន្ថែម	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				ហើយ គ.ផ.ក. បានធ្វើរបាយការណ៍ស្តីពីលទ្ធផលប្រជុំនេះគោរពជូនប្រមុខរាជរដ្ឋាភិបាលកម្ពុជា។ លើកទី២ ស្តីពីការត្រួតពិនិត្យទៅលើលទ្ធផលសិក្សាស្រាវជ្រាវនៃឥទ្ធិពលប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៥ ទៅលើសុខុមាលភាពកម្មករ, ការវាស់វែង និងគណនាប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៦ នៅក្នុងវិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះត្រូវបានគោរពជូនប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។ ▪ កំពុងបន្តការសិក្សាស្រាវជ្រាវលើ "សន្ទស្សន៍ថ្លៃអ្នកផលិត" (Producer Price Index) សម្រាប់ពង្រឹងការគណនាពីផលិតភាពពលកម្ម ដើម្បីបង្ហាញពីសុក្រឹតភាពនៃផលិតភាពការងាររបស់កម្មករ ហើយក្រុមការងារបច្ចេកទេសកំពុងតែបញ្ចូលទិន្នន័យ និងវិភាគទិន្នន័យ។ ▪ កំពុងសហប្រតិបត្តិការសិក្សាស្រាវជ្រាវជាមួយវិទ្យាស្ថានអភិវឌ្ឍន៍កូរ៉េ (KDI) ស្តីពី "ការអភិវឌ្ឍជំនាញ និងវិស័យឧស្សាហកម្ម ដើម្បីលើកកម្ពស់ផលិតភាពពលកម្មក្នុងប្រទេសកម្ពុជា" ដែលផ្តោតលើវិស័យកសិ-ឧស្សាហកម្ម។	

	វិធានការជាក់ស្តែងបួន	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប័នទទួលខុសត្រូវសម្រាបសម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				▪ បានសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវគម្រោងចំនួន ៣ ក្នុងឆ្នាំ២០១៦ រួមមាន÷ គម្រោងទី១ សុខុមាលភាព និងផលិតកម្មពលកម្ម របស់កម្មករនិយោជិតក្នុង វិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និង ផលិតស្បែកជើងនៅកម្ពុជា, គម្រោងទី២ ការវិភាគលើវិស័យឧស្សាហកម្មកម្ពុជា: យល់ដឹងពីឥទ្ធិពលទៅលើផលិតភាពពលកម្ម ការអភិវឌ្ឍវិស័យឧស្សាហកម្មនិងភាពប្រកួតប្រជែង, គម្រោងទី៣ តម្រូវការជំនាញក្នុងវិស័យឧស្សាហកម្មកំពុងលូតលាស់នៅកម្ពុជា។	
ទី៤	អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុ-បំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស ដោយរៀបចំផែនការមេ សម្រាប់ការអភិវឌ្ឍក្រប-ខ័ណ្ឌច្បាប់ និងនិយតកម្ម ព្រមទាំងយន្តការគ្រប់គ្រង ចាំបាច់នានា	- *ផែនការមេសម្រាប់ការអភិវឌ្ឍខេត្តព្រះ-សីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពហុ-បំណង* - *ក្របខ័ណ្ឌច្បាប់ និងនិយតកម្ម* - *យន្តការរដ្ឋបាល និងការគ្រប់គ្រង* - *ផែនការប្រតិបត្តិ និងវិនិយោគ។*	**២០១៨**	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបាននិងកំពុងរៀបចំច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្ត តាមគោលការណ៍តំបន់រដ្ឋបាលពិសេស។ ក្រសួង/ ស្ថាប័នចូលរួម : - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - ក្រសួងមហាផ្ទៃ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ បានចូលរួមសម្រួលឱ្យមានកិច្ចដំណើរការរោងចក្រ	- ក្រសួងពាណិជ្ជកម្ម÷ ▪ កង្វះខាតធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ សម្រាប់បន្តតាក់តែងសេចក្តីព្រាងច្បាប់ដែលមានការពាក់ព័ន្ធតាមកម្មវិធីដែលបានគ្រោង

	ទិសដៅការជាក់ស្តែងបន	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប័នទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
	ដែលនឹងផ្តល់សិទ្ធិអំណាច និងយុត្តាធិការពេញលេញ សម្រាប់ការកៀរគរ ទាក់-ទាញ និងប្រមូលផ្តុំនូវ ប្រភពធនធាន បញ្ញា-ញាណ សកម្មភាពធុរកិច្ច និងវិនិយោគ ដើម្បី អភិវឌ្ឍខេត្តនេះឱ្យទៅជា ប៉ូលសេដ្ឋកិច្ចសំខាន់មួយ និងជាមជ្ឈមណ្ឌល ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ស្របតាម ទស្សនាទានៃការអភិវឌ្ឍ ប្រកបដោយចីរភាព និង មានតុល្យភាពបរិស្ថាន ព្រមទាំងឱ្យប្រែក្លាយជា **ទីក្រុងឧស្សាហកម្មបៃតង អាស៊ាន** នាពេលអនាគត។			និងក្រុមហ៊ុនជាង១០០ រួចហើយ នៅតំបន់សេដ្ឋ-កិច្ចពិសេសក្រុងព្រះសីហនុ។ ▪ បានជំរុញណែនាំឱ្យអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសផ្សេងទៀត ក្នុងភូមិសាស្ត្រនេះនិងកសាងហេដ្ឋារចនាសម្ព័ន្ធឱ្យបានឆាប់ឈានទៅទាក់ទាញវិនិយោ-គិន។ - ក្រសួងទេសចរណ៍ ÷ ▪ ក្នុងនាមជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រ បានចូលរួមជំរុញការ រៀបចំគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ដូចជា÷ ការ រៀបចំសម្អាតឆ្នេរ ការគ្រប់គ្រងឆ្នេរ ការគ្រប់គ្រង សំណល់ និងបរិស្ថានតាមឆ្នេរខេត្តព្រះសីហនុ ព្រមទាំងបានរៀបចំបុណ្យសមុទ្រលើកទី២ នៅក្នុង ខេត្តព្រះសីហនុ (លើកទី៥ នៅតំបន់ឆ្នេរ)។ ▪ ក្នុងនាមជាប្រធានក្រុមការងារអចិន្ត្រៃយ៍ ដើម្បី ដោះស្រាយ ជំរុញ និងតាមដានការអភិវឌ្ឍលើ កោះរ៉ុង បានរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការជំរុញដោះស្រាយផលប៉ះពាល់នានានៅ កោះរ៉ុង (ខេត្តព្រះសីហនុ) ដូចជា÷ ការគ្រប់គ្រង ទេសចរណ៍ អាជីវកម្មទេសចរណ៍ សុវត្ថិភាព ទេសចរណ៍ ការធ្វើដំណើរ និងដឹកជញ្ជូន ទេសចរណ៍ ពិសេសតាមនាវា, ការបញ្ចប់ការវាស់	

	ទិសដៅការជាក់ស្តែងបូន	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				រ៉ែង និងការផ្តល់ដីកម្មសិទ្ធិជូនប្រជាពលរដ្ឋ ការគ្រប់គ្រងស្ថិតិភ្ញៀវ និងបញ្ហាបរិស្ថាននៅលើកោះរ៉ុង។ ▪ បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ ២០១៦-២០២៥ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥។ ផែនការយុទ្ធសាស្ត្រនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍទេសចរណ៍នៅខេត្តព្រះសីហនុ ហើយផែនការនេះ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងអំឡុងពេលសន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍតំបន់ឆ្នេរកម្ពុជា កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ នៅខេត្តព្រះសីហនុ។ ▪ បានជំរុញការគ្រប់គ្រងសេវាកម្ម អាជីវកម្មទេសចរណ៍នៅខេត្តព្រះសីហនុ តាមរយៈការបណ្តុះបណ្តាលមន្ត្រី សេវាករ និងប្រតិបត្តិករ, ការអប់រំការយល់ដឹងជាវគ្គសិក្សាខ្លីៗ ការបង្កើតឆ្នាំសមុទ្រ និងមគ្គុទ្ទេសក៍ទេសចរណ៍ខេត្តព្រះសីហនុ និងការពង្រឹងយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ខេត្តព្រះសីហនុ តាមរយៈយន្តការគណៈកម្មធិការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ខេត្តដែលមានស្រាប់។	

	វិធានការជាក់ស្តែងបន្ត	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប័នទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				▪ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រខាងលើ ក្រសួងបានខិតខំទាក់ទាញឱ្យមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី និងឈានទៅរៀបចំគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ នៅខេត្តព្រះសីហនុ។ គម្រោងនេះ គឺជាគម្រោងហេដ្ឋារចនាសម្ព័ន្ធសម្រាប់កំណើនប្រកបដោយបរិយាបន្នក្នុងមហាអនុតំបន់មេគង្គ លើកទី២ ដែលផ្តោតសំខាន់លើ (១) ការសិក្សាអំពីហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍, (២) ការសិក្សាពីការទប់ស្កាត់ទឹកកខ្វក់ហូរចូលសមុទ្រ, និង (៣) ការពង្រឹងសមត្ថភាពនិងបំណិនជីវិតសហគមន៍ទេសចរណ៍ និងការគ្រប់គ្រងគម្រោងនិងការពង្រឹងស្ថាប័ន។ - ក្រសួងពាណិជ្ជកម្ម បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ក្នុងវិស័យពាណិជ្ជកម្មដើម្បីជួយសម្រួលដល់បរិយាកាសធុរកិច្ច និងវិនិយោគក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម ហើយច្បាប់ និងអនុក្រឹត្យមួយចំនួនបានបញ្ចប់ និងមួយចំនួនទៀតកំពុងបន្តតាក់តែងបញ្ចប់។ - ក្រសួងបរិស្ថាន - ក្រសួងសាធារណការ និងដឹកជញ្ជូន - ទីស្តីការគណៈរដ្ឋមន្ត្រីបាន÷	

	វិធានការជាក់ស្តែងបន្ត	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប័នទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				▪ ចូលរួមរៀបចំផែនការមេ សម្រាប់អភិវឌ្ឍខេត្តព្រះសីហនុ។ ▪ ចូលរួមរៀបចំក្របខ័ណ្ឌច្បាប់ និយ័តកម្ម និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងយន្តការគ្រប់គ្រងចាំបាច់នានា ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាប៉ូលសេដ្ឋកិច្ចសំខាន់និងជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍។ - រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល÷ ▪ បានពិភាក្សាជាមួយមន្ត្រីជំនាញតំណាងក្រុមហ៊ុនខេមបូឌែរ អ៊ែផត (SCA) មន្ត្រីជំនាញតំណាងក្រុមហ៊ុនខាមបូឌែរ អ៊ែរត្រាហ្ស៊ីកសឺ៊រ៉ីស (CATS) និងនាយកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុដើម្បីសិក្សាពីផែនការអភិវឌ្ឍន៍សេវាកម្មអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។ ▪ បានធ្វើការផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ជូនមន្ត្រីជំនាញកំពុងបម្រើការនៅអាកាសយានដ្ឋានអន្តរ-ជាតិខេត្តព្រះសីហនុ។ ▪ បាននិងកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាព ២០១៨-២០២៥ លើវិស័យអាកាស-ចរស៊ីវិល ដើម្បីចូលរួមអភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង។	

	វិធានការជាក់ស្តែងបន្ត	សូចនាករ	ឆ្នាំគោលដៅ	ស្ថានភាពនៃទទួលខុសត្រូវសម្រេចសម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷ ▪ បានរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០ (មានបញ្ជូលការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច) ▪ បានសហការជាមួយក្រុមហ៊ុន (ខេមបូឌា) ហ្វីប៊ើរ អុបទិច ខមញ្ជូនីខេសិន ណេតវើក (Cambodia Fiber Optic Communication Network Co.,Ltd - CFOCN) ដោយបានកសាងបណ្តាញខ្សែកាបអុបទិកបានប្រវែង ១១ 000 គ.ម. ទូទាំងប្រទេស និងបានកសាងខ្សែកាបអុបទិកឆ្លងកាត់តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ រួចរាល់ ▪ បានសហការជាមួយក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា ដោយបាន÷ (១) កសាងបណ្តាញអុបទិកតភ្ជាប់ពីទីក្រុងភ្នំពេញទៅកាន់ក្រុងព្រះសីហនុ ដែលមានចំណុះ ៤៨ សរសៃ និងមានកម្រិតបញ្ជូន និងទទួលបាន Bandwith ១០ជីហ្គាប៊ីតក្នុង១វិនាទី (២) ស្ថាបនាអគារជាស្ថានីយចែកចាយសេវា និងបានរៀបចំស្ថាបនាបណ្តាញចែកចាយសេវាអ៊ីនធើណែតនិងទូរស័ព្ទ តាមរយៈ	

	វិធានការជាក់ស្តែងបួន	សូចនាករ	ឆ្នាំគោលដៅ	ស្ថាប៉ន់នទទួលខុសត្រូវសម្រាប់សម្រួល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
				បច្ចេកវិទ្យា Gigabit Ethernet Passive Optical Network (GEPON) ដែលនឹងអាចផ្តល់សេវា Triple Play បានទៅថ្ងៃអនាគត, សេវា Internet Protocol Port (IP Port), Domestic Private Leased Circuit (DPLC), International Private Leased Circuit (IPLC), Virtual Private Network (VPN) ▪ បានបញ្ចប់ការធ្វើទំនើបកម្មនៃប្រព័ន្ធប្រៃសណីយ៍ ដើម្បីជួយសម្រួលដល់ប្រព័ន្ធភស្តុភារកម្ម នៅតាមតំបន់ទាំងនោះដោយការបង្កើតប្រព័ន្ធត្រួតពិនិត្យតាមបញ្ជារ (Counter Automation) និងប្រព័ន្ធតាមដានបញ្ជីប្រៃសណីយ៍អន្តរជាតិ (International Postal System) និងប្រព័ន្ធតាមដានសេវាផ្ទេរប្រាក់អន្តរជាតិ (International Financial System)។	

ឧបសម្ព័ន្ធទី២ : ឧបសម្ព័ន្ធ "ឃ": យ៉ាន្ទ្រីសនៃវិធានការគោលនយោបាយ និងផែនការសកម្មភាព

វិធានការគោលនយោបាយផែនការ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថាប័នដឹកនាំមុខ/ធនធានមនុស្ស ត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
១)-ការជំរុញការធានាកន្លែងវិនិយោគ			
ក- បរិយាកាសវិនិយោគ			
- ពិនិត្យឡើងវិញនូវច្បាប់វិនិយោគ ព្រមទាំងវិធានច្បាប់ពាក់ព័ន្ធដទៃទៀត ដោយផ្អែកលើតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម សំដៅលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យឧស្សាហកម្ម រួមមានការទាក់ទាញការវិនិយោគ ការផ្ទេរបច្ចេកវិទ្យា ការបង្កើតការងារ និងបណ្តុះបណ្តាលជំនាញ និងការបង្កើនតម្លៃបន្ថែមនៃឧស្សាហកម្មជារួម	២០១៥	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាន÷ ▪ ស្រាវជ្រាវប្រព័ន្ធនៃការលើកទឹកចិត្តវិនិយោគ និងច្បាប់វិនិយោគ នៃបណ្តាប្រទេសក្នុងតំបន់ដើម្បីជាធាតុចូលសម្រាប់ការរៀបចំច្បាប់ស្តីពីវិនិយោគ។ ▪ រៀបចំសេចក្តីព្រាងច្បាប់វិនិយោគក្នុងកម្រិតបច្ចេកទេស ▪ រៀបចំសិក្ខាសាលាស្តីពីរបបលើកទឹកចិត្តវិនិយោគនៅកម្ពុជា ក្រោមកិច្ចសហប្រតិបត្តិការជាមួយធនាគារពិភពលោក និងសហគមន៍អ៊ីរ៉ុប ព្រមទាំងបានជួបពិភាក្សាការងារពាក់ព័ន្ធនឹងច្បាប់ ស្តីពីវិនិយោគជាមួយស្ថាប័នជាតិ និងអន្តរជាតិជាច្រើន។ ▪ រៀបចំកិច្ចប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីសេចក្តីព្រាងអនុក្រឹត្យស្តីពីការបំពេញបន្ថែមមាត្រា១៥ នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ផ្តល់ការលើកទឹកចិត្តចំពោះគម្រោងពង្រីក ផលិតកម្ម។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន ÷ ▪ កំពុងសិក្សាពិនិត្យអំពីចំណុចដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង សម្រាប់ចូលរួមរៀបចំច្បាប់ស្តីពីវិនិយោគថ្មី ▪ រៀបចំបញ្ជូលប្រការលើកទឹកចិត្តវិនិយោគទៅក្នុងសេចក្តីព្រាង	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បាត់ចំណូលពន្ធដារមួយចំនួន ▪ មិនទាន់ទទួលបានសេចក្តីព្រាងច្បាប់វិនិយោគថ្មី ▪ ស្នើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាធ្វើសេចក្តីព្រាងច្បាប់ស្តីពីវិនិយោគថ្មីមក ក.ស.ហ.វ. ▪ ដំណោះស្រាយពិចារណា Sunset Clause ▪ ការផ្តល់ធាតុចូលលើកិច្ចព្រមព្រៀងអន្តរជាតិទាមទារពេលវេលាសមរម្យ និងសមត្ថភាពបន្ថែម

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		វិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ។ ▪ បានធ្វើវិសោធនកម្មច្បាប់ បទប្បញ្ញត្តិមួយចំនួន ដើម្បីលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិកម្ម, ថាមពល និងការសម្អាតកាកសំណល់រឹងរាវ។ល។ ▪ បានត្រៀមធ្វើវិសោធនកម្មមាត្រាមួយចំនួននៃច្បាប់ស្តីពីសារពើពន្ធ ដើម្បីគាំទ្រដល់ការទាក់ទាញវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។ ▪ បានចូលរួមកែសម្រួល និងផ្តល់ធាតុចូលក្នុងកញ្ចប់ឯកសារកិច្ចព្រមព្រៀងប្រេងកាត។ ▪ បានចូលរួមកែសម្រួល និងផ្តល់ធាតុចូលក្នុងកិច្ចព្រមព្រៀងស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ។ ▪ បានរៀបចំប្រកាសរួមជាមួយក្រសួងស្ថាប័នប្រមូលចំណូលមិនមែនសារពើពន្ធសំខាន់ៗ ដូចជារដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងរ៉ែ និងថាមពល, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងពាណិជ្ជកម្ម។ល។ ដើម្បីកំណត់តម្លៃសេវាសំខាន់ៗមួយចំនួន, ឈ្នួលដី, សួយសារជាដើម។ ▪ បានចូលរួមពិនិត្យ ផ្តល់មតិ និងកែសម្រួលសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការប្រមូលចំណូលសួយសារធនធានរ៉ែពីការប្រើប្រាស់ធនធានរ៉ែសំណង់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ។ - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷ ▪ បានបញ្ចប់ការរៀបចំច្បាប់ស្តីពីទូរគមនាគមន៍ ហើយរដ្ឋសភា	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		បានអនុម័តនិងបានប្រកាសដាក់ឱ្យប្រើដោយព្រះមហាក្សត្រ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥។ ▪ បានបញ្ចប់សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ ការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ។	
- ពិនិត្យឡើងវិញនិងកែសម្រួលលក្ខខណ្ឌ វិនិច្ឆ័យពិសេសសម្រាប់ទាក់ទាញ" គម្រោងវិនិយោគសក្តានុពលនិងមានគុណភាព" ដែលផ្ដល់ផលវិជ្ជមាននិងតម្លៃបន្ថែម សម្រាប់ការបើកផ្លូវដល់ការអភិវឌ្ឍ និងការទាក់ទាញឧស្សាហកម្មថ្មីៗមកកម្ពុជា	២០១៥	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានធ្វើការពិភាក្សាផ្ទៃក្នុងពីលក្ខណៈវិនិច្ឆ័យ នានាសម្រាប់ទាក់ទាញគម្រោងវិនិយោគដែលមានសក្តានុពលនិងគុណ ភាព និងបានបញ្ជូលទៅក្នុងសេចក្ដីព្រាងស្ដីពីច្បាប់ស្ដីពីវិនិយោគ។ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ ▪ បានកំពុងពិនិត្យពិចារណាអំពីលក្ខខណ្ឌជ្រើសរើសគុណភាព គម្រោងក្នុងច្បាប់វិនិយោគថ្មី។ ▪ បានចូលរួមផ្ដល់ធាតុចូលក្នុងការសិក្សាចំពោះច្បាប់វិនិយោគថ្មី ជាមួយធនាគារពិភពលោក និងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ ។ - ក្រសួងឧស្សាហកម្មនិងសិប្បកម្ម - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចូលរួមផ្ដល់ធាតុចូលលើ ការពិនិត្យ និងកែសម្រួលលក្ខខណ្ឌវិនិច្ឆ័យពិសេសសម្រាប់ទាក់ទាញ ការវិនិយោគក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន។	
- បន្តពង្រឹងបរិស្ថានអនុគ្រោះសម្រាប់ការ វិនិយោគ និងធុរកិច្ច តាមរយៈការបន្តកែលម្អ ក្របខ័ណ្ឌគតិយុត្ត ក្របខ័ណ្ឌអភិបាលកិច្ च និងប្រសិទ្ធភាពនៃស្ថាប័នសាធារណៈពាក់ព័ន្ध	២០១៥	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បានបង្កើនប្រសិទ្ធភាពច្រកចេញ-ចូលតែមួយ និងបានចុះបញ្ជី គម្រោងវិនិយោគចំនួន១៨១នៅឆ្នាំ២០១៥ និង១៣១ នៅឆ្នាំ ២០១៦	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ ផ្នែកឯកជនគួរលើកទឹកចិត្ត[illegible] ក្នុងវេទិកាមុនទីបានសន្ទនា[illegible] ស្រាយនៅយន្តការ[illegible]

ទិសដៅការគោលនយោបាយផែនការ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ពិសេស ការពង្រឹងយន្តការ ***"ច្រកចេញចូលតែមួយ"*** នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យក្លាយជាយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទាក់ទាញវិនិយោគ		▪ បានពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរបស់ ក.អ.ក. តាមរយៈការតាមដាន និងវិភាគនូវប្រសិទ្ធភាពនៃការផ្តល់សេវាបច្ចុប្បន្ន និងដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដូចជាការកំណត់សេវាអាទិភាពជាដើម ▪ បាននិងកំពុងរៀបចំគេហទំព័រថ្មី និងបាននិងកំពុងរៀបចំការចុះបញ្ជីគម្រោងវិនិយោគតាមប្រព័ន្ធអេឡិកត្រូនិក, ការដាក់ពាក្យស្នើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ ចំពោះវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងតាមប្រព័ន្ធអេឡិចត្រូនិក, និងការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋតាមប្រព័ន្ធអេឡិកត្រូនិក។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បានរៀបចំកិច្ចប្រជុំយន្តការភាពជាដៃគូគយ-ផ្នែកឯកជនលើកទី ៦ នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ និងបានពិនិត្យ និងដោះ-ស្រាយបញ្ហា និងសំណូមពរចំនួន ១៦ របស់វិស័យឯកជនបន្ថែមលើបញ្ហា និងសំណូមពរ ៣០ ដែលត្រូវបានដោះស្រាយរួចក្នុងកម្រិតក្រុមការងារបច្ចេកទេស CPPM (៤៣ បានដោះស្រាយរួច និង ៣ ទៀតត្រូវដោះស្រាយតាមវេទិកាផ្សេងទៀត) ▪ បានចេញសេចក្តីណែនាំពីរតាមស្មារតីនៃកិច្ចប្រជុំ CPPM ទាំងពីរពាក់ព័ន្ធនឹង (១) ការបិទផ្សាយលំហូរនីតិវិធី និងស្តង់ដាការងារ, (២) ការអនុញ្ញាតឱ្យលើទំនិញច្រើនម្ចាស់ផ្ទុកក្នុងកុងតឺន័រ (Less Than Container Load), (៣) ការកែលម្អគេហទំព័រគយ, (៤) ការពង្រឹងប្រសិទ្ធភាពនៃការបង្ក្រាបបទល្មើស, (៥) ការអនុញ្ញាត	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ឱ្យនាំចេញទំនិញកាត់ដេរមានម្ចាស់តែមួយក្នុងរថយន្តមានលក្ខណៈសម្បត្តិជាកុងតឺន័រ, (៦) ការទទួលយកតម្លៃប្រកាសសម្រាប់ QIP និង (៧) ការបង្កើត Hotline សម្រាប់តវ៉ាតាមមាត់ច្រក។ - ក្រសួងពាណិជ្ជកម្ម÷ ▪ បានរៀបចំបង្កើតឱ្យមានសភាពាណិជ្ជកម្មតាមរាជធានី ខេត្ត ដោយមកដល់បច្ចុប្បន្នមានសភាពាណិជ្ជកម្មចំនួន ១៥ មណ្ឌល ▪ បានប្រមូលផ្តុំចងក្រងផលិតករ កសិករ ជាបណ្តាញអាជីវកម្មជួចជាសមាគមជំនួយមីចំនួន ១៤ ▪ បានរៀបចំបង្កើតសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជា ដែលប្រមូលសមាគមជលផលសមុទ្រចំនួន៥ នៅខេត្តកំពត ព្រះសីហនុ និងកោះកុង។ ▪ បានរៀបចំបង្កើតសមាគមសូត្រចំនួន១, សមាគមក្រូចពោធិ៍សាត់ ១, សមាគមស្វាយកែវរមៀត១, សមាគមពងទាកូន១ ត្រូវបានបង្កើតនៅឆ្នាំ២០១៥ និង២០១៦។ ▪ បានបង្កើតកម្មវិធីបង្កើនសមត្ថភាពសហព័ន្ធស្រូវអង្ករកម្ពុជាដើម្បីមានលទ្ធភាពអាចដំណើរការនិងទទួលខុសត្រូវលើការងារអនុវត្តផែនការរបស់ខ្លួន ជាពិសេសពង្រឹងយន្តការនៃការត្រួតពិនិត្យគុណភាពអង្ករកម្ពុជា និងជំរុញការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិឱ្យបានច្រើន។ - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ÷ ▪ បានកែលម្អនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតបង្កើតរោងសន្ទ្ធិធិលក់ចែកចាយផល និងអនុផលព្រៃឈើ ឬរោងសិប្បកម្ម	

ទិដ្ឋានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		កែច្នៃផល និងអនុផលព្រៃឈើប្រភេទតូច ▪ បានចងក្រងនិងរៀបចំផែនទីចង្អុលបង្ហាញតំបន់ផលិតកម្មដំណាំ ចំនួន ៧មុខ (សណ្តែកបាយ សណ្តែកដី ពោត ដំឡូងមី ស្វាយ ម្រេច និងល្ង) ▪ បានរៀបចំកិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរព័ត៌មាន និងបទពិសោធ ស្តីពីដំណើរការ និងការធ្វើពាណិជ្ជកម្មផលិតផលឈើស្របច្បាប់ ជាមួយគណៈប្រតិភូរដ្ឋបាលព្រៃឈើនៃសាធារណរដ្ឋប្រជាមានិតចិន និងគណៈប្រតិភូនៃក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ▪ បាននិងកំពុងរៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីផលិតកម្ម និងសុខភាពសត្ត ▪ បាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួន ជាពិសេស សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិនិងភ្ជួតតាមអនាម័យ និងសេចក្តីព្រាងអនុក្រឹត្យ ប្រកាសអន្តរក្រសួង ប្រកាសក្រសួងមួយចំនួនទៀត ព្រមទាំងផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍន៍ពួជស្រូវនៅកម្ពុជា។ - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷ ▪ បានប្រជុំពិភាក្សាការងារស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោង DMC និងកិច្ចប្រជុំអន្តរក្រសួងជាមួយប្រតិបត្តិករទូរគមនាគមន៍ ស្តីពីការងារពាក់ព័ន្ធមជ្ឈមណ្ឌល DMC។ ▪ ចូលរួមប្រជុំពិភាក្សាដោះស្រាយអំពីផែនការលម្អិត និងនីតិវិធីទម្លាក់ចូលក្នុងដីរាល់ខ្សែកាបទូរគមនាគមន៍ដែលកំពុងព្យួរតាម	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		បង្គោលភ្លើងក្នុងរាជធានីភ្នំពេញ។ - ក្រសួងមហាផ្ទៃ÷ ▪ បានបន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ▪ បានបន្តជំរុញកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋ-បាលថ្នាក់ក្រោមជាតិ ▪ បានរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍធនធានមនុស្ស របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ▪ បន្តធ្វើវិមជ្ឈការហិរញ្ញវត្ថុ ▪ បានពង្រឹងពង្រីកយន្តការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ▪ បានពង្រឹងយន្តការគណនេយ្យភាពរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ ▪ បានបង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យច្រកចេញចូលតែមួយចំនួន៤៦ (ក្រុង៣២ ស្រុក២ និងខណ្ឌ១២ ក្នុងខេត្ត២៤ និងរាជធានីភ្នំពេញ)។ ▪ បានផ្តល់សេវារដ្ឋបាលចំនួន ១៨៦ប្រភេទ ដែលបានទទួលប្រតិភូកម្មមុខងារពីក្រសួង ស្ថាប័នចំនួន១២ រួមមាន÷ វិស័យសាធារណការ និងដឹកជញ្ជូន ពាណិជ្ជកម្ម វប្បធម៌ និងវិចិត្រសិល្ប: ទេសចរណ៍ ឧស្សាហកម្ម រ៉ែ និងថាមពល សំណង់ សុខា-ភិបាល កសិកម្ម អប់រំ នីតិវិធីកូលកម្ម អត្រានុកូលដ្ឋាន និងសុរិយោដី។	

ទំហានការគោលនយោបាយជំនួការ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថាប័នដឹកនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		- រដ្ឋបាលរាជធានីភ្នំពេញ÷ ▪ បានចេញសេចក្តីសម្រេចលេខ ១៩២ សសរ.ធរិ ចុះថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៥ រៀបចំបង្កើតឲ្យមានអង្គភាពទទួលបន្ទុកសម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយនៅថ្នាក់រាជធានី ▪ បានសហការគ្នាជាមួយអនុគណៈកម្មវិធីការវិនិយោគរាជធានី និងមន្ទីរ-អង្គភាពជំនាញផ្សេងៗក្នុងការទាក់ទាញអ្នកវិនិយោគិន និងចុះបញ្ជីសំណើវិនិយោគរបស់ក្រុមហ៊ុនថ្មីៗដោយផ្តល់ជូននូវយន្តការសម្របសម្រួលកាត់បន្ថយពេលវេលា ថវិកានិងការលើកទឹកចិត្ត តាមរយៈយន្តការច្រកចេញ-ចូលតែមួយអនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋាន ▪ បានកាត់បន្ថយការិយាធិបតេយ្យក្នុងការចុះបញ្ជីតាមរយៈការបង្កើតច្រកចេញចូលតែមួយក្នុងគោលបំណងកាត់បន្ថយពេលវេលា និងថវិកាក្នុងការបំពេញបែបបទ។	
- ធ្វើវិចារណកម្មលើការលើកទឹកចិត្តបន្ថែមចំពោះគម្រោងវិនិយោគដែលរួមចំណែកក្នុងការបណ្តុះបណ្តាលជំនាញ ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍	មធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បានពិភាក្សា និងបានដាក់បញ្ចូលការលើកទឹកចិត្តបន្ថែមចំពោះគម្រោងវិនិយោគដែលបានចូលរួមក្នុងការបណ្តុះបណ្តាលជំនាញ ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ នវានុវត្តន៍ទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីវិនិយោគ។ ▪ រៀបចំកិច្ចប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីសេចក្តីព្រាងអនុក្រឹត្យស្តីពីការបំពេញបន្ថែមមាត្រា១៥នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការ	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ ស្នើ ក.អ.ក ធ្វើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិ-យោគ ពិសេសក្រុមទំនុកចិត្ត ឬទស្សនាទានស្តីពីការផ្តល់ជាយលើកទឹកចិត្ត ទាំងនេះ។ ▪ ទំនិញពន្ធអាករជាអនុភាពមួយចំនួនត្រូវបានលក់ ផ្ទេរ និងជួសជុ

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		អនុវត្តច្បាប់ស្តីពីរិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ផ្តល់ការលើកទឹកចិត្តចំពោះគម្រោងពង្រីកផលិតកម្ម។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ កំពុងពិនិត្យអំពីក្របខ័ណ្ឌលើកទឹកចិត្តផ្នែកពន្ធដារ និងគយ។ ▪ បានរៀបចំប្រកាសលេខ១០៥ សហវ.ប្រក ស្តីពីការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ។ ▪ បានរៀបចំប្រកាសលេខ១១៣ សហវ.ប្រក ស្តីពីការគ្រប់គ្រងឯកសារបញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀតទាក់ទងនឹង ការនាំចេញ នាំចូល។ ▪ បានរៀបចំប្រកាសលេខ៩២៨ សហវ.ប្រក ស្តីពីការនាំចូលបណ្ណោះអាសន្នតាមរបបប្រវេសន៍កាលិក។ ▪ បានរៀបចំប្រកាសលេខ៣៨៨ សហវ.រក ស្តីពីយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ។ ▪ បានបញ្ចប់ការសិក្សាដោយសង្ខេបស្តីពីការកែទម្រង់គោលនយោបាយពន្ធអាករ។ ▪ បានចូលរួមយ៉ាងសកម្មក្នុងការផ្តល់យោបល់ និងសម្របសម្រួលការកែតម្រូវបន្ទាត់ពន្ធសម្រាប់ឆ្នាំ២០១៧។ ▪ បានបញ្ចប់ការពិនិត្យឡើងវិញលើចំណាយសាធារណៈស្តីពីចំណាយពន្ធ។ ▪ បានចូលរួមកសាង និងជាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយ និង/ឬលុបបំបាត់ពន្ធគយក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន	ចេញដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយ។

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពខ្សត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងទៀតជាធរមាន (អនុក្រឹត្យលេខ១៧១ អនក្រ.បក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥)។ ▪ បានផ្តល់ធាតុចូលសម្រាប់រៀបចំលិខិតបទដ្ឋាន ក្នុងការផ្តល់ការលើកទឹកចិត្តចំពោះគម្រោងពង្រីកផលិតកម្ម។ ▪ បានចូលរួមក្នុងការពង្រីងនិងតាមដានការអនុវត្តគម្រោងវិនិយោគតាមរយៈការវាយតម្លៃ និងផ្តល់ជូននូវវិញ្ញាបនបត្របញ្ជាក់អំពីកម្រិតអនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានចូលរួមធាតុចូលលើការរៀបចំបទប្បញ្ញត្តិទាក់ទិននឹងការលើកទឹកចិត្តខាងផ្នែកពន្ធដារ និងពន្ធគយលើគម្រោងវិនិយោគក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។	
- ពង្រីងសមត្ថភាពស្ថាប័ន និងសមាហរណកម្ម មុខងារគ្រប់គ្រង និងទាក់ទាញវិនិយោគ ជាមួយមុខងារជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលស្ថិតក្រោមសមត្ថកិច្ចរួមនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈការរៀបចំផែនការសកម្មភាពរយៈពេលខ្លី និងមធ្យម ការកែទម្រង់ និងទំនើបកម្មស្ថាប័ន និងការលើកកម្ពស់សមត្ថភាពមន្ត្រី ដើម្បីប្រកបដោយប្រសិទ្ធភាពទៅនឹងចក្ខុវិស័យ និងគោលដៅនៃគោលនយោបាយអភិវឌ្ឍន៍	២០១៥ ទៅមធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ÷ ▪ បាននិងកំពុងចាប់ផ្តើមរៀបចំកែសម្រួលរចនាសម្ព័ន្ធអភិបាលកិច្ចស្ថាប័ន និងពង្រីងសមត្ថភាពមន្ត្រីក្នុងការរៀបចំ អនុវត្ត និងពិនិត្យការតាមដានអនុវត្តគោលនយោបាយនេះ បន្ថែមលើតួនាទីជាប្រតិបត្តិករ។ ▪ បាននិងកំពុងសិក្សា និងរៀបចំផែនការសកម្មភាពរយៈពេលខ្លី និងរយៈពេលមធ្យមពាក់ព័ន្ធនឹងការគ្រប់គ្រង និងការទាក់ទាញវិនិយោគ ព្រមទាំងការជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម។ ▪ បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការជំរុញ និងកិច្ចសម្រួលការវិនិយោគ ជូនមន្ត្រីកំពុងបម្រើការនៅអនុគណៈកម្មាធិ-	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
វិស័យឧស្សាហកម្ម		ការ វិនិយោគខេត្ត និងតំណាងផ្នែកឯកជន ទាំង២៥ រាជធានី-ខេត្តសំដៅធានាគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាដល់វិនិយោគិនឱ្យកាន់តែមានភាពទាក់ទាញ និងមានទំនុកចិត្តពីវិនិ-យោគិនបន្ថែមទៀត។	
- ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងវិនិយោគ ដើម្បីធានាការគោរពគោលការណ៍ និងលក្ខខណ្ឌនៃកិច្ចសន្យាវិនិយោគ ព្រមទាំងអនុលោមភាពនៃច្បាប់កម្ពុជាជាធរមាន	២០១៥ ទៅមធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាន÷ ▪ រៀបចំប្រកាសអន្តរស្ថាប័នរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការបង្កើតគណៈកម្មការដើម្បីចុះពិនិត្យ ការអនុវត្ត កិច្ចសន្យាវិនិយោគកោះ និងរមណីយដ្ឋាន ។ ▪ បន្តតាមដានក្រុមហ៊ុនគ្មានសកម្មភាព និងបិទទ្វារដោយមិនបានបំពេញបែបបទតាមនីតិវិធីនៃច្បាប់មក "ក.អ.ក."។ ▪ បង្កើនល្បឿន និងភាពសកម្មថែមទៀត ក្នុងការធ្វើបច្ចុប្បន្នកម្ម ▪ តួលេខវិនិយោគ ដើម្បីភ្ជាប់ឱ្យបានន្ធវ៉ុនវិនិយោគ និងការប្រើប្រាស់កម្លាំងពលកម្មជាក់ស្តែងរបស់ក្រុមហ៊ុននីមួយៗ ដោយបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ។ ▪ រៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យការអនុវត្តគម្រោងរបស់បណ្តាក្រុមហ៊ុន ដែលបានចុះកិច្ចសន្យាវិនិយោគលើកោះនានា នៅខេត្តកែប កំពត ព្រះសីហនុ និងកោះកុង។ ▪ បន្តតាមដាន និងជំរុញការអនុវត្តជាក់ស្តែងរបស់បណ្តាតំបន់សេដ្ឋកិច្ចពិសេស ដែលបានទទួលអនុក្រឹត្យបង្កើតតំបន់សេដ្ឋកិច្ចពិសេសពីរាជរដ្ឋាភិបាលឱ្យស្របតាមគោលការណ៍កំណត់។ ▪ បន្តតាមដានការអនុវត្តជាក់ស្តែងរបស់បណ្តាក្រុមហ៊ុនវិនិយោគតាមបណ្តាកោះ-ឆ្នេរ ដែលបានចុះហត្ថលេខារួច ដើម្បីជំរុញការ	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ គណៈកម្មការនេះ មានភារកិច្ចតែលើការទាក់ទាញ្ជ្ជ្ជ្ជ្ជ្ជ្ជ ▪ ទំនិញពន្ធអាករជាបន្ទុកមួយចំនួនត្រូវបានលក់ ផ្ទេរ និងបោះបង់ចោលដោយគ្មានការអនុញ្ញតជាមុនពីរដ្ឋបាលគយ។ ▪ ទំនិញពន្ធអាករបន្ទុករដ្ឋមួយចំនួនត្រូវបានប្រើប្រាស់ខុសពីគោលដៅកំណត់។

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		អនុវត្តស្របតាមគោលការណ៍កំណត់។ ចំពោះក្រុមហ៊ុនណាដែលពុំបានអនុវត្តគម្រោងតាមខ្លឹមសារកិច្ចសន្យាទេនោះ ក.អ.ក នឹងលើកសំណើសុំលុបកិច្ចសន្យា។ - ក្រសួងបរិស្ថាន បាន÷ ▪ បញ្ចប់សេចក្ដីព្រាងច្បាប់ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដើម្បីការពារបរិស្ថាន និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ▪ បានធ្វើបច្ចុប្បន្នកម្មប្រភពបំពុល និងព្យាករណ៍ការបំពុលពីប្រភព (Industrial Pollution Projection System, IPPS) រោងចក្រ សហគ្រាស ទីតាំងអាជីវកម្ម និងសេវាកម្ម ដែលត្រូវធ្វើការកែលម្អ និងបំពេញបន្ថែមទៅតាមសេចក្ដីចែងនៃបទប្បញ្ញត្តិច្បាប់ក្នុងគោលដៅជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មដោយរក្សាបាននិរន្តរភាពបរិស្ថាន។ ▪ បានបង្កើន និងពង្រឹងសកម្មភាពចុះត្រួតពិនិត្យតាមដាន និងធ្វើអធិការកិច្ចទៅតាមទីតាំងប្រភពបំពុលទូទាំងប្រទេស ជំរុញការអនុវត្តច្បាប់ ទប់ស្កាត់ការបំពុលបរិស្ថាន និងអនុវត្តវិធានការច្បាប់លើបទល្មើសបំពុលបរិស្ថាន រួមជាមួយសកម្មភាពដោះស្រាយបណ្ដឹងរបស់ប្រជាពលរដ្ឋលើករណីបង្កផលប៉ះពាល់ពីការបំពុលបរិស្ថានមកលើសុខភាពសាធារណៈពីបណ្ដារោងចក្រ។ ▪ បានប្រជុំក្រុមការងារនាយកដ្ឋាន ពិនិត្យ និងផ្ដល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងពេញលេញបានចំនួន ៨៨គម្រោង ក្នុងនោះមាន IESIA	

វិធានការគោលនយោបាយជំនួការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ចំនួន ៤៥គម្រោង និង ESIA ចំនួន ៤ពាគម្រោង ដែលជាគម្រោងរដ្ឋចំនួន ៦គម្រោង និងជាគម្រោងឯកជនចំនួន ៨២គម្រោង។ ▪ បានរៀបចំលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង និងពេញលេញបានចំនួន ៣៨គម្រោង ដោយក្នុងនោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង មានចំនួន ១៩គម្រោង និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ មានចំនួន ១៩គម្រោង។ ក្នុងចំណោមនោះ មានគម្រោងរដ្ឋចំនួន ៦គម្រោង និងគម្រោងឯកជន ចំនួន ៣២គម្រោង។ ▪ បានរៀបចំលិខិតឯកភាពលើកិច្ចសន្យាការពារបរិស្ថានបានចំនួន ១៨ពាគម្រោង។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បានរៀបចំប្រកាសអន្តរស្ថាប័នរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បង្កើតគណៈកម្មការដើម្បីចុះពិនិត្យការអនុវត្តកិច្ចសន្យាវិនិយោគកោះ និងរមណីយដ្ឋាន។ ▪ បានផ្សព្វផ្សាយបទប្បញ្ញត្តិដល់ធុរជនពាក់ព័ន្ធការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធនិងអាករ, ការគ្រប់គ្រងឯកសារបញ្ជីគណនេយ្យ កំណត់ត្រានិងព័ត៌មានផ្សេងទៀតទាក់ទងនឹងការនាំចេញ-នាំចូល ព្រមទាំងការនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិក និងយន្តការសវនកម្ម ក្រោយពេលបញ្ចេញទំនិញពីគយ។ ▪ បានវាយតម្លៃទំហំទំនិញនាំចូល និងទឹកប្រាក់ពន្ធ និងអាករជា	

ទិសដៅការគោលនយោបាយវិនិយោគ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		បន្ទុករដ្ឋរបស់ QIP តាមខែនីមួយៗជាប្រចាំ។ ▪ បានពង្រីកយន្តការសវនកម្មគយតាមអាជីវកម្មដ្ឋានពីវិស័យកាត់-ដេរទៅវិស័យ និងរបបគយផ្សេងទៀត ចំនួន ១៧ក្រុមហ៊ុន តាមទិន្នន័យឆ្នាំ២០១៥។ ▪ បានលើកកម្ពស់ការយល់ដឹង និងការទទួលខុសត្រូវរបស់សវនករគយ ១៥៨រូប និងបុគ្គលរងសវនកម្ម ១៣០រូប ពីយន្តការសវនកម្មគយតាមរយៈវគ្គហ្វឹកហ្វឺន ២វគ្គ និងសិក្ខាសាលា ២ដង។ ▪ បានចូលរួមក្នុងការពង្រីង និងតាមដានការអនុវត្តគម្រោងវិនិ-យោគ តាមរយៈការវាយតម្លៃ និងផ្តល់ជូននូវវិញ្ញាបនបត្របញ្ជាក់អំពីកម្រិតអនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ។ ▪ បានចូលរួមពិនិត្យ ផ្តល់មតិ និងកែសម្រួលកិច្ចព្រមព្រៀងសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែមួយចំនួន ដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគសម្បទានរ៉ែ។ ▪ បានចូលរួមពិនិត្យ និងរៀបចំគំរូកិច្ចព្រមព្រៀងសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែដោយផ្តោតលើទិដ្ឋភាពហិរញ្ញវត្ថុ និងតម្លាភាពចំណូលចូលក្នុងថវិការដ្ឋ។	
- ពង្រីងយន្តការផ្តល់សេវាថែទាំវិនិយោគ ដោយផ្អែកលើឧត្តមានុវត្តន៍ជាសកល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសម្រួលការវិនិយោគ និងដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិនក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ	២០១៥ ទៅមធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បាននិងកំពុងរៀបចំកម្រងសំណួរ និងក្រុមការងារចុះប្រមូលព័ត៌មានក្នុងគោលបំណងតាមដាន និងស្វែងយល់ពីបញ្ហាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលបាននិងកំពុងជួបប្រទះក្នុងប្រតិបត្តិការរបស់ខ្លួន ដើម្បីបានជាធាតុចូលសម្រាប់រៀបចំយុទ្ធ-សាស្ត្រ និងសេវាថែទាំការវិនិយោគ។	

ទិសដៅការគោលនយោបាយ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពសង្ខេបអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រដែលបម្រើឱ្យការអនុវត្តសេវាថែទាំការវិនិយោគ (Aftercare Service) ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់កិច្ចសម្រួលការវិនិយោគ និងដោះ-ស្រាយបញ្ហាប្រឈមរបស់វិនិយោគិនទៅគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ។	
- បន្តពង្រឹងប្រសិទ្ធភាពនៃ ***"វេទិការាជរដ្ឋាភិបាលជាមួយនឹងវិស័យឯកជន"*** ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម	២០១៥ ទៅមធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងពិភាក្សា និងរៀបចំយន្តការផ្ទៃ-ក្នុងដើម្បីគាំទ្រដល់វេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន ព្រមទាំងបានចូលរួមកិច្ចប្រជុំក្រុមការងារតាមវិស័យ។	
- រៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ និងវិធានការជាក់ស្តែង ដើម្បីជំរុញការផ្សព្វផ្សាយ និងទាក់ទាញការវិនិយោគ ដោយផ្តោតលើប្រទេសគោលដៅមួយចំនួន និងកំណត់ប្រភេទឧស្សាហកម្មអាទិភាពច្បាស់លាស់	២០១៥ ទៅមធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បាននិងកំពុងរៀបចំវីដេអូផ្សព្វផ្សាយដើម្បីទាក់ទាញការវិនិយោគដែលផ្តោតទៅលើប្រទេសគោលដៅមួយចំនួនដូចជាជប៉ុន និងចិន។ ▪ បាននិងកំពុងបន្តកិច្ចសហការជាមួយអ្នកអភិវឌ្ឍន៍តំបន់លើកិច្ចការផ្សព្វផ្សាយ និងទាក់ទាញវិនិយោគិនថ្មីៗឱ្យមកបណ្តាក់ទុនវិនិយោគនៅតំបន់នានាដែលបានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងមានដំណើរការរដ្ឋបាលក្នុងតំបន់រួច។ ▪ បានរៀបចំវេទិកាធុរកិច្ចកម្ពុជា-ចិន ក្រោមប្រធានបទ÷ កម្ពុជាព្រះរាជាណាចក្រនៃកាលានុវត្តភាព "ខ្សែក្រវាត់មួយ-ផ្លូវមួយ" ក្រោមអធិបតីភាព សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ▪ បានចូលរួមវេទិការវិនិយោគកម្ពុជា-កូរ៉ា ជាមួយគណៈប្រតិភូវិនិ-	

ទិសដៅការគោលនយោបាយ/ផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ/ការអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		យោគកូរ៉ែ ដែលដឹកនាំដោយមជ្ឈមណ្ឌលអាស៊ាន-កូរ៉ែ។ ▪ បានរៀបចំ និងចូលរួមសកម្មភាព ឬសិក្ខាសាលា ឬវេទិកា ទាំងក្នុង ទាំងក្រៅប្រទេស ទាក់ទងនឹងការទាក់ទាញវិនិយោគ។	
- ពិនិត្យឡើងវិញនូវយន្តការផ្តល់ព័ត៌មាន វិនិយោគ ដោយយកចិត្តដាក់លើភាពងាយស្រួលក្នុងការទទួលព័ត៌មាន ពិសេស ការកែលម្អមាតិកាព័ត៌មាន ដែលផ្អែកលើប្រពិកម្ម តបនៃអ្នកប្រើប្រាស់។	២០១៥	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បានធ្វើបច្ចុប្បន្នកម្មជាប្រចាំនៅលើគេហទំព័ររបស់ខ្លួន និងបង្ហាញស្តីពីការជំរុញការទាក់ទាញវិនិយោគឱ្យកាន់តែមានភាពទាក់ទាញ និងផ្តល់ព័ត៌មានកាន់តែគ្រប់ជ្រុងជ្រោយជូនវិនិយោគិន។ ▪ បានចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងការដាក់ឱ្យប្រើប្រាស់ការផ្តល់ព័ត៌មានសេវាសាធារណៈ (សេវាអាទិភាព) តាមបច្ចេកវិទ្យាទូរស័ព្ទស្មាតហ្វូន។ ▪ បាននិងកំពុងរៀបចំគេហទំព័រថ្មីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។	
ខ- ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងការរៀបចំតំបន់ឧស្សាហកម្ម			
- ពិនិត្យឡើងវិញអំពីក្របខ័ណ្ឌលើកទឹកចិត្ត សម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទាំងក្រុមហ៊ុនបរទេស ទាំងក្រុមហ៊ុនក្នុងស្រុក និងទាំងសហគ្រាសធុនតូច និងមធ្យម	២០១៥	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋ-កិច្ចពិសេសក្នុងកម្រិតបច្ចេកទេស ដោយបានធ្វើការគិតគូរផ្តល់ការលើកទឹកចិត្តពិសេសជូនក្រុមហ៊ុនទាំងឡាយរាប់ទាំងសហគ្រាសធុនតូច និងមធ្យម ដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បានដាក់ចេញនូវយន្តការអនុគ្រោះពន្ធលើប្រាក់ចៀសវាង ចំពោះអត្ថប្រយោជន៍បន្ថែម សម្រាប់ចំណាយលើការដឹកជញ្ជូន, ស្នាក់នៅ និងហូបចុករបស់កម្មករនិយោជិត (សារាចរលេខ ០១១ សហវ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍)។	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ពុំទាន់បានទទួលសេចក្តីព្រាងច្បាប់នេះនៅឡើយ។

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានលើកលែងពន្ធលើអចលនទ្រព្យសម្រាប់ក្រុមហ៊ុន ដែលមានទីតាំងស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ហើយដែលបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម (ប្រកាស លេខ ៤៩៣ សហវ.ប្រក ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ)។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- ចាត់វិធានការ និងជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀតពីវិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាទីតាំងនៃតំបន់សេដ្ឋកិច្ចពិសេសដែលបានទទួលគោលការណ៍ពីរាជរដ្ឋាភិបាលកន្លងមក សំដៅធានាឱ្យមានភាពទាក់ទាញ និងការចាប់អារម្មណ៍ពីសំណាក់វិនិយោគិន ដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្មក្នុងតំបន់ទាំងនោះ	២០១៥ មធ្យម ទៅវែង	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងជំរុញអ្នកអភិវឌ្ឍតំបន់ឱ្យបន្តកាន់តែសកម្មថែមទៀតក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសរៀងៗខ្លួន។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំ និងអនុវត្តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនដែលនឹងរួមចំណែកយ៉ាងសំខាន់ដល់ការកៀរគរទុនវិនិយោគរបស់វិស័យឯកជនក្នុងការចូលរួមវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ - រដ្ឋបាលខេត្តស្វាយរៀង បានសហការជាមួយបណ្តាភាគីពាក់ព័ន្ធ និងផ្នែកឯកជន ក្នុងការគាំទ្រការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មដែលមានស្រាប់ និងឬបង្កើតថ្មីក្នុងដែនសមត្ថកិច្ច/ខេត្តស្វាយរៀង។	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ។ - រដ្ឋបាលខេត្តស្វាយរៀង÷ មន្ទីរ អង្គភាពពាក់ព័ន្ធមួយចំនួនពុំទាន់អនុវត្តបានល្អ ប្រសើរស្រុបតាមផែនការសកម្មភាពដែលបានកំណត់។
- ជំរុញការបង្កើតកម្រងឧស្សាហកម្ម និងសួនឧស្សាហកម្មធំៗ តាមរយៈការអនុម័ត ***"ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស"*** សំដៅអភិវឌ្ឍតំបន់ទាំងនោះឱ្យឈានដល់កម្រិតស្តង់ដាអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ប្រព័ន្ធ	២០១៥	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសក្នុងកម្រិតបច្ចេកទេស ដោយបានគិតគូរគ្រប់ជ្រុងជ្រោយពីប្រព័ន្ធគ្រប់គ្រងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត។	

វិធានការគោលនយោបាយវិនិយោគ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
គ្រប់គ្រងមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់-ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និងធាតុចូលផ្សេងៗ កិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្ម ព្រមទាំងការលើកទឹកចិត្ត និងវិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដើម្បីជំរុញការវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស		- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ បានសិក្សារៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីភណ្ឌាគារ មានដែនកំណត់សម្រាប់គ្រប់គ្រងទំនិញ ដែលផលិតក្នុងតំបន់សេដ្ឋកិច្ចពិសេស (សេចក្តីព្រាងច្បាប់អាករពិសេស)។ ▪ បានរៀបចំប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម ចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ, វាយនភណ្ឌ, ស្បែកជើង, កាបូប, និងមួក (ប្រកាសលេខ៣១១ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក)។ - រដ្ឋបាលខេត្តស្វាយរៀង បានជំរុញឱ្យតំបន់សេដ្ឋកិច្ចពិសេសមេនហាធេនសាងសង់អាងចម្រោះទឹកស្នុយមួយកន្លែងលើផ្ទៃដី ១៥ ០០០ម^{២} អាចច្រោះបាន ១០ ០០០ម^{៣}/ថ្ងៃ។	
- បន្តអភិវឌ្ឍតំបន់ឧស្សាហកម្មតាមបណ្តាខេត្ត ដែលជាមូលដ្ឋានប្រមូលផ្តុំនៃសហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសទាំងនោះ ពិសេស តាមរយៈការផ្តល់អាទិភាពលើការ	មធ្យម ទៅ វែង	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានពិភាក្សា និងដាក់បញ្ចូលការលើកទឹកចិត្តមួយចំនួនដោយផ្អែកតាមតំបន់ (ឧទាហរណ៍÷ តំបន់ឧស្សាហកម្មតាមខេត្ត) ទៅក្នុងច្បាប់ស្តីពីវិនិយោគ។ - រដ្ឋបាលខេត្តស្វាយរៀង បានជំរុញសហការ និងចុះកិច្ចព្រមព្រៀង	

ទិសនៃការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
តភ្ជាប់បណ្តាញអគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត ការតភ្ជាប់ផ្លូវដឹកជញ្ជូន និងភស្តុភារកម្ម ព្រមទាំងការសម្រួល និងការលើកទឹកចិត្តផ្សេងទៀតពីរដ្ឋ		សហប្រតិបត្តិការប្រមូលព័ត៌មានទិន្នន័យពាណិជ្ជកម្មតាមច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង និងព័ត៌មាន B2B E-Platform រវាងវិទ្យាស្ថានមេគង្គ ដែលមានទីស្នាក់ការនៅប្រទេសថៃ ស្តីពីការលើកកម្ពស់ភាពប្រកួតប្រជែងរវាងសហគ្រាសធុនតូចនិងមធ្យម នៅច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង នៃប្រទេសមហាអនុតំបន់មេគង្គ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈមូលនិធិជប៉ុនអាស៊ាន។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- ជំរុញការអភិវឌ្ឍរបៀងឧស្សាហកម្ម ពិសេសផ្តោតលើរបៀងសេដ្ឋកិច្ចតំបន់ឆ្នេរខាងត្បូង (Southern Coastal Economic Corridor) រួមមាន ខេត្តព្រះសីហនុ និងខេត្តកោះកុង ព្រមទាំងរបៀងតាមបណ្តោយផ្លូវជាតិសំខាន់ៗដែលតភ្ជាប់ប៉ូលសេដ្ឋកិច្ចក្នុងស្រុក ក៏ដូចជា តភ្ជាប់របៀងសេដ្ឋកិច្ចកម្ពុជាទៅនឹងប្រទេសជិតខាង នៅក្នុងក្របខ័ណ្ឌនៃរបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គ និងអាស៊ាន	មធ្យមទៅវែង	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បានរៀបចំកិច្ចប្រជុំលើកទី៣របស់គណៈកម្មាធិការសម្របសម្រួលតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន។ ▪ បានរៀបចំវេទិការបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គលើកទី៨ និងសន្និសីទថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គលើកទី២១ និងបានចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីមហាអនុតំបន់មេគង្គ ជាច្រើនលើក។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ បានសិក្សា និងពិនិត្យគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ ហិរញ្ញប្បទានដោយវិស័យឯកជន តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ▪ បាននិងកំពុងសហការក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ទីក្រុងរបៀងនៃមហាអនុតំបន់មេគង្គទី២ មានទឹកប្រាក់សរុបប្រមាណ ៣៨,១ លានដុល្លារអាមេរិក ដោយផ្តោតទៅការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្រុង២ គឺ ក្រុងកំពត និងក្រុងព្រះសីហនុ (ការសាងសង់	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងតម្រូវការ	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ស្ថានីយច្រោះទឹកកខ្វក់ ប្រព័ន្ធរំដោះទឹកភ្លៀង និងទីលានចាក់សំរាម)។ - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ	
- លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសិក្សាបង្កើតសូចនាករស្នូល សម្រាប់វាស់ស្តង់សមិទ្ធកម្មនៃកិច្ចដំណើរការរបស់តំបន់សេដ្ឋកិច្ចទាំងនោះ សម្រាប់ជាលក្ខខណ្ឌវិនិច្ឆ័យក្នុងការផ្តល់ការលើកទឹកចិត្ត និងជំរុញឧត្តមានុវត្តន៍	២០១៥ មធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ បាននិងកំពុងធ្វើការសិក្សាស្រាវជ្រាវពីយន្ត-ការក្នុងការវាយតម្លៃប្រសិទ្ធភាពនៃកិច្ចដំណើរការតំបន់សេដ្ឋកិច្ចពិសេសពីបណ្តាប្រទេសក្នុងតំបន់។	
- រៀបចំផែនការអភិវឌ្ឍទីប្រជុំជន/ទីក្រុងឱ្យក្លាយជាមជ្ឈមណ្ឌលឧស្សាហកម្ម ផ្តោតលើខេត្តព្រះសីហនុ ខេត្តកោះកុង ក្រុងបាវិត និងក្រុងប៉ោយប៉ែត តាមរយៈការបង្កើតយន្ត-ការស្ថាប័នសម្របសម្រួលមួយ ដើម្បីជំរុញការអភិវឌ្ឍមជ្ឈមណ្ឌលឧស្សាហកម្មគ្រប់ជ្រុងជ្រោយ រួមមាន ការកំណត់តំបន់ដីធ្លីផ្អែកលើផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ការគ្រប់គ្រងបរិស្ថានដែលធានាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលរួមមាន	មធ្យម ទៅ វែង	- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ÷ ▪ បានរៀបចំផែនការសកម្មភាពការងារឆ្នាំ២០១៥-២០២៥ ក្នុងការចុះតាំទ្រនិងចេកទេសរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីទីក្រុង ស្រុក និងទីប្រជុំជន តាមលំដាប់អាទិភាពអនុវត្ត IDP រួមមានផែនការរៀបចំដែនដីខេត្តព្រះសីហនុ (Zoning) ប្លង់គោលនិងផែនការប្រើប្រាស់ដីរាជធានីភ្នំពេញ ផែនការរៀបចំដីខេត្តកោះកុង (Zoning) ប្លង់គោលនិងផែនការប្រើប្រាស់ដីក្រុងបាវិត និងប្លង់គោលនិងផែនការប្រើប្រាស់ដីក្រុងប៉ោយប៉ែត។ ▪ បានរៀបចំផែនការថវិកា និងទទួលបានកញ្ចប់ថវិកាចំនួន ៤០៨ លានរៀល សម្រាប់ចូលរួមអនុវត្ត IDP នៅឆ្នាំ២០១៧ ដោយបានបញ្ចូលទៅក្នុងថវិកាកម្មវិធីរបស់ក្រសួងរៀបចំដែនដី	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពខ្សត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
អគ្គិសនី ផ្លូវថ្នល់ កំពង់ផែ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធបញ្ចេញចោលកាកសំណល់ និងទឹកសម្ងួយ ព្រមទាំងសេវាសង្គម រួមទាំងសេវាសុខាភិបាល អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើផែនការអភិវឌ្ឍរយៈពេលវែង		នគរូបនីយកម្ម និងសំណង់ ន្ទវច្ចាប់ថវិកា២០១៧ ដែលទទួលបានការអនុម័តពីរដ្ឋសភា។ ▪ បានរៀបចំនិងកំពុងស្នើសុំការអនុម័តលើសេចក្ដីព្រាងយុទ្ធសាស្ត្រសមាហរណកម្មតំបន់ឆ្នេរ និងផែនការរៀបចំដែនដីខេត្តព្រះសីហនុ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ▪ កំពុងរៀបចំផែនការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រទាំងនៅលើដីគោក និងតាមកោះ។ ▪ បានគាំទ្របច្ចេកទេសកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត និងប្លង់គោលប្រើប្រាស់ដីក្រុង នៅតំបន់ជុំវិញរាជធានីភ្នំពេញរួមមាន ÷ ក្រុងតាខ្មៅ ក្រុងច្បារមន ក្រុងកំពង់ឆ្នាំង ក្រុងកំពង់ចាម ទីប្រជុំជនអ្នកលឿង និងខេត្តតាកែវ ព្រមទាំងកំពុងជំរុញបញ្ចប់ក្នុងពេលខាងមុខ។ ▪ បានគាំទ្របច្ចេកទេសរៀបចំប្លង់គោលប្រើប្រាស់ដីនៅតំបន់ព្រំដែនដែលជាទីតាំងអាទិភាពសម្រាប់អនុវត្ត IDP មានជាអាទិ៍ ក្រុងបាវិត ក្រុងប៉ោយប៉ែត ក្រុងខេមរភូមិន្ទ។ ▪ បានគាំទ្របច្ចេកទេសរៀបចំកសាងប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុងចំនួន ៨, ស្រុកចំនួន ៦ និងទីប្រជុំជនចំនួន ២ គឺក្រុងព្រះសីហនុ ក្រុងកែប ក្រុងសៀមរាប ក្រុងច្បារមន ក្រុងកំពត ក្រុងព្រៃវែង ក្រុងកំពង់ឆ្នាំង ក្រុងតាខ្មៅ ស្រុករលាប្អៀរ ស្រុកលំផាត់ ស្រុកជ្រើនសៃ ស្រុកថាឡាបរិវ៉ាត់ ស្រុកបរវេល និងស្រុកស្អាង, ថ្នាក់ទីប្រជុំជនចំនួន ០២ រួមមានទីប្រជុំជនស្វាយអន្ទរ និងទីប្រជុំជនអ្នកលឿង, និងថ្នាក់ឃុំចំនួន	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		០៦ រួមមាន ឃុំទួលគគីរ ឃុំតាតៃក្រោម ឃុំស្នាមព្រះ ឃុំរកាត ឃុំរាម និងឃុំអូរឧកញ៉ាហេង។ ▪ បាននិងកំពុងរៀបចំច្បាប់ និងក្របខ័ណ្ឌគតិយុត្ត ដើម្បីគាំទ្រដល់ការគ្រប់គ្រងការអភិវឌ្ឍ និងការសាងសង់ ដូចជារៀបចំច្បាប់សំណង់ ច្បាប់រៀបចំដែនដី និងនគរូបនីយកម្ម ច្បាប់គ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងបទដ្ឋានគតិយុត្តមួយចំនួនទៀតដើម្បីគាំទ្រ និងចូលរួមអនុវត្ត IDP។ ▪ បានបញ្ចប់ការសិក្សាផែនការប្រើប្រាស់ដីតំបន់ពយកំពេញ។ ▪ បានសិក្សាផែនការប្រើប្រាស់ដីតំបន់បឹងព្រែកទំនប់ និងបានសិក្សា រៀបចំដាក់បឹងព្រែកទប់ជាតំបន់អភិរក្សទឹកសាបដោយអនុក្រឹត្យ និងកំពុងសិក្សាប្លង់គោល និងផែនការប្រើប្រាស់ដីកោះរ៉ុង និងឆ្ងៀលដីស្បែកខ្ចីជូនប្រជាពលរដ្ឋនៅកោះរ៉ុងនៃខេត្តព្រះសីហនុ។ ▪ បានសិក្សាប្លង់ស្ថាបត្យកម្ម ស្វែងរកសប្បុរសជនសាងសង់ និងតាមដានការសាងសង់ខ្លោងច្រកចូលឆ្នេរ និងក្រាលថ្មក្រានីតនៅតាមឆ្នេរខ្សាច់កម្សាន្តក្រុងព្រះសីហនុ និងបានសិក្សាប្លង់ស្ថាបត្យកម្មនៃផែនការកែលម្អតូបកម្សាន្តនៅឆ្នេរឯករាជ្យ និងឆ្នេរអូរឈើទាល។ ▪ បានពិនិត្យ វាយតម្លៃ និងកែសម្រួលឯកសារក្របខ័ណ្ឌអភិវឌ្ឍន៍តំបន់ទីក្រុងជុំវិញបឹងទន្លេសាប ដើម្បីត្រៀមរៀបចំកិច្ចប្រជុំគណៈ-កម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីពិនិត្យ និងផ្តល់ការឯកភាពលើឯកសារនេះដោយសហការជាមួយ	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ក្រសួងសាធារណការ និងដឹកជញ្ជូន និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ▪ បានពិនិត្យ វាយតម្លៃ និងរៀបចំកិច្ចប្រជុំគណៈកម្មាធិការរៀបចំផែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីពិនិត្យនិងផ្តល់ការឯកភាពលើផែនការរៀបចំដែនដីខេត្តបាត់ដំបង និងបច្ចុប្បន្នកំពុងកែសម្រួលបន្ថែមទៀត ដើម្បីស្នើសុំការអនុម័តពីគណៈរដ្ឋមន្ត្រី។ ▪ កំពុងចុះប្រមូលទិន្នន័យ និងចងក្រងទិន្នន័យសម្រាប់ធ្វើការវិភាគនៃគម្រោងកសាងផែនការរៀបចំដែនដីខេត្តសៀមរាប។ ▪ បានជ្រើសរើសយកស្រុកស្ទឹងហាវ ដើម្បីសិក្សាប្លង់គោលប្រើប្រាស់ដីដោយបានចុះជួបរដ្ឋបាលខេត្តព្រះសីហនុ និងរដ្ឋបាលស្រុកស្ទឹងហាវ ដើម្បីផ្សព្វផ្សាយបឋម និងពិគ្រោះយោបល់លើការងារកសាងប្លង់គោលស្រុកស្ទឹងហាវ និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈនូវគម្រោងសិក្សាប្លង់គោលស្រុកស្ទឹងហាវ ព្រមទាំងបាន និងកំពុងចុះប្រមូលទិន្នន័យរូបវន្តនៃព្រំប្រទល់រដ្ឋបាល ដែលបានកែសម្រួលថ្មី ទិន្នន័យបណ្តាញផ្លូវ និងទិន្នន័យប្រើប្រាស់ស្រុកស្ទឹងហាវ។ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ បានចូលរួម និងផ្តល់ធាតុចូលក្នុងកិច្ចប្រជុំពាក់ព័ន្ធនឹងសេចក្តីព្រាងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិ និងសេចក្តីព្រាងយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ និងផែនការរៀបចំដែនដីខេត្តព្រះសីហនុ។ - ក្រសួងសាធារណការ និងដឹកជញ្ជូន÷ ▪ បានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១៥-	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		២០១៨ លើការអភិវឌ្ឍសេដ្ឋកិច្ចក្រុងរបៀងភាគខាងត្បូង ដោយផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងក្រុងចំនួនបួន រួមមាន÷ ក្រុងប៉ោយប៉ែត (សាងសង់ប្រព័ន្ធលូចម្រោះទឹកសំណល់ និងទីលានកែច្នៃសំរាម) ក្រុងបាត់ដំបង (សាងសង់ប្រព័ន្ធលូចម្រោះទឹកសំណល់ ប្រព័ន្ធការពារទឹកជំនន់ ទប់ច្រាំងបាក់ និងទីលានកែច្នៃសំរាម) ក្រុងបាវិត (សាងសង់ផ្លូវក្រុង ប្រព័ន្ធលូចម្រោះទឹកសំណល់ និងទីលានកែច្នៃសំរាម) និងទីប្រជុំជនអ្នកលឿង (សាងសង់ទំនប់ការពារទឹកជំនន់ និងផ្លូវរៀង) ដែលគ្រោងចំណាយទឹកប្រាក់ប្រមាណ ៦០លានដុល្លារអាមេរិក និងមានរយៈពេលគម្រោង ៥ឆ្នាំ។ បច្ចុប្បន្នកំពុងបន្តរៀបចំវាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស ហើយគ្រោងនឹងចាប់ផ្តើមអនុវត្តការងារសាងសង់នៅដើមឆ្នាំ២០១៧ ។ ▪ បានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១៦-២០១៩ លើគម្រោងអភិវឌ្ឍន៍ក្រុងរបៀងនៃមហាអនុតំបន់មេគង្គ ជំហានទី២ ដោយផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក្នុងក្រុងចំនួន ២ រួមមាន÷ ក្រុងព្រះសីហនុ (សាងសង់ប្រព័ន្ធលូរំដោះទឹកភ្លៀង និងស្ថានីយទាក់សំរាម) និងក្រុងកំពត (សាងសង់ស្ថានីយច្រោះទឹកកខ្វក់ ប្រព័ន្ធលូចម្រោះទឹកសំណល់ ប្រព័ន្ធលូរំដោះទឹកភ្លៀង និងទីលានចាក់សំរាមថ្មី) ដែលគ្រោងចំណាយទឹកប្រាក់សរុបចំនួនប្រមាណ ៣៨,១ លានដុល្លារអាមេរិក ដែលក្នុងនោះជាកម្ចីឥណទានសម្បទានពីធនាគារអភិវឌ្ឍន៍អាស៊ីមានចំនួន ៣៣លានដុល្លារអាមេរិក និងបដិភាគពីរាជរដ្ឋាភិបាល	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		កម្ពុជាចំនួន ៥,១លានដុល្លារអាមេរិក និងរយៈពេល ៤ឆ្នាំ ហើយគ្រោងនឹងចាប់ផ្តើមអនុវត្តការងារក្នុងឆ្នាំ២០១៧។ បច្ចុប្បន្នបានចុះហត្ថលេខាកិច្ចសន្យាជាមួយក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស Nippon Jogesuido Sekki Co., Ltd (NJS) ចំនួនទឹកប្រាក់ ២.៨២៥.០៤០ដុល្លារអាមេរិក កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការដោះស្រាយផលប ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍បណ្តាក្រុងរបៀងទី១ ដែលផ្តោតលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្រុងចាវិត ក្រុងប៉ោយប៉ែត ក្រុងអ្នកលឿង និងក្រុងបាត់ដំបង ដូចជាការរៀបចំបណ្តាញលូ ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធច្រោះទឹកកខ្វក់ និងទីលានចាក់សំរាមជាដើម។ ▪ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការដោះស្រាយផលប ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍បណ្តាក្រុងរបៀងទី២ ដែលផ្តោត លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្រុងកំពត និងក្រុងព្រះសីហនុ ដូចជាការរៀបចំបណ្តាញលូ ប្រព័ន្ធការពារទឹកជំនន់ ប្រព័ន្ធច្រោះទឹកកខ្វក់ និងទីលានចាក់សំរាមជាដើម។ ▪ បានចូលរួមជាមួយក្រុមបេសកកម្មរបស់ធនាគារពិភពលោក ក្រោមគម្រោងជំនួយបច្ចេកទេសស្តីពី"Cambodia Urbanization Review"។ ▪ បានបញ្ចប់ការងារដោះស្រាយទីតាំងដីសម្រាប់សាងសង់ស្ថានីយ	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		១ បូមជុំរញ្ជាទឹកកខ្វក់ និងចម្រោះទឹកកខ្វក់ នៅក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង និងក្រុងបាវិត។ ▪ បានបញ្ចប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទីប្រជុំជននៃទីរួមខេត្តត្បូងឃ្មុំ បានប្រមាណ ៨០%។ ▪ បានពិនិត្យ និងអនុម័តលើសេចក្ដីព្រាងផែនការដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងសមធម៌ និងកែលម្អគុណភាពសេវាសុខាភិបាល។ - ក្រសួងបរិស្ថាន ÷ ▪ បានកែលម្អការគ្រប់គ្រងសំណល់រឹងទីប្រជុំជនតាមរាជធានី-ខេត្ត បន្ទាប់ពីរាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។ ▪ បានទទួលកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន តាមរយៈប្រកាសអន្តរក្រសួង (ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន) ដោយក្នុងនោះនៅឆ្នាំ២០១៥ បានទទួលកញ្ចប់ថវិកា ចំនួន ៥ ០០០លានរៀល និងនៅឆ្នាំ២០១៦ បានទទួលកញ្ចប់ថវិកាចំនួន ៨ ០០០លានរៀល សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង-រាវនៃទីក្រុងទាំង២៦របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ▪ បានពង្រឹងការគ្រប់គ្រងគុណភាពបរិស្ថាន តាមរយៈការអនុវត្តអនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន,អនុក្រឹត្យស្ដីពីការគ្រប់គ្រងសំណល់បរិការអគ្គិសនី និងអេឡិចត្រូនិក, អនុ-ក្រឹត្យស្ដីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម។	

ទិសដៅការគោលនយោបាយវិនិយោគ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ និងតម្រូវការ	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានបញ្ចប់សេចក្ដីព្រាង (១) ច្បាប់ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (២) អនុក្រឹត្យស្ដីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និង (៣) អនុក្រឹត្យស្ដីពីការគ្រប់គ្រងថង់ប្លាស្ទិក ដើម្បីការពារបរិស្ថាន និងលើកកម្ពស់ការវិនិយោគប្រកបដោយនិរន្តរភាព។ - រដ្ឋបាលរាជធានីភ្នំពេញ ÷ ▪ បានធ្វើការជំរុញ ជាបន្តបន្ទាប់ឱ្យរោងចក្រ (មានទុនវិនិយោគក្រោម ២លានដុល្លារអាមេរិក) សហគ្រាសធុនតូចនិងមធ្យមចូលរួមក្នុងការថែរក្សាគុណភាពបរិស្ថានតាមរយៈការគ្រប់គ្រងបានច្បាស់លាស់នូវសំណល់រឹង សំណល់ឧស្សាហកម្ម និងសំណល់រាវ ដែលបញ្ចេញដោយរោងចក្រ និងជំរុញឱ្យមូលដ្ឋានខាងលើរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន រីកិច្ចសន្យាការពារបរិស្ថាន។ - រដ្ឋបាលខេត្តស្វាយរៀង បាន÷ ▪ ការងារគ្រប់គ្រងសំណល់រឹង÷ ធ្វើការផ្សព្វផ្សាយ ណែនាំ និងអប់រំដល់បណ្ដារោងចក្រទាំងអស់ដែលមាននៅក្នុងខេត្តឱ្យធ្វើការគ្រប់គ្រង និងទុកដាក់សំណល់ឧស្សាហកម្មឱ្យបានត្រឹមត្រូវ ហើយបច្ចុប្បន្ននេះ នៅក្រុងបាវិត មានក្រុមហ៊ុនដឹកជញ្ជូនសំណល់ឧស្សាហកម្ម ១ និងក្រុមហ៊ុនដឹកជញ្ជូនសំណល់ទីប្រជុំជន ១។ ▪ ការគ្រប់គ្រងសំណល់រាវ÷ ធ្វើការតាមដានត្រួតពិនិត្យគុណភាព	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ទឹកនៅតាមបណ្តាតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការយកសំណាកទឹកទៅពិសោធនៅក្រសួងបរិស្ថាន។	
- អភិវឌ្ឍតំបន់ជុំវិញទីក្រុងភ្នំពេញឱ្យក្លាយជាតំបន់ឧស្សាហកម្មប្រមូលផ្តុំ ដោយមានផែនការប្រើប្រាស់ដីធ្លីច្បាស់លាស់ ដោយបែងចែករវាងតំបន់ឧស្សាហកម្ម និងតំបន់និវេសនដ្ឋាន ឬទីប្រជុំជន រួមទាំងផែនការរយៈពេលវែងសម្រាប់ប្រែក្លាយទីក្រុងភ្នំពេញទៅជាមជ្ឈមណ្ឌលរដ្ឋបាល ឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍	មធ្យមទៅវែង	- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់÷ បានបញ្ចប់ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ និងបានស្នើសុំការអនុម័តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញដែលទទួលបានការឯកភាព នាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ - ក្រសួងមហាផ្ទៃ/ សាលារាជធានីភ្នំពេញ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ បានចូលរួមប្រជុំ និងផ្តល់ធាតុចូលពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ព្រមទាំងសេចក្តីសម្រេចស្តីពីការរៀបចំផែនការរៀបចំដែនដីថ្នាក់ជាតិ និងសេចក្តីសម្រេចស្តីពីនីតិវិធីនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី។ - ក្រសួងសាធារណការ និងដឹកជញ្ជូន - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន÷ ▪ ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើការសិក្សាសមិទ្ធិលទ្ធភាពគម្រោងសាងសង់ផ្លូវក្រវាត់ក្រុងទី៣។ ▪ បញ្ចប់ការងារដោះស្រាយទីតាំងសម្រាប់សាងសង់សាលាជាតិបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ នៅរាជធានីភ្នំពេញ។ ▪ បញ្ចប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងសាងសង់ផ្លូវក្រវាត់ក្រុងទី២ បាន ៨០% - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		- ក្រសួងពាក់ព័ន្ធផ្សេងទៀត - រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំប្លង់គោលប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥ និងត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ បន្ទាប់ពីទទួលបានការអនុម័ត នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។	
- សិក្សារៀបចំសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុក ពិសេស ការចូលរួមក្នុងខ្សែចង្វាក់តម្លៃ និងខ្សែចង្វាក់ផលិតកម្មតំបន់ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់	មធ្យម ទៅ រៃង	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ បានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេស ដោយបានធ្វើការសិក្សា និងបានគិតគូរចំពោះតំបន់ឧស្សាហកម្មទូទៅសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងការតភ្ជាប់ខ្សែចង្វាក់តម្លៃរវាងសហគ្រាសក្នុងស្រុក និងសហគ្រាសធំបរទេស។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - រដ្ឋបាលខេត្តស្វាយរៀង÷ បានចូលរួមសហការជាមួយអាជ្ញាធរដែនដីអង្គភាពពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃ កំណត់ទីតាំងសម្រាប់រៀបចំបង្កើតតំបន់ឧស្សាហកម្ម សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ចំនួន ៩លើក។	
- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍ជាដើម សំដៅបម្រើឱ្យគោលដៅឧស្សាហកម្ម ពិសេសការបោះទីតាំងតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍប្ដូលឧស្សាហកម្ម និងការប្រែក្លាយតំបន់ទីប្រជុំជន/ទីក្រុងជាមជ្ឈមណ្ឌលឧស្សាហកម្មជាតិ ស្របតាមផែនការរៀបចំដែនដី នគរូបនីយកម្ម និង	មធ្យម ទៅ រៃង	- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ បានចូលរួម និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសនៅជុំវិញតំបន់សេដ្ឋកិច្ចពិសេស។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រសួងរ៉ែនិងថាមពល - ក្រសួងសាធារណៈការ និងដឹកជញ្ជូន - រដ្ឋបាលខេត្តស្វាយរៀង÷ បានសិក្សាគម្រោងពង្រីកវិសាលភាពផ្ដត់ផ្ដង់	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងតម្លៃនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ផែនការប្រើប្រាស់ដី		ទឹកស្អាតនៅតាមទីប្រជុំជន តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហ- កម្ម តាមរយៈការជំរុញឱ្យមានការបង្កើតហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹក ស្អាតអនុលោមតាមស្តង់ដាទឹកបរិភោគជាតិ។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បានចូលរួមរៀបចំ និងវិភាជថវិកាឆ្នាំ២០១៦ សម្រាប់កសាង ហេ ដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចមាននៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ ការគ្រប់គ្រងឆ្នាំ២០១៦។ ▪ បានសិក្សា និងពិនិត្យគម្រោងចែកចាយទឹកស្អាតភ្ជាប់ពីទីរួមខេត្ត ស្វាយរៀងទៅតំបន់សេដ្ឋកិច្ចពិសេសបាវិត របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ▪ បានសិក្សា និងពិនិត្យគម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសរបស់ កំពង់ផែស្វយ័តភ្នំពេញ។ ▪ បានសិក្សា និងពិនិត្យគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូ ស្ថានីយសម្អាតទឹកលូ និងការកែច្នៃសំណល់រឹង នៅក្រុងខេមរភូមិន្ទ ក្រុងកែប ក្រុងកំពត និងក្រុងព្រះសីហនុ តាមយន្តការភាពជាដៃគូ រវាងរដ្ឋ និងឯកជនរបស់ក្រសួងបរិស្ថាន។ ▪ បានសិក្សា និងពិនិត្យគម្រោងមជ្ឈមណ្ឌលភស្តុភារ នៅខេត្តចំនួន ១០ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនរបស់ក្រសួង សាធារណការ និងដឹកជញ្ជូន។ ▪ បានរៀបចំបញ្ជីគម្រោងកម្មវិធីដែលគ្រោង/ចុះហត្ថលេខាក្នុងឆ្នាំ ២០១៧ ក្នុងក្របខ័ណ្ឌនៃហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ទ្វេភាគី និង ពហុភាគីដែលនឹងចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមាន	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ផ្លូវថ្នល់ ទឹកស្អាត អគ្គិសនី គមនាគមន៍ និងទូរគមនាគមន៍។ ▪ បានចុះហត្ថលេខាលើគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជំហានទី២ ដែលអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងទឹកប្រាក់សរុប ១៦,៥ លានដុល្លារអាមេរិក។ ▪ បានដាក់បញ្ចូលគម្រោងចំនួន ១ គម្រោងផ្គត់ផ្គង់ទឹកស្អាតនៅថ្នាក់ខេត្ត នៅក្នុងផែនការផ្តល់ហិរញ្ញប្បទាន២០១៧-២០១៩ របស់ ADB ដែលមានទឹកប្រាក់សរុប ៦០លានដុល្លារអាមេរិក។ ▪ បានត្រៀមចុះហត្ថលេខាលើគម្រោងទឹកស្អាតនៅភ្នំពេញ ជាមួយ AFD ដែលមានទឹកប្រាក់សរុប ៣០ លានដុល្លារអាមេរិក។ ▪ បានបញ្ចប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងផ្លូវជាតិលេខ១, លេខ៥ (ពីស្ពានព្រែកព្នៅទៅស្ពានព្រែកក្តាម), លេខ ៦, លេខ៣១, លេខ៣៣, លេខ៥៦, គម្រោងស្តារឡើងវិញផ្លូវដែកនៅកម្ពុជា (ខ្សែភ្នំពេញ-ខេត្តព្រះសីហនុ) និងគម្រោងសាងសង់ប៉ុស្តិ៍ត្រួតពិនិត្យច្រកទ្វារអន្តរជាតិព្រែកថ្នូរ។ ▪ បាននិងកំពុងអនុវត្តការងារដោះស្រាយផលប៉ះពាល់ ដោយសារគម្រោងផ្លូវជាតិលេខ៥ (បាត់ដំបង-បន្ទាយមានជ័យ និងព្រែកក្តាម-ផ្ទាមួម),លេខ២១, លេខ៥៨, លេខ៥៣, លេខ១៣, លេខ២ និង ២២, លេខ ១៥៧៧ និងផ្លូវខេត្តលេខ១៥0B និង១៥១B, ផ្លូវជាតិលេខ១៣ និងផ្លូវខេត្តលេខ៣១4D, គម្រោងជួសជុលកែលម្អស្ពានមិត្តភាពកម្ពុជា-ជប៉ុនជ្រោយចង្វារ, គម្រោងរៀបចំច្រកទ្វារអន្តរជាតិស្ទឹងបត់ និងគម្រោងសាងសង់ប៉ុស្តិ៍ត្រួតពិនិត្យច្រកទ្វារអន្តរជាតិព្រៃវ៉ាល្លី។	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
- កំណត់ឱ្យបានច្បាស់លាស់នូវឯកសារបទដ្ឋាន និងគោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន និងសុវត្ថិភាពផលិតកម្ម សម្រាប់គម្រោងវិនិយោគដែលបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មផ្សេងទៀត	២០១៥ ទៅមធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាន÷ ▪ ចូលរួមកិច្ចប្រជុំជាមួយក្រុមពិគ្រោះយោបល់របស់ក្រសួងបរិស្ថាន ពាក់ព័ន្ធនឹងយន្តការហិរញ្ញប្បទានប្រកបដោយចីរភាព ជាពិសេសទៅលើទស្សនវិស័យស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន និងការវិនិ-យោគបៃតង ដើម្បីអភិវឌ្ឍនិងការពារបរិស្ថាន និងធនធានធម្មជាតិ ក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ (NESAP)។ ▪ ចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។ ▪ ចូលរួមសិក្សាសាលាថ្នាក់ជាតិស្តីពីសេចក្តីព្រាងគោលការណ៍ណែនាំការចូលរួមជាសាធារណៈថ្នាក់ជាតិនៅក្នុងដំណើរការ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ - ក្រសួងបរិស្ថាន÷ ▪ បានកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង តាមរយៈអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង។ ▪ បានពន្លឿនដំណើរការរៀបចំក្រមបរិស្ថាន។ ▪ បានរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថាន (២០១៦-២០២៣)។ ▪ បានផ្ញើរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការអនុវត្តថវិកាកម្មវិធី ដើម្បីចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ដោយកំពុងគិតគូរ និងពិនិត្យលើការអនុវត្ត សេ-	

ទិសដៅការគោលនយោបាយ/ផែនការ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		វាកម្មចុះបញ្ជី ការផ្តល់អាជ្ញាបណ្ណ និងការកសាងឯកសារបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំមួយចំនួនពាក់ព័ន្ធការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស សុវត្ថិភាពផលិតកម្ម និងតំបន់ឧស្សាហកម្មផ្សេងៗទៀត។ ▪ បានជំរុញការអនុវត្តយន្តការស្វ័យត្រួតពិនិត្យការគ្រប់គ្រង និងប្រព័ន្ធប្រព្រឹត្តកម្មសំណល់ និងប្រព័ន្ធស្វ័យរាយការណ៍ព័ត៌មាន និងទិន្នន័យសំណល់ ពីទីតាំងប្រភពបំពុលបរិស្ថានខ្លាំង។ ▪ កំពុងរៀបចំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីស្លាកសញ្ញាបៃតង (Eco-Label) ដើម្បីកំណត់លើផលិតផល និងសេវាកម្មផ្សេងៗ សំដៅលើកកម្ពស់សុវត្ថិភាព និងគុណភាពនៃផលិតផលនិងសេវាកម្ម។ - រដ្ឋបាលខេត្តស្វាយរៀង បាន÷ ▪ ជំរុញរោងចក្រ សហគ្រាស សិប្បកម្ម អាជីវកម្ម និងសេវាកម្មឱ្យធ្វើការកែលម្អខ្សែចង្វាក់ផលិតកម្ម ដើម្បីធានាបានទ្ធវបរិស្ថានឧស្សាហកម្ម និងគុណភាពស្របតាមស្តង់ដាជាតិ និងអន្តរជាតិ ▪ ជំរុញការអនុវត្តច្បាប់ក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្ម តាមរយៈការចុះផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅតាមបណ្ដារោងចក្រ សិប្បកម្ម ក្នុងក្រុង ស្រុក ក្នុងខេត្ត។	
- បន្តពង្រីង និងលើកកម្ពស់សមត្ថភាពរដ្ឋបាលនិងក្របខ័ណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិបត្តិ-ការនៃតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការបង្កើនប្រសិទ្ធភាពនៃយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស	២០១៥ ទៅមធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បាននិងកំពុងចាប់ផ្ដើមរៀបចំកែសម្រួលរចនាសម្ព័ន្ធអភិបាលកិច្ចស្ថាប័ន និងពង្រីងសមត្ថភាពមន្ត្រីនៅតាមរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ដើម្បីផ្ដល់សេវាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជូនវិនិ-យោគិន។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
សំដៅជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឯកទេស ដោយផ្តោតលើវិស័យអាទិភាពមួយចំនួន ដូចជា ការកែច្នៃកសិផល សម្រាប់នាំចេញ (ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចឯកទេស ត្រូវចំណុះលើកត្តាសំខាន់ៗដូចជាទីតាំងភូមិសាស្ត្រ ប្រភេទប្រតិបត្តិការអាជីវកម្ម មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធ រួមទាំង អគ្គិសនី និងទឹកស្អាត និងប្រព័ន្ធភស្តុភារកម្ម ព្រមទាំងការលើកទឹកចិត្តផងដែរ)			
- ពិនិត្យលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ ដោយប្រើយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន។	មធ្យម	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ បានបញ្ចប់សេចក្តីព្រាងឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍ យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោង វិនិយោគសាធារណៈ ២០១៦-២០២០។ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដោយមានការគិតគូរពីការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗ និងមានបទដ្ឋានខ្ពស់ដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន។	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ។
២)-ការពង្រីក និងធំធេងកម្មសហគ្រាសតូចតូច និងមធ្យម			
ក-ការរៀបចំស្ថាប័ន និងការលើកទឹកចិត្ត			
- ជំរុញឱ្យមានការរៀបចំផែនការរយៈពេល	២០១៥	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	- ក្រសួងពាណិជ្ជកម្ម÷ ថវិកា និងធនធាន

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
មធ្យមសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយកំណត់យកមុខសញ្ញាសហ-គ្រាសដែលមានសក្តានុពលក្នុងការនាំចេញ ការអភិវឌ្ឍផលិតផលថ្មី ការតភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs) ការតភ្ជាប់ខ្សែចង្វាក់តម្លៃ និងការតភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយរៀបចំនូវក្របខ័ណ្ឌសកម្មភាពចាំបាច់ និងជាក់ស្តែងដើម្បីអភិវឌ្ឍន៍សហគ្រាសទាំងនោះ	ទៅមធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានចូលរួម និងផ្តល់ឆន្ទៈចូលលើសេចក្តីព្រាងឯកសារក្របខ័ណ្ឌគោលនយោបាយលើកទឹកចិត្តសហគ្រាសធុន-តូច និងមធ្យមនៅកម្ពុជា។ - ក្រសួងពាណិជ្ជកម្ម ÷ ▪ បានរៀបចំសិក្ខាសាលាជាសើរីសម្រាប់ពង្រឹង បង្កើតគំនិតច្នៃប្រឌិតលើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (MoC 101)។ ▪ បានរៀបចំយុទ្ធនាការទិញផលិតផលខ្មែរបានចំនួន ៤ លើកនៅក្នុងរាជធានី-ខេត្ត ដោយបានប្រមូលកៀរគរសហគ្រាសតូចធំដែលបានកំពុងផលិតផលិតផល និងសេវាកម្មមកដាក់តាំងបង្ហាញដើម្បីស្វែងរកដៃគូពាណិជ្ជកម្ម និងទទួលការបណ្តុះបណ្តាលបន្ថែមពីកិច្ចការអភិវឌ្ឍផលិតផល និងសេវាកម្ម ការពង្រឹងឡើងវិញនូវប្រព័ន្ធផលិតកម្ម ដើម្បីផលិតទំនិញ និងសេវាមានគុណភាព មានសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់។ ▪ បាននឹងកំពុងពង្រីកទីផ្សារគោលដៅថ្មីបន្ថែមសម្រាប់បញ្ជាប់ការនាំចេញផលិតផលកម្ពុជាទៅទីផ្សារទាំងនោះ ▪ បានបើកមជ្ឈមណ្ឌលដាក់តាំងបង្ហាញផលិតផលកម្ពុជា នៅក្នុងប្រទេសចិនបានចំនួន ៥ទីតាំង និងបន្តចរចាបើកមជ្ឈមណ្ឌលដាក់លក់ផលិតផលខ្មែរនៅក្នុងប្រទេសវៀតណាម និងប្រទេសថៃ និងតំបន់មួយចំនួននៅក្នុងប្រទេសចិនបន្តទៀត ▪ បានសម្របសម្រួលឱ្យសហគ្រាសខ្នាតតូច និងមធ្យមបានចូលរួមពិព័រណ៍ក្នុង និងក្រៅប្រទេស និងរៀបចំបេសកកម្មពាណិជ្ជកម្មទៅកាន់គោលដៅទីផ្សារដើម្បីឱ្យសហគ្រាសខ្នាតតូច និង	មនុស្សមានកំណត់

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		មធ្យមបានសិក្សារៀនសូត្រពីភាពជឿនលឿននៃឧស្សាហកម្ម ខ្នាតតូច និងមធ្យមនៃបណ្តាប្រទេសទាំងនោះ។ - រដ្ឋបាលខេត្តស្វាយរៀង បានជំរុញសហគ្រាសធុនតូចនិងមធ្យម ដែលមាននៅក្នុងខេត្ត ធ្វើការផលិតនូវផលិតផលពាក់កណ្តាលសម្រេច ឬគ្រឿងបង្គុំសម្រាប់គាំទ្រ ឬផ្គត់ផ្គង់ឱ្យសហគ្រាសធុនធំ ។	
- ពង្រឹងនូវក្របខ័ណ្ឌ និងយន្តការអភិវឌ្ឍសហ-គ្រាសធុនតូចនិងមធ្យម ពិសេសសំដៅរៀបចំការចុះបញ្ជី ការគ្រប់គ្រង និងការតាមដានវឌ្ឍនភាពនៃវិស័យនេះ ដែលទាក់ទាញសហគ្រាសកម្ពុជាឱ្យទៅចុះបញ្ជីរបបពន្ធផ្លូវការ ដែលអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាមានព័ត៌មានច្បាស់លាស់សម្រាប់រៀបចំគោលនយោបាយគាំទ្រ ដើម្បីផ្តល់លទ្ធភាពឱ្យសហ-គ្រាសទាំងនោះមានលទ្ធភាពទទួលបានព័ត៌មានពីឥណទាន និងការពិគ្រោះយោបល់ផ្នែកធុរកិច្ច ដើម្បីពង្រឹកសកម្មភាព និងការវិនិយោគ	២០១៥ ទៅមធ្យម	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បាន÷ ▪ រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្របសម្រួលការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូច និងមធ្យម និងសេវាកម្ម នៅក្រោមក្របខ័ណ្ឌដំបូលតែមួយ ដែលបច្ចុប្បន្នបានដាក់ជូនទៅដល់គណៈ-កម្មាធិការគោលនយោបាយសេដ្ឋកិច្ច ដើម្បីដាក់ប្រជុំឆ្លងចុងក្រោយមុននឹងជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។ ▪ កសាងឯកសារក្របខ័ណ្ឌគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការពី JICA ។ ▪ បានចេញប្រកាសស្តីពីនីតិវិធី និងបែបបទស្នើសុំប្រកាសបង្កើតរោងចក្រ និងសិប្បកម្ម និងប្រកាសស្តីពីនីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើការរោងចក្រ និងសិប្បកម្ម ព្រមទាំងបាននិងកំពុងរៀបចំនិយមន័យទៅតាមវិស័យនីមួយៗ។ ▪ បានរៀបចំកសាងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីពង្រឹងការគ្រប់គ្រងរោងចក្រ និងសិប្បកម្មនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងជំរុញការចុះបញ្ជីឱ្យមានប្រសិទ្ធភាព គម្លាភាព គណនេយ្យភាព និងសង្គតិភាពខ្ពស់។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទីតម្លៃសក្តានុពល និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		- ក្រសួងពាណិជ្ជកម្ម÷ បានចាត់បញ្ជូនមន្ត្រីជំនាញចូលរួមក្នុងក្រុមការងារទទួលចុះបញ្ជីសហគ្រាសខ្នាតតូច និងមធ្យម នៅច្រកចេញ-ចូលតែមួយ ដែលមានការិយាល័យនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រុមប្រឹក្សាជាតិគណនេយ្យ÷ បានបង្កើតក្រុមការងារគណនេយ្យពន្ធដារ និងមូលបត្រ ដើម្បីសិក្សាលើការអភិវឌ្ឍក្របខ័ណ្ឌគណនេយ្យងាយស្រួលសម្រាប់សហគ្រាសធុនតូច (Simplified Accounting Template for Micro-Enterprises) ក្នុងគោលដៅសម្រួលដល់ការបង់ពន្ធតាមរបបពិត និងបង្កលក្ខណៈងាយស្រួលឱ្យសហគ្រាសធុនតូច និងមធ្យមអាចចូលរួមនៅក្នុងទីផ្សារមូលបត្រ។ ជាលទ្ធផល ឯកសារគំរូកត់ត្រាចំណូលចំណាយងាយ។ និងរបាយការណ៍ហិរញ្ញវត្ថុគំរូងាយ។ សម្រាប់មីក្រូសហគ្រាស (Simplified Financial Reporting for Micro-Enterprises) ត្រូវបានបង្កើតឡើង។ ក្រុមការងារនឹងសិក្សាបន្ត អំពីលទ្ធភាពរបស់សហគ្រាសធុនតូចនិងមធ្យម ក្នុងការចូលរួមនៅក្នុងទីផ្សារមូលបត្រ។ - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបង្កើតយន្តការពិគ្រោះយោបល់ និងទំនាក់ទំនងជាប្រចាំជាមួយក្រុមហ៊ុនបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានក្នុងស្រុក។ - ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំការងារពាក់ព័ន្ធនឹង IDP លើការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។ - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ÷ ▪ បាននិងកំពុងសិក្សាលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីស្នើ	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		សុំបង្កើតសាខាត្រួតពិនិត្យភ្ជួតតាមអនាម័យចំនួន ៥កន្លែង និងស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីចាត់បញ្ជូនមន្ត្រីភ្ជួតតាមអនាម័យទៅបំពេញការងារនៅតាមច្រកទ្វារព្រំដែនឡើងវិញ ▪ បានរៀបចំសំណើថវិការដ្ឋ ដើម្បីរៀបចំស្ថានីយចត្តាឡីស័កចំនួន ៤កន្លែង ដែលក្នុងនោះនៅខេត្តបន្ទាយមានជ័យចំនួន ២កន្លែង និងខេត្តតាកែវចំនួន ២កន្លែង ▪ បាននិងកំពុងរៀបចំចងក្រងឯកសារមគ្គុទ្ទេសក៍ សម្រាប់អ្នកវិនិយោគក្នុងវិស័យកសិកម្ម (Guidebook for Investor in Agricultural Sector ដែលបានបង្ហាញអំពីស្ថានភាពនៃការអភិវឌ្ឍវិស័យកសិកម្ម លក្ខណៈអំណោយផល សក្តានុពលនៃការអភិវឌ្ឍ និងនីតិវិធីសំខាន់ៗសម្រាប់ការធ្វើវិនិយោគក្នុងវិស័យនេះ។ - រដ្ឋបាលរាជធានីភ្នំពេញ÷ ▪ បានជំរុញការចុះបញ្ជីផ្លូវការរបស់សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មឱ្យបាន ១០០% ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម២០១៥-២០២៥។ ជាក់ស្តែងត្រឹមឆ្នាំ២០១៦ សាលារាជធានីភ្នំពេញ បានជំរុញឱ្យម្ចាស់សិប្បកម្មចុះបញ្ជីសិប្បកម្មស្របច្បាប់បានចំនួន ៤១៥មូលដ្ឋាន ក្នុងនោះមូលដ្ឋានថ្មីមានចំនួន ២៣១មូលដ្ឋាន និង ចុះបញ្ជីបន្តមានចំនួន ១៨៤ទីតាំង។ ▪ បានបង្កើតជាបណ្តាញទំនាក់ទំនងរវាងស្ថាប័នដែលពាក់ព័ន្ធ ឬជំនាញការជាន់ខ្ពស់ដើម្បីជួយដោះស្រាយបញ្ហាចំពោះមុខ ឬពេលខ្លះអាចជួយជាកម្លីក្នុងអត្រាការប្រាក់ទាបដល់សិប្បកម្ម ឬរោងចក្រ	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទន្ទឹលទ្ធលទ្ធសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		សហគ្រាស។ ▪ បានចុះពិនិត្យ និងវាយតម្លៃពាក្យសុំស្នើបង្កើត បន្ត និងសុំវិញ្ញាបនបត្រដំណើរការច្បាប់ថ្នាក់ក្រសួងបានចំនួន ១០២មូលដ្ឋាន ក្នុងនោះសំណើសុំថ្មីមានចំនួន ២៨មូលដ្ឋាន បន្តមានចំនួន ៤៣មូលដ្ឋាន និងសំណើសុំវិញ្ញាបនបត្រដំណើរការមានចំនួន ២៧មូលដ្ឋាន ▪ បានចុះជំរុញមូលដ្ឋានផលិតម្ហូបអាហារអោយយកផលិតផលទៅពិនិត្យគុណភាពបាន ២៩១មុខផលិតផល។ ▪ បានចុះពិនិត្យ និងអនុវត្តផលិតកម្មល្អ (GMP) និងអនាម័យល្អ (GHP) បានចំនួន ៥៦មូលដ្ឋាន ▪ បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងនៅស្ថានីយប្រេងឥន្ធនៈ: បានចំនួន ២០២ស្ថានីយ និង៥៣៣ទូ ស្មើនឹង២ ៧០៤ដៃបាញ់ប្រេង។ ▪ បានចុះជំរុញមូលដ្ឋានផលិតម្ហូបអាហារអោយយកផលិតផលទៅពិនិត្យគុណភាពបាន ២៩១មុខផលិតផល។ ▪ បានចុះត្រួតពិនិត្យ លើបរិមាណ ចំណុះ និងទំងន់ លើផលិតផលវេចខ្ចប់ចំនួន ៥៩ច្បាប់ មាន ១០៥មុខផលិតផល។ ▪ បានចុះយកសំណាកទឹក នៅស្ថានីយផលិតទឹកស្អាតចំនួន ៣មូលដ្ឋាន ទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា។ ▪ បានបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពីគីមីចំណីអាហារ (គ្រឿងផ្សំក្នុងចំណីអាហារ) Food Additive។ ▪ បានបើកវគ្គផ្សព្វផ្សាយច្បាប់រោងចក្រ សិប្បកម្ម ការពង្រីងខ្សែ	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ធនធានមនុស្សត្រូវអនុវត្ត និងតម្រូវការ	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ចង្វាក់ផលិតកម្ម និងការពង្រឹងគុណភាពទឹកកកដើម ទឹកកកអនាម័យ។ ▪ បានជួបជាមួយអង្គការ PUM Netherland senior experts (Non-profit organization) និងផ្នែក SME ដើម្បីពិភាក្សាលើផ្នែកអនាម័យចំណីអាហារការលើកកំពស់ផលិតភាពផលិតផលក្នុងវិស័យ SME និងការពិភាក្សាពីបញ្ហាកម្ចីមូលនិធិក្នុងអត្រាការប្រាក់ទាបដើម្បីអភិវឌ្ឍខ្សែចង្វាក់ផលិតកម្មក្រោមការសម្របសម្រួលពីមន្ទីរ។ ▪ បានបង្កើតយន្តការច្រកចេញចូលតែមួយ ដើម្បីកែសម្រួលក្នុងការបំពេញបែបបទ កាត់បន្ថយពេលវេលា និងចំណាយផ្សេងៗ។	
- ជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា តាមរយៈទស្សនកិច្ចសិក្សា និងការបណ្តុះបណ្តាលពីបណ្តាប្រទេសនានាជុំវិញពិភពលោក	២០១៥ មធ្យមទៅវែង	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- បង្កើតមូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ដោយមានយន្តការគ្រប់គ្រងត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ដោយរដ្ឋាភិបាលផ្តល់ទ្រព្យការវិភាជថវិកាសមស្របយោងតាមតម្រូវការ និងលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ	២០១៥ ទៅមធ្យម	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីយន្តការសម្រាប់គ្រប់គ្រងមូលនិធិកសាងសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ វិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (Information and Communications Technology - ICT)។	
- កសាងធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យមានភាពរឹងមាំ និងជវភាព	មធ្យម ទៅវែង	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះ-	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិន្នន័យខ្វះខាតត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ដោយផ្តល់ការហ្វឹកហាត់លើជំនាញឯកទេសសម្រាប់ដោះស្រាយកង្វះខាតជំនាញក្នុងវិស័យអាទិភាព ដោយបង្កើនអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាលវិស្វករ និងអ្នកបច្ចេកទេស		បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើ សេចក្តីព្រាងទី១ រហូតដល់ទី១១។ ▪ កំពុងសិក្សាស្រាវជ្រាវឯកសារ ដើម្បីរៀបចំសេចក្តីព្រាងបឋមច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ▪ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើគោលនយោបាយយេនឌ័រ និងផែនការសកម្មភាពសម្រាប់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ▪ បានបណ្តុះបណ្តាលកម្លាំងពលកម្មផ្នែកលើសមត្ថភាព ដើម្បីបម្រើដល់តម្រូវការពលករជំនាញផ្នែកឧស្សាហកម្ម ពិសេសក្នុងតំបន់សេដ្ឋកិច្ចពិសេស។ ▪ បានផ្តល់ការហ្វឹកហ្វឺនកូនជាង នៅតាមបណ្តាសហគ្រាស គ្រឹះស្ថានក្រុមហ៊ុន សរុបសិក្ខាកាមចំនួន ២១ ០៤៤នាក់ ក្នុងនោះ ស្រី១៤ ៣១០នាក់។ ▪ បានរៀបចំការប្រឡងជ្រើសរើសគរុនិស្សិត ការប្រឡងបញ្ចប់ និងការបែងចែកប៉ុស្តិ៍គរុនិស្សិតជំនាន់ទី១៥ ចំនួន ២៩៨នាក់ ក្នុងនោះ ស្រី៨១នាក់។ ▪ បានចុះត្រួតពិនិត្យ និងវាយតម្លៃការបណ្តុះបណ្តាលរបស់គ្រូបច្ចេកទេស/ឯកទេស ចំនួន ៣លើក ៨គ្រឹះស្ថាន។ ▪ បានបង្កើតក្រុមការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ▪ បានចុះត្រួតពិនិត្យ និងតាមដានលើលក្ខណៈវិនិច្ឆ័យទាំង៦ នៃការធានាគុណភាពនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		និងវិជ្ជាជីវៈ ចំនួន ៤លើក ១៨គ្រឹះស្ថាន។ ▪ បានអនុវត្តវិធីសាស្ត្របណ្តុះបណ្តាលផ្អែកលើសមត្ថភាពសម្រាប់ជ្រើសរើសគ្រូបង្គោលចំនួន ១០រូប ដំណាក់កាលទី១ ចំនួន ៤វគ្គ មានគ្រូបច្ចេកទេសចូលរួមចំនួន ១១៨នាក់ ក្នុងនោះ ស្រី១១នាក់។ ▪ បានបណ្តុះបណ្តាលធនធានមនុស្សចំនួន ៣វគ្គ ស្តីពី "ការស្ថាបនាការបណ្តុះបណ្តាល" សិក្ខាកាមចំនួន៤០នាក់ ក្នុងនោះ ស្រី១០នាក់។ ▪ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តការងារអធិការកិច្ចគ្រូ សិក្ខាកាមចំនួន ៧៧នាក់ ក្នុងនោះ ស្រី៩នាក់។ ▪ ទស្សនកិច្ចសិក្សានៅប្រទេសបែលហ្ស៊ីក សិក្ខាកាមចំនួន ៦នាក់ ក្នុងនោះ ស្រី១នាក់។ ▪ បានរៀបចំសិក្ខាសាលាប្រឹក្សាយោបល់ស្តីពីក្របខ័ណ្ឌគុណវុធ្ឍិគ្រូបង្រៀន មានសិក្ខាកាម ចំនួន ៨០នាក់ ក្នុងនោះ ស្រី១១នាក់។ ▪ បានចេញប្រកាសលេខ៥២៣ ក.ហ/ប្រ.ក ស្តីពីការដាក់ឱ្យប្រើប្រាស់លក្ខណៈវិនិច្ឆ័យទាំង៦ នៃការធានាគុណភាពវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ▪ បានសហការជាមួយគម្រោងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីក្នុងនាយកដ្ឋាន និងមន្ត្រីនៅតាមបណ្តាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិង វិជ្ជាជីវៈ ចំនួន ៥ខេត្ត (សៀមរាប បាត់ដំបង ស្វាយរៀង តាកែវ និងកំពង់) ស្តីពីដំណើរការត្រួតពិនិត្យ និងធានាគុណភាពនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ▪ បានបណ្តុះបណ្តាលអ្នកវាយតម្លៃជំនាញលើមុខរបរជំនឿងទូរបញ្ជា	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ទេសនៃសម្រេចអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ចែកចាយថាមពលនៅប្រទេសជប៉ុនចំនួន ២រូប។ ▪ បានបណ្តុះបណ្តាលវិធីសាស្ត្រវាយតម្លៃជំនាញ Sequence Control នៅប្រទេសជប៉ុនចំនួន ២រូប។ ▪ បានបណ្តុះបណ្តាលអ្នកវាយតម្លៃជំនាញ និងការធ្វើតេស្តសាកល្បងលើមុខរបរដំឡើងទូរបញ្ជាចែកចាយថាមពលនៅក្នុងប្រទេសចំនួន ០៧រូប។ ▪ បានបញ្ជូនមន្ត្រីបច្ចេកទេសចំនួន ១០រូប ទៅបណ្តុះបណ្តាលនៅប្រទេសកូរ៉េកម្មវិធីសិក្សាផ្នែកសំណង់ និងមេកានិករថយន្ត។ ▪ កំពុងអភិវឌ្ឍស្តង់ដាសមត្ថភាព (CS) កម្មវិធីសិក្សាផ្អែកលើសមត្ថ-ភាព (CBC) និងកញ្ចប់វាយតម្លៃ (CAP) លើមុខរបរ÷ ផ្សារអគ្គិសនី បន្ទ្យុលោហៈ ផលិតនំ និងកែច្នៃបន្លែផ្លែឈើ ចាប់ពីកម្រិត ១ដល់កម្រិត៤។ ▪ អភិវឌ្ឍកម្មវិធីសិក្សា CQF កម្រិត៥ និងកំពុងដាក់ឱ្យសាកល្បងនៅ NPIC, PPI និង NTTI នៅឆ្នាំ២០១៧។ ▪ បានរៀបចំបោះពុម្ពខិតបណ្ណផ្សព្វផ្សាយស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចំនួន ១១ ០០០សន្លឹក។ ▪ បានរៀបចំវេទិកាផ្សព្វផ្សាយវិស័យអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ចំនួនអ្នកចូលរួម ៥ ០០០នាក់ ក្នុងនោះ ស្ត្រី២ ០០០ នាក់។ ▪ បានចុះជំរុញការផ្សព្វផ្សាយនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចំនួន ១៥គ្រឹះស្ថាន និង៨៤រោងចក្រ សហ-គ្រាស។	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		- ក្រសួងអប់រំ យុវជន និងកីឬា បាន÷ ▪ អភិវឌ្ឍផែនការគោលស្តីពីការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ។ ▪ កែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូនិងកំពុងរៀបចំស្តង់ដារអ្នកផ្តល់សេវាបណ្តុះបណ្តាលគ្រូ។ ▪ លើកគម្រោងសាងសង់សាលាមធ្យមសិក្សាបន្ថែម សំដៅបង្កើនលទ្ធភាពទទួលបានការអប់រំនៅមធ្យមសិក្សាកាន់តែច្រើន។ ▪ កំពុងបណ្តុះបណ្តាលគ្រូឧទ្ទេសនៅតាមមជ្ឈមណ្ឌលគរុកោសល្យចំនួន ៥៦នាក់ ឱ្យមានបរិញ្ញាបត្រជាន់ខ្ពស់។ ▪ កំពុងអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងភូមិភាគបាត់ដំបងឱ្យក្លាយជាវិទ្យាស្ថានគរុកោសល្យ។ - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ចេញប្រកាសលេខ១១៦៤ ស.អ.យ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មរាជធានី ខេត្ត។ រហូតមកដល់ឆ្នាំ២០១៦ មានមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន ១១កន្លែង និងសហគ្រាសផលិតរទេះជនពិការ ៣កន្លែង ដែលស្ថិតនៅក្នុងរាជធានី ខេត្ត ចំនួន ៧ គឺរាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តបាត់ដំបង និងខេត្តសៀមរាប។ ក្នុងឆ្នាំ២០១៦ មជ្ឈមណ្ឌលទាំងនោះបានផលិតឧបករណ៍សិប្បនិម្មិត និងរណប ចំនួន ១៩ ១៣៧គ្រឿង និងរទេះប្រមាណ ១ ៨០០គ្រឿង ជូនជនពិការ ចំនួនប្រមាណ ២០ ០០០ នាក់/ឆ្នាំ ដោយឥតគិតថ្លៃ។ ឧបករណ៍សិប្បនិម្មិត និងរណបរួមមាន	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ឈើច្រត់ ឈើជ្រែង គ្រោងលើនិងក្រោមក្បាលជង្គង់ គ្រោងដៃ ប្រអប់ដៃកៅស៊ូ ប្រអប់ដៃមានរាងទំពក់គ្រោងរណប និងប្រអប់ជើង។	
- ពិនិត្យលទ្ធភាពផ្តល់ការគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យមសម្រាប់ការបណ្តុះបណ្តាល និងការវិនិយោគលើគ្រឿងម៉ាស៊ីន ឬបរិក្ខារផលិតកម្ម ព្រមទាំងការលើកទឹកចិត្តផ្សេងទៀត ដោយផ្សារភ្ជាប់លក្ខខណ្ឌនៃការផលិតវត្ថុធាតុដើមក្នុងស្រុក ការលើកកម្ពស់គុណភាពផលិតផល និងទំនើបកម្មនៃខ្សែចង្វាក់ផលិតកម្ម សំដៅផ្សារភ្ជាប់ទៅនឹងសាជីវកម្មពហុជាតិ (MNCs)	មធ្យម ទៅវែង	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ បានចេញប្រកាសស្តីពីភតិសន្យាហិរញ្ញវត្ថុ ដែលកម្រិតការអនុវត្ត VAT ត្រឹមតែថ្លៃទំនិញ ឬទ្រព្យសកម្ម។ ▪ បានចេញអនុក្រឹត្យ និងប្រកាសចាត់ទុកការផ្តត់ផ្គង់មិនជាប់អាករនូវផលិតផលមិនទាន់កែច្នៃ។ ▪ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសខ្នាតតូចនិងមធ្យម ដែលចុះបញ្ជីដោយស្ម័គ្រចិត្ត។ - រដ្ឋបាលខេត្តស្វាយរៀង÷ បានជំរុញសហគ្រាសធុនតូច និងមធ្យមនៅក្នុងស្រុកឱ្យចូលរួមខ្សែចង្វាក់ផលិតកម្មសកល ដែលជាការតភ្ជាប់រវាងសហគ្រាសធុនធំបរទេស ជាមួយនឹងសហគ្រាសក្នុងស្រុក មានន័យថាជំរុញឱ្យសហគ្រាសធុនតូច និងមធ្យមក្នុងស្រុកផលិតនូវផលិតផលពាក់កណ្តាលសម្រេច ឬគ្រឿងបង្គុំសម្រាប់គាំទ្រ និងផ្តត់ផ្គង់ឱ្យសហគ្រាសធុនធំ។	
- លើកស្នូយសមត្ថភាពវិទ្យាស្ថានឧត្តមសិក្សា ដើម្បីជាមូលដ្ឋានរឹងមាំមួយសម្រាប់ក្រេបជញ្ជក់យកវិទ្យាសាស្ត្រ បង្កើនការហ្វឹកហ្វឺន និងនវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ សម្រាប់តម្រូវការទីផ្សារ	មធ្យម ទៅវែង	- ក្រសួងអប់រំ យុវជន និងកីឡា÷ ▪ បានលើកទឹកចិត្តឱ្យបើកគ្រឹះស្ថានឧត្តមសិក្សាដែលផ្តល់សេវាអប់រំ ឆ្លើយតបនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងទីផ្សារពលកម្ម។ ▪ បានបង្កើនប្រាក់ឧបត្ថម្ភអាហារូបករណ៍សម្រាប់សិស្សក្រីក្រ សិស្សពូកែនៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានអភិវឌ្ឍគោលនយោបាយស្តីពីចក្ខុវិស័យអប់រំឧត្តមសិក្សាឆ្នាំ ២០៣០ ផ្តោតលើដំណើរការបង្កើតគោលការណ៍គម្រោងផ្តល់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភ និងឥណទានសម្រាប់អ្នកសិក្សានៅកម្រិតឧត្តមសិក្សា។ ▪ បានលើកទឹកចិត្តឱ្យគ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ ទាំងឯកជនបង្កើតផែនការយុទ្ធសាស្ត្រ និងបង្កើនសកម្មភាពស្រាវជ្រាវទាំងសាស្ត្រាចារ្យ និងនិស្សិត។ ▪ បានដាក់ឱ្យដំណើរការសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ។ ▪ មានវិទ្យាស្ថានកំពង់ឈើទាល ខេត្តកំពង់ធំ ដែលជាព្រះរាជទានរបស់ព្រះមហាក្សត្រីព្រះរាជាណាចក្រថៃ, វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្ល្រាត ខ្សាច់កណ្តាល និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី នៅខេត្តកំពង់ឆ្នាំង និងកំពុងរៀបចំដំណើរការវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ។ ▪ បានទទួលថវិការវិភាជពីរាជរដ្ឋាភិបាលសម្រាប់ការបង្រៀនមុខជំនាញពាក់ព័ន្ធ នៅតាមវិទ្យាស្ថាន និងគ្រឹះស្ថានឧត្តមសិក្សានានា។ ▪ បានកែលម្អនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំនៅគ្រឹះស្ថានឧត្តមសិក្សា និងកំពុងធ្វើការវាយតម្លៃលើគ្រឹះស្ថានឧត្តមសិក្សាចំនួន១៦។ ▪ បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា។ ▪ បានរៀបចំសេចក្តីព្រាងស្តីពីការធានាគុណភាពឧត្តមសិក្សាផ្ទៃក្នុង។	

ទិសដៅគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពខ្សត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានរៀបចំឯកសារទស្សនាទានស្តីពីការបង្កើតការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។ ▪ បានពង្រឹង និងពង្រីកការសិក្សាមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្ប:ច្នៃប្រឌិត (STEAM) នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ និស្សិតកំពុងសិក្សាបរិញ្ញាបត្រលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្ប:ច្នៃប្រឌិត និងគណិតវិទ្យា (STEAM) កើនឡើងដល់ ៤៤ ៥៥៨ នាក់ ក្នុងនោះ ស្រី ២៥,៥ភាគរយ ស្មើនឹង២៤,៣៥ភាគរយ ធៀបនឹងនិស្សិតបរិញ្ញាបត្រសរុប។ ▪ បានសហការយ៉ាងជិតស្និទ្ធជាមួយ÷ - ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន (JICA) ដោយទទួលបានការគាំទ្រគម្រោងថ្មីមួយដែលបាននិងកំពុងអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងភូមិភាគបាត់ដំបងឱ្យក្លាយជាវិទ្យាស្ថានគរុកោសល្យ សម្រាប់បណ្តុះបណ្តាលគ្រូកម្រិតបរិញ្ញាបត្រ និងបានលើកស្នើគម្រោង "បណ្តុះបណ្តាលការលើកកម្ពស់គុណភាពអប់រំមូលដ្ឋានកម្រិតបរិញ្ញាបត្រជាន់ខ្ពស់" សម្រាប់គ្រូឌុនទ្មេស ៥នាក់ នៅតាមគរុកោសល្យ។ - ធនាគារពិភពលោក គាំទ្រឧត្តមសិក្សា តាមរយៈគម្រោង "លើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា" ដោយបានផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាទៅសិក្សានៅបរទេស និងផ្តល់ហិរញ្ញប្បទានសម្រាប់ពង្រឹង	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		សមត្ថភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា។	
- បង្កើតពានរង្វាន់សម្រាប់ការប្រកួតប្រជែងបច្ចេកទេសនៅលើគ្រប់មុខសញ្ញាអាទិភាព	២០១៥ ទៅមធ្យម	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷ បានផ្តល់ពានរង្វាន់ស ចំនួន ៥ ពានរង្វាន់ ជូនដល់ក្រុមហ៊ុនសហគ្រាស រោងចក្រ និងសិប្បកម្ម។ - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍÷ បានរៀបចំពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០១៥និង២០១៦។	
- ជំរុញការបង្កើតសមាគមតាមអនុវិស័យវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ឥស្សរជនៈ និងការពារសិទ្ធិប្រយោជន៍ ក៏ដូចជា ពង្រឹងទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ក្នុងការទទួលការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ	២០១៥ ទៅមធ្យម	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសក្នុងស្រុក ដើម្បីអាចផ្សារភ្ជាប់ និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាស និងវិនិយោគបរទេសធំៗ ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស។	មធ្យម ទៅវែង	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	
ទ-ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យ			
- ធ្វើវិសោធនកម្មកែលម្អច្បាប់ស្តីពីគណនេយ្យ សហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដោយរៀបចំស្តង់ដាគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច និងមធ្យម		- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បានកែប្រែរបបកំណត់ពន្ធដោយលុបចោលរបបម៉ៅការទៅជារបបស្វ័យប្រកាសសម្រាប់អ្នកជាប់ពន្ធតូច មធ្យម និងធំ។ ▪ បានអនុគ្រោះពីការប្រមូលពន្ធចំពោះអ្នកជាប់ពន្ធមានផលរបរក្រោមអប្បបរមានៃការចុះបញ្ជី (២៥០លានរៀល)។	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ ភាពមមាញឹករបស់សហគ្រាសអនុម័តច្បាប់គណនេយ្យ និងសវនកម្ម ដែលនាំឱ្យមានការយឺតយ៉ាវ និងប៉ះពាល់ដល់ពេលវេលា

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បាននិងកំពុងដាក់ឱ្យប្រើប្រាស់គំរូគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច។ ▪ បានប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយបានរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធចុះបញ្ជី និងធ្វើបច្ចុប្បន្នកម្ម ដើម្បីសម្រួលដល់អ្នកជាប់ពន្ធក្នុងការផ្តល់សេវា ការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ (ប្រកាសលេខ៤៩៦ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីពន្ធដារ)។ ▪ បានរៀបចំ និងដាក់អនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច (ប្រកាសលេខ១៨២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកំណត់វិធាន និងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច)។ ▪ បានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវទម្រង់លិខិតប្រកាសប្រចាំខែ ប្រចាំឆ្នាំ របស់អ្នកជាប់ពន្ធតូចមានលក្ខណៈងាយស្រួលមិនស្មុគ-ស្មាញ តាមរយៈសេចក្តីជូនដំណឹងលេខ១៣៦៩ អពដ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ អំពីការដាក់ឱ្យប្រើប្រាស់ទម្រង់លិខិតប្រកាសបង់ប្រាក់ពន្ធប្រចាំខែសម្រាប់អ្នកជាប់ពន្ធតូច។ - ក្រុមប្រឹក្សាជាតិគណនេយ្យ ÷ ▪ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវបានអនុម័ត និងដាក់ឱ្យប្រើកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦។ ▪ បានរៀបចំអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ និងបានបញ្ជូនទៅលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្មដើម្បីសុំយោបល់តាំងពីខែឧសភា ឆ្នាំ២០១៦។	ដែលចង់បាន។ ▪ មន្ត្រីក្រុមប្រឹក្សាជាតិគណនេយ្យមានចំនួនតិច និងសមត្ថភាពនៅមានកម្រិត។

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានរៀបចំអនុក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្មរួចក្នុងក្របខ័ណ្ឌបច្ចេកទេស និងរង់ចាំការសម្រេចពីកិច្ចប្រជុំក្រុមប្រឹក្សាជាតិគណនេយ្យ។ ▪ បាននិងកំពុងរៀបចំអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ក្នុងក្របខ័ណ្ឌបច្ចេកទេស។ ▪ កំពុងរៀបចំសេចក្តីព្រាងប្រកាសមួយចំនួន តាមខ្លឹមសារនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- ពង្រឹងយន្តការក្រោមដំបូលតែមួយសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ដោយប្រើប្រាស់ការចុះបញ្ជី និងការកាន់បញ្ជីគណនេយ្យសម្រាប់ជាមូលដ្ឋានវាយតម្លៃ និងជាលក្ខខណ្ឌសម្រាប់ការផ្តល់ការលើកទឹកចិត្ត និងការគាំទ្រពីរាជរដ្ឋាភិបាល	២០១៥	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷ ▪ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្របសម្រួលការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូច និងមធ្យម និងសេវាកម្ម នៅក្រោមក្របខ័ណ្ឌដំបូលតែមួយ ដែលបច្ចុប្បន្នបានដាក់ជូនទៅដល់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច ដើម្បីដាក់ប្រជុំឆ្លងចុងក្រោយ មុននឹងជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច។ - ក្រសួងពាណិជ្ជកម្ម - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន÷ ▪ រៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីពន្ធដារអំពីគំរូបញ្ជីកាគណនេយ្យសាមញ្ញ។ ▪ បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលអ្នកជាប់ពន្ធគ្រប់សាខាពន្ធដារខេត្ត-ខណ្ឌអំពីគំរូបញ្ជីកាគណនេយ្យសាមញ្ញ។	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានផ្តល់កិច្ចសហការក្នុងការពង្រឹងយន្តការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យមជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ÷ បានបញ្ចប់សេចក្តីព្រាងប្រកាសស្តីពីការចុះបញ្ជី និងផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុន បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងស្រុក។ - រដ្ឋបាលខេត្តស្វាយរៀង÷ បានជំរុញការចុះបញ្ជីរោងចក្រចំនួន ៦២ រោងចក្រ និងចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មចំនួន ៦៥កន្លែង។	
- លើកទឹកចិត្តដល់សហគ្រាសធុនធំ សហគ្រាសធុនតូចនិងមធ្យម ឱ្យកាន់បញ្ជីគណនេយ្យ និងធ្វើការបង់ពន្ធតាមរបបពិត	២០១៥ ទៅមធ្យម	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន÷ ▪ បង្កើតក្រុមការងារគណនេយ្យ ពន្ធដារ និងមូលបត្រ ដើម្បីសិក្សាលើការអភិវឌ្ឍក្របខ័ណ្ឌគណនេយ្យងាយស្រួលសម្រាប់សហ-គ្រាសធុនមីក្រូ (Simplified Accounting Template for Micro-enterprises) ក្នុងគោលដៅសម្រួលដល់ការបង់ពន្ធតាមរបបពិត និងបង្កលក្ខណៈងាយស្រួលឱ្យសហគ្រាសធុនតូច និងមធ្យមអាចចូលរួមនៅក្នុងទីផ្សារមូលបត្រ។ ជាលទ្ធផល ឯកសារគំរូកត់ត្រាចំណូល ចំណាយងាយៗ និងរបាយការណ៍ហិរញ្ញវត្ថុគំរូងាយៗ សម្រាប់សហគ្រាសធុនមីក្រូ (Simplified Financial Reporting for Micro-enterprises) ត្រូវបានបង្កើតឡើង និងបានបណ្តុះបណ្តាលមន្ត្រីពន្ធដារ ដើម្បីបណ្តុះបណ្តាលបន្តជូនសហគ្រាសជាប់កាតព្វកិច្ច។ ▪ ចងក្រងទិន្នន័យសហគ្រាសធុនតូចនិងមធ្យម ដែលបានចុះបញ្ជី	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ▪ ផ្សព្វផ្សាយអំពីសារៈសំខាន់នៃការកាន់បញ្ជីគណនេយ្យជូនសហ-គ្រាសធុនតូចនិងមធ្យម ក្នុងក្របខ័ណ្ឌតំបន់រដ្ឋបាល តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ។ ▪ រៀបចំផែនការបណ្តុះបណ្តាលជូនសហគ្រាសក្នុងក្របខ័ណ្ឌតំបន់រដ្ឋបាល។ ▪ សម្រេចជាគោលការណ៍អនុញ្ញាតឱ្យរោងចក្រកាត់ដេរប្រតិបត្តិតាមមូលដ្ឋានផលិតកម្ម (Free on Board: FOB) ផង និងមូលដ្ឋានកាត់ដេរ/ផលិត និងតម្រឹម/សម្អាត (Cut, Make and Trim: CMT) ផង ក្នុងករណីរោងចក្រកាត់ដេរកាន់បញ្ជីគណនេយ្យត្រឹមត្រូវ។ ▪ សម្រេចជាគោលការណ៍ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធចំពោះសហ-គ្រាសធុនតូច និងមធ្យមដែលកាន់បញ្ជីគណនេយ្យត្រឹមត្រូវ។ - ក្រុមប្រឹក្សាជាតិគណនេយ្យ÷ បានបង្កើតនិងដាក់ឱ្យអនុវត្តគំរូបញ្ជីគណនេយ្យសាមញ្ញសម្រាប់សហគ្រាសធុនតូច (មីក្រូសហគ្រាស) ដោយប្រកាសលេខ១៨២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកំណត់វិធាន និងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។	
- ពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់ពង្រឹងនិងពង្រីកវិស័យឯកជន ដើម្បីលើកស្ទួយវប្បធម៌នៃគណនេយ្យភាពសង្គម និងលទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងទីផ្សារហិរញ្ញវត្ថុ តាមរយៈផ្តល់ការបណ្តុះបណ្តាលលើការគ្រប់គ្រងទូទៅ ការគ្រប់គ្រងប្រព័ន្ធផលិតកម្ម	២០១៥ ទៅមធ្យម	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រសួងពាណិជ្ជកម្ម÷ បានបើកវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវពាណិជ្ជកម្ម ដើម្បីពង្រឹងសមត្ថភាពវិស័យឯកជនឱ្យបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញក្នុងការធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធ-ភាព។	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
និងការគ្រប់គ្រងបច្ចេកវិទ្យាសម្រាប់សហ-គ្រាសធុនតូច និងមធ្យម			
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីភាពងាយស្រួល និងអត្ថប្រយោជន៍នៃការចុះបញ្ជី	២០១៥	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- ផ្តល់ការបណ្តុះបណ្តាលលើការកាន់បញ្ជីគណនេយ្យសម្រាប់សហគ្រាសធុនតូច និងមធ្យម	២០១៥ ទៅមធ្យម	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ បាននិងបន្តរៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីពន្ធដារអំពីគំរូបញ្ជីគណនេយ្យសាមញ្ញ។ ▪ បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលអ្នកជាប់ពន្ធតូចអំពីគំរូបញ្ជីគណនេយ្យសាមញ្ញ និងកាតព្វកិច្ចសារពើពន្ធនានា។ ▪ បានលើកទឹកចិត្តដល់អ្នកជាប់ពន្ធគ្រប់ប្រភេទ ដែលបានកាន់កាប់បញ្ជីគណនេយ្យបានត្រឹមត្រូវឱ្យរួចផុតពីការបង់ពន្ធអប្បបរមា។ - ក្រុមប្រឹក្សាជាតិគណនេយ្យ÷ បានរៀបចំការបណ្តុះបណ្តាលមន្ត្រីពន្ធដារអំពីឯកសារគំរូកត់ត្រាចំណូល ចំណាយងាយៗ និងរបាយការណ៍ហិរញ្ញវត្ថុគំរូងាយៗសម្រាប់មីក្រូសហគ្រាស (Simplified Financial Reporting for Micro-Enterprises) ដើម្បីបណ្តុះបណ្តាលបន្ថែមជូនសហគ្រាសជាប់កាតព្វកិច្ច។	- ក្រុមប្រឹក្សាជាតិគណនេយ្យ÷ ▪ កត្តាកង្វះខាតធនធានមនុស្ស ▪ កត្តាកិច្ចសហការអន្តរស្ថាប័ននៅមានកម្រិត ▪ កត្តាធនធានថវិកា
គ- ការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម			
- ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផលដូចជាតំបន់កែច្នៃ និងផលិតសង្ហារិម តំបន់កែច្នៃផលិតសម្ភារៈពីកៅស៊ូ តំបន់កែច្នៃផលិតអ្នបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារ	២០១៥ ទៅមធ្យម	- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ÷ ▪ បាននិងកំពុងអនុវត្តផែនការស្រាវជ្រាវរបស់ខ្លួនក្នុងការអភិវឌ្ឍបច្ចេកវិទ្យា មានដូចជាពូជដំណាំ បង្កាត់បច្ចេកវិទ្យាដាំដុះដំណាំប្រកបដោយគុណភាព និងទិន្នផលខ្ពស់ ដើម្បីជាធាតុចូលក្នុង	

វិធានការគោលនយោបាយវិនិយោគ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
សម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផង និងនាំចេញផង ជាពិសេសដោយប្រើប្រាស់យន្តការភាពជាដៃគូររវាងរដ្ឋ និងវិស័យឯកជន		ដំណើររៀបចំយន្តការសម្របសម្រួល និងគាំទ្រក្នុងការបង្កើត និងដំណើរការតំបន់កសិ-ឧស្សាហកម្ម។ ▪ បាននិងកំពុងដាំពិសោធពោតពូជ Hybrid សណ្តែកបាយ សណ្តែកសៀង ម្រេច ស្វាយចន្ទី ជាដើម និងកំពុងអភិវឌ្ឍបច្ចេកទេសជាំដុះដំណាំស្រូវ ស្របតាមបរិបទនៃការប្រែប្រួលអាកាសធាតុ ពាក់ព័ន្ធនឹងសកម្មភាពស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្សព្វផ្សាយពូជដំណាំដែលមានផលិតភាពខ្ពស់ធន់ទ្រាំនឹងការប្រែ-ប្រួលអាកាសធាតុ និងឆ្លើយតបទីផ្សារជាសក្តានុពលសម្រាប់ផលិតជាវត្ថុធាតុដើមបម្រើឱ្យវិស័យកសិ-ឧស្សាហកម្ម។ ▪ បានសហការជាមួយក្រុមហ៊ុន Tian Rui (Cambodia) Agriculture Cooperation SEZ Co., Ltd នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងផ្នែកសហប្រតិបត្តិការបច្ចេកទេសកសិកម្ម ដើម្បីដំណើរការតំបន់សេដ្ឋកិច្ចពិសេសអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម តាមរយៈការអនុវត្តអនុស្សរណៈយោគយល់ដែលបានចុះហត្ថលេខាកាលពីខែតុលា ឆ្នាំ២០១៦។ ▪ បានរៀបចំសកម្មភាពស្តីពីការសិក្សា វិភាគ និងវាយតម្លៃតំបន់សក្តានុពលនៃផលិតកម្មកៅស៊ូធម្មជាតិនៅកម្ពុជា ព្រមទាំងបាន និងកំពុងរៀបចំចង្អោមសកម្មភាពដើម្បីធ្វើការសិក្សាជំហានដំបូងនៅតាមតំបន់នានាដែលបានកំណត់សម្រាប់អនុវត្តចាប់ពីឆ្នាំ ២០១៦តទៅ។ ▪ បានបង្កើត (១)មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍អាហារ និង២)មជ្ឈមណ្ឌលតូចមួយមានឈ្មោះថា "មជ្ឈមណ្ឌលសុខុមាល-	

ទិសដៅគោលនយោបាយវិនិយោគ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពខ្សត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ភាពសង្គម និងអាហារូបត្ថម្ភ" សម្រាប់សហការជាមួយដៃគូក្នុងការបណ្តុះបណ្តាលកម្មវិធីពាក់ព័ន្ធផ្សេងៗ ជូនដល់និស្សិតនិងក្រុមហ៊ុនមួយអាហារ។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷ ▪ បានបង្កើតក្រុមការងារចុះពិនិត្យសិក្សា និងកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់នូវតំបន់ការពារដីស្រែអំបិល និងរៀបចំផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ស្រែអំបិល។ ▪ បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល ដាក់ជូនថ្នាក់ដឹកនាំចុះហត្ថលេខា និងប្រើប្រាស់ផ្លូវការ។ ▪ បាននិងកំពុងរៀបចំកម្រងបណ្តុំសហគ្រាសធុនតូចនិងមធ្យម នៅខេត្តកណ្តាល ដើម្បីកែច្នៃផលិតផលផ្លែឈើសម្រាប់នាំចេញ និងនៅកំពង់ឆ្នាំង ដើម្បីកែច្នៃជលផលកម្ពុជាសម្រាប់នាំចេញ។ - ក្រសួងពាណិជ្ជកម្ម ÷ ▪ បានសម្របសម្រួលក្រុមហ៊ុនមកពីប្រទេសចិន មកបង្កើតតំបន់កែច្នៃផលិតផលកសិ-ឧស្សាហកម្មកម្ពុជា នៅខេត្តព្រះសីហនុ។ ▪ បាននិងកំពុងធ្វើសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលអាស៊ាន-ចិន ,អាស៊ាន-ជប៉ុន, អាស៊ាន-កូរ៉េ និងដៃគូជំរុញពាណិជ្ជកម្មដទៃទៀតទាំងក្នុងតំបន់ និងលើពិភពលោក ដើម្បីបើកច្រកទីផ្សារលើផលិតផលដែលបានកែច្នៃរួចហើយ។ ▪ បានផ្តល់ការលើកទឹកចិត្តដល់ផលិតផលកសិកម្ម កសិ-ឧស្សាហកម្មដែលបានកែច្នៃរួចហើយ។	

ទិសដៅគោលនយោបាយវិនិយោគ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានចូលរួមតាំងពិព័រណ៍ដើម្បីស្វែងរកដៃគូពាណិជ្ជកម្ម និងធ្វើចរាចរបានទូលំទូលាយនៅលើទីផ្សារ។ ▪ បានសហការជាមួយអង្គការ UNIDO រៀបចំកែលម្អទីតាំងមួយកន្លែងនៅខេត្តកំពត ធ្វើជាផ្សាររួមដាក់តាំងបង្ហាញ និងលក់ផលិតផលជលផលសមុទ្ររបស់សមាជិកសម្ព័ន្ធសមាគមជលផលសមុទ្រកម្ពុជា។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ បានសិក្សា និងពិនិត្យគម្រោងកែច្នៃចំណីអាហារ និងឃ្លាំងសម្ងួតរបស់កំពង់ផែស្វយ័តភ្នំពេញ។ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ÷ ▪ បានដឹកនាំកិច្ចប្រជុំអន្តរក្រសួងក្នុងក្របខ័ណ្ឌអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មស្តីពីការជំរុញវិស័យកសិ-ឧស្សាហកម្ម។ ▪ បានធ្វើការផ្សព្វផ្សាយជូនវិនិយោគិនទាំងក្នុង និងក្រៅប្រទេសអំពីបរិយាកាស និងកាលានុវត្តភាពវិនិយោគនៅកម្ពុជា ជាពិសេសសក្តានុពលនៃការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម ព្រមទាំងបានពិភាក្សាការងារជាមួយតំណាងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ក្នុងការផ្តល់ការគាំទ្រ និងលើកកម្ពស់ការវិនិយោគក្នុងវិស័យនេះ។ - ទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមប្រជុំការងារពាក់ព័ន្ធនឹង IDP លើវិស័យកសិ-ឧស្សាហកម្ម។	
- ផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុន	២០១៥ ទៅ មធ្យម	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីវិនិយោគ	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷

ទិសដៅនៃការគោលនយោបាយវិធានការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិន្នន័យមូលដ្ឋាន និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ		ដោយបានគិតគូរផ្តល់ការលើកទឹកចិត្តបន្ថែមដល់ក្រុមហ៊ុនទាំងឡាយណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងដែលបានបោះទីតាំងនៅក្នុងតំបន់កែច្នៃកសិផល។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន÷ ▪ ចូលរួមពិនិត្យ និងសម្រេចសំណើសុំវិនិយោគក្នុងកិច្ចប្រជុំយន្តការច្រកចេញ-ចូលតែមួយ។ ▪ រៀបចំប្រកាស ប្រកាសរួម និងប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងនានាចំនួន ២៣។ ▪ ធ្វើវិសោធនកម្មច្បាប់-បទប្បញ្ញត្តិមួយចំនួន ដើម្បីលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិកម្ម (ការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃជាការផ្គត់ផ្គង់មិនជាប់អាករ)។ល។ (ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, អនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៥៦នៃអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម, ប្រកាសលេខ៤៩៥ សហវ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ)។ ▪ ពិនិត្យលទ្ធភាពផ្តល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនទាំងឡាយណាដែលបោះទីតាំងនៅក្នុងតំបន់ទាំងនោះ។ ▪ កំពុងបន្តចូលរួមជាមួយក្រុមការងារក្រសួងមុខងារសាធារណៈចុះពិនិត្យ និងកែលម្អការផ្តល់សេវាសាធារណៈអាទិភាពសំខាន់	▪ ក្រសួងសាមីមិនទាន់ស្នើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងតួនាទី	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		នៅក្នុងយុត្តាធិការនៃក្រសួងពាណិជ្ជកម្ម។ - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផលបច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេស ដោយភ្ជាប់ទៅនឹងសក្តានុពលនាំចេញ	មធ្យមទៅវែង	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ បានបញ្ចប់ការចរចាគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (Accelerating Inclusive Markets for Smallholders - AIMS) ជាមួយមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម (International Fund for Agricultural Development: IFAD) ដែលមានទឹកប្រាក់សរុបប្រមាណ ៦១លានដុល្លារអាមេរិក។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- រៀបចំនូវយន្តការសម្រួលដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាភស្តុភារកម្ម លុបបំបាត់ការគ្រៃគ្រាក្នុងវិការ និងកែលម្អការសម្រួលពាណិជ្ជកម្ម	២០១៥ ទៅមធ្យម	- ក្រសួងពាណិជ្ជកម្ម÷ ▪ កំពុងធ្វើកំណែទម្រង់លើច្រើនវិស័យដើម្បីជួយសម្រួលដល់វិស័យឯកជនដូចជា ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម/ការចុះបញ្ជីក្រុមហ៊ុនតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនិងការចុះបញ្ជីពាណិជ្ជនាម តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ▪ បានចេញប្រកាសស្តីពីនីតិវិធីនៃការនាំចូលអង្ករពីបរទេសដើម្បីពង្រឹងឧស្សាហកម្មស្រូវអង្ករ ជាពិសេស ថែរក្សាការពារទីផ្សារអង្ករកម្ពុជា។ - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ÷ ▪ បានកែលម្អនីតិវិធីសម្រាប់ផ្តល់លិខិតអនុញ្ញាតបង្កើតរោងសន្ធិធិ លក់ចែកចាយផលអនុផលព្រៃឈើ ឬរោងសិប្បកម្មកែច្នៃកសិផលអនុផលព្រៃឈើប្រភេទតូចជូនដល់អតិថិជនតាមការស្នើសុំជាក់	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ស្ពែង ដោយបានអនុញ្ញាតផ្តល់ជាគោលការណ៍ប្រចាំឆ្នាំជូនដល់ខណ្ឌរដ្ឋបាលព្រៃឈើ ដើម្បីផ្តល់សេវារហ័សជូនអ្នកស្នើសុំ ▪ បានទិតទំជំរុញឱ្យក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ច ធ្វើការដាំដុះដំណាំកសិ-ឧស្សាហកម្មតាមកិច្ចសន្យា ដោយសម្រេចការដាំដុះបានប្រមាណជាង ៤៣ម៉ឺនហិកតាត្រឹមឆ្នាំ២០១៦នេះ។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បានធ្វើវិមជ្ឈការតម្លៃគិតពន្ធគយដល់មាត់ច្រកបំពេញបែបបទគយ។ ▪ បានចេញសេចក្តីណែនាំស្តីពីការពង្រឹងប្រសិទ្ធភាពនៃការផ្តល់ប្រព្រឹត្តកម្មសមធម៌ក្នុងការត្រួតពិនិត្យបែបបទគយ។ ▪ បានបន្តផ្សព្វផ្សាយ និងអនុវត្តការកែសម្រួលនីតិវិធីគយដើម្បីផ្តល់កិច្ចសម្រួលពាណិជ្ជកម្មបន្ថែមទៀត ដល់វិស័យឯកជនក្នុងការបំពេញបែបបទគយ តាមស្មារតីនៃកិច្ចប្រជុំ CPPM លើកទី៥ និងលើកទី៦ រួមមាន (១) ការបិទផ្សាយលំហូរនីតិវិធី និងស្តង់ដាការងារ (២) ការអនុញ្ញាតឱ្យរើទំនិញច្រើន ម្ចាស់ផ្ទុកក្នុងកុងតឺន័រ (Less Than Container Load) (៣) ការកែលម្អគេហទំព័រគយ (៤) ការពង្រឹងប្រសិទ្ធភាពនៃការបង្ក្រាបបទល្មើស (៥) ការអនុញ្ញាតឱ្យនាំចេញទំនិញកាត់ដេរមានម្ចាស់តែមួយក្នុងរថយន្តមានលក្ខណសម្បត្តិជាកុងតឺន័រ (៦) ការទទួលយកតម្លៃប្រកាសសម្រាប់ QIP និង (៧) ការបង្កើត Hotline សម្រាប់ឥវ៉ាតាមមាត់ច្រក។	
- សិក្សាកំណត់ទ្វារមុខទំនិញអាទិភាពដែលមានសក្តានុពលកែច្នៃសម្រាប់នាំចេញ ហើយ	មធ្យមទៅវែង	- ក្រសួងពាណិជ្ជកម្ម÷ ▪ បានកសាងឯកសារយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា	- ក្រសួងពាណិជ្ជកម្ម÷ ▪ ទីផ្សារតូចចង្អៀត

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទន្ទឹលខ្ទុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
រៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើខ្សែចង្វាក់តម្លៃ ដើម្បីកំណត់មូលដ្ឋានគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍវិស័យទាំងនោះ។		និងផែនទីបង្ហាញផ្លូវអភិក្រមគ្របដណ្ដប់លើវិស័យពាណិជ្ជកម្ម ២០១៤-២០១៨ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកាលពីខែមករា ឆ្នាំ២០១៤ ដោយបានកំណត់ទ្ធវមុខទំនិញជាអាទិភាពរបស់កម្ពុជា រួមមានផលិតផល អង្ករ ជលផល ចំណីអាហារកែច្នៃ ម្រេច ដំឡូងមី ស្វាយចន្ទី ពោត សណ្ដែកសៀង កញ្ចុងអង្ករ ស្ងួត ក្រៅស្ងួ បន្លែ និងផ្លែឈើ ទំនិញសម្ភាល់ភូមិសាស្ត្រ។ល។ ▪ បានរៀបចំបង្កើតអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា ដើម្បីបម្រើទីផ្សារក្នុងស្រុក និងជំរុញការនាំចេញផលិតផលហាឡាលកម្ពុជាទៅទីផ្សារអន្តរជាតិ ជាពិសេសទីផ្សារនៅមជ្ឈិមបូព៌ា។ ▪ បានសិក្សាផលិតផលថ្មីៗ ដែលមានសក្តានុពលបម្រើឱ្យទីផ្សារក្នុងស្រុក និងសម្រាប់នាំចេញដែលទើបតែលេចចេញនៅក្នុងខេត្តមួយចំនួនដូចជា ស្ករអំពៅខេត្តស្វាយរៀង កោះកុង ព្រះ-វិហារ, ផ្លែចេកខេត្តកំពង់ចាម ព្រះវិហារ, ផ្លែល្ពៅខេត្តព្រះវិហារ, ផលិតផលស្ងួតខេត្តសៀមរាប កំពង់ធំ តាកែវ បន្ទាយមានជ័យ កំពត និងខេត្តកណ្ដាល។ - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ÷ ▪ បានចងក្រងផលិត និងបោះពុម្ពផ្សព្វផ្សាយផែនទីកំណត់តំបន់ដាំដុះដំណាំ ចំនួន ៨ស្រុក និងផែនទីនៃការប្រើប្រាស់ដីកសិកម្មចំនួន ៩ខេត្ត ព្រមទាំងបានសិក្សា និងចងក្រងទិន្នន័យផ្ទៃដីដាំដុះដំណាំ ឈើហូបផ្លែនៅតាមបណ្ដាឃុំ/ សង្កាត់ ចំនួន ១០២ឃុំ។ ▪ បានចងក្រង និងរៀបចំជាផែនទីចង្អុលបង្ហាញតំបន់ផលិតកម្ម	▪ ការអភិវឌ្ឍន្ធនូវសម្ភារៈវេចខ្ចប់ និងស្ដង់ដាអនាម័យនៅមានកម្រិត ▪ កង្វះលទ្ធភាពក្នុងការវិនិយោគក្នុងស្រុក និងបរទេស ▪ កង្វះខាតថវិកា ធនធានមនុស្ស និងបច្ចេកទេសក្នុងការអនុវត្ត

ទិសដៅការគោលនយោបាយវិនិយោគ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ ដែលត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ដំណាំចំនួន ៧មុខ (សណ្តែកបាយ សណ្តែកដី ពោត ដំឡូងមី ស្វាយ ម្រេច ល)។ ▪ បានចូលរួមសន្និសីទ សន្និបាត និងកិច្ចប្រជុំនានាប្រចាំឆ្នាំ២០១៦ របស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិនៅប្រទេសឥណ្ឌា។ ▪ បានរៀបចំសន្និសីទកៅស៊ូអន្តរជាតិ និងកិច្ចប្រជុំប្រចាំឆ្នាំ២០១៦ របស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ នៅខេត្តសៀមរាប។ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា÷ ▪ បានចូលរួមពិភាក្សានិងផ្តល់យោបល់លើការលើកកម្ពស់ខ្សែចង្វាក់តម្លៃនៃផលិតផលកសិកម្ម និងការកំណត់មុខដំណាំអាទិភាពមួយចំនួនសម្រាប់កែច្នៃនាំចេញក្នុងកិច្ចប្រជុំ និងសិក្ខាសាលាពាក់ព័ន្ធមួយចំនួនដូចជា (១) កិច្ចប្រជុំតុមូល ដែលសហការរៀបចំដោយក្រសួងឧស្សាហកម្មនិងសិប្បកម្មនិងអង្គការ UNIDO ដើម្បីសិក្សានិងកំណត់ដំណាំអាទិភាពមួយចំនួន រួមមានអង្ករ កៅស៊ូ (ផលិតផលពាក់កណ្តាលសម្រេច) ស្វាយ ម្រេច អំបិល ត្រាប់ស្វាយចន្ទី ដំឡូងមី សណ្តែកសៀង និងពោត ដែលអាចធ្វើការកែច្នៃសម្រាប់នាំចេញ, (២) សិក្ខាសាលាស្តីពីការផ្សព្វផ្សាយលទ្ធផលសិក្សាស្រាវជ្រាវលើខ្សែចង្វាក់ផលិតផលស្ករត្នោត និងស្វាយ ដែលមានសក្តានុពលសម្រាប់កែច្នៃ និងនាំចេញ, (៣) សិក្ខាសាលាស្តីពីភាពជាដៃគូ Grow Asia នៅកម្ពុជា ដើម្បី	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		វិស័យកសិកម្មប្រកបដោយនិរន្តរភាព ដោយបានកំណត់បញ្ហាប្រឈម និងជំរុញខ្សែចង្វាក់តម្លៃនៃផលិតផលកសិកម្ម ៦មុខ រួមមាន ដំឡូងមី ដូង ម្រេច អង្ករ បន្លែ និងស្រូវរត្នោត, និង (៤) សិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍ពាក់កណ្តាល ការសិក្សារៀបចំគម្រោងខ្សែចង្វាក់តម្លៃនៃកសិធុរកិច្ចប្រកប ដោយភាពរបរិស្ថាន ដោយផ្តោតលើមុខដំណាំ ៤មុខរួមមាន ស្រូវ ពោត ដំឡូងមី និងស្វាយ ដែលគ្រោងអនុវត្តនៅខេត្តតាកែវ កំពត កំពង់ចាម និងត្បូងឃ្មុំ ក្នុងគោលបំណងបង្កើនផលិតភាពតាមរយៈការអនុវត្តផលិតកម្ម និងការកែច្នៃផលិតផលកសិកម្មឱ្យមាននិរន្តរភាព និងសម្របតាមការប្រែប្រួលអាកាសធាតុ កែលម្អគុណភាព និងបង្កើនតម្លៃបន្ថែម។	
៣)-ការកែលម្អបរិស្ថានវិយតកម្ម			
ក-វិធានការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញ			
- ពន្លឿនបញ្ចប់ការអនុវត្តផែនការកែទម្រង់ការសម្រួលពាណិជ្ជកម្ម រួមទាំងការដាក់ឱ្យប្រើប្រាស់សេវា ***"បញ្ជរតែមួយជាតិ"*** ដោយមានការសម្របសម្រួលគ្នាក្នុងចំណោមអាជ្ញាធរតាមមាត់ច្រកអន្តរជាតិទាំងអស់ ហើយធានាឱ្យមានសមាហរណកម្មជាមួយនឹងសេវា ***"បញ្ជរតែមួយអាស៊ាន"*** និងការតភ្ជាប់ទៅនឹងបណ្តាញភស្តុភារកម្មអន្តរជាតិ	២០១៥ ទៅមធ្យម	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន÷ ▪ ដំឡើងប្រព័ន្ធអាស៊ីគ្លូដា តាមការិយាល័យគយ និងរដ្ឋាករចំនួន៥៤ និងបន្តពង្រីកភាពគ្របដណ្ដប់ប្រព័ន្ធនេះទៅគ្រប់ការិយាល័យគយសំខាន់ៗ។ ▪ សិក្សាផែនការលម្អិតសម្រាប់អនុវត្តគម្រោងបញ្ជរតែមួយជាតិ។ ▪ សិក្សាអំពីតម្លាភាពផ្នែកច្បាប់។ ▪ បង្កើតក្រុមការងារចំនួន ៣ គឺ÷ (១)ក្រុមផ្តល់ប្រឹក្សាផ្នែកច្បាប់ និងគោលនយោបាយ (២)ក្រុមអនុវត្តគម្រោង និង (៣) លេខាធិការដ្ឋានបញ្ជរតែមួយជាតិ។	- ក្រសួងពាណិជ្ជកម្ម បានស្នើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាក្រសួងនាំមុខលើបញ្ហានេះតាមស្មារតីកិច្ចប្រជុំប្រចាំខែ ឧសភានៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ ខ្វះប្រភពថវិកាសម្រាប់អនុវត្ត ▪ ខ្វះធនធានមនុស្សសម្រាប់ដំណើរការ និងថែរក្សា

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ កំពុងជំរុញអនុវត្តដោយស្ថិតក្រោមយន្តការភាពជាដៃគូគយ-ផ្នែកឯកជន និងតាមបញ្ញត្តិប្រកាសអន្តរក្រសួងស្តីពីការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យជាធរមាន។ ▪ ជ្រើសរើស និងបណ្តុះបណ្តាលជើងសាគយវិជ្ជាជីវៈជាមធ្យមជាង ១០០រូបក្នុងឆ្នាំ ត្រៀមបម្រុងអនុវត្តប្រព័ន្ធនេះ។ - ក្រសួងសាធារណការ និងដឹកជញ្ជូន	
- បង្កើតនូវមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម ដែលប្រមូលផ្ដុំនូវព័ត៌មានអំពីវិធានពាណិជ្ជកម្ម តារាងពន្ធ និងកម្រៃផ្ទេរការដែលត្រូវបង់ដោយពាណិជ្ជករ ហើយដាក់ព័ត៌មានទាំងនេះលើបណ្ដាញអ៊ីនធើណែត	២០១៥	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន÷ ▪ ដាក់ឱ្យដំណើរការគេហទំព័រគយថ្មី www.customs.gov.kh និងកម្រងអត្ថបទនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ និងបានដាក់ឱ្យដំណើរការពេញលេញចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ ព្រមទាំងបានធ្វើបច្ចុប្បន្នកម្មជាប្រចាំ។ ▪ រៀបចំកែលម្អស្តង់ដារសេវាសាធារណ :និងជំរុញឱ្យអនុវត្តប្រកាសរួមស្តីពីការផ្ដល់សេវាសាធារណរបស់ក្រសួង: ពាណិជ្ជកម្ម។	- ក្រសួងពាណិជ្ជកម្ម បានស្នើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាក្រសួងនាំមុខលើបញ្ហានេះ តាមស្មារតីកិច្ចប្រជុំប្រចាំខែ ឧសភា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ ក្រុមការងារត្រូវធ្វើបច្ចុប្បន្នកម្ម បទប្បញ្ញត្តិថ្មីៗ
- កែលម្អការធ្វើបែបបទបញ្ចេញទំនិញ (Custom Clearance) សម្រាប់ទំនិញដែលលើកលែងពន្ធ ដោយពង្រឹងកិច្ចសហប្រតិបត្តិ-ការរវាងស្ថាប័នពាក់ព័ន្ធ កាត់បន្ថយនូវតម្រូវការឯកសារមិនចាំបាច់ សម្រួលនីតិវិធីឱ្យបានឆាប់រហ័ស និងលុបបំបាត់ចំណាយក្រៅផ្លូវការ	២០១៥	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន÷ ▪ ដាក់ឱ្យអនុវត្តប្រកាសលេខ១១១៥១ សហវ.ប្រក ស្តីពីការផ្ដល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ▪ កំពុងដំណើរការកសាងសេចក្ដីព្រាងប្រកាស កសហវ ចុងក្រោយពាក់ព័ន្ធនឹងកម្រៃគយផ្សេងទៀត។ ▪ បានធ្វើការសិក្សារយៈពេលបញ្ចេញទំនិញពីគយ (TRS) ចុង	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ ស្នើសុំឱ្យមានការចូលរួមពីស្ថាប័នជំនាញ និងផ្នែកឯកជន

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពសង្ក្រៃ អនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ក្រោយនាខែវិច្ឆិកា ឆ្នាំ២០១៤។ រយៈពេលបំពេញបែបបទគយ ត្រូវបានកាត់បន្ថយមកត្រឹម ១ម៉ោង៣នាទី សម្រាប់ផ្លូវអាកាស, ២ម៉ោង៥៨ នាទី សម្រាប់ផ្លូវទឹកនិង១ម៉ោង៣៥ នាទី សម្រាប់ផ្លូវគោក (គិតពីពេលចុះបញ្ជីកា SAD ដល់ពេលអនុញ្ញាតឱ្យយកទំនិញចេញ - Release order)។ ▪ កំពុងចាត់ចែងឱ្យមានការធ្វើ TRS នាពេលដ៏ខ្លីខាងមុខម្តងទៀត។ ▪ រៀបចំកិច្ចប្រជុំក្រោមក្របខ័ណ្ឌយន្តការភាពជាដៃគូគយ-ផ្នែកឯកជន ទៀងទាត់តាមសំណូមពរក្នុងកម្រិតក្រុមការងារបច្ចេកទេសទាំង ៣នៃយន្តការនេះ ហើយកិច្ចប្រជុំរបស់យន្តការនេះត្រូវបានធ្វើភ្លាមប្រសិនបើមានសំណូមពរការងារចាំបាច់។ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបន្តពង្រឹងការពិនិត្យ និងការអនុម័តលើសំណើការនាំចូលដោយពន្ធជាបន្ទុករបស់រដ្ឋ របស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។	
- កាត់បន្ថយនូវនីតិវិធីត្រួតពិនិត្យដែលជាន់ជ្នា និងគ្មានតម្លាភាព	២០១៥	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យវិនិយោគ (Investment Tracking System) ក្នុងគោលបំណងតាមដានគម្រោងវិនិយោគ និងបង្កើនតម្លាភាព។ - ក្រសួង/ស្ថាប័នពាក់ព័ន្ធ	
- រៀបចំឱ្យមានផែនការមេមួយអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ដែលជាមូលដ្ឋានក្នុងការជួយ សម្រួលពាណិជ្ជកម្ម និងជាប្រព័ន្ធដែលមានប្រសិទ្ធភាពអាចទុកចិត្តបាន និងមាន	២០១៥ ទៅមធ្យម	- ក្រសួងសាធារណការ និងដឹកជញ្ជូន បានដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១៧-២០១៩ លើការរៀបចំផែនការមេប្រព័ន្ធភស្តុភារកម្ម ដោយសិក្សាពីយន្តការខាងលំហូរទំនិញឆ្លងកាត់ (បរិមាណ និងប្រភេទទំនិញ) ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់	

ទិសដៅនៃការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ និងតម្រូវការ	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ភាពប្រកួតប្រជែងខ្ពស់		ផែ និងតំបន់សេដ្ឋកិច្ចពិសេស និងកំណត់ទីតាំងកំពង់ផែ ដើម្បីស្តុក រក្សាទុក ផ្គត់ផ្គង់ និងចែកចាយទំនិញ។ បច្ចុប្បន្ន ក្រុមជំនាញការរបស់ក្លាវ៉ែ បានសិក្សាអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ចំណែកឯក្រុមជំនាញការ JICA ក៏បាននិងកំពុងដំណើរការអង្កេត និងស្រាវជ្រាវដើម្បីរៀបចំផែនការមេដឹកជញ្ជូននិងភស្តុភារកម្ម នៅកម្ពុជាផងដែរ។ - ក្រសួងពាណិជ្ជកម្ម - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាស្តីពីផែនការមេអំពីការអភិវឌ្ឍប្រព័ន្ធភស្តុភារកម្ម ដែលជាមូលដ្ឋានក្នុងការជួយសម្រួលពាណិជ្ជកម្ម។	
- ជំរុញកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់និងអនុតំបន់នានា ដូចជា អាស៊ាន និងកម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន (CBTA) និង" ***យន្តការបញ្ជូនតែមួយ*** "ដែលត្រូវបានបង្កើតឡើងក្នុងគោលដៅកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារកម្មអន្តរជាតិក្នុងតំបន់ ទន្ទឹមនឹងការរៀបចំបង្កើតក្របខ័ណ្ឌស្ថាប័នចាំបាច់នានាដើម្បីធ្វើសមាហរណកម្មបញ្ជូលក្នុងប្រព័ន្ធភស្តុភារកម្ម កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលឱ្យកាន់តែទូលំទូលាយជាមួយអាជ្ញាធរដែលពាក់ព័ន្ធដែលមានកាតព្វកិច្ចក្នុងការសម្រួលការដឹកជញ្ជូន ការចល័តមនុស្ស	២០១៥ ទៅមធ្យម	- ក្រសួងសាធារណការ និងដឹកជញ្ជូន÷ ▪ បានចុះអនុស្សរណៈនៃការយោគយល់ស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-ឡាវ-វៀតណាមនិងបានរៀបចំពិធីសម្ពោធបើកប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់បីប្រទេស CLV ជានិមិត្តរូបនៅច្រកត្រពាំងស្រែវ៉ាលី ដែលរៀបចំដោយភាគីវៀតណាម និងអញ្ជើញភាគីកម្ពុជានិងឡាវ ចូលរួម ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៥ កន្លងទៅ នៅច្រកទ្វារនៅត្រពាំងស្រែ-ភ៉ាលី។ ភាគីនីមួយៗ មានកូតាយានយន្តចំនួន១៥០គ្រឿង សម្រាប់ធ្វើប្រតិបត្តិការឆ្លងកាត់ពាប្រទេស។ ▪ កិច្ចសហប្រតិបត្តិការជាមួយឡាវ÷ ➢ គណៈកម្មាធិការសម្រួលការដឹកជញ្ជូនរបស់ភាគីទាំងពីរកម្ពុជា-ឡាវ បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំកាលពីថ្ងៃទី២២ និងទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយបានឯកភាពគ្នាជំរុញកូតាយានយន្ត	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷ ▪ ខ្វះថវិកា ▪ ខ្វះធនធានមនុស្ស

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
និងទំនិញ		ឱ្យដល់ ១៥០គ្រឿង, ស្នើអនុវត្ត និងអនុញ្ញាតឱ្យរថយន្តគ្រួសារអាចចេញចូលទៅវិញទៅមករវាងប្រទេសទាំងពីរ, ស្នើផ្លូវឆ្លងកាត់ថ្មី ស្ពឹងត្រែង-ព្រះវិហារ-សៀមរាប, ស្នើរៀបចំពិធីសារស្តីពីការដឹកជញ្ជូនអ្នកដំណើរទៀងទាត់តាមកាលវេលា, និងស្នើការរៀបចំមន្ត្រីទំនាក់ទំនងនៅថ្នាក់ក្រសួង និងមន្ទីរថ្នាក់ខេត្ត រវាងភាគីទាំងពីរ។ ▪ កិច្ចសហប្រតិបត្តិការជាមួយវៀតណាម÷ ➢ ភាគីទាំងពីរកំពុងបន្តពិនិត្យពិភាក្សាបញ្ចប់ និងគ្រោងចុះហត្ថ-លេខាលើសេចក្តីព្រាង MOU ស្តីពីការជំរុញការសាងសង់ផ្លូវល្បឿនលឿន និងចំណុចតភ្ជាប់ផ្លូវល្បឿនលឿន និង MOU ស្តីពីកិច្ចសហប្រតិបត្តិការនិងការតភ្ជាប់វិស័យដឹកជញ្ជូនឆ្នាំ២០១៦-២០២០ និងទស្សនវិស័យឆ្នាំ២០៣០។ ➢ បានប្រជុំពិគ្រោះយោបល់ផ្ទៃក្នុង និងជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ស្តីពីការកំណត់ចំណុចតភ្ជាប់ផ្លូវល្បឿនលឿនភ្នំពេញ-ហ្ជូដីមិញ ដែលសិក្សាដោយ JICA ដែលគ្រោងធ្វើនៅក្បែរបង្គោលព្រំដែនលេខ១៦៤ (ភូមិធ្លក) មានចម្ងាយប្រមាណ ៤ គីឡូម៉ែត្រ ពីផ្លូវជាតិលេខ១ ត្រង់ភូមិព្រៃផ្តៅ សង្កាត់ច្រកម្ទេស ក្រុងបាវិត។ ក្រសួងនឹងរៀបចំលិខិតជាផ្លូវការសុំយោបល់ពីលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិកិច្ចការព្រំដែន និងសុំគោលការណ៍ឯកភាពប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យសម្រេចលើចំណុចតភ្ជាប់នេះ។ ➢ បន្តអនុវត្តកូតាយានយន្ត៥០០គ្រឿង ក្នុងក្របខ័ណ្ឌអនុស្សរណៈ	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		នៃការយោគយល់ ស្តីពីការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជា-វៀតណាម។ ➢ បានស្នើដល់វៀតណាមនូវចំណុចមួយចំនួនដូចជា ពិចារណាឱ្យក្រុមហ៊ុនកម្ពុជា អាចបើកការិយាល័យសាខានៅប្រទេសវៀត-ណាម បានពិនិត្យបញ្ជាបង់ប្រាក់ការដឹកទំនិញកុងតឺន័រឆ្លងកាត់ ស្នើបន្ថែមមន្ត្រីអន្តោប្រវេសន៍បំពេញការងារនៅបញ្ជរ ៥ ដែលមានស្រាប់។ ➢ ភាគីវៀតណាម ក៏បានស្នើនូវចំណុចមួយចំនួនផងដែរ ដូចជា (១) សុំបង្កើតគណៈកម្មការរួម ថ្នាក់ឧបនាយករដ្ឋមន្ត្រី ដើម្បី អនុវត្តអនុស្សរណៈស្តីពីការផ្ទេរផ្តើមអនុវត្តកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន (MOU-IICBTA) ដែលបានចុះហត្ថលេខាឆ្នាំ២០០៦, (២) ការត្រួតពិនិត្យរួមគ្នាឈប់តែមួយលើក (SSI) និងការត្រួតពិនិត្យរួមគ្នាបញ្ជរតែមួយ (SWI), (៣) ការងារសាងសង់ទីលានត្រួតពិនិត្យរួមគ្នា (CCA) ចុះហត្ថលេខា MOU ស្តីពីនីតិវិធីគយរវាងប្រទេសទាំងពីរ, (៤) ការស្នើឱ្យមានការដឹកជញ្ជូនឆ្លងកាត់ Transit ពីហ្ជីមិញ-ភ្នំពេញ-បាងកក និង (៥) ការរៀបចំខ្សែផ្លូវដឹកជញ្ជូន ឬរបៀងថ្មី និងច្រកទ្វារថ្មី នៅតំបន់បាវិត-ម៉ុកបាយ។ល។ ➢ ត្រៀងប្រើប្រាស់ថវិកាជាតិ ដើម្បីពង្រីកកំណាត់ផ្លូវជាតិលេខ១១ ពីទីតាំងម៉ាស៊ីនស្កែន (ស្នាក់ការគយ) ដល់ប៉ុស្តិ៍ព្រំដែនបាវិត និងពង្រីកផ្លូវជា ៤ ឬ ៦ គន្លង ដើម្បីតភ្ជាប់ផ្លូវពីប៉ុស្តិ៍ច្រកទ្វារព្រំដែនបាវិតទៅដល់ចំណុចសូន្យ ហើយស្នើវៀតណាមធ្វើបន្តដល់ប៉ុស្តិ៍ម៉ុ	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ក្បាយ។ ▪ កិច្ចសហប្រតិបត្តិការជាមួយថៃ÷ ➢ បានចុះហត្ថលេខាលើសេចក្តីព្រាងអនុស្សរណៈរវាងភាគីកម្ពុជានិងថៃ ស្តីពីការដំឡើងកូតាយានយន្តពី ៤០គ្រឿង ដល់ ១៥០ គ្រឿង តាមច្រកទ្វារប៉ោយប៉ែត-អារញ្ញប្រាថេត ក្នុងឱកាសនៃកិច្ចប្រជុំលើកទី៥ គណៈកម្មការរួមនៃគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូន អនុវត្តកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលនឹងចូលជាធរមាននៅចុងខែមីនា ឆ្នាំ២០១៧ នេះ។ ➢ ចំពោះគម្រោងសាងសង់ច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់-ណងអៀន និងសាងសង់ផ្លូវភ្ជាប់ពីអគារប៉ុស្តិ៍ព្រំដែន មកភ្ជាប់នឹងផ្លូវជាតិលេខ៥ ក្នុងខេត្តបន្ទាយមានជ័យ ក្រសួងសាធារណការ និងដឹកជញ្ជូន បានចុះហត្ថលេខាជាមួយក្រសួងដឹកជញ្ជូនថៃ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ លើសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីការសាងសង់ស្ពានឆ្លងកាត់ចំណុចព្រំដែន(ស្ទឹងបត់)។ បច្ចុប្បន្ន គណៈកម្មការវិចលនាលទ្ធកម្ម (PRC) និងគណៈកម្មការវាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស (CEC) កំពុងពិនិត្យ និងវាយតម្លៃជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស។ - ក្រសួងពាណិជ្ជកម្ម បានចាត់មន្ត្រីជំនាញចូលរួមចរចាលើកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែនក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ កម្ពុជា-វៀតណាម កម្ពុជា-ឡាវ។ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ ▪ បានចូលរួមសិក្ខាសាលា និងកិច្ចប្រជុំក្នុងកម្មវិធី CBTA, ACTS។	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខ្ទុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ កំពុងបន្តដំណើរការអនុវត្ត (តាមការវាយតម្លៃ LPI - Logistic performance index របស់ WB កម្ពុជាបានកែលម្អ ៤៦ថ្នាក់ ពីចំណាត់ថ្នាក់ ១២៩/១៦០ នាឆ្នាំ ២០១០ មកចំណាត់ថ្នាក់ ៨៣ នាឆ្នាំ២០១៤ និងមកចំណាត់ថ្នាក់ ៧៣ នាឆ្នាំ២០១៦ ដែលជាការវាយតម្លៃវិជ្ជមានមួយ)។	
- ពង្រឹងសមត្ថភាពអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ឱ្យក្លាយជាភ្នាក់ងារ ជំរុញការនាំចេញ ដែលមានជំនាញខ្ពស់ក្នុងការវិភាគទីផ្សារនាំចេញ កំណត់មុខសញ្ញានាំចេញ និងរៀបចំបណ្តាញធុរកិច្ចដែលជាមូលដ្ឋានក្នុងការផ្តល់ការពិគ្រោះយោបល់ផ្នែកពាណិជ្ជកម្ម ផ្តល់ព័ត៌មានអំពីទីផ្សារក្រៅប្រទេស និងជួយសម្របសម្រួលសកម្មភាពជំរុញការនាំចេញ រួមទាំង ការរៀបចំការផ្សព្វផ្សាយទីផ្សារ ឬការតាំងពិព័រណ៍	២០១៥	- ក្រសួងពាណិជ្ជកម្ម បានធ្វើកំណែទម្រង់ដោយដំឡើងអតីតនាយកដ្ឋានជំរុញពាណិជ្ជកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មតាមអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ដោយមាននាយកដ្ឋានចំនួន៣ចំណុះ ។	- ក្រសួងពាណិជ្ជកម្ម÷ បញ្ហាថវិកា និងធនធានមនុស្សមានកំណត់
- ពិចារណាបង្កើតស្ថាប័នហិរញ្ញប្បទានតាមគោលនយោបាយដែលមានកាតព្វកិច្ចផ្តល់កម្ចីទៅឱ្យអ្នកនាំចេញ ដែលផលិតទំនិញនាំចេញក្នុងឧស្សាហកម្មអាទិភាព និងផ្តល់នូវសេវាធានារ៉ាប់រងការនាំចេញ ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាទាក់ទងនឹងការនាំចេញ	២០១៥ ទៅមធ្យម	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានត្រៀមរៀបចំកិច្ចប្រជុំ ដើម្បីបង្កើតក្រុមការងារអនុវត្តសកម្មភាពនេះ។ - ក្រសួងពាណិជ្ជកម្ម ធ្លាប់បានអនុវត្តគម្រោងបើកច្រកទីផ្សារនាំចេញដោយបានជួយវិស័យឯកជន រៀបចំឯកសារគតិយុត្តសម្រាប់បម្រើដល់ការនាំចេញដោយប្រើប្រាស់ថវិកាជំនួយរបស់ដៃគូអភិវឌ្ឍន៍។	- ក្រសួងពាណិជ្ជកម្ម÷ គម្រោងថវិកាជំនួយត្រូវបានបញ្ចប់
- ពង្រឹងការសម្រួលពាណិជ្ជកម្ម តាមរយៈការ	២០១៥ ទៅ	- ក្រសួងពាណិជ្ជកម្ម÷	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ខ្វះថវិកា

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
កែលម្អនីតិវិធី ការពង្រឹងយន្តការដឹកជញ្ជូនឆ្លងដែន ការកាត់បន្ថយថ្លៃចម្លងការពាណិជ្ជកម្ម និងការពង្រឹងការសម្របសម្រួលស្ថាប័ន	មធ្យម	▪ អនុវត្តការចុះបញ្ជីសហគ្រាស តាមប្រព័ន្ធអេឡិចត្រូនិក។ ▪ អនុវត្តការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធអេឡិចត្រូនិក។ ▪ បានអនុវត្តការចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក។ ▪ បានដាក់ឱ្យអនុវត្តការបង់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអេឡិច-ត្រូនិក (E-payment)។ ▪ បានចរចាជាមួយភាគីវៀតណាមក្នុងការសាងសង់ផ្សារព្រំដែនវៀតណាម-កម្ពុជានៅឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ ▪ ចេញបទប្បញ្ញត្តិជាធរមានជាបន្តបន្ទាប់ និងបានដាក់ឱ្យមានកិច្ចពិភាក្សាគ្នាជាបន្តបន្ទាប់ជាមួយវិស័យឯកជន។ ▪ ចូលជាសមាជិកហត្ថលេខីនៃអនុសញ្ញាអន្តរជាតិស្តីពីសាមញ្ញកម្ម និងសុខដុមនីយកម្មនីតិវិធីគយ (RKC)។ ▪ ពង្រឹងការអនុវត្តអនុក្រឹត្យលេខ២១ អនក្រ.បក ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ។ ▪ ធ្វើវិមជ្ឈការនៃការកំណត់តម្លៃគិតពន្ធគយដល់ការិយាល័យបំពេញបែបបទគយ។ ▪ បានដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងភាពជឿជាក់ធុរជន (Trader Credibility Management System)។ ▪ មានកំណើនចំណូលពន្ធអាករ ឆ្នាំ២០១៦ ប្រមាណ ១៥% ប្រៀបធៀបឆ្នាំ២០១៥។ ចំនួន SAD ច្រកក្រហមមានកម្រិត ១២,៣៨% នៃ SAD សរុប (៩ខែ) ស្របតាមគោលនយោបាយ	សម្រាប់បន្តអនុវត្ត

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		របស់រាជរដ្ឋាភិបាលកម្ពុជា។ - ក្រសួងសាធារណការ និងដឹកជញ្ជូន÷ ▪ បាននិងកំពុងបន្តពិភាក្សា ដើម្បីធ្វើការកែលម្អគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដែលមានអនុគណៈកម្មាធិការភស្តុភារកម្ម អនុគណៈកម្មាធិការសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (ប៉ូស្តីព្រំដែន) និងអនុគណៈកម្មាធិការប្រតិបត្តិការឆ្លងកាត់ព្រំដែន (សម្រួលការអនុវត្តច្បាប់)។ ▪ បានអនុវត្តឱ្យកាន់តែប្រសើរច្រើនជាងមុនន្ទូវការកែលម្អការផ្តល់សេវាសាធារណៈ ហើយបច្ចុប្បន្ន អង្គភាពជំនាញ បាននិងកំពុងបន្តកែលម្អទៅមុខទៀត។ - រដ្ឋបាលខេត្តស្វាយរៀង បានសម្រួលដល់ចរជនក្នុងការធ្វើអាជីវកម្មនាំចេញ នាំចូល និងដោះស្រាយការកកស្ទះមធ្យោបាយដឹកជញ្ជូន នៅច្រកទ្វារព្រំដែនអន្តរជាតិបាវិត តាមរយៈការណែនាំឱ្យចរជនធ្វើការផ្លាស់ប្តូរព័ត៌មានពាណិជ្ជកម្មឱ្យបានលឿន ពន្លឿនការដាក់ពាក្យបំពេញបែបបទមធ្យោបាយដឹកជញ្ជូននៅច្រកទ្វារព្រំដែន បង្កើនប្រសិទ្ធភាពការត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូន និងបន្ថែមពេលវេលាធ្វើការរបស់មន្ត្រីជំនាញ (មន្ត្រីគយ និងរដ្ឋាករ) អនុញ្ញាតដល់ប្រតិបត្តិករផ្នែកស្ងួតអាចជ្រើសរើសយកការស្ពែនកុងតឺន័រទំនិញនាំចេញ នាំចូល និងឆ្លងកាត់នៅមាត់ច្រកដើមទី។ ទន្ទឹមនេះ បាននិងកំពុងសិក្សាពិនិត្យលទ្ធភាពពង្រីក ទីតាំងម៉ាស៊ីនស្ពែនកុងតឺន័រ និងបំពាក់បន្ថែមម៉ាស៊ីនស្ពែននៅការិយាល័យគយ និងរដ្ឋាករបាវិត។	
- ពិចារណាបង្កើតប្រព័ន្ធលើកទឹកចិត្តសម្រាប់	២០១៥	- ក្រសួងពាណិជ្ជកម្ម បាន÷	- ក្រសួងពាណិជ្ជកម្ម÷

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ក្រុមហ៊ុនក្នុងស្រុកដែលនាំចេញទំនិញថ្មីៗ និងនាំចេញបានចំនួនច្រើនជាងគេ ដោយផ្តល់នូវរង្វាន់លើកទឹកចិត្តពិសេស និងរង្វាន់នានាសម្រាប់ក្រុមហ៊ុនដែលបាននាំទំនិញដល់ចំនួនដែលបានកំណត់ តាមរយៈការវាយតម្លៃប្រកបដោយតម្លាភាព ដោយផ្សារភ្ជាប់នឹងគោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម		▪ លើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ឱ្យបានចូលរួមតាំងពិព័រណ៍តាមរយៈការផ្តល់ជូនស្តង់ដោយឥតគិតថ្លៃ និងចូលរួមព្រឹត្តិការណ៍ពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស។ ▪ សម្របសម្រួលដល់ក្រុមហ៊ុនបានទៅស្វែងរកដៃគូនៅក្រៅប្រទេស ▪ រៀបចំវេទិកាអភិវឌ្ឍកសិ-ពាណិជ្ជកម្មនៅតាមរាជធានី-ខេត្ត ដើម្បីជំរុញលើកទឹកចិត្តដល់ផលិតករ សិប្បករ កសិករ ខិតខំផលិតទំនិញ និងសេវាសម្រាប់បម្រើឱ្យទីផ្សារក្នុងមូលដ្ឋាន។ ក្រសួងក៏បានរៀបចំកម្មវិធីជួនបំណ្ណសរសើរដល់កសិករឆ្នើម និងពាណិជ្ជករគំរូដើម្បីលើកទឹកចិត្តឱ្យពួកគាត់បានចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មយ៉ាងពេញលេញ។ ▪ សហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងទេសចរណ៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំជំនួបពាណិជ្ជកម្មរវាងអ្នកផលិតនិងម្ចាស់ផ្សារទំនើបដើម្បីនាំយកផលិតផលខ្មែរ (ផលិតផលឆ្នើម) ដាក់លក់ក្នុងទីផ្សារទំនើបមានដូចជា ផ្សារអ៊ីអន ផ្សារឡាក់គី ផ្សារស៊ីធីម៉ល ...។ - ក្រសួងឧស្សាហកម្មនិងសិប្បកម្ម	▪ រង់ចាំកញ្ចប់ថវិកាកម្មវិធីឆ្នាំ២០១៧ ▪ ផលិតផលខ្មែរនៅមានកម្រិតទាំងគុណភាព និងសោភ័ណភាព មិនទាន់អាចឆ្លើយតបតាមតម្រូវការទីផ្សារទំនើបនៅឡើយ
- ជំរុញការបង្កើតសមាគមតាមអនុវិស័យនីមួយៗ ដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាពង្រឹងទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល។	២០១៥ ទៅ មធ្យម	- ក្រសួងពាណិជ្ជកម្មបាន÷ ▪ ទទួលចុះបញ្ជីសមាគមចំនួន ១១៨ ដូចជា សមាគមម៉ាស៊ីនកិនស្រូវ សមាគមស្វាយចន្ទី សមាគមដំឡូងមី សមាគមស្វាយ សមាគមគ្រឿងអលង្ការ សមាគមស្ករត្នោត... ។ល។ ▪ បង្កើតកម្មវិធីពង្រឹងសមត្ថភាពសមាគមអាជីវកម្មទាំងនោះតាមរយៈ	- ក្រសួងពាណិជ្ជកម្ម÷ ▪ កង្វះធនធាន ទាំងធនធានមនុស្ស និងហិរញ្ញវត្ថុនៅមានកម្រិត ▪ កញ្ចប់ថវិកាតូច និងអាទិភាពមានយ៉ាង

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខ្សត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ការចូលរួមសិក្ខាសាលាបណ្តុះបណ្តាល និងការផ្លាស់ប្តូរទស្សនកិច្ចសិក្សាពីតំបន់មួយទៅតំបន់មួយ។ ▪ រៀបចំវេទិកាជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍកសិ-ពាណិជ្ជកម្មកម្ពុជានៅតាមមូលដ្ឋានក្នុងរាជធានី-ខេត្តមួយចំនួន ដើម្បីលើកកម្ពស់ទ្រទ្រង់ដល់ការផលិតនូវផលិតផលកសិកម្ម និងផលិតផលកែច្នៃដទៃទៀតសម្រាប់បម្រើឱ្យទីផ្សារនៅមូលដ្ឋាន។ ▪ សហការជាមួយអង្គការ UNDP រៀបចំជាគម្រោងកម្មវិធីពង្រឹងសមត្ថភាពសមាគមដំឡូងមីកម្ពុជា។ - ក្រសួងឧស្សាហកម្មនិងសិប្បកម្ម	
ខ- ការពង្រឹងបទដ្ឋានឧស្សាហកម្ម និងកម្មសិទ្ធិឧស្សាហកម្ម			
- បន្តពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដាដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម និងខិតខំប្រឹងប្រែងបន្តរៀបចំក្របខ័ណ្ឌគតិយុត្ត និងការទទួលស្គាល់ជាអន្តរជាតិនូវស្ថាប័នជាតិសំខាន់ៗ រួមមាន មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដាកម្ពុជា	មធ្យមទៅវែង	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- កែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម តាមរយៈអនុវត្តនីតិវិធីធ្វើកិច្ចសហប្រតិបត្តិការ ផ្តល់សិទ្ធិចុះបញ្ជីដល់ភ្នាក់-ងារនៃប្រទេសជាដៃគូនានា និងសម្រួលក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើ	២០១៥ ទៅមធ្យម	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷ ▪ បានទទួលការស្នើសុំចុះបញ្ជីពីអ្នកស្នើសុំមានដូចជាប្រកាសនីយបត្រតក្កកម្ម ចំនួន**៧៧** ក្នុងនោះមានចំនួន ១ ជារបស់តក្ការខ្មែរ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ចំនួន ១**៧** គំនូរឧស្សាហកម្ម ចំនួន១០២។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ជាតំណាងរបស់អ្នកដាក់ពាក្យសុំក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម		▪ បានស្នើសុំប្រមុខរាជរដ្ឋាភិបាលចេញលិខិតូបករណ៍មួយចំនួន ដូចតទៅ÷ - ប្រកាសលេខ១៨១ MIH/2016 ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្តកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួល ការផ្តល់ប្រកាសនីយបត្រតក្តកម្មកម្ពុជា ទាក់ទងនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្តកម្ម ជាមួយអង្គភាពប្រកាសនីយបត្រតក្តកម្មជប៉ុន។ - ប្រកាសលេខ១៨២ MIH/2016 ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការពន្លឿនផ្តល់ប្រកាសនីយបត្រតក្តកម្មសិង្ហបុរីនៅកម្ពុជា។ - លិខិតូបករណ៍លេខ៥១ លស.សប្រ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីលិខិតូបករណ៍នៃការចូលជាសមាជិកសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្តកម្ម (PCT)។ - លិខិតូបករណ៍លេខ ១០៦៥ លស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីលិខិតូបករណ៍នៃការចូលជាសមាជិកសន្ធិសញ្ញាទីក្រុងហ្ស៊ីណេវ (ឆ្នាំ១៩៩៩) នៃកិច្ចព្រមព្រៀងទីក្រុងឡាអេ ទាក់ទងនឹងការងារចុះបញ្ជីឧស្សាហកម្មអន្តរជាតិ ដែលកម្ពុជាជាសមាជិកពេញសិទ្ធិទី ១៥១។	
- ពង្រឹងការប្រើប្រាស់ស្តង់ដានីយកម្ម និងការវាយតម្លៃការទទួលស្គាល់អនុលោមភាពដោយ	២០១៥ ទៅមធ្យម	- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម÷ ▪ បានបង្កើតក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ ដែលមាន	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ផ្សារភ្ជាប់ទៅនឹងការធ្វើលទ្ធកម្មសាធារណៈ ការទទួលបានការលើកទឹកចិត្ត និងការជួយឧបត្ថម្ភផ្សេងៗ		សមាជិកពីអង្គក្រសួង និងវិទ្យាស្ថានទានានាក្នុងការលើកកម្ពស់ការងារវាយតម្លៃទទួលស្គាល់នៅកម្ពុជា។ ▪ បានរៀបចំ និងដាក់ឱ្យដំណើរការជាផ្លូវការគេហទំព័ររបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ដែលមានឈ្មោះ "www.da-canc.gov.kh" ដោយភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ▪ បានរៀបចំបង្កើតឯកសារពាក់ព័ន្ធនឹង Quality Management System មានដូចជា÷ Management, Directives, Working Documents និង Record/Forms ដោយបានបកប្រែជាភាសាខ្មែរ។ ▪ បានចេញប្រកាសស្តីពីការបង្កើតស្តង់ដាជាតិរួមមាន ÷ អង្ករជ្លាវ ១ដួល និងអង្ករជ្លាចំនួនសែនស ផ្នែកផលិតផលពីឈើ ចំនួន ៣៤ ស្តង់ដា ផ្នែកផលិតផលពីកៅស៊ូចំនួន ៤៦ស្តង់ដា ផ្នែកផលិតផលយានយន្ត ចំនួន ១៩ស្តង់ដា ផ្នែកផលិតផលអគ្គិសនី និងអេឡិចត្រូនិក ចំនួន១១៩ ស្តង់ដា និងផ្នែកវិធីសាស្ត្រធ្វើតេស្ត ចំនួន ៩៩ស្តង់ដា។	
- បង្កើនការយល់ដឹង និងធ្វើការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃស្តង់ដា មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហកម្ម ដើម្បីជំរុញចូលរួមឱ្យបានទ្ទួលំទ្ធលាយពីសំណាក់សហគ្រិន	២០១៥ ទៅមធ្យម	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷ ▪ បានធ្វើការផ្សព្វផ្សាយស្តីពីស្តង់ដាកម្ពុជា លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធការងារស្តង់ដានានា និងការវាយតម្លៃភាពអនុលោមតាមគេហទំព័រវិទ្យាស្ថានស្តង់ដា និងតាមប្រព័ន្ធផ្សព្វផ្សាយ ទូរទស្សន៍ វិទ្យុ កាសែតជាដើម។ ▪ បានរៀបចំបណ្ណាល័យតម្កល់ឯកសារស្តង់ដា និងបន្ទប់ស្រាវជ្រាវ សម្រាប់អតិថិជនសិក្សាស្វែងយល់ការងារស្តង់ដា ដែលក្នុងនោះមាន ច្បាប់ស្តីពីស្តង់ដាកម្ពុជាចំនួន២០០ក្បាល ស្តង់ដាសម្រាប់	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ទឹកពិសាចំនួន២០ក្បាល ស្តង់ដាទឹកពិសាដបចំនួន ១៥ក្បាល ស្តង់ដាទឹកត្រី ទឹកពិសាដប បិទស្លាកលើផលិតផលចំណីអាហារ និងគោលការណ៍រួម និងតម្រូវការរបស់អាស៊ានសម្រាប់អនាម័យម្ហូបអាហារចំនួន២០០ក្បាល និងស្តង់ដាស្ពីពីអគ្គិសនី និងអេឡិច-ត្រូនិកចំនួន២៥ក្បាល។ ▪ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលអំពីការជំរុញការអនុវត្តស្តង់ដា ការអភិវឌ្ឍស្តង់ដា ផលប៉ះពាល់ដល់សុខភាពនៃការប្រើប្រាស់សារធាតុគីមី នីតិវិធី និងពង្រឹងការគ្រប់គ្រងសារធាតុគីមី និងការប្រើប្រាស់ ដើម្បីធានាបាននូវការការពារសុខុមាលភាពសាធារណៈជាដើម ដោយមានសិក្ខាកាមចូលរួមពីបណ្តាសហគ្រិនម្ចាស់រោងចក្រ សិប្បកម្ម ដៃគូអភិវឌ្ឍ និងក្រសួងស្ថាប័នពាក់ព័ន្ធនានា។	
- ជួយគាំទ្រលើកកម្ពស់សមត្ថភាពនិងសមត្ថកិច្ចមាត្រាសាស្ត្រ និងស្តង់ដាក្នុងការធានានូវបរិមាណ គុណភាព សុវត្ថិភាព សេវាកម្ម បរិស្ថាន និងគ្រប់គ្រង	មធ្យមទៅវែង	- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម	
- ចាត់វិធានការជាក់ស្តែងក្នុងការពង្រឹងការអនុវត្ត ស្តង់ដា មាត្រាសាស្ត្រ និងកម្មសិទ្ធិឧស្សាហ-កម្ម ដើម្បីប្រែក្លាយក្របខ័ណ្ឌទាំងនេះឱ្យក្លាយជាឧបករណ៍សម្រាប់ជំរុញការប្រកួតប្រជែង	មធ្យមទៅវែង	- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម	
- ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចរបស់ *"មជ្ឈមណ្ឌលផលិតភាពកម្ពុជា"* សំដៅ	មធ្យមទៅវែង	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
លើកកម្ពស់ផលិតភាព និងគុណភាពដល់សហគ្រាសធុនតូច និងមធ្យម			
- ពង្រឹងសមត្ថភាព ***"វិទ្យាស្ថានស្តង់ដាកម្ពុជា"*** ក្នុងការសិក្សាស្រាវជ្រាវរៀបចំស្តង់ដាជាតិ សម្រាប់ផលិតផល សេវាកម្ម ផលិតកម្ម និងបច្ចេកទេស អនុលោមតាមស្តង់ដាតំបន់ និងអន្តរជាតិ	មធ្យមទៅវែង	- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម	
- ពង្រឹងសមត្ថភាពមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិក្នុងការសិក្សាស្រាវជ្រាវរៀបចំនីតិវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ព្យាសកម្ម គេស្តវិភាគ និងការអនុម័តតំរូឧបករណ៍មាត្រាសាស្ត្រដែលបម្រើឱ្យការអភិវឌ្ឍវិស័យឧស្សាហកម្ម	មធ្យមទៅវែង	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម÷ ▪ បានបង្កើនសមត្ថភាពមន្ទីរពិសោធន៍មាត្រាសាស្ត្រឱ្យទទួលបាន ISO/IEC 17025 ។ ▪ បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិឱ្យជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស ឧបករណ៍មាត្រាសាស្ត្រ និងឧបករណ៍ស្តង់ដាមាត្រាសាស្ត្របន្ថែមទៀត។ ▪ បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងតាមផ្សារ ជញ្ជីងថ្លឹងស្រូវ ម៉ាស៊ីនចែកចាយប្រេង រថយន្តផ្ទុកទម្ងន់ដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីជាប្រយោជន៍ដល់សាធារណជនទាំងអស់។ ▪ បានធ្វើការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាសាធារណៈដែលពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្របានយ៉ាងទូលំ-ទូលាយដល់សហគ្រិន។	
ក-ការសម្រួលការបំពេញភាពវ្យកិច្ចពន្ធ និងអាករ			

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
- សិក្សាឡើងវិញពីប្រព័ន្ធពន្ធដារ និងពន្ធគយ ដោយប្រែក្លាយឱ្យទៅជាឧបករណ៍ប្រមូលចំណូលផង និងជាឧបករណ៍ជំរុញការអភិវឌ្ឍឧស្សាហកម្មផង	មធ្យមទៅវែង	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន÷ ▪ កែប្រែរបបកំណត់ពន្ធដោយលុបចោលរបបម៉ៅការទៅជារបបស្វ័យប្រកាសសម្រាប់អ្នកជាប់ពន្ធតូច មធ្យម និងធំ។ ▪ អនុគ្រោះពីការប្រមូលពន្ធចំពោះអ្នកជាប់ពន្ធមានផលរបរក្រោមអប្បបរមានៃការចុះបញ្ជី (២៥០លានរៀល)។ ▪ បញ្ចប់ការសិក្សាដោយសង្ខេបស្តីពីការកែទម្រង់គោលនយោបាយពន្ធអាករ។ ▪ បញ្ចប់ការសិក្សា និងវាយតម្លៃគោលនយោបាយពន្ធបច្ចុប្បន្ន។	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ÷ ▪ ខ្វះថវិកា ▪ ការយល់ដឹងរបស់អ្នកជាប់ពន្ធនៅមានកម្រិត ▪ ត្រូវបញ្ជាបវប្បធម៌បង់ពន្ធដល់អ្នកជាប់ពន្ធ ▪ គួរមានការចូលសិក្សាដោយអង្គការអន្តរជាតិ ដូចជា World Bank, IFC, ADB
- ធ្វើវិចារណកម្មយន្តការប្រមូលចំណូល និងកែលម្អសេវាអ្នកជាប់ពន្ធ សំដៅលើកកម្ពស់វប្បធម៌បង់ពន្ធ ក្នុងចំណោមសហគ្រាស និងអ្នកជាប់ពន្ធគ្រប់ប្រភេទ	២០១៥ ទៅមធ្យម	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ ▪ បានរៀបចំការទទួលប្រាក់ពន្ធតាមបញ្ជរប្រព័ន្ធធនាគារដែគ្ន។ ▪ បានធ្វើទំនើបភាវូបនីយកម្ម (Modernization) យន្តការពន្ធដារ រួមទាំងយន្តការប្រមូលចំណូល តាមរយៈការធ្វើវិចារណកម្ម និងការគាំទ្រដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ÷ ▪ កង្វះថវិកាក្នុងការទិញឧបករណ៍ ▪ ការរៀបចំប្រព័ន្ធមានភាពស្មុគស្មាញ
- បង្កើនការផ្តល់សេវាដើម្បីឱ្យអ្នកជាប់ពន្ធងាយស្រួលទទួលព័ត៌មានពីការបង់ពន្ធ និងការលើកលែងពន្ធ	២០១៥ ទៅមធ្យម	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន÷ ▪ បង្កើតបញ្ជរពិគ្រោះយោបល់។ ▪ បញ្ចូលព័ត៌មានចាំបាច់ទានាសម្រាប់អ្នកជាប់ពន្ធទៅក្នុងគេហទំព័រអគ្គនាយកដ្ឋានពន្ធដារ។ ▪ បង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មាន (Call Center) ដើម្បីឆ្លើយតបនឹងការសាកសួរតាមទូរសព្ទពីអ្នកជាប់ពន្ធ។ ▪ បង្កើតកម្រងសៀវភៅសំណួរចម្លើយដែលសួរញឹកញាប់ (Frequently Asked Question) ដើម្បីគាំទ្រ Call Center។	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ÷ ▪ កង្វះឧបករណ៍សម្រាប់ដំណើរការ ▪ ខិតខំរកដំណោះស្រាយដើម្បីឱ្យ Call Center ដំណើរការ

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ រៀបចំការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធតាមធនាគារ និងកំពុងរៀបចំប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធផងដែរ។	
- ជំរុញការបង្វិលសងឱ្យបានឆាប់ ឬប្រើប្រាស់ជាឥណទានយោង (Tax Credit) ស្របតាមបទប្បញ្ញត្តិពន្ធដារជាធរមាន	មធ្យមទៅវែង	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ ▪ បានចេញប្រកាសលេខ២៥០ សហវ.ប្រក ០៣/០៣/២០១៥ ស្តីពីការប្រគល់សិទ្ធិចុះហត្ថលេខាជាអាណាប័ត្រផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុលើអាណត្តិបើកប្រាក់បង្វិលសងអាករលើតម្លៃបន្ថែម។ ▪ បានពង្រីងយន្តការបង្វិលសងតាមរយៈការរៀបចំយន្តការវាយតម្លៃអនុលោមភាពរបស់អ្នកជាប់ពន្ធ(សេចក្តីព្រាងប្រកាសស្តីពីចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធ)។	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ÷ ▪ ទាមទារឱ្យមានការត្រួតពិនិត្យសក្តិ-បត្រច្បាស់លាស់ ▪ ដំណោះស្រាយ÷ ពង្រីង និងពង្រីកព្រមទាំងបង្កើនលេ្យនបង្វិលសង។
- ពិនិត្យ និងសម្រួលឡើងវិញនូវក្របខ័ណ្ឌនៃការអនុវត្ត ដោយសម្រួល ឬដកចេញនូវយន្តការទាំងឡាយណាដែលបណ្តាលឱ្យខ្ជាស់គ្នារវាងនីតិវិធីនៃការយកពន្ធ និងការលើកលែងពន្ធ។	២០១៥ ទៅមធ្យម	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន÷ ▪ ធ្វើរបាយការណ៍ស្តីពីការអនុវត្តការងារពាក់ព័ន្ធនឹងក្របខ័ណ្ឌនៃការលើកទឹកចិត្តវិនិយោគនៅកម្ពុជា ដើម្បីក្រសួងត្រៀមជំហរពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ។ ▪ បង្កើតក្រុមការងារមួយសម្រាប់ទទួលខុសត្រូវលើកិច្ចការខាងលើ។ ▪ ចូលរួមរៀបចំបទប្បញ្ញត្តិទាក់ទិននឹងការសម្រួល ឬដកចេញនូវយន្ត-ការទាំងឡាយណាដែលបណ្តាលឱ្យខ្ជាស់គ្នារវាងនីតិវិធីនៃការយកពន្ធ និងការលើកលែងពន្ធ។	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ បាត់បង់ចំណូលពីការលើកទឹកចិត្តពន្ធ ▪ ស្នើសុំសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ ▪ ត្រូវមាន Sunset Clause
ii- ការរៀបចំទីផ្សារពលកម្ម និងទំនាក់ទំនងវិជ្ជាជីវៈ			
- បន្តពង្រីងយន្តការទំនាក់ទំនងត្រីភាគី រួមមានរដ្ឋាភិបាល និយោជក និងនិយោជិត តាមរយៈ *"គណៈកម្មការប្រឹក្សាការងារ"* ដើម្បីបង្កើនការ	២០១៥ ទៅមធ្យម	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ គណៈកម្មការប្រឹក្សាការងារ បានបង្កើតក្រុមការងារបច្ចេកទេសត្រីភាគីដែលមានតំណាងពីត្រីភាគីចំនួន ១៦-១៦-១៦ ដែលទទួល	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ/ការងារ	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
យោគយល់គ្នា ទន្ទឹមនឹងការខិតខំរៀបចំប្រព័ន្ធយន្តការមួយប្រកបដោយប្រសិទ្ធភាពសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ដែលស៊ីចង្វាក់ទៅនឹងផលិតភាពការងារសមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច-សង្គម និងធានាបានន្ទូវការអភិវឌ្ឍឧស្សាហកម្មជារួម		ការឯកភាពពីគ្រប់ភាគីដើម្បីពិភាក្សាប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៧ និងបានប្រជុំពិភាក្សាអស់រយៈពេល ៦ថ្ងៃ ស្មើនឹង ៩លើក។ ▪ បានរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារសរុបចំនួន២លើក។ ▪ បានកំណត់ប្រាក់ឈ្នួលអប្បបរមាដោយជោគជ័យ នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ ស្របតាមកាលវិភាគដែលត្រីភាគីបានឯកភាពដោយកំណត់យកប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៧ ចំនួន ១៥៣ដុល្លារ/ខែ។ ▪ បានប្រើប្រាស់ទិន្នន័យផ្លូវការបែបវិទ្យាសាស្ត្រ ដែលមានប្រភពពីវិទ្យាស្ថានជាតិស្ថិតិ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងទិន្នន័យពីអង្គការអន្តរជាតិខាងការងារ (ILO) ដើម្បីសិក្សាពីបម្រែបម្រួលនៃលក្ខណៈវិនិច្ឆ័យបែបសេដ្ឋកិច្ច និងសង្គម ដែលត្រីភាគីបានឯកភាពដើម្បីជាមូលដ្ឋានក្នុងការចរចាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៧។ ▪ បានធ្វើអង្កេតស្តីពីស្ថានភាពជីវភាពរបស់កម្មករនិយោជិតផ្នែកវាយ-នភណ្ឌ កាត់ដេរ និងផលិតស្បែកជើង លើគំរូកម្មករនិយោជិតចំនួន ១.០០១នាក់ នៅក្នុងរោងចក្រចំនួន ៥០ នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ខេត្តកណ្ដាល។ ▪ បានបន្ត សហការជាមួយអង្គការ ILO សិក្សាពីបម្រែបម្រួលលក្ខណ-វិនិច្ឆ័យទាំង៧ ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាសម្រាប់ឆ្នាំ២០១៧ ដោយអង្គការអន្តរជាតិខាងការងារបានបណ្ដុះ-បណ្ដាលមន្ត្រីលេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារក្នុងនិង	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ក្រៅប្រទេសចំនួន ២លើក (បណ្តុះបណ្តាលស្តីពីម៉ាក្រូសេដ្ឋកិច្ចការងារ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងការបណ្តុះ-បណ្តាលស្តីពីការវិភាគទិន្នន័យអង្កេត)។ ▪ ក្រៅពីប្រាក់ឈ្នួលអប្បបរមា គណៈកម្មការប្រឹក្សាការងារបានសម្រេចផងដែរឱ្យមានការបន្តផ្តល់ជូននូវអត្ថប្រយោជន៍ផ្សេងៗ ដល់កម្មករនិយោជិត ក្នុងគោលបំណងលើកកម្ពស់ផលិតភាពការងារ និងសុខុមាលភាពកម្មករនិយោជិតដែលក្នុងនោះរួមមានប្រាក់រង្វាន់ការងារទៀងទាត់ចំនួន ១០ដុល្លារ/ខែ សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ដុល្លារ/ខែ និងប្រាក់រង្វាន់អតីត-ភាពការងារពី ២ដុល្លារ - ១១ដុល្លារ/ខែ។ ▪ បានរៀបចំសិក្ខាសាលាត្រីភាគីថ្នាក់ជាតិស្តីពី "ប្រាក់ឈ្នួលអប្ប-បរមានៅកម្ពុជា" កាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦ នៅសណ្ឋាគារភ្នំពេញ ដើម្បីពង្រឹងយន្តការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា និងដើម្បីធ្វើបច្ចុប្បន្នភាពស្ថានភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែងសេដ្ឋកិច្ចរបស់កម្ពុជា ដល់មន្ត្រីរាជរដ្ឋាភិបាលពាក់-ព័ន្ធ និយោជក និងសហជីព។ ▪ បានផ្សព្វផ្សាយពីយន្តការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមា និងផលិតភាពក្នុងតំបន់ តាមរយៈកិច្ចពិភាក្សាក្នុងកម្មវិធី ASEAN Connect របស់ទូរទស្សន៍ក្នុងស្រុកចំនួន ១ដង។ ▪ បានធ្វើការផ្សព្វផ្សាយអំពីការវិវឌ្ឍនៃប្រាក់ឈ្នួលអប្បរមានៅ កម្ពុជា និងបណ្តាប្រទេសប្រកួតប្រជែងនានាតាមរយៈបណ្តាញ សង្គម	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		Facebook ផ្លូវការ គេហទំព័ររបស់ក្រសួង និងសារព័ត៌មានានា ដើម្បីឱ្យកម្មករនិយោជិត និងសាធារណជនបានជ្រាប។ ▪ សហការជាមួយអង្គការអន្តរជាតិខាងការងារបានបោះពុម្ព និងចែកចាយដល់ភាគីរដ្ឋាភិបាល និយោជក និងសហជីព កម្មករនិយោជិតនូវសៀវភៅកំណត់ហេតុដែលមានភ្ជាប់ការពន្យល់ពីយន្តការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាចំនួន៥ ០០០ច្បាប់ ក្នុងសៀវភៅស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាចំនួន១០ ០០០ ច្បាប់។ ▪ បានផលិត និងចែកចាយខិត្តប័ណ្ណស្តីពីយន្តការ និងលក្ខណៈវិនិច្ឆ័យនៃការកំណត់ប្រាក់ឈ្នួល និងខិត្តប័ណ្ណស្តីពីការវិវឌ្ឍនៃប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ។ ▪ ដោយមានសំណូមពររួមពីភាគីសហជីព និងនិយោជក ក្នុងក្របខ័ណ្ឌគណៈកម្មការប្រឹក្សាការងារ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយដូចខាងក្រោម÷ - ការអនុគ្រោះពន្ធលើប្រាក់អត្ថប្រយោជន៍ ដោយមិនរាប់បញ្ចូលទៅក្នុងមូលដ្ឋានគិតពន្ធលើបៀវត្ស ដែលក្នុងនោះរួមមានមូលនិធិបេឡាជាតិរបបសន្តិសុខសង្គម ប្រាក់ថ្លៃបាយ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ និងប្រាក់ឧបត្ថម្ភទារក ឬចំណាយទារកដ្ឋាន។ - អគ្គិសនីកម្ពុជាបានតភ្ជាប់ចរន្តអគ្គិសនីដល់បន្ទប់ជួលកម្មករនិយោជិតចំនួន២៣៤ ៤២០ បន្ទប់ជួលនៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ គិតត្រឹមខែមិថុនា ឆ្នាំ២០១៦។	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលភ្នកសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានតបណ្តាញទឹកស្អាតបាន ១១៥ ៦៦៨បន្ទប់ជួល នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ គិតត្រឹមខែធ្នូ ឆ្នាំ២០១៦។ - កម្រិតប្រាក់បៀវត្សជាប់ពន្ធត្រូវបានដំឡើងដល់ ១ ០០០ ០០០រៀល នៅឆ្នាំ២០១៧ ដែលអាចកាត់បន្ថយចំណាយបង់ពន្ធរបស់កម្មករនិយោជិត ដែលមានប្រាក់ចំណូលទាបជាង ១ ០០០ ០០០ រៀល ប្រមាណ២,៥ ដុល្លារក្នុង១ខែ ធៀបនឹងឆ្នាំមុន ▪ ក្រុមអធិការកិច្ចការងារតែមួយចំនួន៤៩ក្រុម ទូទាំងប្រទេសបានចុះ អធិការកិច្ចចំនួន ៧ ៦៨៧លើក (គិតត្រឹមខែវិច្ឆិកា ឆ្នាំ ២០១៦) ដោយផ្តោតសំខាន់លើលក្ខខណ្ឌការងារ និងជាពិសេសការអនុវត្តប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ។ - ក្រសួងស្ថាប័នពាក់ព័ន្ធ	
- ផ្តួចផ្តើមឱ្យមានការសិក្សាស្រាវជ្រាវទៅលើទំនាក់ទំនងរវាងបុគ្គលិកនិយោជិត និងនិយោជក ដើម្បីកំណត់ពីបទពិសោធល្អៗក្នុងការស្វែងរកដំណោះស្រាយជាប្រព័ន្ធមួយ ដែលអាចបង្កើនផលិតផលសរុប ជាពិសេសការបណ្តុះបណ្តាលអាជីពក្នុងការដោះស្រាយបញ្ហារបស់កម្មករ ស្របទៅតាមច្បាប់ការងារ និងបទប្បញ្ញត្តិជាធរមាន	២០១៥ ទៅមធ្យម	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ បានធ្វើការបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពក្នុងការដោះស្រាយវិវាទការងារដល់មន្ត្រីពាក់ព័ន្ធចំនួន ១១ខេត្ត សរុបសិក្ខាកាមចំនួន ២ ៤១៧នាក់។ - រដ្ឋបាលខេត្តស្វាយរៀង÷ បានចុះដោះស្រាយវិវាទ ដូចជាវិវាទបុគ្គលមាន១៨ករណី សះជា១១ករណី មិនសះជា៧ករណី លើសហគ្រាសគ្រឹះស្ថានចំនួន១៤សហគ្រាស។ វិវាទការងាររួមមាន៩ករណី សះជា៦ករណី មិនសះជា៣ករណី លើសហគ្រាសគ្រឹះស្ថានចំនួន៩សហគ្រាស ដែលមានកម្មករនិយោជិតចូលរួមចំនួន៥៨៤៣នាក់។	- រដ្ឋបាលខេត្តស្វាយរៀង÷ ▪ កង្វះការចូលរួមសហការពីភាគីពាក់-ព័ន្ធ ជួយ៉ាងសហគ្រាស គ្រឹះស្ថានមួយចំនួននៅតែអនុវត្តច្បាប់ស្តីពីការងារមិនទាន់បានល្អ ដោយសារការយកចិត្តទុកដាក់លើការងារសុខភាពអនាម័យ និងសុវត្ថិភាពការងារសម្រាប់កម្មករ និយោជិត។

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
- រៀបចំច្បាប់ស្តីពីសហជីពនិងច្បាប់ស្តីពីតុលាការការងារ	២០១៥ ទៅមធ្យម	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ការងារពាក់ព័ន្ធនឹងច្បាប់ស្តីពីសហជីព÷ ▪ ច្បាប់ស្តីពីសហជីពត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦។ ▪ បានដាក់ចេញប្រកាសពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីសហជីពមួយចំនួន ហើយបានបញ្ចប់ការព្រាងប្រកាសមួយចំនួនទៀត។ ▪ បានធ្វើគំរូលក្ខន្តិកៈរបស់សហជីពនិងសមាគមនិយោជក។ ▪ កំពុងព្រាងសេចក្តីពន្យល់មាត្រាសំខាន់ៗមួយចំនួននៃច្បាប់ស្តីពីសហជីព។ ▪ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីសហជីព និងការចុះបញ្ជីសហជីព និងសមាគមនិយោជក សម្រាប់មន្ត្រីក្រោមឱវាទក្រសួង សហជីព និងសមាគមនិយោជក។ ▪ កំពុងរៀបចំបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងទិន្នន័យសហជីព និងសមាគមនិយោជក តាមបែបព័ត៌មានវិទ្យា នាពេលឆាប់ៗ។ ▪ បានធ្វើការរៀបចំឯកសារគំរូ ដែលត្រូវបានតម្រូវឱ្យមានក្នុងការចុះបញ្ជី និងការរក្សាបញ្ជីកា ដោយបានដាក់ឯកសារទាំងនោះនៅលើគេហទំព័រផ្លូវការរបស់ក្រសួងសម្រាប់សាធារណជនទាញយកដោយសេរី។ ការងារពាក់ព័ន្ធនឹងច្បាប់ស្តីពីតុលាការការងារ÷ ▪ បានបញ្ចប់សេចក្តីព្រាងដំបូង និងបានដាក់ជូនក្រសួងយុត្តិធម៌ និងអង្គការអន្តរជាតិខាងការងារ ដើម្បីពិនិត្យនិងផ្តល់យោបល់។ ▪ កំពុងពិនិត្យលើកិច្ចសហការជាមួយក្រសួងយុត្តិធម៌ និងដៃគូ	

ទិដ្ឋានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ពាក់ព័ន្ធ ដើម្បីកំណត់លក្ខណសម្បត្តិរបស់ទីប្រឹក្សាការងារអមតុលាការការងារ ព្រមទាំងបណ្តុះបណ្តាល និងបំប៉ន់សមត្ថភាពបេក្ខជនជាទីប្រឹក្សាការងារអមតុលាការការងារ។ ▪ បានចេញប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ដើម្បីសម្រួលនីតិវិធីក្នុងការបញ្ជូនសំណុំរឿងនៃវិវាទការងាររួមទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដើម្បីសម្រួលដល់ដំណើរការនៃការផ្សះផ្សាវិវាទការងាររួម ព្រមទាំងបានបញ្ចប់ផងដែរនូវការព្រាងប្រកាសថ្មីស្តីពីនីតិវិធីដោះស្រាយវិវាទការងាររួម ។	
- ពង្រឹងយន្តការចុះធ្វើអធិការកិច្ចលក្ខខណ្ឌការងារ តាមរយៈការពង្រីកកម្មវិធីរោងចក្រល្អប្រសើរ ឬពិនិត្យលទ្ធភាពក្នុងការបង្កើតក្រុមការងារចម្រុះធ្វើអធិការកិច្ចជាប្រចាំ និងមានកម្មវិធីច្បាស់លាស់ ដើម្បីកាត់បន្ថយចំនួនត្រួតពិនិត្យផង និងធានាបានប្រសិទ្ធភាពក្នុងការត្រួតពិនិត្យផង។ ក្រុមការងារចម្រុះនេះត្រូវរាយការណ៍ជាទៀងទាត់ជូនរាជរដ្ឋាភិបាល	២០១៥	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានប្រជុំបញ្ជាការងកភាពក្រុមអធិការកិច្ចតែមួយចំនួន ១០លើក។ ▪ បានពង្រឹងសមត្ថភាពដល់មន្ត្រីអធិការកិច្ចការងារតាមខេត្តចំនួន ៣វគ្គ សរុបសិក្ខាកាមចំនួន១២៧នាក់។ ▪ បានបណ្តុះបណ្តាលវគ្គ PQI ដល់មន្ត្រីអ.គ.ក.ប មន្ត្រីអធិការកិច្ចការងារ និងមន្ត្រីពាក់ព័ន្ធចំនួន៤២២នាក់ និងវគ្គ Managerial Communication ចំនួន៣៤នាក់។ ▪ បានបញ្ជូនមន្ត្រីអធិការពេទ្យការងារឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសវៀតណាម ចិន ម៉ាឡេស៊ី និងសិង្ហបុរី សរុបចំនួន២០នាក់។ ▪ បានចុះធ្វើអធិការកិច្ចការងារក្នុងក្រុមអធិការកិច្ចតែមួយ ចំនួន ▪ ៨ ៧៦៣លើក ក្នុងនោះសិប្បកម្មឡូតដ្ឋចំនួន ៣៧៦លើក។ ▪ បានទប់ស្កាត់ និងដកហូតពលកម្មកុមារក្នុងវិស័យសេដ្ឋកិច្ចមិន	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		រៀបរយបានចំនួន៣ ៤២១នាក់ (កុមារី ២ ៣៩៥នាក់)។ ▪ បានធ្វើអធិការកិច្ចការងារពលកម្មកុមារនៅតាមរោងចក្រដែលបានស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេង ចំនួន ២៦លើក។ - រដ្ឋបាលខេត្តស្វាយរៀង÷ បានចុះធ្វើអធិការកិច្ចការងារចំនួន ៤៥ លើក ក្នុងនោះអធិការកិច្ចការងារសាមញ្ញ២៨ លើក អធិការកិច្ចការងារពិសេស ១៧លើក ស្មើនឹង៤៥សហគ្រាស។	
- ពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាពនិងសិទ្ធិស្របច្បាប់របស់ខ្លួន ពិសេសកាត់បន្ថយការចំណាយហួសហេតុក្នុងការទទួលបានការងារ	២០១៥ ទៅមធ្យម	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានពង្រីកការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារទូទាំងប្រទេសដល់ទីជនបទ តាមរយៈ ÷ - ការសិក្សាទីតាំង និងប្រកាសជ្រើសរើសមន្ត្រីក្នុងការបង្កើតមជ្ឈមណ្ឌលការងារថ្មីចំនួន ២ នៅក្នុងខេត្តបន្ទាយមានជ័យ និងព្រះសីហនុ។ - ការចូលរួម និងរៀបចំពិព័រណ៍ការងារថ្នាក់ជាតិ/ខេត្ត, រៀបចំពិព័រណ៍ចល័ត និងវេទិកាការងារចំនួន ១៧៥ ដង (៦៥ ៤២៧នាក់) និងប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ៦២ ៤២០កន្លែង។ - បោះពុម្ពព្រឹត្តិបត្រការងារចំនួន ១២ ០០០ក្បាល បណ្ណផ្សព្វផ្សាយចំនួន១៨០ ០០០សន្លឹក ផលិតកម្មវិធីទូរទស្សន៍ចំនួន ៥២ ផ្សព្វផ្សាយតាមវិទ្យុចំនួន ១.៧៩៥ដង អ្នកចូលប្រើប្រាស់គេហទំព័រចំនួន៤ ៧០៦ ០២៣លើក និង Facebook ចំនួន៣៥ ៧៤១ នាក់។ - ចុះឈ្មោះអ្នកស្វែងរកការងារធ្វើបានចំនួន១៣៤ ៨០នាក់	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពខ្វះខាតត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		បញ្ជូនអ្នកស្វែងរកការងារទៅឱ្យនិយោជកបានចំនួន ១១ ២៨១នាក់ អ្នកទទួលបានការងារតាមរយៈ NEA ចំនួន ២.៤៤៣នាក់ ផ្តល់ការណែនាំអំពីអាជីពចំនួន ២ ៩៦៧ នាក់ ផ្សព្វផ្សាយសេវាការងារ និងព័ត៌មានទីផ្សារការងារតាមមូលដ្ឋានចំនួន២៦ដង និងអ្នកចូលរួមចំនួន១ ១៤៨នាក់ (ថ្នាក់ឃុំ២ដង, ថ្នាក់សង្កាត់២ដង, ថ្នាក់ស្រុក ១៧ដង, ថ្នាក់ខណ្ឌ ៤ដង និងថ្នាក់ក្រុង ១ដង) និងធ្វើការបណ្តុះបណ្តាលស្តីពីការត្រៀមលក្ខណសម្បត្តិមុនឈានចូលទីផ្សារការងារ បានចំនួន ៣៧ដង (៩៤៤ នាក់)។ - បានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលនៅក្នុងស្រុក ចំនួន២វគ្គ (៧នាក់)។ ▪ បានធ្វើអធិការកិច្ចសាមញ្ញ និងពិសេសដល់ទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីអប់រំ និងជំរុញការអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធ-ភាពខ្ពស់។ ▪ បាននិងកំពុងបន្តចាត់វិធានការចំពោះទីភ្នាក់ងារជ្រើសរើសឯកជនដែលធ្វើការផ្សព្វផ្សាយការជ្រើសរើសពលករទៅធ្វើការនៅបរទេសដោយគ្មានការអនុញ្ញាត។ ▪ បានចេញបណ្ណសម្គាល់ខ្លួនដល់ទីភ្នាក់ងារជ្រើសរើសឯកជន សរុបចំនួន ១៩៤នាក់ (ស្រី៥៦នាក់)។ ▪ បានចេញបណ្ណសម្គាល់ខ្លួន និងលិខិតឧទ្ទេសនាមដល់ទីភ្នាក់ងារឯកជនសម្រាប់ចុះទៅធ្វើការផ្សព្វផ្សាយ និងជ្រើសរើសពលករនៅតាមបណ្តារាជធានីខេត្ត ក្នុងគោលបំណងទប់ស្កាត់ និងលុបបំបាត់	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ការឆបោក និងកេងប្រវ័ញ្ច។ ▪ បានអនុវត្តកម្មវិធីអប់រំណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅបរទេសបានចំនួន ១ ៧៤០នាក់ (ស្រី ៨៨១នាក់)។ - ទីភ្នាក់ងារជាតិមុខរបរ និងការងារ - រដ្ឋបាលខេត្តស្វាយរៀង បានសហការពង្រឹងយន្តការគ្រប់គ្រងការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានទីផ្សារពលកម្ម និងបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាព និងសិទ្ធិស្របច្បាប់របស់ខ្លួន។	
- លើកកម្ពស់សុខុមាលភាពរបស់កម្មករ តាមរយៈការជំរុញអនុវត្តគោលនយោបាយលំនៅឋានសម្រាប់កម្មករ ដែលអនុញ្ញាតឱ្យពួកគេអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេក ដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី	មធ្យមទៅវែង	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ ស្ថានភាពសហគ្រាសគ្រឹះស្ថានបើកថ្មីសរុបចំនួន៦១៦សហគ្រាស និងកម្មករនិយោជិតសរុប៥៨ ០០០នាក់ (ស្រី ៣៩.៥០៧នាក់) ក្នុងនោះ÷ - រោងចក្រវាយនភណ្ឌនិងផលិតស្បែកជើងសរុប ១៤៩ សហគ្រាស និងកម្មករនិយោជិតសរុប ៤១ ៥៧០នាក់ (ស្រី ៣៣.៦៣៩នាក់)។ - រោងចក្រសហគ្រាសក្រៅពីកាត់ដេរសរុបចំនួន ៤៦៧ សហគ្រាស និងកម្មករនិយោជិតសរុប ១៦ ៤៣០នាក់ (ស្រី៥ ៨៦៨នាក់)។ - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - រដ្ឋបាលខេត្តស្វាយរៀងគិតត្រឹមបំណាច់ឆ្នាំ២០១៦ ខេត្តស្វាយរៀង មានរោងចក្រ សហគ្រាស គ្រឹះស្ថាន សរុបចំនួន១៥៥ បាននិងកំពុងដំណើរការសកម្មភាព មានកម្មករនិយោជិតសរុប៥៧១៣៧នាក់ ស្រី៣៨១០៤នាក់	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ក្នុងនោះកម្មករ និយោជិតខ្មែរចំនួន៥៥ ១៦៦នាក់ ស្រី៣៧៥៣៣នាក់។	
- ពិនិត្យឡើងវិញពីច្បាប់ការងារ និងការអនុវត្តកន្លងមក ដើម្បីស្វែងរកចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ហើយធ្វើការគូសបញ្ជាក់ឡើងវិញពីតួនាទីរបស់និយោជក និងសហជីពក្នុងដំណើរការអភិវឌ្ឍទីផ្សារការងារ ដែលថ្លឹងបានទ្ធវតុល្យភាពនៃការអភិវឌ្ឍ និងសុខុមាលភាពកម្មករ	មធ្យមទៅវែង	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានរៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធស្តីពីការងារដូចជា÷ - ជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ - ចាត់វិធានការតឹងរ៉ឹងចំពោះការអនុវត្តសិទ្ធិសេរីភាពសហ-ជីពដែលផ្ទុយពីលក្ខន្តិកៈសហជីព ការមិនគោរពភាពជាតំណាងបំផុត និងការមិនគោរពបទប្បញ្ញត្តិដែលបង្កឱ្យមានវិវាទ និងកូដកម្មខុសនីតិវិធី។ - ចាត់វិធានការតឹងរ៉ឹងចំពោះសហជីព កម្មករនិយោជិត និងនិយោជក ដែលរំលោភច្បាប់ និងពុំគាន់បានអនុវត្តឱ្យត្រឹមត្រូវតាមច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធ។	
- ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ជាពិសេសត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់សមាហរណកម្មអាស៊ាន។	២០១៥ ទៅមធ្យម	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានរៀបចំសេចក្តីជូនដំណឹង ស្តីពីការជំរុញការអនុវត្តក្របខ័ណ្ឌគុណវុធ្ឍជាតិកម្ពុជាសម្រាប់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ)។ ▪ បានបន្តចូលរួមប្រជុំ និងសិក្ខាសាលាពាក់ព័ន្ធនឹងការអភិវឌ្ឍ និងអនុវត្តក្របខ័ណ្ឌគុណវុធ្ឍជាតិ។ ▪ បានចេញប្រកាសលេខ៤៦៣ កប/ប្រក ស្តីពីទីភ្នាក់ងារឯកជនផ្តល់សេវាកការងារឱ្យធ្វើក្នុងស្រុក។ ▪ បានដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យហត្ថពលកម្មបរទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម តាមរយៈប្រកាសលេខ៣៥២	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		កប/ប្រក។ ▪ បានជំរុញ និងពង្រឹងការអនុវត្តច្បាប់ស្តីពីការងារអំពីកូតានៃការប្រើប្រាស់ជនបរទេសប្រចាំឆ្នាំ។	
- រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ។	២០១៥ ទៅមធ្យម	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ក្នុងសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥ និងត្រូវបានប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ ▪ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៩៣ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ២០១៥-២០២៥។ ▪ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៨២៨ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥។ ▪ បានរៀបចំកិច្ចប្រជុំលើកទី១របស់គណៈកម្មការអន្តរក្រសួង និងបានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការរៀបចំផែនការសកម្មភាពនិងអំពីនីតិវិធីស្នើសុំថវិកា ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥។	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានរៀបចំកិច្ចប្រជុំអនុគណៈកម្មការនីមួយៗ និងបានរៀបចំតារាងផែនការសកម្មភាពសម្រាប់រយៈពេល៣ឆ្នាំ២០១៧-២០១៩។ ▪ ចូលរួមចំណែកក្នុងការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនឱ្យយល់ដឹងអំពីគោលនយោបាយនេះតាមរយៈ គេហទំព័រ NEA, បណ្តាញសង្គម Facebook, ការផ្សព្វផ្សាយផ្ទៃក្នុងជូនដល់មន្ត្រី និងព្រឹត្តិការណ៍ផ្សេងៗ។ ▪ បានរៀបចំកិច្ចប្រជុំអនុគណៈកម្មការពង្រឹងអភិបាលកិច្ចទីផ្សារការងារ ដើម្បីពិភាក្សារៀបចំផែនការសកម្មភាពដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦។ ▪ បានរៀបចំផែនការសកម្មភាព៣ឆ្នាំ របស់ NEA ដែលស្របតាមគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ។	
៤)-ការសម្រេចសម្រួលគោលនយោបាយគាំទ្រ			
ក-ការបណ្តុះបណ្តាលជំនាញនិងធនធានមនុស្ស			
- បង្កើតឱកាសទីពីរសម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា តាមរយៈការបង្កើតប្រព័ន្ធសមមូលសញ្ញាបត្រ ដោយផ្អែកលើការធ្វើតេស្តដែលអនុញ្ញាតឱ្យទទួលបានវិញ្ញាបនបត្រចំណេះដឹងទូទៅគ្រប់កម្រិត ទោះនៅក្រៅប្រព័ន្ធអប់រំផ្លូវការក៏ដោយ	២០១៥	- ក្រសួងអប់រំ យុវជន និងកីឬា - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានអភិវឌ្ឍមុខរបរចំនួន២១មុខរបរ សម្រាប់សិស្សដែលបានបោះបង់ការសិក្សាមុនបញ្ចប់ថ្នាក់ទី៩ ដែលរួមមាន÷ - វិស័យធុរកិច្ច និង ICT មាន៧មុខរបរ; សេវាកម្មធនធានមនុស្ស សេវាកម្មអតិថិជន សេវាកម្មកុំព្យូទ័រ សេវាកម្មរដ្ឋបាល សេវាកម្មទីផ្សារ ការរៀបចំក្រាហ្វិចកុំព្យូទ័រ និង សេវាកម្មលក់។	

ទិសដៅគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ធនធានមនុស្ស/ក្រុមហ៊ុនអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		- វិស័យសំណង់មាន៧មុខរបរ÷ ការងារកំបោរ ដំឡើងពុម្ព ដំឡើងគ្រឿងឈើសម្រេច ដំឡើងសរសៃដែក ដំឡើងអគ្គិសនីក្នុងអគារ ដំឡើងបណ្តាញក្នុងបំពង់ទឹក និងដំឡើងគ្រោងពីដែក។ - វិស័យមេកានិកមាន៧មុខរបរ÷ ថែទាំនិងជួសជុលរថយន្ត ថែទាំនិងជួសជុលម៉ាស៊ីនត្រជាក់រថយន្ត ថែទាំនិងជួសជុលអគ្គិសនីរថយន្ត ថែទាំនិងជួសជុលទោចក្រយានយន្ត ជួសជុលតួរថយន្ត បាញ់ថ្នាំរថយន្ត និងជួសជុល និងកែច្នៃគ្រឿងបន្ទាស់រថយន្ត។ - រដ្ឋបាលខេត្តស្វាយរៀង÷ ▪ មានគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកជនសរុបចំនួន៧គ្រឹះស្ថាន និងវិទ្យាស្ថានពហុបច្ចេកទេសតេជោសែនភូមិភាគស្វាយរៀង ១កន្លែង។ នៅឆ្នាំ២០១៦ គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈទាំងនោះបានផ្តល់ធនធានមនុស្សចំនួន១ ៦៧៦នាក់ ស្រី៦១៣នាក់។ ▪ មានគ្រឹះស្ថានហ្វឹកហ្វឺនកូនជាងចំនួន៤២កន្លែង ដែលមានកូនជាងសរុប២ ៣៨២នាក់ ស្រី១ ៥៤៦នាក់។	
- ពង្រឹងគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដោយផ្តោតលើការពង្រឹងមូលដ្ឋានចំណេះដឹងរបស់កុមារ និងយុវជនលើផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងបច្ចេកវិទ្យា	២០១៥ មធ្យមវែង	- ក្រសួងអប់រំ យុវជន និងកីឬ÷ ▪ បាននិងកំពុងពិនិត្យកែសម្រួលឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សាលើមុខវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រ ប្រវត្តិវិទ្យា និងអក្សរសាស្ត្រខ្មែរ ដោយបានទៅធ្វើទស្សនកិច្ចសិក្សាជក្រស់ងបទពិសោធន៍ពីប្រទេសនានា។ ▪ កំពុងបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន៧០០នាក់	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		តាមប្រព័ន្ធពន្លឿន ដើម្បីឱ្យក្លាយទៅជាគ្រូកម្រិតឧត្តមលើ ៦មុខវិជ្ជារួមមាន គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា អក្សរសាស្ត្រខ្មែរ និងប្រវត្តិវិទ្យា។ ▪ បានអភិវឌ្ឍន៍សមត្ថភាពគ្រូឧទ្ទេសនៅសាលាគរុកោសល្យផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ និងកម្មសិក្សាគរុកោសល្យ។ ▪ បានអនុម័តគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី និងបានដាក់ឱ្យដំណើរការសាលារៀនជំនាន់ថ្មីនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ ដោយរៀបចំឱ្យមានបន្ទប់ពិសោធន៍តាមមុខវិជ្ជា បន្ទប់កុំព្យូទ័រ និងបំពាក់កុំព្យូទ័រ បន្ទប់មុខវិជ្ជា បន្ទប់សាស្ត្រាចារ្យ និងបណ្ណាល័យ។ ▪ បានជំរុញការរៀបចំវេទិកាស្តីពីវិទ្យាសាស្ត្រ និងគណិតវិទ្យា និងការបង្កើតក្លឹបសិក្សាដើម្បីទាក់ទាញការចាប់អារម្មណ៍ និងបណ្តុះគំនិតសិស្សានុសិស្សសិក្សាមុខវិជ្ជាទាំងនេះតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា។ ▪ បានអនុម័ត និងផ្សព្វផ្សាយក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។ ▪ បានអនុម័តនិងដាក់ឱ្យអនុវត្តបញ្ញត្តិធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា។ ▪ បានសហការជាមួយ÷ - សាធារណរដ្ឋប្រជាមានិតចិន ដោយទទួលបានហិរញ្ញប្បទានឥតសំណងប្រមាណ ៤០លានដុល្លារ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់សាងសង់ និងជួសជុលអគារអនុវិទ្យាល័យ បន្ទប់សម្រាប់គ្រូ សាលប្រជុំ និងពាក់	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		សម្ភារៈកីឬ្ឬ កុំព្យូទ័រ នៅតាមរាជធានីខេត្ត ១១ និងការបណ្តុះបណ្តាលមន្ត្រីអប់រំនៅប្រទេសចិន និងបានស្នើសុំការគាំទ្រដល់ការ អនុវត្តគម្រោងពីរបន្ថែមទៀតគឺ÷ ១) គម្រោងសាលាជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិ និង២) គម្រោងលើកកម្ពស់មុខជំនាញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅកម្រិតឧត្តមសិក្សា។ - KOICA ដោយបានលើកសំណើគម្រោង ៥ គឺ÷ ១) គម្រោងពង្រីកការអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ២) គម្រោងអភិវឌ្ឍន៍ និងអនុវត្តវគ្គវិក្រឹតការទៀងទាត់ ៣) គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឬ្ឬ ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស ៤) គម្រោងអំណានថ្នាក់ដំបូងនៅបឋមសិក្សា និង ៥) គម្រោងលើកកម្ពស់សុខភាព និងអប់រំសុខភាពសិស្សស្រី ដែលសិក្សានៅតាមគ្រឹះស្ថានសាធារណៈ។ - ធនាគារអភិវឌ្ឍន៍អាស៊ី ដោយទទួលបានការគាំទ្រដល់ការអប់រំនៅមធ្យមសិក្សាទុតិយភូមិ ក្នុងនោះក៏បានគាំទ្រដល់ការអប់រំមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ដោយបំពាក់គ្រឿងបរិក្ខារពាក់ព័ន្ធ និងការផ្តល់អាហារូបករណ៍។ - ធនាគារពិភពលោក ដោយកំពុងរៀបចំគម្រោងគាំទ្រការអប់រំនៅមធ្យមសិក្សាបឋមភូមិ។	
- ជំរុញការអប់រំចំណេះទូទៅឱ្យបានយ៉ាងហោចណាស់ប្រាំបួនឆ្នាំ ដោយកាត់បន្ថយឱ្យបានជា	២០១៥ មធ្យម	- ក្រសួងអប់រំ យុវជន និងកីឬ្ឬ	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
អតិបរមានូវអត្រាបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា និងលើកកម្ពស់ការចូលរៀននៅថ្នាក់មធ្យមសិក្សា	រ៉ែង		
- កែលម្អកម្មវិធីសិក្សាដោយដាក់បញ្ចូលជំនាញទន់ (Soft Skills) រួមមាន ជំនាញទំនាក់ទំនងសង្គមក្នុងការដោះស្រាយបញ្ហា ការគោរពវិន័យនៅកន្លែងធ្វើការ និងជំនាញជាច្រើនទៀតដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍមូលដ្ឋានគ្រឹះឧស្សាហកម្ម	មធ្យមទៅវែង	- ក្រសួងអប់រំ យុវជន និងកីឬា - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ:បានអភិវឌ្ឍកម្មវិធីសិក្សាជំនាញទន់ និងសហគ្រិនភាព ដើម្បីបញ្ចូលនៅក្នុងវគ្គបណ្តុះបណ្តាលជំនាញ និងកម្មវិធីសិក្សា ដោយបានចងក្រងមេរៀនស្តីពីជំនាញទន់ដល់សិស្ស និស្សិត យុវជន និងអ្នកស្វែងរកការងារ និងធ្វើការបណ្តុះបណ្តាលចំនួន១៥វគ្គ (៣៨៨នាក់)។	
- ពង្រឹងការយល់ដឹងអប់រំអំពីការចាប់អាជីពនិងជំនាញបច្ចេកទេស ក៏ដូចជាកម្មវិធីសិក្សាបន្ត ដើម្បីអភិវឌ្ឍជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់	២០១៥ ទៅមធ្យម	- ក្រសួងអប់រំ យុវជន និងកីឬា បានអនុម័តស្តង់ដាគ្រឹះស្ថានបណ្តុះ-បណ្តាលគ្រូ កំពុងរៀបចំស្តង់ដាគ្រូបង្រៀន និងបានពិភាក្សាលើឯកសារទស្សនាទានស្តីពីគន្លងអាជីព។ - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានលើកកម្ពស់ការយល់ដឹងអំពីអាជីពការងារមុខរបរ និងជំនាញតាមរយៈ÷ - ការរៀបចំសិក្ខាសាលាស្តីពីមគ្គុទ្ទេសក៍អាជីពតាមវិទ្យាល័យ បានចំនួន២១៧ដង (១២ ០៣៣នាក់) និងស្តីពីអាជីព និងការងារ តាមសាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ បានចំនួន៥៤ដង (៤ ៣៥៥នាក់)។ - ការចូលរួមចំណែកក្នុងការផ្សព្វផ្សាយស្តីពីការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		របស់ NEA។ - ការចូលរួមផ្សព្វផ្សាយវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅតាមបណ្តាវិទ្យាល័យ និងអនុវិទ្យាល័យចំនួន ២លើក ដែលសរុបមានសិស្សានុសិស្សចំនួន៣០ ៧១៧នាក់ (ស្រី ១១ ៤០៧នាក់)។ - ទំនាក់ទំនងជាមួយវិស័យឯកជនដើម្បីស្វាបស្ទង់ពីតម្រូវការជំនាញ ចុះទំនាក់ទំនងបានចំនួន ៨៤សហគ្រាស។ - កិច្ចសហការក្នុងការបញ្ជូនសិស្សសិក្ខាកាមចុះធ្វើកម្មសិក្សាតាមសហគ្រាស ភ្លេងចក្រ គ្រឹះស្ថានឯកជន ចំនួន ៤៨៦នាក់ (ស្រី១៤៤នាក់)។ - ទីភ្នាក់ងារជាតិមុខរបរនិងការងារបានចូលរួមចំណែកក្នុងការផ្សព្វផ្សាយស្តីពីការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទរបស់ NEA។	
- បង្កើនការបណ្តុះបណ្តាលបច្ចេកទេសឱ្យបានច្រើនដងជាងមុន តាមលទ្ធភាពលើជំនាញបច្ចេកទេស ជាពិសេស នៅក្នុងផ្នែកអគ្គិសនី អេឡិចត្រូនិកមេកានិក ស្តង់ដា មាត្រាសាស្ត្រ (ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ព្យាសកម្ម គេស្ត និងជំនាញប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ) និងពីមីសាស្ត្រ ទាំងក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេស ទាំងក្នុងកម្រិតឧត្តមសិក្សា	មធ្យមទៅវែង	- ក្រសួងអប់រំ យុវជន និងកីឬា បានកែលម្អកម្មវិធីសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារលើជំនាញមេកានិក អគ្គិសនី អេឡិចត្រូនិក ក្សេត្រសាស្ត្រ និងបសុវប្បកម្ម។ - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានបំពាក់មូលដ្ឋានសម្ភារៈបណ្តុះបណ្តាលចំនួន១៨គ្រឹះស្ថាន។ ▪ បានចុះត្រួតពិនិត្យសម្ភារៈបណ្តុះបណ្តាលដែលមិនបានប្រើនៅតាមបណ្តាគ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ចំនួន ១២គ្រឹះស្ថាន។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា÷ ▪ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិសង្គមកិច្ច ក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ វិទ្យាស្ថាននេះមានមហាវិទ្យាល័យចំនួន២ គឺ មហាវិទ្យាល័យសង្គមកិច្ច និងមហាវិទ្យាល័យវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប និងនៅក្នុងឆ្នាំ២០១៦ មាននិស្សិតបាននិងកំពុងសិក្សាចំនួន៤៣៣នាក់ និងបានបញ្ចប់ការសិក្សាចំនួន៣៣នាក់ ក្នុងនោះមាននិស្សិតបរទេសចំនួន៧នាក់។ នេះជាវិទ្យាស្ថានតែមួយគត់ដែលបម្រើលើវិស័យសង្គមកិច្ច ស្តារលទ្ធភាពពលកម្មកាយសម្បទាសម្រាប់ជនពិការ អាចដោះស្រាយឧបសគ្គក្នុងសង្គម បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា បង្កើនគុណវុធិវិជ្ជាជីវៈ ព្រមទាំងអាចឱ្យជនងាយរងគ្រោះ បានចូលរួមយ៉ាងពេញលេញរាល់សកម្មភាពសង្គម ដោយស្មើភាព ស្មើសិទ្ធិ និងថ្លៃថ្នូរ ▪ បានសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានរៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ចំនួន១៩ ជូនជនពិការ នៅក្នុងឆ្នាំ២០១៦ ▪ បានផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសរុបចំនួន ១៦ ៩៣១ នាក់។ ជំនាញទាំងនេះរួមមាន ជួសជុលគ្រឿងអេឡិចត្រូនិក,	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ជួសជុលកុំព្យូទ័រ, កសិកម្ម, ជាងដែក, ជួសជុលទូរស័ព្ទ, កាត់ដេរ, សំអាងការ, ជួសជុលគ្រឿងម៉ាស៊ីន, គំនូរ, ក្បាច់, ចម្លាក់ ។ល។	
- ផ្តល់អាទិភាពដល់ការបង្កើតសាលាមធ្យមសិក្សាបច្ចេកទេសឱ្យបានច្រើន (ទាំងក្នុងប្រព័ន្ធអប់រំទូទៅ ទាំងក្រៅប្រព័ន្ធ) ដោយផ្តោតលើផ្នែកសំខាន់ៗ ដូចជាអគ្គិសនី អេឡិចត្រូនិក ព័ត៌មានវិទ្យា កុំព្យូទ័រ ម៉ាស៊ីន ការជួសជុល និងការដំឡើងរថយន្ត និងម៉ូតូ ការកែច្នៃកសិផល និងសិប្បកម្ម	មធ្យមទៅវែង	- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ▪ បានដំឡើងកម្រិតបណ្តុះបណ្តាលរយៈពេលវែងមានគ្រឹះស្ថានសាធារណៈចំនួន ៣ និងគ្រឹះស្ថានឯកជនចំនួន ៣។ ▪ បានចុះអនុស្សរណៈយោគយល់ជាមួយអង្គការ សមាគម ចំនួន ៧។ - ក្រសួងអប់រំ យុវជន និងកីឬ - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍÷ បានចូលរួមសិក្ខាសិលា ស្តីពីគោលនយោបាយអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (Science, Technology, Engineering and Mathematics - STEM) ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឬ។	
- រៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្ម ដោយរួមមានផែនការវិនិយោគច្បាស់លាស់ និងក្នុងទស្សនវិស័យរយៈពេលវែង	២០១៥	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានរៀបចំសិក្ខាសាលាស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៤-២០១៨។ ▪ បានចុះត្រួតពិនិត្យតាមដានការអនុវត្តសកម្មភាពនៃអនុកម្មវិធី និងបំប៉ន់សមត្ថភាពលើការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំដល់មន្ត្រីទទួលបន្ទុកផ្នែកផែនការ និងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសិក្សាចំនួន២៧ខេត្ត។ - ក្រសួងអប់រំ យុវជន និងកីឬ	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
- ជំរុញស្ថាប់ននីយកម្មនូវកម្មវិធីប្រព័ន្ធកម្មសិក្សា (Apprenticeship Schemes) ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់ក្រុមហ៊ុន និងសហគ្រាស ដែលទទួលអនុវត្តតាមប្រព័ន្ធកម្មសិក្សាបែបនេះ	២០១៥ ទៅមធ្យម	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ កំពុងអនុវត្តច្បាប់ស្តីពីការងារឱ្យមានប្រសិទ្ធភាព ជាពិសេស ពាក់ព័ន្ធនឹងការហ្វឹកហ្វឺនកូនជាង។	
- ពង្រឹងការបណ្តុះបណ្តាលជំនាញឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជនទាំងវិនិយ កម្រិតជំនាញ និងសមត្ថភាពតាមរយៈការធ្វើសហ-ប្រតិបត្តិការជាមួយនឹងវិនិយោគិនបរទេសពោលដៅ មានដូចជាការបង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនជំនាញជប៉ុន កូរ៉េ សិង្ហបុរី។	២០១៥ ទៅមធ្យម	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានចងក្រងក្រុមជនបង្គោលផ្នែកទំនាក់ទំនងឧស្សាហកម្មនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈទាំង ៣៩សរុបចំនួន៧៨នាក់។ ▪ បានចុះពង្រឹងគ្រឹះស្ថានចំនួន១៥គ្រឹះស្ថាន និងបានរៀបចំសិក្ខា-សាលាពង្រឹងសមត្ថភាពមន្ត្រីទំនាក់ទំនងឧស្សាហកម្មមានសរុបចំនួន៦៥នាក់ ស្រី២៣នាក់។ - ក្រសួងអប់រំ យុវជន និងកីឬ÷ បានប្រជុំជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធនឹងសភាពាណិជ្ជកម្ម ដើម្បីទាក់ទាញការចូលរួមរបស់វិស័យឯកជន និងគាំទ្រដល់ការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធ។	
- ជំរុញការបណ្តុះបណ្តាលត្រីភាគី "រដ្ឋស្ថាប័ន បណ្តុះបណ្តាលក្រុមហ៊ុន/រោងចក្រ" ដើម្បីបំពាក់ជំនាញ និងបង្កើនផលិតភាពជាពិសេស ការដាក់បញ្ចូលក្នុងកម្មវិធីអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានស្រាប់ តាមរយៈកិច្ចសហប្រតិបត្តិការរវាងវិស័យ	២០១៥ ទៅមធ្យម	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈកំពុងពង្រឹង និងពង្រីកប្រព័ន្ធភាពជាដៃគូសាធារណៈ និងឯកជន តាមរយៈការលើកទឹកចិត្ត ក្នុងការចូលរួម និងបង្កើតច្បាប់ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងច្បាប់ស្តីពីប្រាក់ពន្ធសម្រាប់ការអភិវឌ្ឍជំនាញ (Levy Grant)។ - ក្រសួងអប់រំ យុវជន និងកីឬ	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
សាធារណៈ និងសមាគមនុស្សាហកម្ម		- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានចុះអនុស្សរណៈយោគយល់ជាមួយក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍អ៊ីនធើណែត និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ចំនួន១០ក្រុមហ៊ុន ដើម្បីជំរុញដល់ការអភិវឌ្ឍកម្មវិធីសិក្សាឱ្យត្រូវតាមទីផ្សារបច្ចុប្បន្ន។	
- ពង្រីកការបណ្តុះបណ្តាលជំនាញនៅនឹងកន្លែង ដោយផ្តោតការយកចិត្តទុកដាក់លើពលករតាមរោងចក្រ ដើម្បីឱ្យពលករទាំងនោះទទួលបានការអប់រំបណ្តុះបណ្តាល និងផ្តល់ក្តីសង្ឃឹម ក្នុងការអភិវឌ្ឍជំនាញ និងបច្ចេកទេសក្នុងពេលអនាគត	២០១៥ ទៅមធ្យម	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានផ្តល់ការហ្វឹកហ្វឺនជំនាញដល់កម្មករនិយោជិតនៅតាមបណ្តារោងចក្រ សហគ្រាសចំនួន២១ ០៤៤នាក់ ស្រី១៤ ៣១០នាក់។ ▪ កំពុងរៀបចំប្រព័ន្ធទទួលស្គាល់សមត្ថភាពជំនាញតាមរយៈការអនុវត្តកម្មវិធីទទួលស្គាល់ការសិក្សាពីមុន (RPL) និងការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន (RCC)។ - ក្រសួងអប់រំ យុវជន និងកីឬា	
- ពង្រឹងការអប់រំនៅសាកលវិទ្យាល័យដែលទាក់ទងទៅនឹងវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រមូលដ្ឋានសំខាន់ៗផ្សេងទៀត និងវិស្វកម្ម ដោយពង្រឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍ ដើម្បីឈានទៅកសាងគុណភាពអប់រំសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍។	មធ្យមទៅវែង	- ក្រសួងអប់រំ យុវជន និងកីឬា - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានបំពាក់ឧបករណ៍បច្ចេកវិទ្យាថ្មីៗដូចជាយន្តហោះគ្មានអ្នកបើកបរ (Drone) និងទូរស័ព្ទឆ្លាតវៃ សម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍។	
ខ- ការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍			
- ជំរុញការរៀបចំនូវក្របខ័ណ្ឌគោលនយោបាយ និងយន្តការអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	មធ្យមទៅវែង	- ក្រសួងផែនការ បាន÷ ▪ កសាងផែនការមេជាតិស្តីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាឆ្នាំ២០១៤-២០២០ ក្រោមជំនួយរបស់សាធារណរដ្ឋកូរ៉េ ដែលមានគោល-	- ក្រសួងផែនការ ÷ ▪ ក្របខ័ណ្ឌគតិយុត្ត និងការអនុវត្ត ក្របខ័ណ្ឌគតិយុត្តដែលមានមាន

ទិសដៅការគោលនយោបាយ/ផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		បំណងសំខាន់ ៤គឺ÷ បង្កើតមូលដ្ឋានសម្រាប់ជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ពង្រឹងសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) បង្កើតបរិយាកាសវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងពង្រឹងសមត្ថភាពឧស្សាហកម្មស្នូល។ ▪ បញ្ជាបក្របខ័ណ្ឌទស្សនៈនៃការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ទៅក្នុងដំណើរការនៃការរៀបចំគោលនយោបាយនានា ក៏ដូចជាទៅក្នុងដំណើរការនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ▪ បង្កើតក្របខ័ណ្ឌគតិយុត្ត និងកសាងយន្តការស្ថាប័នជាមូលដ្ឋាន ក្នុងនោះរួមមាន ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា(ក.ជ.វ.ប.) នាខែកញ្ញា ឆ្នាំ២០១៤, សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នាខែមីនា ឆ្នាំ២០១៥, អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នាខែឧសភា ឆ្នាំ២០១៥, និងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នាខែកក្កដា ឆ្នាំ២០១៥។ ▪ ប្រជុំក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាលើកទី១ស្តីពីការជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅទីស្តីការក្រសួង	កម្រិត ▪ យន្តការស្ថាប័ននៅមានកម្រិត ▪ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស ធនធានសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់អភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេក-វិទ្យានៅមានកម្រិត

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ផែនការ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយបានពិនិត្យ និងឯកភាពលើសំណើទាំង៦របស់អគ្គលេខាធិការដ្ឋាន ក.ជ.វ.ប. ÷ ទី១ សំណើបច្ចេកវិទ្យាជាអាទិភាពជាតិ ឆ្នាំ២០១៧-២០២៥, ទី២ សំណើស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្រចម្បងចំនួន១០ សម្រាប់រយៈពេលខ្លី, ទី៣ សំណើការអភិវឌ្ឍធនធានមនុស្សជាអ្នកស្រាវ-ជ្រាវ និងជាអ្នកបច្ចេកទេស សម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ឆ្នាំ២០១៧-២០២៥, ទី៤ សំណើគ្រោងចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ឆ្នាំ២០១៧-២០២៥, ទី៥ សំណើចំណាត់ថ្នាក់នៃ វិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងទី៦ សំណើក្របខ័ណ្ឌ ទស្សនៈរួមក្នុងការអភិវឌ្ឍគោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ២០១៧-២០២៥។ ជាមួយគ្នានោះ អង្គប្រជុំក៏បានឯកភាពលើសំណើបង្កើតក្រុមការងារបច្ចេកទេសផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការផ្តល់អាទិភាពឱ្យកិច្ចការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាទទួលបានកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ▪ រាយការណ៍ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានក្រុម-ប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា អំពីលទ្ធផលនៃកិច្ចប្រជុំក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាលើកទី១ និងទទួលបានការអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់លើចំណុចជាយុទ្ធ-សាស្ត្របី÷ ១) ការកំណត់យកបច្ចេកវិទ្យាអាទិភាពជាតិ៦សម្រាប់ឆ្នាំ២០១៧-២០២០, ២) បង្កើនការវិនិយោគរបស់រដ្ឋលើការ	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ស្រាវជ្រាវនិងអភិវឌ្ឍ (R&D) និង៣) ផ្តល់អាទិភាពក្នុងការទទួលជំនួយ និងការទទួលកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ▪ កំពុងរៀបចំគោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ២០១៧-២០២៥។ ▪ បង្កើតវេបសាយដើម្បីផ្តល់ព័ត៌មានអំពីការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ ▪ សហការជាមួយភាគីកូរ៉េក្នុងការកសាងផែនការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានការស្រាវជ្រាវនិងអភិវឌ្ឍន៍ជាតិ។ ▪ ចូលរួម និងផ្សព្វផ្សាយពីសារៈសំខាន់នៃវិទ្យាសាស្ត្រនិងបច្ចេក-វិទ្យាក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងគុណភាពជីវិតឱ្យកាន់តែប្រសើរឡើង នៅក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងព្រឹត្តិការណ៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាផ្សេងទៀត។ ▪ បង្កើតព្រឹត្តិបត្រព័ត៌មានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ ▪ ធ្វើការអង្កេតពីសមាជិកនៃក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាស្តីពីបច្ចេកវិទ្យាជាអាទិភាពជាតិឆ្នាំ២០១៦ ▪ ធ្វើការអង្កេតថ្នាក់ជាតិស្តីពីការស្រាវជ្រាវនិងអភិវឌ្ឍន៍ផ្នែកវិទ្យា-សាស្ត្រនិងបច្ចេកវិទ្យាឆ្នាំ២០១៦ ▪ ធ្វើការអង្កេតថ្នាក់ជាតិស្តីពីឧបករណ៍ស្រាវជ្រាវវិទ្យាសាស្ត្រសំខាន់ៗ ឆ្នាំ២០១៦ ▪ ធ្វើការស្រាវជ្រាវ និងចងក្រងចំណាត់ថ្នាក់ស្តង់ដានៃវិស័យវិទ្យា-សាស្ត្របច្ចេកវិទ្យា - ក្រសួងអប់រំ យុវជន និងកីឬា បាន÷	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បំប៉ន គ្រូថ្នាក់ទី១២ លើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ទូទាំងប្រទេស។ ▪ ចុះអធិការកិច្ចតាមប្រធានបទលើមុខវិជ្ជាគណិតវិទ្យានៅតាមវិទ្យាល័យ ចំនួន១៩៨ ក្នុងខេត្តចំនួន ២០។ ▪ រៀបចំ និងបោះពុម្ពសៀវភៅតេស្តថ្នាក់ទី៣ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងកម្រងសំណួរសិស្ស និងគ្រូ សម្រាប់ការធ្វើតេស្តថ្នាក់ជាតិ។ ▪ លើកកម្ពស់សមត្ថភាព និងគុណភាពនៅឧត្តមសិក្សា ដោយបានផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ និងនវានុវត្តន៍ នៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ▪ បានអនុម័តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា និងបានផ្សព្វផ្សាយឱ្យអនុវត្តដល់អង្គភាពពាក់ព័ន្ធ។ ▪ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកបច្ចេកវិទ្យា (NCOST) ស្តីពីការធ្វើផែនការ និងលើកទិសដៅតាមវិស័យ ដើម្បីអនុវត្តផែនការសកម្មភាពអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (APASTI 2016-2025)។ - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានចូលរួមជាសមាជិកនៃការរៀបចំគោលការណ៍អភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។	
- ជំរុញនិងលើកទឹកចិត្តការផ្ទេរបច្ចេកវិទ្យាថ្មីៗ	មធ្យម	- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងតួនាទី	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ក្នុងវិស័យកម្មន្តសាល រួមទាំងផ្នែកសិប្បកម្ម			
- ពង្រឹងការគ្រប់គ្រងមណ្ឌលច្នៃប្រឌិត និងបង្កើតថ្មីកម្ពុជា ដើម្បីលើកកម្ពស់ការបង្កើតឥណ្ណកម្ម និងការបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម	មធ្យមទៅវែង	- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម	
- ពង្រឹង និងកសាងសមត្ថភាពធនធានមនុស្សទៅតាមតម្រូវការសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាឧស្សាហកម្ម	មធ្យមទៅវែង	- ក្រសួងអប់រំ យុវជន និងកីឬ÷ បានលើកកម្ពស់ការស្រាវជ្រាវនៅថ្នាក់ឧត្តមសិក្សាតាមរយៈការបង្កើតបណ្តាញអ្នកស្រាវជ្រាវ និងស្តង់ដាស្រាវ-ជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការ និងកម្មវិធីផ្លាស់ប្តូរទស្សនកិច្ចសិក្សារវាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ជាមួយគ្រឹះស្ថាន និងសាកលវិទ្យាល័យបច្ចេកទេសបរទេស។ ▪ បានរៀបចំសិក្ខាសាលាបំប៉នសមត្ថភាពមន្ត្រីរាជការនិងគ្រូបច្ចេកទេសនៅក្នុងនាយកដ្ឋាន និងគ្រឹះស្ថានសិក្សា។	
- សហការ និងជំរុញការសិក្សាស្រាវជ្រាវ និងការលើកទឹកចិត្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	មធ្យម	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ក្រសួងអប់រំ យុវជន និងកីឬ - ក្រសួងឧស្សាហកម្មនិងងសិប្បកម្ម÷ ▪ បានចូលរួមកិច្ចសហប្រតិបត្តិការជាមួយអន្តរក្រសួង និងអន្តរជាតិលើការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថានឧស្សាហកម្ម ដូចជាជីវៈបច្ចេកវិទ្យា (Biotechnology) ណាណូបច្ចេកវិទ្យា (Nanotechnology) ការអភិវឌ្ឍកាបូនកម្រិតទាប	

ទិសដៅនៃការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		សម្រាប់ផលិតភាព និងការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ តាមរយៈការផ្ទេរវិធីសាស្ត្របច្ចេកវិទ្យាត្រឹមត្រូវ ដែលស្របតាមបទដ្ឋានបរិស្ថាន បរិស្ថានឧស្សាហកម្ម និងការជំរុញការគ្រប់គ្រងសុវត្ថិភាពនៅកម្ពុជា។ ▪ បានរៀបចំជំនួយបច្ចេកទេសផ្នែកសុវត្ថិភាព និងបរិស្ថានឧស្សាហ-កម្ម ដល់វិស័យឯកជន ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហ-កម្មនៅកម្ពុជា។ ▪ បានចុះអនុស្សរណៈយោគយល់គ្នាអំពីវិទ្យាសាស្ត្របរិស្ថាន និងវិទ្យាសាស្ត្រទឹក ជាមួយនឹងបណ្ឌិតសភាវិទ្យាសាស្ត្រនៃសាធារណ-រដ្ឋប្រជាមានិតចិន។	
- សិក្សាលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាភ្ជាប់នឹងសួនឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម	មធ្យមទៅវែង	- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសដោយពិចារណាពីលទ្ធភាពបង្កើតសួនវិទ្យាសាស្ត្រ និង បច្ចេកវិទ្យាភ្ជាប់នឹងសួនឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីផ្តល់សេវាពិសោធន៍ និងសិក្សាស្រាវជ្រាវដល់ឧស្សាហកម្ម - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- បង្កើតយន្តការប្រឡងប្រណាំងអ្នកជំនាញបច្ចេកវិទ្យា អ្នកមានគំនិតផ្ដួចផ្ដើមធុរកិច្ច វិស្វករដែលមានទេពកោសល្យ ដើម្បីចម្រាញ់ឧស្សាហករ ដែលមានទេពកោសល្យ និងបង្កើតកម្លាំងចលករឱ្យខិតខំបង្កើតនវានុវត្តន៍ជាពិសេសក្នុងចំណោមវិស្វករ និងសហគ្រិនវ័យក្មេង	២០១៥	- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម - ក្រសួងអប់រំ យុវជន និងកីឬា - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានរៀបចំការប្រកួតប្រជែងរ៉ូបូត រៀបចំដោយទូរទស្សន៍ជាតិកម្ពុជា និងក្រុមហ៊ុនតូយ៉ូតា ដោយមានបេក្ខជនចំនួន៤០ក្រុម មកពីគ្រឹះស្ថាន អ.ប.រ ចូលរួមប្រកួតប្រជែង។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានរៀបចំការប្រកួតប្រជែងជំនាញចិន Industrial Automation ដោយមានបេក្ខជន ០៧ក្រុម តំណាងឱ្យ៦ប្រទេស (កម្ពុជា ថៃ ម៉ាឡេស៊ី ស៊ីមបាវ៉ ដ្ឍ អេស្ប៉ាញ និងអាឡឺម៉ង់) ក្នុងនោះបេក្ខជនតំណាងឱ្យប្រទេសកម្ពុជាទទួលបានមេដាយមាស។ ▪ បានរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ជាតិលើកទី៥ ដែលមានបេក្ខជន៤៥នាក់ មកពី១២គ្រឹះស្ថានTVET ចូលរួម។ ▪ បានបញ្ជូនបេក្ខជន១៣នាក់ ទៅចូលរួមប្រកួតប្រជែងជំនាញថ្នាក់អាស៊ានលើកទី៤ នៅប្រទេសម៉ាឡេស៊ី លើ៤មុខជំនាញ ដោយទទួលបានលទ្ធផលដូចខាងក្រោម÷ - ទទួលបានមេដាយសំរិទ្ធចំនួន២លើមុខជំនាញ Industrial Automation ។ - ទទួលបានវិញ្ញាបនបត្រល្អប្រសើរចំនួន២លើមុខជំនាញ Restaurant Service ។ - ទទួលបានវិញ្ញាបនបត្រ The Best Nation ចំនួន១ និងវិញ្ញាបនបត្រល្អប្រសើរចំនួន ១លើជំនាញតបណ្តាញអគ្គិសនី។	
- ពិនិត្យលទ្ធភាពវិនិយោគលើវិទ្យាស្ថានស្រាវជ្រាវរដ្ឋ ដោយផ្តោតទាំងស្រុងទៅលើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពិសេស ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងវិស័យអាទិភាពនីមួយៗ ដោយជ្រើសរើស អ្នកវិទ្យាសាស្ត្រ និងវិស្វករ មានសមត្ថភាពជាមួយនឹងសម្ភារៈបរិក្ខារមន្ទីរពិសោធន៍សមស្រប	មធ្យមទៅវែង	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ ▪ បានរៀបចំរួចព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ▪ បានចូលរួមរៀបចំ និងផ្តល់យោបល់លើអនុក្រឹត្យស្តីពីការបង្កើត គ.ស.រ ពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់គ្រឹះស្ថានចំនួន ១០/ ៣០។ ▪ បានចូលរួមជំរុញ គ.ស.រ. ឱ្យរៀបចំអនុក្រឹត្យថ្មីស្តីពីការបង្កើត	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		គ.ស.រ.។ ▪ បានពិនិត្យ និងស្រាវជ្រាវច្បាប់ចាស់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងសហគ្រាសសាធារណៈ។ - ក្រសួងអប់រំ យុវជន និងកីឬ - ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	
- ជំរុញការសិក្សាអប់រំលើជំនាញវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (STEM) ពីកម្រិតបឋមសិក្សា រហូតដល់ក្រោយមធ្យមសិក្សា ពិសេសផ្តោតលើសិស្សក្មេងៗ ជាមួយនឹងការកែទម្រង់កម្មវិធីសិក្សា ដោយការធ្វើស្តង់ដានីយកម្មនៃកម្មវិធីសិក្សាទាំងនោះពីកម្រិតបឋមសិក្សាឡើងទៅ	២០១៥ ទៅមធ្យម	- ក្រសួងអប់រំ យុវជន និងកីឬ បាន÷ ▪ លើកកម្ពស់ការបណ្តុះបណ្តាលជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)។ ▪ ពង្រឹង និងពង្រីកការអប់រំបច្ចេកទេសនៅថ្នាក់មធ្យមសិក្សា។	
- ពិនិត្យឡើងវិញ និងប្រមូលផ្តុំសក្តានុពលធនធានធម្មជាតិ ដែលជំរុញឱ្យមានការវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់។	មធ្យមទៅវែង	- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានរៀបចំលើកគម្រោងថវិកាតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់អនុវត្តផែនការសកម្មភាពឆ្នាំ ២០១៧ និងឆ្នាំបន្តបន្ទាប់ ដើម្បីសិក្សាពីសក្តានុពលធនធានធម្មជាតិក្នុងស្រុកសម្រាប់ទាក់ទាញវិនិយោគលើវិស័យឧស្សាហកម្មធុនធ្ងន់។	
ค- ការកសាងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ឧស្សាហកម្ម			
- បង្កើតយន្តការសម្របសម្រួលការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ផ្លូវថ្នល់ ផ្លូវរថភ្លើង ផ្លូវអាកាស និងកំពង់ផែ) ដោយផ្សារភ្ជាប់ទៅនឹងតំបន់គោលដៅនៃការអភិវឌ្ឍឧស្សាហកម្ម	២០១៥ ទៅមធ្យម	- ក្រសួងសាធារណការនិងដឹកជញ្ជូន÷ ▪ អង្គភាពជំនាញបាននិងកំពុងបន្តរៀបចំច្បាប់ពាក់ព័ន្ធទៅនឹងការងារកំពង់ផែ ដើម្បីជំរុញអនុវត្តជាបន្តបន្ទាប់គោលនយោបាយជាតិស្តីពីកំពង់ផែ និងប្រព័ន្ធគ្រប់គ្រងកំពង់ផែ សំដៅអភិវឌ្ឍកំពង់	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ផ្លែប្រកបដោយចីរភាព មានទំនុកចិត្តពីអ្នកប្រើប្រាស់ និងអាចចូលរួម ប្រកួតប្រជែងជាមួយកំពង់ផែនានានៅក្នុងតំបន់ដែលអាចបម្រើឱ្យប្រព័ន្ធភស្តុភារកម្មមួយដ៏ប្រសិទ្ធភាព និងភាពប្រកួតប្រជែងខ្ពស់។ ▪ ក្នុងការអភិវឌ្ឍ និងកែលម្អកំពង់ផែបម្រើឱ្យការដឹកជញ្ជូនជាលក្ខណៈទ្វេភាគី តាមរយៈគោលនយោបាយជាតិស្តីពីកំពង់ផែ ក្រសួងបាននិងកំពុងកែលម្អកំពង់ផែសំខាន់ៗមួយចំនួន និងកំពុងបន្តរៀបចំសេចក្តីព្រាងប្រកាសស្តីពីសន្តិសុខសហនីយភណ្ឌ ផ្តោតលើសន្តិសុខជុំវិញផែ ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ។ ▪ បាននិងកំពុងរៀបចំកែសម្រួលរចនាសម្ព័ន្ធថ្មីរបស់ក្រសួង ដែលក្នុងនោះក៏នឹងបង្កើតអគ្គនាយកដ្ឋានផ្លូវទឹក និងកំពង់ផែផងដែរ ដើម្បីពង្រឹងការគ្រប់គ្រងកំពង់ផែ។ ▪ បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស លើគម្រោងសាងសង់កំណាត់ផ្លូវជាតិលេខ៥ ក្រាលកៅស៊ូ AC ប្រវែង ១៣៣ គ.ម (ឆ្លាមួម ខេត្តពោធិ៍សាត់-បាត់ដំបង និងសីរីសោភ័ណ-ប៉ោយប៉ែត) កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ហើយគ្រោងនឹងចាប់ផ្តើម អនុវត្តសាងសង់នៅឆ្នាំ២០១៧។ ▪ បានបញ្ចប់ការសិក្សាបច្ចេកទេស លើគម្រោងផ្លូវលឿនលឿន (ភ្នំពេញ-បាវិត) និងបន្តចុះប្រជុំពិគ្រោះយោបល់សាធារណៈ និងការងារផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ នៅតាមភូមិឃុំនីមួយៗ ក្នុងខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តស្វាយរៀង កាលពីថ្ងៃទី ១៧-២២ ខែតុលា ឆ្នាំ២០១៦ ហើយគ្រោងបញ្ចប់របាយការណ៍បឋម នៅខែមករា ឆ្នាំ២០១៧។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ/ការអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
- ពិនិត្យតម្រង់ការផ្គត់ផ្គង់ថាមពលទៅកាន់តំបន់ផលិតកម្មសំខាន់ៗ ដោយធានាឱ្យបានការផ្គត់ផ្គង់ចរន្តអគ្គិសនីស្របតាមតម្រូវការ និងមានស្ថិរភាពបំផុត ដែលអនុញ្ញាតឱ្យរោងចក្រ អាចគ្រោងផលិតកម្មខ្លួនប្រកបដោយប្រសិទ្ធភាព	២០១៥ ទៅមធ្យម	- ក្រសួងរ៉ែនិងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា÷ ▪ ផ្នែកផលិតកម្ម÷ - គម្រោងស្ថានីយវារីអគ្គិសនីសេសានក្រោម២ អានុភាព ៤០០ MW កំពុងសាងសង់បាន ៨០% ដែលនឹងដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ២០១៨ ដោយឡែកម៉ាស៊ីនទី១ អានុភាព៥០ MW គ្រោងដំណើរការនៅចុងឆ្នាំ២០១៧ ។ - ស្ថានីយអគ្គិសនីដុតធ្យូងថ្ម អានុភាព១៣៥ MW របស់ក្រុមហ៊ុន CIIDG នៅខេត្តព្រះសីហនុ កំពុងដំណើរការសាកល្បង។ - គម្រោងវិនិយោគបន្ថែមម៉ាស៊ីនផលិតអគ្គិសនីដុតធ្យូងថ្ម អានុភាព ១៣៥MW កំពុងសុំរាជរដ្ឋាភិបាលចុះហត្ថលេខាលើកិច្ចព្រមព្រៀង IA និង PPA ហើយគ្រោងនឹងដាក់ឱ្យដំណើរការនៅឆ្នាំ២០១៩។ - ស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យអានុភាព១0MW នៅក្រុងបាវិត ខេត្តស្វាយរៀងគ្រោងនឹងដាក់ឱ្យដំណើរការនៅត្រីមាសទី២ ឆ្នាំ២០១៧។ ▪ ផ្នែកខ្សែបញ្ជូនជាតិ÷ - ទី១ ចំពោះផែនការត្រីមាសទី១ឆ្នាំ២០១៧ គ្រោងធ្វើតេស្ត និងដាក់ឱ្យដំណើរការខ្សែបញ្ជូន១១5kV តភ្ជាប់ពីភ្នំពេញ-កំពង់សីហ-បាវិតនៅខែកុម្ភៈ ឆ្នាំ២០១៧។ - ទី២ ខ្សែបញ្ជូន២៣0kV តភ្ជាប់ពីខេត្តកំពង់ចាម-ក្រចេះ-ស្ទឹងត្រែងនៅឆ្នាំ២០១៧, វឌ្ឍនភាពការងារគឺ (១) ខ្សែបញ្ជូនកំពង់ចាម ក្រុមហ៊ុនអគ្គិសនីកម្ពុជាបានជំរុញឱ្យក្រុមហ៊ុន	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ពន្លឿនការសាងសង់ឱ្យទាន់តាមកាលកំណត់, និង (២) ខ្សែបញ្ជូនក្រចេះ-ស្ទឹងត្រែង ជារួមសម្រេចបាន ៩០%។ - ទី៣ ចំពោះផែនការឆ្នាំ២០១៧ ដាក់ឱ្យដំណើរការខ្សែបញ្ជូន ១១៥kV ឥភ្ជាប់ពីព្រះវិហារ-ឡាវ វឌ្ឍនភាពគឺបានធ្វើគ្រឹះបង្គោល Section M (ពីព្រំដែនឡាវមកអនុស្ថានីយអគ្គិសនីជ័យសែន) 48/158 គ្រឹះសម្រេចបាន៣០%។ - ទី៤ ចំពោះផែនការឆ្នាំ២០១៧ កំពុងរៀបចំសាងសង់ដាក់ឱ្យដំណើរការខ្សែបញ្ជូន១១៥kV ឥភ្ជាប់ពីបាត់ដំបង-ប៉ៃលិន។ - ទី៥ ចំពោះផែនការឆ្នាំ២០១៨ កំពុងវាយតម្លៃទីប្រឹក្សាគម្រោងនិងឯកសារដេញថ្លៃដាក់ឱ្យដំណើរការខ្សែបញ្ជូន (១) ២៣០kV អនុស្ថានីយកោះកុង-ក្រុងកោះកុង, (២) ២៣០ kV បទុមសាគរ-ចំការលួង និង (៣) ១១៥kV កំពង់ចាម-ព្រៃកប្រសព្ធ។ - ទី៦ ចំពោះផែនការឆ្នាំ២០១៨ ដាក់ឱ្យដំណើរការខ្សែបញ្ជូន ១១៥kV ឥភ្ជាប់ពីព្រះវិហារ-កំពង់ធំ វឌ្ឍនភាពការងារគឺបានធ្វើគ្រឹះបង្គោល Section N (ពីអនុស្ថានីយអគ្គិសនីជ័យសែនមកអនុស្ថានីយអគ្គិសនីកំពង់ធំ) 147/410 គ្រឹះសម្រេចបាន ៣៦%។ - ទី៧ ចំពោះផែនការឆ្នាំ២០១៨ ដាក់ឱ្យដំណើរការខ្សែបញ្ជូន ១១៥kV ឥភ្ជាប់ពីក្រុងព្រះសីហនុ-ភ្នំ និង១១៥kVឥភ្ជាប់កំពង់សិង្ហ-ស្វាយអន្ទរ វឌ្ឍនភាពការងារគឺ បានពិនិត្យគន្លងខ្សែបញ្ជូន និងទីតាំងបង្គោលជាក់ស្តែងនៃខ្សែបញ្ជូន	

ទិដ្ឋានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		និងទីតាំងសាងសង់អនុស្ថានីយ។ - ទី៨ ចំពោះផែនការឆ្នាំ២០១៨ ដាក់ឱ្យដំណើរការខ្សែបញ្ជូន ២៣០kV តភ្ជាប់ពីខេត្តបាត់ដំបង-សៀមរាប-កំពង់ធំ-កំពង់ចាម និងបណ្តាញជាកងបន្ថែមជុំវិញរាជធានីភ្នំពេញ (ពីអនុ-ស្ថានីយទី៦, អនុស្ថានីយខាងលិចភ្នំពេញ (EPP), អនុ-ស្ថានីយទី៧) - ទី៩ ចំពោះផែនការឆ្នាំ២០១៨ កំពុងសិក្សាដាក់ឱ្យដំណើរការ ខ្សែបញ្ជូន១១៥kV តភ្ជាប់ពីក្រឡាញ់-ឧត្តរមានជ័យ។ - ទី១០ ចំពោះផែនការ២០១៩ កំពុងសាងសង់ដាក់ឱ្យដំណើរ-ការខ្សែបញ្ជូន២៣០kV និង៥០០kV តភ្ជាប់ពីរាជធានី-ភ្នំពេញ-ខេត្តព្រះសីហនុ តាមផ្លូវជាតិលេខ៤។ - ទី១១ បានទទួលអនុម័តលើថវិកាកម្ម និងកំពុងសិក្សាលម្អិត លើលក្ខណៈបច្ចេកទេស ចំពោះផែនការឆ្នាំ២០១៩ ដាក់ឱ្យ-ដំណើរការខ្សែបញ្ជូន២៣០kV ស្ទឹងត្រែង-រតនគិរី, ២៣០ kV ក្រចេះ-មណ្ឌលគិរី និង២៣០kV ពីអនុស្ថានីយតាតៃ-ភ្នំពេញ។ - រដ្ឋបាលខេត្តស្វាយរៀង ÷ ▪ បាននិងកំពុងសហការជំរុញការអនុវត្តគម្រោងថ្នាក់ជាតិ ខ្សែបញ្ជូន-អគ្គិ-សនីតង់ស្យុងខ្ពស់១១៥គីឡូវ៉ុល ឱ្យសម្រេចបានទាន់ពេ-លវេលាតាមផែនការដែលបានកំណត់។ ▪ បាននិងកំពុងរៀបចំផែនការវិនិយោគ ផែនការសាងសង់ និង-ពង្រីកបណ្តាញអគ្គិសនី ដែលអាចមានលទ្ធភាពផលិត និងផ្គត់ផ្គង់	

ទិដ្ឋានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ថាមពលអគ្គិសនី បានកាន់តែទូលំទូលាយ។ ▪ បានចូលរួមសហការគម្រោងពង្រីកបណ្តាញចែកចាយសម្រាប់ច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងជាមួយ JICA អគ្គិសនីកម្ពុជា និងអាជ្ញាធរដែនដីស្រុក ស្វាយទាប និងក្រុងបាវិត។ ដោយប្រើគម្រោងបណ្តាញចែកចាយ២២KV តាមផ្លូវជាតិលេខ១ ប្រវែង ៣៧,៥០គ.ម. ដែលចេញពីអនុស្ថានីយច្រកម្ទេស ឆ្ពោះទៅទីតាំងចំនួន២ គឺទីតាំងទី១ ចេញទៅអង្គភាពអគ្គិសនីខេត្តស្វាយរៀង ប្រវែង២៦,៥គ.ម. និងទី២ ចេញទៅតំបន់សេដ្ឋកិច្ចពិសេស មេនហាធេន (MANHATIAN) មានប្រវែង ១១គ.ម. ប្រើបង្គោលសរុប ៥៩០បង្គោល។ ▪ បានចូលរួមពិគ្រោះយោបល់លើការកែសម្រួលតម្លៃអគ្គិសនីនៅស្រុកស្វាយជ្រំ ចំនួន៣តំបន់ដែលទទួលប្រភពអគ្គិសនីពីប្រទេសវៀតណាមក្នុងតម្លៃ៩៥០៛/KWH។	
- អនុវត្តគម្រោងកសាងស្ថានីយផលិតអគ្គិសនីដែលបានគ្រោង និងកំពុងបន្តអនុវត្តឱ្យទាន់ពេលវេលា ដើម្បីបំពេញកង្វះខាតថាមពលអគ្គិសនីនៅឆ្នាំ២០២០ រួមទាំងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងគុណភាពនៃការបញ្ជូនថាមពល	មធ្យមទៅវែង	- ក្រសួងរ៉ែនិងថាមពល - អាជ្ញាធរអគ្គិសនីកម្ពុជា - ក្រុមហ៊ុនអគ្គិសនីកម្ពុជា	
- ពិនិត្យឡើងវិញនូវការប៉ាន់ស្មានពីតម្រូវការអគ្គិសនីរយៈពេលវែង និងផែនការអភិវឌ្ឍ វិស័យថាមពល ធៀបនឹងចក្ខុវិស័យថ្មី	២០១៥	- ក្រសួងរ៉ែនិងថាមពល, អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា÷ ▪ ចំពោះផែនការឆ្នាំ២០១៥ ដែលត្រូវបញ្ចប់ការសិក្សាពិនិត្យ និងកែ	

ទិសដៅការគោលនយោបាយផែនការ/ សកម្មភាព	រយៈពេល/ ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្ម រួមទាំងពិនិត្យឡើងវិញនូវជម្រើសក្នុងការផ្គត់ផ្គង់ថាមពល ដែលមានសមត្ថភាពគ្រប់គ្រាន់ជាពិសេស សម្រាប់ផ្គត់ផ្គង់តំបន់ឧស្សាហកម្ម យុទ្ធសាស្ត្រសំខាន់ៗ		សម្រួលផែនការមេវិស័យថាមពល ដែលមានការព្យាករតម្រូវការពីឆ្នាំ២០១៥-២០៣០ បច្ចុប្បន្ន EDC បានបញ្ចប់ការសិក្សា និងរៀបចំរបាយការណ៍ ដើម្បីអនុម័តប្រើប្រាស់ជាផ្លូវការ និងបានធ្វើបច្ចុប្បន្នកម្មផែនការមេអភិវឌ្ឍន៍វិស័យអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦។ ▪ តាមផែនការវិនិយោគផ្នែកថាមពលរហូតដល់ឆ្នាំ២០២០ EDC មានលទ្ធភាពផ្គត់ផ្គង់តាមតម្រូវការ។ ▪ ចំពោះផែនការឆ្នាំ២០១៧ ដែលត្រូវសិក្សាសមិទ្ធិលទ្ធភាពស្ថានីយអគ្គិសនីដុតធ្យូងថ្ម ឬឧស្ម័នប្រមាណ២០០ MW នៅក្បែររាជធានីភ្នំពេញដើម្បីលើកកម្ពស់សមត្ថភាពផ្គត់ផ្គង់ និងស្ថិរភាពប្រព័ន្ធបណ្តាញជាតិ បច្ចុប្បន្នទីប្រឹក្សាគម្រោងរបស់ក្រុមហ៊ុនធ្យូងថ្ម ជំហានទី២ (CIIDG) កំពុងសិក្សាពីសមិទ្ធលទ្ធភាព។	
- បង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបវន្ត និងកែលម្អសេវា និងមធ្យោបាយដឹកជញ្ជូនសម្រាប់សម្រួល និងជួយគាំទ្រប្រតិបត្តិការអាជីវកម្ម	មធ្យមទៅវែង	- ក្រសួងសាធារណការនិងដឹកជញ្ជូន÷ ▪ ចំពោះគម្រោងសាងសង់ចំណតផែកុងតឺន័រថ្មី គឺបានកំពុងដំណើរការស្នើសុំប្រាក់កម្ចីពី ODA ជប៉ុន។ ▪ ចំពោះការពង្រីងសមត្ថភាពទីលានកុងតឺន័រ៤០០ម៉ែត្រ ដោយបំពាក់បន្ថែមនូវគ្រឿងចក្រលើកដាក់កុងតឺន័រ QC ២គ្រឿង និង RTG: ៩គ្រឿង នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ, បច្ចុប្បន្នកំពុងដំណើរការសាងសង់ និងលទ្ធកម្មនៅឡើយ។ ▪ ចំពោះការពង្រីកសមត្ថភាពទីលានរបស់ចំណតផែកុងតឺន័រថ្មី (ជំហានទី២) របស់កំពង់ផែស្វយ័តភ្នំពេញ, បច្ចុប្បន្ន បានធ្វើផ្លូវត	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ ឥណទានសម្បទានកម្រិតខ្ពស់ កាន់តែខ្សត់ក្នុងបរិការណ៍ដែលកម្ពុជាកំពុងអភិវឌ្ឍខ្លួនក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

ទិដ្ឋានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ភ្ជាប់ពីទីលានបច្ចុប្បន្នរបស់ចំណតផែថ្មី ភ្ជាប់ទៅទីលានគ្រោងផ្តើមសម្រាប់ជំហានទី២រួចហើយ និងសម្រាប់ផែនការឆ្នាំបន្ទាប់នឹងពង្រីកទីលានដាក់កុងតឺន័រ។ ▪ ក្នុងការពង្រឹងការថែទាំ និងការការពារផ្លូវទឹកសម្រាប់នាវាចរណ៍ រួមទាំងការបូមស្តារផ្លូវទឹក និងបំពាក់ពោងសញ្ញានាវាចរណ៍ ក្រសួងបានកំពុងបន្តអនុវត្តការបូមស្តារនៅទីតាំងសំខាន់ៗផ្សេងទៀត។ ▪ អង្គភាពជំនាញបាននិងកំពុងស្នើសុំទីតាំងពីក្រសួង ដើម្បីរៀបចំបង្កើតអ៊ូរសម្រាប់ត្រួតពិនិត្យ និងជួសជុលនាវា ដើម្បីបម្រើឱ្យវិស័យដឹកជញ្ជូនតាមផ្លូវទឹក។ - រដ្ឋបាលខេត្តស្វាយរៀង បាន÷ ▪ សហការរៀបចំគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ក្រុងបាវិត ដូចជាសាងសង់ផ្លូវក្រុង ប្រព័ន្ធលូ អាងចម្រោះកាកសំណល់ និងទីលានកែច្នៃសំរាម សម្រាប់គម្រោងរបៀងសេដ្ឋកិច្ចភាគខាងត្បូង (SECTDP)។ ▪ អនុវត្តគម្រោងស្ថាបនាលូមេរ៉ដោះទឹកនៅក្រុងស្វាយរៀង ដែលនឹងបញ្ចប់នៅឆ្នាំ២០១៦ និងបានរៀបចំគម្រោងអាងចម្រោះទឹកកាកសំណល់សម្រាប់អនុវត្តឆ្នាំ២០១៧។ ▪ បានចូលរួមសិក្សាសមិទ្ធិលទ្ធភាពជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងដៃគូអភិវឌ្ឍន៍លើគម្រោងពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត នៅក្នុងតំបន់ទីប្រជុំជន តំបន់ជាយក្រុង តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មក្នុង។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន÷ ▪ ធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់រយៈពេលវែង និងបានចូលរួមក្នុងដំណើការរៀបចំ និងបង្កើតមូលនិធិវិនិយោគអាស៊ាន (ASEAN Investment Fund-AIF) និងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (Asian Infrastructure Investment Bank-AIIB) ។ ▪ បានអនុម័តសេចក្ដីព្រាងឯកសារគោលនយោបាយស្ដីពីការអភិវឌ្ឍយន្ដការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈដែលជាមូលដ្ឋានក្នុងការកៀរគរទុនវិនិយោគពីវិស័យឯកជនសម្រាប់រួមចំណែកវិនិយោគហេដ្ឋារចនាសម្ព័ន្ធរូបវន្ដសាធារណៈ។	
- ពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានី ទីប្រជុំជន តំបន់ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស តាមរយៈការពង្រឹងសមត្ថភាព អង្គភាពរដ្ឋាភិបាលទឹកសាធារណៈ និងឯកជន ស្របតាមបទដ្ឋានបច្ចេកទេសនៃការផ្គត់ផ្គង់សេវាទឹកស្អាត និងអនុលោមតាមស្តង់ដាទឹក បរិភោគជាតិ	២០១៥ ទៅមធ្យម	- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម÷ ▪ បាននិងកំពុងរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការផ្គត់ផ្គង់ទឹកស្អាតដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន។ ▪ បានផ្គត់ផ្គង់ទឹកស្អាតសាធារណៈ និងឯកជន ក្នុងឆ្នាំ២០១៦ បានចំនួន២៨១ ៩២៥ ៦៥៦ម៉ែត្រគូប មានកំណើនស្មើនឹង២៨% បើប្រៀបធៀបឆ្នាំ២០១៥។	
- បន្ដពង្រីក និងថែទាំកំណាត់ផ្លូវជាតិសំខាន់ៗដែលជាច្រកសម្រាប់ការដឹកជញ្ជូនទំនិញ ជាពិសេស ផ្លូវជាតិឱ្យក្លាយជាផ្លូវថ្នល់ធំទូលាយ ដើម្បីធ្វើឱ្យប្រសើរនូវការតភ្ជាប់ទៅកាន់	មធ្យមទៅវែង	- ក្រសួងសាធារណការ និងដឹកជញ្ជូន÷ ▪ ចំពោះផ្លូវជាតិលេខ៥១(ឧត្ដុង្គ-ថ្នល់ទទឹង) ក្រសួងបានធ្វើការសិក្សា ចរចា និងចុះកិច្ចសន្យាគម្រោងរួចហើយ និងបានចាប់ផ្ដើមការដ្ឋានសាងសង់	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន÷ ▪ សមត្ថភាពធនធានមនុស្ស ទាក់ទងស្ថាប៉ន់ពាក់ព័ន្ធនៅតាមក្រសួង។ ▪ ផលប៉ះពាល់មានទំហំធំ ហើយវេ

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពសង្ខេបអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ប្រទេសថៃ និងវៀតណាម ព្រមទាំងច្រករបៀងភ្នំពេញ-សៀមរាប និងភ្នំពេញ-ក្រុងព្រះសីហនុ ទន្ទឹមនឹងការពិនិត្យសម្រាប់រយៈពេលវែងនូវលទ្ធភាពកសាងផ្លូវបាយវ៉ែចំពោះផ្លូវជាតិសំខាន់ៗ សម្រាប់ពង្រឹងសមត្ថភាពប្រព័ន្ធភស្តុភារកម្មរវាងកម្ពុជា និងប្រទេសដទៃទៀត ជាអាទិ៍ ប្រទេសថៃ និងវៀតណាម		▪ ចំពោះផ្លូវជាតិលេខ១១(អ្នកលឿង-ថ្នល់ទទឹង) ក្រសួងបានរៀបចំ គម្រោងស្នើសុំទៅម្ចាស់ជំនួយ និងចាប់ផ្តើមអនុវត្ត គម្រោងនាពេលខាងមុខ ▪ ចំពោះផ្លូវជាតិលេខ៥ (ព្រែកក្តាម-សេរីសោភ័ណ-ប៉ោយប៉ែត) ➢ កំណាត់ផ្លូវជាតិលេខ៥ ប្រវែង៨៤ ៧៤គ.ម. (បាត់ដំបង-សេរីសោភ័ណ)÷ ក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេសកំពុងបន្តរៀបចំឯកសារតាមនីតិវិធី ដើម្បីជ្រើសរើសក្រុមហ៊ុនសាងសង់កំពុងបន្តរៀបចំឯកសារតាមនីតិវិធី ដើម្បីជ្រើសរើសក្រុមហ៊ុនសាងសង់ ហើយគ្រោងនឹងចាប់ផ្តើមសាងសង់នៅខែមករា ឆ្នាំ២០១៧ វិញ ➢ កំណាត់ផ្លូវជាតិលេខ៥ ប្រវែង១៣៥ ៤គ.ម. (ព្រែកក្តាម-ឆ្លាមួម ខេត្តពោធិ៍សាត់)÷ បច្ចុប្បន្ន ក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស បានបញ្ចប់សិក្សារបាយការណ៍លម្អិត និងកំពុងរៀបចំនីតិវិធីលើឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនសាងសង់ ហើយគ្រោងនឹងចាប់ផ្តើមអនុវត្តការដេញថ្លៃសាងសង់នៅចុងឆ្នាំ២០១៦។ ➢ កំណាត់ផ្លូវជាតិលេខ៥ ប្រវែង១៣៣គ.ម. (ឆ្លាមួម ខេត្តពោធិ៍សាត់-បាត់ដំបង និងសេរីសោភ័ណ-ប៉ោយប៉ែត)÷ បច្ចុប្បន្នបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស ហើយគ្រោងនឹងចាប់ផ្តើមអនុវត្តសាងសង់នៅឆ្នាំ២០១៧។ ▪ ចំពោះផ្លូវជាតិលេខ២(ក្រុងតាខ្មៅ-ក្រុងជួនកែវ) និងផ្លូវជាតិ	រងផលប៉ះពាល់ ភាគច្រើនជាដីឯកជនស្របច្បាប់ ដូចនេះតម្រូវការវិការដោះស្រាយផលប៉ះពាល់ក៏មានទំហំធំខ្លាំងផងដែរ។

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ/ទិសដៅ និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		លេខ២២ (អូរចំបក់-អង្គតាសោម) ក្រសួងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាន បច្ចុប្បន្ន ក្រសួងកំពុងដំណើរការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស។ ▪ ចំពោះគម្រោងលើកកម្រិតផ្លូវជាតិលេខ៣(ចោមចៅ-វាលវេញ) ប្រវែង២០១,៧គ.ម. ក្រាលកៅស៊ូ AC ត្រូវបានបញ្ចប់ការសិក្សារបាយការណ៍បឋម ដោយធនាគារ Exim កូរ៉ែ។ ▪ កំណាត់ផ្លូវជាតិលេខ៦ ប្រវែង២៤៧,៧០គ.ម. (ថ្នល់កែង-អង្ក្រង ខេត្តសៀមរាប) សម្រេចបាន ៩៨ ១២%។ ▪ គម្រោងកែលម្អផ្លូវជាតិលេខ១ ដំណាក់កាលទី៤ ប្រវែង៤គ.ម. (គល់ស្ពានព្រះមុនីវង្ស-វត្តក្តីតាកុយ) សម្រេចបាន៧០,១០%។ ▪ គម្រោងស្តារឡើងវិញផ្លូវជាតិលេខ២១ ប្រវែង៥៥គ.ម (រង្វង់មូលតាខ្មៅ-ជ្រៃធំ) សម្រេចបាន៣៨%។ ▪ ផ្លូវជាតិលេខ១៣ ប្រវែង៦២,៤០គ.ម. (កំចាយមារ ខេត្តព្រៃវែង-ប្រសូត ខេត្តស្វាយរៀង) សម្រេចបាន៣៨,៣០% និងផ្លូវខេត្តលេខ៣១៤D ប្រវែង២៥,៥០គ.ម. (ប្រសូត-ព្រៃវល្លិ ព្រំដែនកម្ពុជា-វៀតណាម) សម្រេចបាន៤៥%។ ▪ ផ្លូវជាតិលេខ៤៤ ប្រវែង១៣៩,១៤គ.ម. (ច្បារមន-ឌ៉ាល់-ឧត្តុង្គ) បានធ្វើពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី២ ខែសីហា ឆ្នាំ២០១៦។ ▪ កំណាត់ផ្លូវជាតិលេខ៧៦បន្ត ប្រវែង១៧១,៧៨គ.ម. (សែនមនោរម្យ-កោះញ្ញែក ខេត្តមណ្ឌលគីរី ដល់លំផាត់-តាអង់ ខេត្តរតនគីរី) បានធ្វើពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី	

ទិដ្ឋានការគោលនយោបាយវិនិយោគ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពខ្សត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		២១ ខែវិច្ឆិកា ឆ្នាំ២០១៦។ ▪ ផ្លូវជាតិលេខ៥៦ កំណាត់ទី១ ក្រាលកៅស៊ូ DBST ប្រវែង២៩គ.ម. (សីរីសោភ័ណ-ស្វាយចេក) និងកំណាត់ទី២ ប្រវែង៨៤,៤៥គ.ម. (ស្វាយចេក-សំរោង) និងផ្លូវចូលប្រាសាទបន្ទាយឆ្នារ ប្រវែង១០,៧៥គ.ម. បានធ្វើពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦។ ▪ ផ្លូវជាតិលេខ៥៥ ប្រវែង១៨២,១៦គ.ម. (ពោធិ៍សាត់-វ៉ាលវែង-ថ្មដា ព្រំប្រទល់កម្ពុជា-ថៃ) សម្រេចបាន៦៨,៦១%។ ▪ ផ្លូវជាតិលេខ៥៨ ប្រវែង១៧៤គ.ម (ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ-ត្រង់ផ្ទុង ខេត្តឧត្តរមានជ័យ) សម្រេចបាន៤៨,៩៧%។ ▪ ផ្លូវខេត្តលេខ១៥៧ក ប្រវែង៥១,៧៩គ.ម. (ឃុំត្រែង ស្រុករតនមណ្ឌល-ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង) សម្រេចបាន ៥២,៣៥%។ ▪ គម្រោងសាងសង់ស្ពានជ្រៃធំ ប្រវែង៤២៧,៨ម៉ែត្រ និងផ្លូវតភ្ជាប់ស្ពាន ប្រវែង២,៦៦គ.ម. (ស្រុកកោះធំ ខេត្តកណ្តាល-ឡុងបិញ ខេត្តអាងយ៉ាង) សម្រេចបាន៨៧,២៦%។ ▪ ស្ពានកោះធំ ប្រវែង៤១៥ម៉ែត្រ សម្រេចបាន១០០%។ ▪ ចំពោះផ្លូវលឿនលឿន ភ្នំពេញ-បាវិត ក្រសួងបានធ្វើពិធីចុះហត្ថលេខារវាងក្រសួងសាធារណការនិងដឹកជញ្ជូន ជាមួយ JICA កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤។ ក្រុមការងារផ្លូវលឿនលឿនរបស់ក្រសួង បានបញ្ចប់ការសិក្សាបច្ចេកទេស និងបន្តចុះប្រជុំពិគ្រោះយោបល់សាធារណៈ និងការងារផលប៉ះពាល់ជាមួយ	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ប្រជាពលរដ្ឋនៅតាមភូមិឃុំនីមួយៗក្នុងខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តស្វាយរៀង កាលពីថ្ងៃទី១៧ដល់២២ ខែតុលា ឆ្នាំ២០១៦ ហើយគ្រោងបញ្ចប់ការសិក្សារបាយការណ៍បឋមនៅខែមករា ឆ្នាំ២០១៧។ ▪ ចំពោះផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ កំពុងចរចាលើកិច្ចសន្យាសម្បទានដែលនឹងវិនិយោគដោយក្រុមហ៊ុនមកពីសាធារណរដ្ឋប្រជាមានិតចិន ហើយគ្រោងចាប់ផ្តើមដំណើរការគម្រោងនៅចុងឆ្នាំ២០១៧។ - រដ្ឋបាលខេត្តស្វាយរៀង បាន÷ ▪ និងកំពុងសហការសិក្សាផ្លូវវាងសម្រាប់រថយន្តដឹកជញ្ជូនធុនធ្ងន់នៅក្រុងបាវិត និងសិក្សាផែនការអភិវឌ្ឍន៍ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត។ ▪ និងកំពុងអនុវត្តគម្រោងជួសជុលផ្លូវជាតិលេខ១៣ ពីកំចាយមារ ខេត្តព្រៃវែង ទៅក្រុងស្វាយរៀង និងផ្លូវខេត្តលេខ៣១៤D ពីប្រសូត ទៅព្រៃវល្លិ ព្រំដែនកម្ពុជា-វៀតណាម។ ▪ ឥឡូវនេះ ផ្លូវជាតិលេខ១ និងផ្លូវជាតិលេខ៨ ប្រវែង៦២គ.ម. និងផ្លូវជាតិលេខ១៨ ពីផ្លូវជាតិលេខ១ ត្រង់ចំណុចផ្សារប្រសូត ស្រុកស្វាយទាប ទៅច្រកទ្វារអន្តរជាតិព្រៃវល្លិ ព្រំដែនកម្ពុជា-វៀតណាម ប្រវែង២៦គ.ម.។ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ÷ ▪ បានអនុវត្តឥណទានថវិការដ្ឋសម្រាប់ការងារថែទាំកំណាត់ផ្លូវ	

ទិដ្ឋានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ជាតិសំខាន់ៗ។ ▪ បានចរចាសេចក្តីព្រាងកិច្ចសន្យាសម្បទានគម្រោងផ្លូវលឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន ជាមួយសាជីវកម្មផ្លូវស្ពានចិន។ ▪ កំពុងអនុវត្តគម្រោងពង្រីកផ្លូវជាតិលេខ១, ៥, ៦, និងលេខ៧ ឱ្យទៅជា៤គន្លង(តាមតំបន់) ដែលហិរញ្ញប្បទានដោយភាគីចិន ជប៉ុន ADB និង WB។ ▪ បានចូលរួមសិក្សារៀបចំគម្រោងផ្លូវលឿនលឿន ភ្នំពេញ-បាវិត ដែលនឹងហិរញ្ញប្បទានដោយភាគីជប៉ុន។ ▪ បានរៀបចំសេចក្តីព្រាងក្របខ័ណ្ឌការងារដោះស្រាយផលប៉ះពាល់ និងធ្វើលទ្ធកម្មដីសម្រាប់គម្រោងសាងសង់ផ្លូវលឿនលឿន ឆ្លងកាត់ពីភ្នំពេញទៅក្រុងព្រះសីហនុរួចរាល់ ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើការសិក្សាសមិទ្ធិលទ្ធភាពសាងសង់ផ្លូវលឿនលឿន ឆ្លងកាត់ពីរាជធានីភ្នំពេញទៅក្រុងបាវិតដែលផ្តល់ហិរញ្ញប្បទានដោយប្រទេសជប៉ុន។ ▪ បានរៀបចំសេចក្តីព្រាងកិច្ចសន្យាសម្បទានសម្រាប់គម្រោងផ្លូវលឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ ដែលនឹងហិរញ្ញប្បទានដោយភាគីចិន។ ▪ បានបន្តចូលរួមក្នុងកិច្ចដំណើរការពិភាក្សាលើការរៀបចំសេចក្តីព្រាងសម្បទានសម្រាប់គម្រោងសាងសង់ផ្លូវលឿនលឿនឆ្លងកាត់ពីរាជធានីភ្នំពេញទៅក្រុងព្រះសីហនុ ក្នុងក្របខ័ណ្ឌ BOT រវាងភាគីក្រុមហ៊ុនសាងសង់ចិន CRBC និងរាជរដ្ឋាភិបាលកម្ពុជា។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
- ធ្វើឱ្យប្រសើរឡើង និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៃតំបន់សេដ្ឋកិច្ចពិសេស រួមមានប្រព័ន្ធផ្លូវថ្នល់ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ជាពិសេសនៅខេត្តស្វាយរៀង និងកោះកុង ដែលមានច្រកព្រំដែនអន្តរជាតិ និងខេត្តព្រះសីហនុ ដែលមានកំពង់ជែសមុទ្រអន្តរជាតិ	មធ្យមទៅវែង	- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ÷ ▪ បានជំរុញឱ្យអ្នកវិនិយោគតំបន់អភិវឌ្ឍ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់របស់ខ្លួននីមួយៗឱ្យកាន់តែល្អប្រសើរឡើងស្របទៅតាមផែនការមេ និងតម្រូវការជាក់ស្តែងនៃសកម្មភាពវិនិយោគនៅក្នុងតំបន់ទាំងនោះ។ ▪ កំពុងសិក្សាបញ្ចូលបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស។ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាពគម្រោងធ្វើឱ្យប្រសើរឡើងវិញផ្លូវជាតិលេខ ៤៨។ - ក្រសួងសាធារណការនិងដឹកជញ្ជូន - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានជំរុញប្រតិបត្តិការទូរគមនាគមន៍ ពង្រីង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ជាពិសេស នៅខេត្តស្វាយរៀង និងខេត្តព្រះសីហនុ។ - រដ្ឋបាលខេត្តស្វាយរៀង÷	
- បន្តអភិវឌ្ឍផ្លូវដែកនៅកម្ពុជា បន្ទាប់ពីផ្លូវដែកភ្នំពេញ-ខេត្តព្រះសីហនុ បានដាក់ឱ្យដំណើរការ ដើម្បីប្រែក្លាយផ្លូវដែកជាជម្រើសដឹកជញ្ជូនមួយសំខាន់ ដែលចូលរួមចំណែកធ្វើឱ្យថ្លៃដឹក	មធ្យមទៅវែង	- ក្រសួងសាធារណការនិងដឹកជញ្ជូន÷ ▪ ចំពោះគម្រោងខ្សែផ្លូវដែកទិសខាងត្បូង ក្រសួងបានជ្រើសរើសអ្នកម៉ៅការជួសជុល ក្រុមហ៊ុន Italian-Thai Development ចំពោះការងារជួសជុលពង្រីងទៅលើការខូចខាតនៃខ្សែផ្លូវដែក	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
ជញ្ជូនធ្លាក់ចុះ និងមានប្រសិទ្ធភាពជាងមុន		ដែលបានស្ការួច (ទិសខាងត្បូង) សម្រេចបាន៦២,០៧%។ ▪ ចំពោះគម្រោងខ្សែផ្លូវដែកទិសខាងជើង ការងារជួសជុល និងសាងសង់ជាអាទិភាពសម្រាប់ខ្សែផ្លូវដែកនេះ មានដូចតទៅ÷ ➢ ការងារដោះដែករ៉ និងការងារសាងសង់ឡើងវិញ (គ.ម ៣០០+០០០ - គ.ម. ៣១០+០០០) សម្រេចបាន ៥៣%។ ➢ ការងារសាងសង់ផ្លូវដែក(គ.ម. ៣២៨+០០០ - គ.ម ៣៣៨+០០០ ពីមង្គលបុរីទៅសិរីសោភ័ណ) សម្រេចបាន២២,៤៨%។ ➢ ការសាងសង់ថ្មីបន្ត (គ.ម. ៣៧៨+៥០០ - គ.ម ៣៨៥+០៥០ នៅក្រុងប៉ោយប៉ែត) និងផ្លូវរថភ្លើងចៀសក្នុងស្ថានីយប៉ោយប៉ែត បានចាប់ផ្តើមការសាងសង់ និងសម្រេចបាន៤៥,៨៦%។ ➢ ការងារជួសជុលផ្លូវដែក(គ.ម. ៣១០+០០០ - គ.ម. ៣២៨+៥០០) សម្រេចបាន១១,២៦%។ ➢ ការងារជួសជុលពង្រឹងផ្លូវដែក(គ.ម. ៣៣៨+៥០០- គ.ម. ៣៧៨+៥០០) សម្រេចបាន ២១,៧៥%។ ➢ ការងារជួសជុលពង្រឹងស្ពាន(គ.ម. ៣២៨+៥០០- គ.ម. ៣៧៨+៥០០) សម្រេចបាន១៤%។ ➢ ការងារជួសជុលផ្លូវដែក (គ.ម. ២៧៣+២៥០ - គ.ម. ៣០០+០០០) សម្រេចបាន១២,០៨%។ ➢ បំពាក់ប្រព័ន្ធសុវត្ថិភាពផ្លូវឆ្លងកាត់ផ្លូវដែកពាយ័ព្យ (គ.ម.	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		៣៨៤+៥៦៥- ត.ម. ៣៨៤+៩២១) សម្រេចបាន៥%។ ➢ បានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងកិច្ចព្រមព្រៀងបច្ចេកទេស និងនីតិវិធីដឹកជញ្ជូនឆ្លងកាត់ព្រំដែនតាមផ្លូវដែកកម្ពុជា-ថៃ បច្ចុប្បន្ន កំពុងរៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងដឹកជញ្ជូនថៃ។	
- អភិវឌ្ឍបណ្តាញដឹកជញ្ជូនតាមផ្លូវទន្លេ ដែលមានសក្តានុពលក្នុងការកាត់បន្ថយចំណាយភស្តុភារកម្ម ជាពិសេស សម្រាប់ការដឹកជញ្ជូន កសិផល ដោយកសាងកំពង់ផែតូចៗ ដែល អាចឱ្យនាវាដឹកជញ្ជូនចូលផ្ទុក និងផ្ទេរទំនិញនៅតាមដងទន្លេមេគង្គ ស្របគ្នានឹងការសាងសង់កំពង់ផែថ្មីនៅភ្នំពេញ និងខេត្តព្រះសីហនុ ដែលនឹងសម្រួលដល់ការដឹកជញ្ជូនតាមនាវាក្នុងបរិមាណកាន់តែច្រើន	មធ្យមទៅវែង	- ក្រសួងសាធារណការនិងដឹកជញ្ជូន	
- ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នៅជាយក្រុងភ្នំពេញ ដែលធ្វើឱ្យចំណាយភស្តុភារកម្មកើនឡើងជាប្រចាំ ពិសេស ការកសាងផ្លូវក្រវាត់ក្រុង ឬផ្លូវវៀងក្រៅក្រុង ដើម្បីធានាឱ្យចរាចរប្រព្រឹត្តទៅដោយរលូន	២០១៥ ទៅមធ្យម	- ក្រសួងសាធារណការនិងដឹកជញ្ជូន÷ ▪ ចំពោះផ្លូវខ្សែក្រវាត់រាជធានីភ្នំពេញទី២ (ទឹកថ្ម-វេងស្រេង-ព្រែកហ្ជូ) ក្រសួងបានធ្វើការសិក្សា ចរចា និងចុះកិច្ចសន្យាគម្រោង និងបានបើកការដ្ឋានសាងសង់ ▪ ចំពោះផ្លូវក្រវាត់រាជធានីភ្នំពេញទី៣(ព្រែកញ្ជោ-ទំនប់កប់ស្រូវ-អូរដីម-ទួលក្រសាំង-សិតឆ្ម-បន្ទាយដែក) ក្រសួងកំពុងធ្វើការចរចា	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធរណ៍ខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		និងបានប្រជុំដើម្បីបង្ហាញ និងពិនិត្យអំពីគម្រោងនៃការសិក្សាបឋម។ ▪ បានជំរុញលើកទឹកចិត្តការសាងសង់ ជួសជុល ថែទាំផ្លូវ នៅទីប្រជុំជន ពីពេលថ្ងៃមកពេលយប់វិញ ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍នៅពេលថ្ងៃ។ - រដ្ឋបាលរាជធានីភ្នំពេញ បាន÷ ▪ ស្ថាបនាកំណាត់ផ្លូវលេខ១០១៩(ផ្លូវក្រវ៉ាត់ក្រុងទី២) ចាប់ពីទំនប់កប់ស្រូវដល់មហាវិថី សហព័ន្ធរុស្សីប្រវែង ១០ ១២០ម. ▪ ស្ថាបនាពង្រីកផ្លូវទំនប់កប់ស្រូវ (ផ្លូវក្រវ៉ាត់ក្រុងទី៣) ពីផ្លូវជាតិលេខ៥ ដល់ផ្លូវជាតិលេខ៤ ប្រវែង ១៧ ២៥០ម. ▪ ស្ថាបនាពង្រីកផ្លូវកំណាត់ផ្លូវជាតិលេខ៤ ចាប់ពីរង្វង់មូលចោមចៅ ដល់ផ្លូវទំនប់កប់ស្រូវ ប្រវែង១ ៧៥០ម. ▪ ស្ថាបនាផ្លូវលេខ២១៧(ផ្លូវជើងឯក)ចាប់ពីស្ថានអាកាស ស្ទឹងមានជ័យ ដល់ផ្លូវជាតិលេខ២ ប្រវែង១២ ៣២០ម. និងផ្លូវបេតុងទំហំ៩,៧៥ម. ▪ ជួសជុលគ្រឹះ និងចាក់អ៊ីតកៅស៊ូ កំណាត់ផ្លូវជាតិលេខ២ ចាប់ពីស្ថានអាកាសក្បាលថ្នល់ ដល់រូបសំណាក់ព្រះនរាយណ៍ប្រវែង ៤ ៣៥០ម. ▪ ស្ថាបនាពង្រីកកំណាត់ផ្លូវជាតិលេខ៥ ចាប់ពីមុខឃ្លាំងស្តុកប្រេងឥន្ធនៈសូតិ៍ម៉ិច ដល់ព្រែកព្នៅប្រវែង៥ ៣៨០ម. ▪ ដំឡើងបង្គោលភ្លើង ដំឡើងស្លាកសញ្ញាចរាចរ និងគូសគំនូសចរាចរ(២០១៥-២០១៨) តាមបណ្តាផ្លូវ, ផ្លូវជាតិ និងវិថី ដែលបានស្ថាបនារួចរាល់។	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
- ពិនិត្យលទ្ធភាពនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជន សម្រាប់ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធដែលអាចបន្ទរបន្ទុកវិនិយោគសាធារណជន។	២០១៥ មធ្យមវែង	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុម័តឯកសារគោលនយោបាយ ស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ សមត្ថភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។
ii-វិធានការផ្នែកហិរញ្ញប្បទាន			
- បន្តអនុវត្ត ***"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០"*** ដែលជាក្របខ័ណ្ឌរួមនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា	មធ្យមទៅវែង	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន÷ ▪ សម្របសម្រួល និងសហការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីរៀបចំសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ, និងសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។ ▪ សម្របសម្រួលរាល់ការចុះបំពេញបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍-អាស៊ី មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិភាក្សាការងារអំពីការរៀបចំធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រឱ្យសមស្របតាមការវិវឌ្ឍនៃស្ថានភាពវិស័យហិរញ្ញវត្ថុ។ ▪ នៅក្នុងដំណើរការនៃការធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហការជាមួយធនាគារជាតិនៃកម្ពុជា សម្រេចបាន (១) ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥នេះ ត្រូវបានកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីអនុម័តនៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៦ និង(២) បានសម្របសម្រួល និងសហការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីបកប្រែឯកសារយុទ្ធសាស្ត្រនេះពី	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ភាសាខ្មែរទៅជាភាសាអង់គ្លេស។ - ធនាគារជាតិនៃកម្ពុជា÷ ▪ ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការកេណ្ឌប្រមូលមូលនិធិសម្រាប់ការវិនិយោគ ធនាគារជាតិបាន÷ (១)រក្សាស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់ ដើម្បីរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដែលបង្កបរិយាកាសអំណោយផលដល់ការវិនិយោគ ÷ - ក្នុងមួយទសវត្សចុងក្រោយ អត្រាប្តូរប្រាក់ធៀបនឹងប្រាក់ដុល្លារអាមេរិកមានកម្រិតជាមធ្យមត្រឹម៤ ០៨២ រៀល ហើយនៅឆ្នាំ២០១៦នេះ មានកម្រិតជាមធ្យម៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ជាមួយនឹងកំណើន១០,៤% នៃប្រាក់រៀលត្រូវបានប្រើប្រាស់ក្នុងចរាចរណ៍ ដែលបានឆ្លុះបញ្ចាំងឱ្យឃើញពីតម្រូវការប្រាក់រៀលមានការកើនឡើងជាលំដាប់។ - អត្រាអតិផរណាត្រូវបានរក្សាឱ្យស្ថិតក្នុងកម្រិតទាប ស្របតាមក្របខ័ណ្ឌគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលក្រោយពីវិបត្តិហិរញ្ញវត្ថុសកល និងចាប់ពីឆ្នាំ២០០៩មក អត្រាអតិផរណាមានកម្រិតទាបជាមធ្យម២,៩% ប៉ុណ្ណោះ ហើយមានកម្រិតប្រហាក់ប្រហែលនឹងអត្រាអតិផរណាឆ្នាំ២០១៦។ - ឆ្នាំ២០១៦ ជញ្ជីងទូទាត់កម្ពុជាមានអតិរេកប្រមាណ ៥,៣% នៃផ.ស.ស. គឺកើនឡើង៤៣% ដល់១ ១៤៨ លាន	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ដុល្លារអាមេរិក ដែលបានរួមចំណែកគរពួនទុនបម្រុងអន្តរជាតិដុលដល់៦,៤ប៊ីលានដុល្លារអាមេរិក និងអាចធានាការនាំចូលទំនិញនិងសេវាបានប្រមាណ ៥ខែ។ (២) ពង្រឹងប្រព័ន្ធធនាគារនិងលើកកម្ពស់ការកេណ្ឌប្រមូលមូលនិធិសម្រាប់បម្រើដល់គម្រោងវិនិយោគរបស់ក្រុមហ៊ុនសហគ្រាសឯកជន÷ - បច្ចុប្បន្ន(គិតត្រឹមចុងឆ្នាំ២០១៦) កម្ពុជាមានធនាគារពាណិជ្ជចំនួន៣៧ និងធនាគារឯកទេសចំនួន១៥ ហើយសាខារបស់គ្រឹះស្ថានធនាគារបានកើនដល់៨១០សាខា និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិបានកើនឡើងដល់ ១ ២៥៥ ម៉ាស៊ីន។ - បើធៀបនឹងឆ្នាំ២០១៥ ក្នុងឆ្នាំ២០១៦ ចំនួនអ្នកដាក់ប្រាក់បញ្ជើបានកើន១៤%ដល់៣លាននាក់ស្របពេលដែលចំនួនប្រជាជនដែលទទួលបានឥណទានកើនឡើង៤៩% ដល់០,៨លាននាក់។ - ចាប់ពីឆ្នាំ២០០៥មកដល់ឆ្នាំ២០១៦ អត្រាការប្រាក់ជារៀល បានថយចុះពី២៤%មកត្រឹម១៧% ជាមធ្យម និងអត្រាការប្រាក់ជាដុល្លារអាមេរិកបានថយពី១៧%មក១២% ជាមធ្យម។ ▪ ក្នុងការជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម ធនាគារជាតិបាន÷ ▪ (១) លើកកម្ពស់ការទទួលបានឥណទាន÷ កំណើនឥណទាន	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ និងតម្លៃ	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		កើនដល់៥៦,៣ទ្រីលានរៀល (ប្រមាណ១៣,៩ ប៊ីលានដុល្លារអាមេរិក) មានកំណើន១៨% ដោយបានដើរតួនាទីយ៉ាងសកម្មក្នុងការជំរុញការពង្រីកអាជីវកម្ម និងការប្រើប្រាស់ក្នុងស្រុក។ កំណើនឥណទាន ត្រូវបានបែងចែកទៅកាន់វិស័យសំខាន់ៗនៃសេដ្ឋកិច្ច ក្នុងនោះវិស័យពាណិជ្ជកម្ម៣២%, សំណង់និងអចលនទ្រព្យ២១%, កសិកម្ម១១% និងជាពិសេស វិស័យកម្ចីន្តសាលដែលជាវិស័យអាទិភាពសម្រាប់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា បានស្រូបយកប្រមាណ៨% នៃសំពៀតឥណទានសរុប។ ▪ (២) បន្តអភិវឌ្ឍប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដើម្បីពង្រឹងតម្លាភាព និងកាត់បន្ថយហានិភ័យក្នុងប្រព័ន្ធធនាគារ ដែលទាំងនេះនឹងរួមចំណែកបង្កើនគុណភាពសំពៀតឥណទាន បន្ថយចំណាយប្រតិបត្តិការឥណទាន និងអត្រាការប្រាក់÷ ប្រសិទ្ធភាពនៃប្រព័ន្ធនេះបានរួមចំណែកបន្ថែមទៀតលើការយល់ដឹងកាន់តែច្បាស់ពីវប្បធម៌ឥណទានរបស់ប្រជាជន និងការផ្តល់ឥណទានអនុលោមតាមគោលការណ៍កិច្ចការពារអតិថិជន (CPP) ដើម្បីធ្វើឱ្យកម្រិតនៃបំណុលវណ្ណក (Over-indebtedness) ស្ថិតនៅកម្រិតដ៏ទាបនៅកម្ពុជា។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានកម្ពុជា ត្រូវបានទទួលស្គាល់ដោយប្រទេសក្នុងតំបន់ និងពិភពលោក ហើយធនាគារជាតិនៃកម្ពុជា បានចែករំលែកបទពិសោធន៍លើការបង្កើត និងគ្រប់គ្រងប្រព័ន្ធនេះដល់ប្រទេសមួយចំនួនផងដែរ។	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧទ្ធលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ (៣) ជំរុញប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដើម្បីបង្កើនការផ្តល់សេវានេះដល់ក្រុមហ៊ុន សហគ្រាស ដោយជំរុញឱ្យឥណទានទៅកាន់អាជីវកម្មជួល និងប្រតិបត្តិការភតិសន្យារបស់គ្រឹះស្ថានធនាគារ និងក្រុមហ៊ុនភតិសន្យាបានកើនឡើងជាលំដាប់÷ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន១២។ ហិរញ្ញ-ប្បទាននៃវិស័យនេះបានកើនឡើង៤០,៦% ធៀបនឹងឆ្នាំ២០១៥ និងបានបែងចែកទៅវិស័យដឹកជញ្ជូន៦% ជំនួញ១៤% កសិកម្ម ២៣% សំណង់១៣% សេវាកម្ម៥% ក្រុមគ្រួសារ២៨% និងវិស័យដទៃទៀត ១១%។ បច្ចុប្បន្ន សេវាកម្មភតិសន្យាហិរញ្ញវត្ថុដែលវិស័យនេះបានផ្តល់ឱ្យ រួមមាន ម៉ូតូ រថយន្ត គ្រឿងយន្ត សម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម គ្រឿងចក្រសាងសង់ គ្រឿងអេឡិចត្រូនិកគ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងចលនវត្ថុផ្សេងៗ។ ▪ (៤) អភិវឌ្ឍការការពារអតិថិជន (Consumer protection) ដើម្បីធានាបានការទទួលបានព័ត៌មានច្បាស់លាស់ទាំងមុន ក្នុង ឬបន្ទាប់ពីពេលទទួលសេវាឥណទាន÷ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបាននិងកំពុងសហការជាមួយស្ថាប័នហិរញ្ញវត្ថុ IFC ដើម្បីសិក្សារៀបចំ និងអភិវឌ្ឍក្របខ័ណ្ឌការងារនេះ។ ▪ (៥) លើកកម្ពស់ការអប់រំអំពីសេវាហិរញ្ញវត្ថុ(Financial literacy) ដើម្បីបង្កើនការយល់ដឹងរបស់អ្នកខ្ចីប្រាក់ និងកាត់បន្ថយឧបសគ្គក្នុងការទទួលបានកម្ចី÷ ធនាគារជាតិនៃកម្ពុជា	

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		បានចុះធ្វើការផ្សព្វផ្សាយដល់សាធារណជននៅស្ទើរគ្រប់រាជធានី ខេត្តអំពីអន្តរការីកម្មធនាគារ ជាពិសេស ទាក់ទងនឹងសេវាឥណទាន។ នាដើមឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជានឹងចាប់ផ្តើមយុទ្ធនាការផ្សព្វផ្សាយការអភិវឌ្ឍសមត្ថភាពយល់ដឹងអំពីសេវាហិរញ្ញវត្ថុរបស់អតិថិជន ដល់សាធារណជននៅទូទាំងប្រទេស ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនានា។ ▪ (៦) លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដើម្បីពង្រីកការផ្តល់សេវាហិរញ្ញវត្ថុឱ្យបានកាន់តែទូលំទូលាយដល់ក្រុមហ៊ុន សហគ្រាសឯកជន និងអាចទទួលបានមូលនិធិក្នុងការពង្រីកសកម្មភាពធុរកិច្ច÷ បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជាបានកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានពង្រីក បណ្តាញសាខារបស់ខ្លួននៅទូទាំងប្រទេស។ បច្ចុប្បន្នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានពង្រីកបណ្តាញប្រតិបត្តិការដល់ ៤ ០៧៩សាខា និងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិកើនដល់ ៣១០ម៉ាស៊ីន។ ការពង្រីកវិសាលភាពនេះ បានជំរុញឱ្យទំហំឥណទាន កើនដល់ ១២,២ ទ្រីលានរៀល (ប្រមាណ៣ប៊ីលានដុល្លារអាមេរិក) ដោយបានបែងចែកទៅតាមវិស័យផ្សេងៗរួមមាន វិស័យកសិកម្ម៣៤% ក្រុមគ្រួសារ២៨% ពាណិជ្ជកម្ម ១៨% សេវាកម្ម១០% ដឹកជញ្ជូន៤% សំណង់៣% និងវិស័យផ្សេងៗ២%។ ចំនួនអ្នកខ្ចីប្រាក់ក្នុងវិស័យនេះ បានកើនឡើងដល់ ១,៩លាននាក់ ស្របពេលដែលចំនួនអ្នកដាក់ប្រាក់បញ្ញើមានចំនួន១,៥លាននាក់ ដែលបានគរពួនប្រាក់បញ្ញើដល់៥,៩ទ្រី	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទិដ្ឋភាពសង្ខេបអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		លានរៀល (ប្រមាណ១,៥ប៊ីលានដុល្លារអាមេរិក)។ អត្រាការប្រាក់ឥណទានប្រចាំឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មាននិន្នាការថយចុះជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងមក ដោយបានថយចុះពី៣៦% ក្នុងឆ្នាំ២០០៦មក២២,៥% ក្នុងឆ្នាំ២០១៦ ហើយត្រូវបានរំពឹងថានឹងថយចុះបន្ថែមទៀត។ ▪ ក្នុងការអភិវឌ្ឍផ្នែកភស្តុភារកម្ម ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់ ដើម្បីសម្រួលការទូទាត់ឱ្យបានឆាប់រហ័ស សុវត្ថិភាព និងចំណាយតិច ដែលនឹងរួមចំណែកកាត់បន្ថយថ្លៃដើមនៃការផលិតរបស់ក្រុមហ៊ុន សហគ្រាស ព្រមទាំងជំរុញ និងសម្រួលដល់ការធ្វើពាណិជ្ជកម្ម÷ - ធនាគារជាតិនៃកម្ពុជាបាននឹងកំពុងធ្វើទំនើបកម្មនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់ឱ្យកាន់តែប្រសើរឡើង ដូចជាការដាក់ឱ្យប្រើប្រាស់ការទូទាត់សងប្រាក់តាមរយៈប្រព័ន្ធអេឡិចត្រូនិកសម្រាប់សេវាទូទាត់រហ័ស(Fast Payment) និងកំពុងបន្តរៀបចំអភិវឌ្ឍប្រព័ន្ធ Cambodia Shared Switch ដែលជាប្រព័ន្ធរួមមួយដែលអនុញ្ញាតឱ្យអតិថិជនដកសាច់ប្រាក់តាមម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ និងទូទាត់ថ្លៃទំនិញតាមម៉ាស៊ីន POS ពីគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដោយមិនចំពោះ។ - បច្ចុប្បន្ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់សេវាផ្ទេរប្រាក់តាមសេវា Western Union, Money Gram និង IME ដែលមានភ្នាក់ងារសរុបចំនួន២០ពាន់ន្លែង។ លើសពី	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គ និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		នេះ ប្រតិបត្តិការផ្តល់សេវាទូទាត់ចល័ត មានចំនួន៦ ដូចជា ÷ រ៉ីង (Wing) ទ្រូម៉ានី(True Money) អ៊ីម៉ានី(E-Money) លីហ្ហូរផេប្រ៉ូ(Ly Hour Pay Pro) ស្មាតលុយ(Smart Luy) និងផេហ្គូស៊ី(PayGo Sea) ដែលមាននៅ១៤ ១០៤ទីតាំងផ្សេងគ្នា។ ▪ ក្នុងការបណ្តុះបណ្តាលជំនាញ និងធនធានមនុស្ស ធនាគារជាតិនៃកម្ពុជាបាននិងកំពុងសហការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីរៀបចំសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈធនាគារ។ សញ្ញាបត្រជំនាញធនាគារនេះ នឹងត្រូវបានទទួលស្គាល់ពីប្រទេសក្នុងតំបន់ផងដែរ មានន័យថា បុគ្គលដែលត្រូវបានបណ្តុះបណ្តាលក្នុងសាលានេះ អាចទទួលបានឱកាសក្នុងការស្វែងរកការងារនៅបរទេស។ បច្ចុប្បន្ន បុគ្គលិកនៅក្នុងប្រព័ន្ធធនាគារសរុបមានចំនួនប្រមាណជិត៥០ពាន់នាក់។	
- សិក្សា និងរៀបចំឱ្យមានយន្តការហិរញ្ញវត្ថុសមស្របសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហ-កម្ម ពិសេស ការផ្តល់កម្ចីដល់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងជំរុញការផ្តល់ហិរញ្ញ-ប្បទានដល់ឧស្សាហកម្មអាទិភាព	២០១៥ ទៅមធ្យម	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន÷ ▪ រៀបចំស្នើសុំផ្តល់រចនាសម្ព័ន្ធការណ៍វឌ្ឍនភាពការងារពាក់ព័ន្ធទៅនឹងការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាសម្រាប់ជំរុញប្រតិបត្តិការដែលមានកិច្ចធានា និងភតិសន្ធាហិរញ្ញវត្ថុ (បន្ទាប់ពីកិច្ចប្រជុំលើកទី ៦) ពីក្រសួងពាណិជ្ជកម្ម។ ▪ សម្របសម្រួលដឹកនាំកិច្ចប្រជុំ និងសិក្ខាសាលា ចំនួន៦លើកជាមួយក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ ធនាគារជាតិនៃកម្ពុជា និង IFC។ ▪ ចូលរួមប្រជុំចំនួន០២លើក ជាមួយក្រសួងពាណិជ្ជកម្ម, ធនាគារ	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ គម្រោងធានាឥណទានជាផ្លូវការ ផ្ទាល់ថ្មីមួយដែលទាមទារការប្រជុំ ផ្សព្វផ្សាយសិក្ខាសាលាច្រើន និងគោលនយោបាយ ▪ ត្រូវការជំនាញការដែលមាន ចំណេះដឹង និ ▪ ទាមទារសិក្សាឱ្យ ទៀត

វិធានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ធនធានខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ជាតិនៃកម្ពុជា និងក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ▪ រៀបចំសេចក្តីព្រាងប្រកាសស្តីពីការធានារបស់រដ្ឋ ដែលនឹងផ្តល់ការធានាដល់សហគ្រាសរបស់រដ្ឋក្នុងការទទួលឥណទាន និងផ្តល់ការធានាដល់គម្រោងដែលមានយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ▪ ចូលរួមតាមដានវឌ្ឍនភាពនៃការកែទម្រង់ និងការកសាងសមត្ថភាពរបស់ធនាគារអភិវឌ្ឍន៍ជនបទ ។ ▪ ចូលរួមប្រជុំគណៈកម្មការឥណទាននៃមូលនិធិទ្រទ្រង់និងអភិវឌ្ឍន៍វិស័យកសិកម្មចំនួន៧លើក ដើម្បីពិនិត្យនិងវាយតម្លៃឥណទានកម្ចីដល់អតិថិជនគាំទ្រវិស័យស្រូវអង្ករ។ ▪ សេចក្តីសម្រេចស្តីពីតួនាទី និងភារកិច្ចរបស់នាយកដ្ឋាននៃធនាគារអភិវឌ្ឍន៍ជនបទមានចំនួន០៩ រួមមាន (១) សវនកម្មផ្ទៃក្នុង (២) កិច្ចការគតិយុត្ត (៣) រដ្ឋបាល និងហិរញ្ញវត្ថុ (៤) ធនធាន មនុស្ស (៥) គ្រប់គ្រងហានិភ័យ (៦) ប្រតិបត្តិការ (៧) អភិវឌ្ឍន៍អាជីវកម្ម និងយុទ្ធសាស្ត្រ (៨) តាមដានការប្រើប្រាស់ឥណទាន និងការប្រមូលបំណុល និង (៩) ឥណទាន។ ▪ រៀបចំសិក្ខាសាលា និងរបាយការណ៍ថ្នាក់ជាតិស្តីពីការទទួលហិរញ្ញប្បទានសម្រាប់ SMEs និងត្រៀមសហការជាមួយជំនាញការ ADB ដើម្បីរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការអនុវត្តគម្រោងធានាឥណទានសម្រាប់គាំទ្រអភិវឌ្ឍវិស័យស្រូវអង្ករនៅកម្ពុជា។	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បង្កើតក្រុមការងារសិក្សាស្រាវជ្រាវ រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការអនុវត្តគម្រោងធានាឥណទានសម្រាប់គាំទ្រវិស័យស្រូវអង្ករ នៅកម្ពុជា។ ▪ លទ្ធផលនៃការសិក្សានិងរៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍការធានាឥណទាន ត្រូវបានបញ្ចប់ និងស្នើសុំនីតិវិធីបន្តពីថ្នាក់ដឹកនាំ។ - ក្រសួងឧស្សាហកម្មនិងសិប្បកម្ម÷ ▪ កំពុងជ្រើសរើសធនាគារដែលមានភាពអនុគ្រោះបំផុត និងការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម ដើម្បីធ្វើជាដៃគូក្នុងការជំរុញកិច្ចអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងរៀបចំសិក្ខាសាលា ដើម្បីផ្ដល់ឱកាសឱ្យធនាគារដែលបានជ្រើសរើសទាំងអស់ធ្វើការបង្ហាញផលិតផលរបស់ខ្លួន និងរៀបចំបណ្ដុះ-បណ្ដាលស្ដីពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់បណ្ដុះបណ្ដាលដល់សហគ្រាសធុនតូចនិងមធ្យមទាំងឡាយណាដែលមានបំណងចង់ទទួលយកកម្ចីពីធនាគារសាមី។ ▪ បានអញ្ជើញធនាគារចំនួន២៨មូលដ្ឋាន ដើម្បីពិភាក្សាអំពីការផ្ដល់កម្ចីអនុគ្រោះបំផុត និងលើកទឹកចិត្តដល់ការបង្កើតសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា។ រហូតមកដល់ពេលនេះ ក្រុមការងាររបស់អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម បាននឹងកំពុងសរុបលទ្ធផលដែលបានពិភាក្សាកន្លងមក នឹងដាក់ជូនថ្នាក់ដឹកនាំសម្រេច ជ្រើសរើសយកធនាគារអនុគ្រោះបំផុត និងមានការលើកទឹកចិត្តដល់សហគ្រាសធុនតូចនិងមធ្យម និង	

ទិដ្ឋានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		សិប្បកម្ម។	
- កែលម្អប្រសិទ្ធភាព និងអភិបាលកិច្ចប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេស ការវិភាជ និងការរៀបចំកម្មវិធីវិនិយោគសាធារណៈ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម	២០១៥ មធ្យម	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ ▪ កំពុងពិនិត្យឡើងវិញនូវក្របខ័ណ្ឌចំណាយសាធារណៈ។ ▪ កំពុងរៀបចំសេចក្ដីព្រាងក្របខ័ណ្ឌវិនិយោគសាធារណៈ។ ▪ បានអនុម័តឯកសារគោលនយោបាយស្ដីពីការអភិវឌ្ឍយន្ដការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលនឹងជាមូលដ្ឋាននៃការធ្វើវិចារណកម្មក្នុងការវិភាជ និងអនុវត្តថវិកាសម្រាប់ការវិនិយោគសាធារណៈ រាប់ទាំងការអភិវឌ្ឍវិស័យឧស្សាហកម្មដែលមានហិរញ្ញប្បទានពីប្រភពថវិការដ្ឋ ថវិកាពីដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគតាមយន្ដការភាពដៃគូរវាងរដ្ឋ និងឯកជន។ - ក្រសួងផែនការ	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ សមត្ថ-ភាពធនធានមនុស្ស និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។
- ពង្រឹងទីផ្សារមូលបត្រ ដើម្បីកៀរគរប្រភពហិរញ្ញវត្ថុ និងប្រើប្រាស់វាឱ្យមានប្រសិទ្ធភាពជាពិសេស ពិចារណាលើលទ្ធភាពបង្កើតមូលបត្ររតនាគារ ដើម្បីធ្វើហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការបង្កើតមូលដ្ឋានឧស្សាហកម្ម	មធ្យមទៅវែង	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន÷ ▪ រៀបចំប្រជុំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រង និងការបោះផ្សាយមូលបត្ររដ្ឋកម្រិតអន្ដរស្ថាប័ន និងបានប្រជុំប្រឹក្សាយោបល់ជាមួយក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីទទួលបានធាតុចូលបន្ថែម។ ▪ រៀបចំប្រជុំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រង និងការបោះផ្សាយមូលបត្ររដ្ឋ ជាមួយថ្នាក់ដឹកនាំក្រសួងចំនួន៣លើក។ ▪ ចូលរួមរៀបចំអនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងការលើកទឹកចិត្ដពន្ធដារក្នុងវិស័យមូលបត្រ (អនុក្រឹត្យលេខ០១ អនក្រ.បក ស្ដីពីការលើកទឹកចិត្ដពន្ធដារក្នុងវិស័យមូលបត្រ, និងប្រកាសលេខ ៨៥៥ សហវ.ប្រក ស្ដីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើ	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ប្រាក់ចំណេញសម្រាប់ក្រុមហ៊ុន/ សហគ្រាសទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ)។ ▪ លើកលែងពន្ធប្រថាប់ត្រាក្នុងការទទួលសិទ្ធិកាន់កាប់ភាគហ៊ុនតាម រយៈការជួញដូរមូលបត្រក្នុងទីផ្សារដំបូង ឬក្នុងទីផ្សារបន្ទាប់។ (ប្រកាសលេខ២២៣ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា)។ ▪ កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីប្រតិបត្តិការមូលបត្ររដ្ឋកម្រិតបច្ចេកទេស។ ▪ កំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងការបោះផ្សាយមូលបត្ររដ្ឋកម្រិតបច្ចេកទេស។ ▪ កំពុងរៀបចំសេចក្តីព្រាងឯកសារយុទ្ធសាស្ត្រនៃការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជាកម្រិតបច្ចេកទេស។	
- ពង្រឹងយន្តការសន្សំក្នុងស្រុក រួមមាន ការអភិវឌ្ឍ និងការកែទម្រង់មូលនិធិសោធន និងវិស័យធានារ៉ាប់រង ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ	មធ្យមទៅវែង	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន÷ **១- វិស័យធានារ៉ាប់រង÷** ▪ បានរៀបចំធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៦-២០២៥ សម្រាប់ផ្នែកដែលពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រង។ ▪ រៀបចំ និងអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង។ ▪ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងជាកាតព្វកិច្ច, សេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច, សេចក្តីព្រាងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណជូនភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង, សេចក្តីព្រាងប្រកាសមួយចំនួនពាក់ព័ន្ធកិច្ចការពារអតិថិជន, និងសេចក្តីព្រាងបទប្បញ្ញត្តិពាក់	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ÷ ▪ ចំណេះដឹងបច្ចេកទេសរបស់មន្ត្រីជំនាញនៅមានកម្រិត ដូច្នេះត្រូវការការបណ្តុះបណ្តាល និងជំនួយផ្នែកបច្ចេកទេសបន្ថែម។ ▪ ធនធានមនុស្សនៅមានកម្រិត ដូច្នេះត្រូវការការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសបន្ថែម ដើម្បីរៀបចំយុទ្ធសាស្ត្រ ▪ ទាមទារពេលវេលាកន្លែង ដើម្បីសិក្សា

ទិដ្ឋានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ព័ន្ធមួយចំនួនទៀត។ ▪ ពិនិត្យសេចក្តីព្រាងលក្ខន្តិកៈរបស់សមាគមជើងសាធានារ៉ាប់រង និងផ្តល់គំនិតគាំទ្រក្នុងការបង្កើតសមាគមនេះ។ ▪ បានធ្វើបទបង្ហាញពាក់ព័ន្ធនឹងវិស័យនេះតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សានានា។ ▪ បានរៀបចំធ្វើបច្ចុប្បន្នកម្ម និងថែទាំគេហទំព័រ (website) និង server របស់អគ្គនាយកដ្ឋាន។ **២. វិស័យសោធន÷** ▪ បានបញ្ចប់ការរៀបចំក្របខ័ណ្ឌគោលនយោបាយជាតិ គាំពារសង្គមត្រឹមកម្រិតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ▪ បាននឹងកំពុងប្រមូលធាតុចូលដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម និងឯកសារគតិយុត្តសំខាន់ៗពាក់ព័ន្ធ។ - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា÷ ចំពោះការងារមូលនិធិជនពិការ គ្លីនិកព្យាបាលដោយចលនារបស់មូលនិធិជនពិការ បានព្យាបាលអតិថិជនបានចំនួន៤១នាក់ ស្មើ១០០ដង និងទទួលបានថវិកាចំនួន ២ ០៤០ ០០០៛។ - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ÷ ▪ បានរៀបចំសេចក្តីព្រាងលិខិតបទដ្ឋាន និងបែបបទផ្សេងៗ - ប្រកាសស្តីពីការបង់ភាគទាន - ប្រកាសស្តីពីតាវកាលិក - ប្រកាសស្តីពីការដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន - សិក្សាអំពីនីតិវិធីនៃការបើកផ្តល់ និងការត្រួតពិនិត្យលើសិទ្ធិ	ស្រាវជ្រាវ និងរៀបចំ

ទិសដៅការគោលនយោបាយវិនិយោគ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថានភាពនាំមុខ/ឧបសគ្គសក្រិតអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		វិនិយោគផ្នែកប្រាក់សោធន - រៀបចំទម្រង់របាយការណ៍ ដើម្បីវាយតម្លៃលើដំណើរការរបបប្រាក់សោធន - បានរៀបចំសេចក្ដីព្រាងកិច្ចព្រមព្រៀងជាមួយធនាគារដៃគូ។ ▪ បានរៀបចំប្រព័ន្ធព័ត៌មានវិទ្យា - បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់តាវកាលិកវិភាជសោធនជរាភាព វិភាជសោធនទុព្វលភាព និងវិភាជសោធនអ្នកនៅក្នុងបន្ទុក - បានអភិវឌ្ឍកម្មវិធីចុះបញ្ជិកា និងបង់ភាគទានផ្នែកប្រាក់សោធន (E-Form)។ ▪ បានសហការជាមួយអង្គភាពពាក់ព័ន្ធ÷ - នាយកដ្ឋានអត្តសញ្ញាណកម្មសម្រាប់គ្រប់គ្រងព័ត៌មានអត្តសញ្ញាណកម្មការនិយោជិត - ប្រជុំពិគ្រោះយោបល់ផ្នែកប្រាក់សោធនជាមួយជំនាញការរបស់ HITACHI JICA ILO រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អគ្គិសនីកម្ពុជា ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា - ដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិ បញ្ជូនមន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលស្តីពីផ្នែកប្រាក់សោធននៅបណ្តាប្រទេសមួយចំនួនដូចជា វៀតណាម សាធារណរដ្ឋកូរ៉េ ជប៉ុន និងអ៊ីតាលី។	
- ផ្តល់អាទិភាពខ្ពស់នៅក្នុងកម្មវិធីវិនិយោគសាធារណៈ សម្រាប់សកម្មភាពគម្រោងនិង	មធ្យមទៅវែង	- ក្រសួងផែនការ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន÷	

ទិដ្ឋានការគោលនយោបាយជ្រើសការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
កម្មវិធីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម កន្សោមឧស្សាហកម្ម ឬរបៀងឧស្សាហកម្ម។		▪ ចូលរួមធ្វើអាទិភាវូបនីយកម្មកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល។ ▪ បានដាក់បញ្ចូលគម្រោងចំនួន៦ទៅក្នុងបញ្ជីគម្រោង/កម្មវិធីដែលគ្រោងចុះហត្ថលេខាក្នុងឆ្នាំ២០១៦ ក្នុងក្របខ័ណ្ឌនៃហិរញ្ញប្បទានពីដៃគូអភិវឌ្ឍទ្វេភាគី និងពហុភាគី ។ - ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា÷ ▪ បានរៀបចំឯកសារទស្សនាទានដើម្បីកំណត់តួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ ▪ បានកំណត់វិស័យសំខាន់ៗដែលមានសក្តានុពលសម្រាប់ដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្ររួមមាន ១) ការអភិវឌ្ឍរចនាសម្ព័ន្ធសាធារណៈ និងប្រព័ន្ធភស្តុភារកម្ម ២) ភាពជាដៃគូដោយផ្ទាល់ជាមួយវិស័យឯកជន ៣) ការវិនិយោគគន្លឹះជាយុទ្ធសាស្ត្រសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម និងលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច និង៤) ការគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលសម្រាប់ធ្វើឱ្យមានភាពប្រសើរឡើងនូវបរិស្ថានអំណោយផល និងការទាក់ទាញវិនិយោគ។	

ទិដ្ឋានការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័នឆ្លើមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		▪ បានកំណត់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការដែលគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម តាមរយៈការកែសម្រួល និងបង្កើតវិស័យនិងអនុវិស័យបន្ថែមក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធានាសង្គតិភាពជាមួយនឹងកម្មវិធីនិងអនុកម្មវិធីអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា។ ▪ បានរៀបចំរបាយការណ៍វិភាគស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូឆ្នាំ២០១៦ ក្នុងនោះបានវិភាគអំពីនិន្នាការនៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រគោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្ម ។ ដៃគូអភិវឌ្ឍដែលបានផ្តល់ការគាំទ្រច្រើនជាងគេ ហើយមានទំហំលើសពី១០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ រួមមាន សាធារណរដ្ឋប្រជាមានិតចិន ជប៉ុន ធនាគារអភិវឌ្ឍន៍អាស៊ី និងសហគមន៍អ៊ីរ៉ុប។ ▪ បាននិងកំពុងបញ្ចូលសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មទៅក្នុងផែនការសកម្មភាព ដែលត្រូវមានសង្គតិភាពជាមួយក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ សម្រាប់ពង្រឹងភាពជាដៃគូ ការតម្រឹម និងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល។ ▪ បាននិងកំពុងរៀបចំផែនការវិនិយោគ ដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងបានវាយតម្លៃអំពីតម្រូវការធនធាន និងរៀបចំបញ្ជីសំណើគម្រោងសម្រាប់គាំទ្រការអនុវត្ត	

ទិសដៅការគោលនយោបាយផែនការ/សកម្មភាព	រយៈពេល/ឆ្នាំ	ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត និងវឌ្ឍនភាព	ផ្សេងៗ (បញ្ហាប្រឈម និងសំណូមពរ)
		ផែនការសកម្មភាពរបស់ក្រសួង និងស្ថាប័ននីមួយៗ។ ▪ បាននិងកំពុងដឹកនាំការកៀរគរធនធាន ស្របតាមផែនការវិនិយោគដែលផ្តល់ជូនក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍ ព្រមទាំងប្រកាន់យកអភិក្រមបុរេសកម្ម ដើម្បីកំណត់ ឬស្វែងរកដៃគូ និងកៀរគរធនធានជំនៃទៀតសម្រាប់គាំទ្រការអនុវត្តគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។	

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

លេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួល

ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

អាសយដ្ឋាន	÷ វិមានរដ្ឋាភិបាល (វត្តភ្នំ) វិថីព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ	÷ (+៨៥៥) ២៣ ៩៩២ ៤៥៥
សារអេឡិចត្រូនិក	÷ idpsecretariat.cdc@gmail.com
គេហទំព័រ	÷ www.cambodiainvestment.gov.kh